# ស្ត្រីនៅក្នុងអ៊ីស្លាម

## អារម្ភកថា

ស្ត្រីនៅក្នុងអ៊ីស្លាម ជាការសន្ទនារវាងស្ត្រីមុស្លីមនិងអ៊ូឡាម៉ាអ៍ (លោកអ្នកប្រាជ្ញខាងសាសនាអ៊ីស្លាម) ។ សៀវភៅនេះវិភាគនិងអធិប្បាយបំភ្លឺច្រើនរឿងទាក់ទងនឹងសិទ្ធិនិងច្បាប់ធរមាន ដែលពោលដល់ស្ត្រីក្នុងសាសនាអ៊ីស្លាមនិងបើកឲ្យឃើញកេរ្តិ៍ឈ្មោះដែលត្រូវគេបង្ខូច និងការភាន់ច្រឡំជុំវិញរឿងស្ត្រីមុស្លីម ។

## អំពីអ្នកនិពន្ធ

សៃយីដ្ធ មុសត៍្ហហ្វា អាល់-ក្វូស្វ៊ីនី (سيد مصطفى القزويني) បានប្រសូតនៅឯទីក្រុងការបាឡាអ៊ុំ ប្រទេសអ៊ីរ៉ាក់។ លោកបានទទួលសញ្ញាប័ត្រសិក្ខាសាលាអ៊ីស្លាមទីក្រុងគូម ប្រទេសអ៊ីរ៉ង់ បានចាកមាតុភូមិទៅរស់នៅឯសហរដ្ឋអាមេរិក។ លោកបានសរសេរសៀវភៅអ៊ីស្លាមនិងបានធ្វើសន្និបាតជាច្រើននៅក្នុងទូទាំងប្រទេស។ លោកជាអ៊ីម៉ាំអ្នកបង្កើតមជ្ឈមណ្ឌលសិក្សាអ៊ីស្លាមនៃស្រុកអូរេន្ស៍ (Orange) រដ្ឋកាលីហ្វ័រនីយ៉ា។

លោកស្រី ហ្វាត់ម៉ាស់ ស្វ៊លេស្ក មានកំណើតនៅឯប្រទេសលីបង់ ធាត់ធំនៅសហរដ្ឋអាមេរិក ប៉ែកខាងកើតនៃរដ្ឋកាលីហ្វ័រនីយ៉ាតាំងពីឆ្នាំ ១៩៧១ មក។ លោកស្រីជាសមាជិកាសកម្មមួយរូបនៃសហគមន៍មុស្លីមនៃទីក្រុងឡូស អាន់ស្ជេលេស (Los Angeles)។ លោកស្រីបានផ្សាយការងារនិពន្ធអំពីអ៊ីស្លាម ហើយបានធ្វើសន្និបាតរឿងស្ត្រីនៅឯសាកលវិទ្យាល័យនិងវិទ្យាស្ថានសាសនា។

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

وَٱلۡعَصۡرِ ۝١ إِنَّ ٱلۡإِنسَٰنَ لَفِي خُسۡرٍ ۝٢ إِلَّا ٱلَّذِينَ ءَامَنُواْ وَعَمِلُواْ ٱلصَّٰلِحَٰتِ وَتَوَاصَوۡاْ بِٱلۡحَقِّ وَتَوَاصَوۡاْ بِٱلصَّبۡرِ ۝٣

*ដោយនូវព្រះនាមអល់ឡោះហ្ទ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី។*

*១. [អញស្បថស្បថ]នឹងសម័យកាល។ ២. ពិតណាស់ មនុស្សនៅក្នុងសេចក្ដីវិនាស ៣. លើកលែងតែបណ្ដាអ្នកដែលមានសទ្ធា សាងអំពើល្អ ដាស់តឿន[គ្នាទៅវិញទៅមក]ឲ្យទៅកាន់ការពិត ដាស់តឿន[គ្នាទៅវិញ*

*ទៅមក]ឲ្យអត់ធ្មត់[នៅលើមាគ៌ាអល់ឡោះហ្ទ៍] (ស៊ូរ៉ោះត្ទ៍ អាល់-អុាស្ទ៍រ៍) ។*

ដូចវិញ្ញាណដែលផ្តោតទៅឯព្រះម្ចាស់អ្នកបង្កើតវានោះដែរ យើងសូមឧទ្ទិសកិច្ចកាតរបស់យើងចំពោះអល់ឡោះហ្ទ៍عز وجل ព្រះតែមួយគត់ ។
នាងខ្ញុំសូមថ្លែងអំណរគុណដល់ហ្សាសាន់ ស្វាមីនាងខ្ញុំ ដល់កូននាងខ្ញុំ អុាលី, លេណា និង ដេណា ដល់មាតាបិតានាងខ្ញុំ និងដល់លោកគ្រូនាងខ្ញុំ សៃយីដ្ទ មុសត្ទ៏ហ្វា ។
កិច្ចការទាំងនេះប្រាកដជាពុំបានសម្រេចឡើងបានទេ ប្រសិនបើយើងខ្ញុំទាំងអស់គ្មានអំណត់ទេនោះ ។

សូមអរគុណ ។
ហ្វាត្ទ៍ម៉ាស្ទ៍ ។

## អារម្ភកថារបស់សៃយីដ៍ អាល់-គូស្ស៍វីនី

بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ

រឿងស្ត្រីដែលជារឿងស្មុគស្មាញមួយនៅក្នុងសាសនាអ៊ីស្លាមនោះ រងការនិយាយបង្ខូច បំភ្លៃនិងកាឡៃបន្លំ ។ ការងារនិពន្ធជាច្រើនស្តីអំពីរឿងស្ត្រីមុស្លីមត្រូវបានបោះផ្សាយដោយអ្នកនិពន្ធផ្សេងៗ ដោយអ្នកព័ត៌មានដោយអ្នកប្រាជ្ញខាងសាសនានិងដោយអ្នកប្រាជ្ញមុស្លីម ។

អ្នកនិពន្ធខ្លះបង្ហាញឲ្យឃើញរឿងស្ត្រីមុស្លីមពិតប្រាកដ រីឯមួយចំនួនទៀតដែលពុំមានការចេះដឹងជ្រៅជ្រះអំពីខ្លឹមសាសនាទេនោះ បានយករឿងស្ត្រីក្នុងសាសានាអ៊ីស្លាមមកប្រើជាវេទិកា ដែលពោរពេញដោយមជ្ឈធាតុនិយម (គឺមិនតាមមតិទូទៅ) ពោរពេញដោយការនិយាយបំផ្លើសនិងការសិក្សាស្រាវជ្រាវមិនត្រឹមត្រូវ ។

គេនិយាយជាញឹកញយថាអ៊ីស្លាមចាត់ទុកស្ត្រីជាមនុស្សថ្នាក់អន់ ថាព្រះសាស្តាមូហ៊ាំម៉ាដ៍ﷺល្បីខាងស្អប់ស្ត្រី តែបន្ទាប់ពីបានពិនិត្យគួរអាននិងព្រះវចនៈរបស់ព្រះសាស្តាﷺយ៉ាងហ្មត់ចត់ គេនឹងឃើញថាសម្តីទាំងនេះជាការចោទប្រកាន់គ្មានហេតុផល ។ ព្រះសាស្តាﷺដឹងច្បាស់ជាទីបំផុតនូវសេចក្តីត្រូវការរបស់ស្ត្រី ព្រះអង្គﷺបានតស៊ូដើម្បីឆ្លើយតបសេចក្តីត្រូវការទាំងនោះដោយបង្កើតច្បាប់និងតាមរយៈការអនុវត្តិ ។

អ្នកនិពន្ធបានលាបព័ណ៌ បានឲ្យមូលដ្ឋានអ៊ីស្លាមដោយផ្អែកទៅលើទង្វើមិនគប្បីរបស់មុស្លីម ជាជាងផ្អែកទៅលើខ្លឹមសារនិងទ្រឹស្តីពិតប្រាកដរបស់អ៊ីស្លាម ។ អ្នកនិពន្ធអាមេរិកាំងម្នាក់ ដែលជាអ្នករិះគន់ បានសរសេរថា៖ "ប៉ែកបាយម៉ានដែលផ្សារបណ្តាបុរសមុស្លីមឲ្យជាប់គ្នានោះគឺការលុប

បំបាត់ស្ត្រីទាំងស្រុង" ។ ផ្ទុយស្រឡះ ដែលអ៊ីស្លាមកើតឡើងនោះព្រោះតែមានជនទ័លក្រនិងជនរងការសង្កត់សង្កិននោះវិញទេ ជាពិសេសស្ត្រីតែម្តង ។

តួយ៉ាងបង្ហាញការលំអៀង ការប្រឆាំងនិងការធ្វើឲ្យធូរស្រាលនៃរឿងនេះបានជិតជាមនៅក្នុងបទនិពន្ធអក្សរសាស្ត្ររឿងស្ត្រីមុស្លីមដែលត្រូវសរសេរដោយបុរសតាមទស្សនៈបុរស ឬជួនកាលសរសេរដោយស្ត្រីដោយលើកយកបញ្ហាពិបាកឡើងដើម្បីធ្វើឲ្យរំជួលចិត្ត ដូចជារឿងពហុពន្ធភាព (គឺរឿងមានប្រពន្ធច្រើន) ជាដើម ឯអ្នកផ្សេងទៀតដែលនៅក្រោមឥទ្ធិពលគេ (គឺត្រូវគេញុះញង់) ដើម្បីអនុលោមឬកែព្រះអធិបញ្ញាគួរអានឲ្យទៅជា "ស្របតាមនយោបាយ" សម្រាប់សង្គមពួកគេ ឧទាកហរណ៍ ដូចជាអះអាងថាគួរអានមិនបានដាក់ព្រះបញ្ញាឲ្យស្ត្រីបិទបាំងខ្លួនទេ ជាដើម ។

អ្នកប្រាជ្ញមុស្លីមមិនបានពិព័ណ៌នា រឿងស្មុគស្មាញរបស់ស្ត្រីនៅក្នុងអ៊ីស្លាមឲ្យបានជ្រៅជ្រះទេ ហើយក៏ពុំបានយកចិត្តទុកដាក់ឲ្យស័ក្តិសមអំពីរឿងនេះទេ ។ ញាតា (គឺអ្នកចេះដឹង) បានធ្វេសប្រហែសក្នុងការស្រាវជ្រាវនិងក្នុងការវិភាគរឿងនេះយ៉ាងជ្រាលជ្រៅ ។ មុស្លីមនិងអ្នកមិនមែនមុស្លីមជាច្រើនមិនស្គាល់ទម្រង់បែបបទទាក់ទងនឹងសិទ្ធិសង្គម និងសិទ្ធិបុគ្គលដែលត្រូវប្រតិបត្តិខានមិនបាន និងជម្រើសបម្រុងទុកសម្រាប់ស្ត្រីនោះទេ ។

ជាញឹកញយ មនុស្សមើលតែលទ្ធផលចុងក្រោយ ឬការវិនិច្ឆ័យដែលចាប់ផ្ទាក់ស្ត្រីមុស្លីមដោយមិនបើកចិត្តឲ្យទូលំទូលាយទេដើម្បីស្វែងយល់ ឬពិនិត្យឡើងវិញទំនាក់ទំនងសមហេតុផលដែលជាបុព្វហេតុនៃទង្វើ ឬការពាក់ព័ន្ធស្មុគស្មាញនៃស្ថានភាពឯទៀតដែលជាប់ទាក់ទងគ្នា ដែលជាមូលដ្ឋាននៃការវិនិច្ឆ័យ ។ ជាញឹកញយ ប្រការទាំងនេះត្រូវលើកចោល

ទាំងស្រុង ។ ត្រូវរិះគិតដោយឥតលំអៀងអំពីមូលហេតុនៃការអនុវត្តិរឿងស្ត្រីមុស្លីម ។

ការលើកចោលរឿងនីមួយដោយមិនដាក់ឲ្យពិនិត្យពិច័យមើលទេនោះ ធ្វើឲ្យប៉ះពាល់ដល់ខ្លឹមសារនៃការចេះដឹង ។ ត្រូវជម្រុះចោលឲ្យអស់នូវការគិតស្មានជាមុនអំពីរឿងស្ត្រីមុស្លីម ហើយត្រូវចាប់ផ្តើមរកផ្លូវដោះស្រាយរឿងនេះដូចការងារស្រាវជ្រាវឯទៀតដែរ ដោយធ្វើចិត្តឲ្យទូលាយនិងមិនលំអៀង ។ គេបានតំណាលរឿងបុរសម្នាក់បានជួបព្រះសាស្តាមូហ៊ាំម៉ាដ់ ﷺ ។ ក្នុងពេលសន្ទនាជាមួយព្រះសាស្តាﷺ ព្រះអង្គﷺដឹងថាបុរសនោះជាមនុស្សដែលចូលចិត្តប្រកែក ។ ព្រះសាស្តាﷺប្រាប់បុរសនោះថា៖ "ចូរសួរខ្ញុំﷺក្នុងនាមជាអ្នកស៊ើបអង្កេត មិនមែនក្នុងនាមជាអ្នកឆ្លើយឆ្លងតទល់គ្នាយកឈ្នះចាញ់ទេ ។"

សៀវភៅនេះត្រូវចងក្រងឡើង មិនមែនក្នុងគោលបំណងជាការឆ្លើយឆ្លងតទល់គ្នាយកឈ្នះចាញ់ទេ តែជាការចរចាក្នុងបំណងបំភ្លឺរឿងពិបាកយល់នៃស្ត្រីមុស្លីម ។

អ៊ីស្លាមបានបង្កើតសិទ្ធិវិស័យសង្គម និងវិស័យឯកត្តជន (គឺផ្ទាល់ខ្លួន) សម្រាប់ស្ត្រី ហើយបានទទួលស្គាល់ស្ត្រីជាផ្លូវការជាដៃគូពេញលក្ខណៈក្នុងជីវិត ។ អ៊ីស្លាមអនុញ្ញាតឲ្យស្ត្រីអាចមានទ្រព្យសម្បត្តិនិងមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិនោះបានតាមបំណង ដោយមិនបាច់ទទួលការយល់ព្រមពីឪពុកឬពីស្វាមីទេ ។ គេអនុញ្ញាតឲ្យស្ត្រីអាចធ្វើកិច្ចសន្យានិងគ្រប់គ្រងធុរកិច្ចផ្ទាល់ខ្លួនបាន អនុញ្ញាតឲ្យស្ត្រីរកប្រាក់ចំណូលផ្ទាល់ខ្លួននិងគ្រប់គ្រងប្រាក់ចំណូលផ្ទាល់ខ្លួននោះបាន ។

អ៊ីស្លាមបើកសិទ្ធិឲ្យស្ត្រីមានសិទ្ធិទទួលមរតកបានក្នុងនាមជាមាតា ក្នុង

នាមជាកូនស្រី ក្នុងនាមជាបងស្រីប្អូនស្រី និងក្នុងនាមជាភរិយា ។ ស្ត្រីមានសិទ្ធិបដិសេធ ឬយល់ព្រមទទួលការស្នើសូមរៀបអាពាហ៍ពិពាហ៍ ។ ប្រាក់ខាន់ស្លា (مهر) របស់ស្ត្រីជាកម្មសិទ្ធិដាច់មុខរបស់ស្ត្រី ។ ស្ត្រីមានសិទ្ធិបោះឆ្នោត ហើយសិទ្ធិនេះត្រូវចាត់ទុកជាករណីយកិច្ចសាសនា ហើយស្ត្រីមានសិទ្ធិឲ្យយោបល់ឬប្រកែករឿងនីមួយៗ ។ ទណ្ឌកម្មស្ត្រីក្នុងបទល្មើសស៊ីវិលដូចទណ្ឌកម្មបុរសដែរ ។ ប្រសិនបើស្ត្រីរងការប្រព្រឹត្តិដោយអយុត្តិធម៌ ស្ត្រីមានសិទ្ធិទទួលបាននូវការទូទាត់សងវិញយ៉ាងត្រឹមត្រូវ ។

ចាំបាច់ត្រូវតែចងក្រងសៀវភៅដែលស្តីអំពីរឿងស្ត្រី ។ នេះគឺឱកាសសម្រាប់ខ្ញុំបាទ ក្នុងនាមជាអ្នកក្រេបជញ្ជក់ជានិច្ចនូវចំណេះដឹងអ៊ីស្លាមដែលអល់ឡោះហ្ទ័عزّ وجلّបានប្រោសប្រណី ដែលមានសំណាងបានស្គាល់យោបល់ (ចាស់និងថ្មី) ផ្នែកសិក្ខាសាសនានិងសាកលវិទ្យាសាស្ត្រនៃសង្គមប៉ែកខាងកើតនិងប៉ែកខាងលិច ដែលបានចរចានៅលើវេទិកាសន្ទនាអំពីបញ្ហាពាក់ព័ន្ធនឹងស្ត្រីមុស្លីម ។

មុនជាអ្នកប្រាជ្ញមុស្លីម ខ្ញុំបាទជាមនុស្សម្នាក់ ក្នុងនាមជាមនុស្សដែលបានសិក្សាអ៊ីស្លាម មិនត្រឹមត្រូវទេដែលអះអាងយ៉ាងម៉ឺងម៉ាត់ថាខ្ញុំបាទស្គាល់ច្បាស់គ្រប់វិស័យដែលទាក់ទងនឹងធម្មជាតិនិងចិត្តស្ត្រី ។ ជាពិសេសច្បាប់ដែលគ្រប់គ្រងស្ត្រីក្នុងអ៊ីស្លាម ជះឥទ្ធិពលមកលើស្ត្រីចំៗ ហើយជះឥទ្ធិពលមកលើបុរសដោយមិនចំ ជាមូលហេតុធ្វើឲ្យយើងមិនដឹងទស្សនៈផ្ទាល់ខ្លួនរបស់ស្ត្រី ។

ហេតុដូច្នេះ ខ្ញុំបាទយល់ឃើញថា ក្នុងនាមជាអ្នកប្រាជ្ញខាងសិក្ខាសាសនា ខ្ញុំបាទចាំបាច់ត្រូវយល់ដឹងឲ្យបានច្បាស់លាស់ ដោយចូលរួមផ្ទាល់តែម្តង និងដោយពិភាក្សារឿងស្ត្រីក្នុងអ៊ីស្លាមដែលពិបាកដោះស្រាយនោះ ។

ដូចរឿងព្រះសាស្ដាﷺជួបមនុស្សប្រកែកយកឈ្នះដែរ ខ្ញុំបាទឃើញថាគូនិពន្ធរបស់ខ្ញុំបាទផ្ទុយពីមនុស្សនោះ ដែលចង់ចេះចង់ដឹងច្រើន ។ លោកស្រី ហ្វាត់ម៉ាស់ ស្វ៊ីលេស្ មានបុគ្គលលក្ខណៈចម្រើនលូតលាស់ - ស្រាឡាញ់ការស្វែងយល់ និងការស្វែងរកចំណេះអំពីសាសនារបស់ខ្លួន ។ លោកស្រីស្រឡាញ់ការសិក្សា មានសភាវគតិឈ្វេងយល់ក្នុងការរកឃើញប្រការផ្សេងៗយ៉ាងសមហេតុសមផល ។

ជាមួយសំណួររបស់លោកស្រី លោកស្រីហ្វាត់ម៉ាស់ព្យាយាមស្វែងយល់ ស្វែងរកចម្លើយអធិប្បាយបំភ្លឺឬមូលហេតុដែលបញ្ជាក់ថាត្រូវនៃរឿងដែលធ្វើឲ្យភាន់ភាំងស្មារតីនៅជុំវិញស្ត្រីមុស្លីម ។ អាស្រ័យកំណត់សម្គាល់ផ្ទាល់ខ្លួននិងសំណួរស្ត្រី និងអាស្រ័យការពិភាក្សាយ៉ាងយូរអំពីសំណុំប្រការទាំងនេះ ខ្ញុំបាទអាចយកចិត្តទុកបានប្រសើរជាងមុនៗអំពីមនោសញ្ចេតនារបស់ស្ត្រី ហើយអាចវាយតម្លៃមនោសញ្ចេតនាទាំងនេះបាននៅក្នុងចម្លើយរបស់ខ្ញុំបាទ ។

ទីបញ្ចប់ ខ្ញុំបាទព្យាយាមកុំឲ្យលំអៀងក្នុងយោបល់ផ្ទាល់ខ្លួននៅក្នុងកិច្ចសន្ទនាពីដើមដល់ចប់ ។ ខ្ញុំបាទផ្អែកលើនិងបត់បែនទៅតាមការយល់ស្រប តាមមតិនិងតាមសេចក្ដីសម្រេចរបស់អស់លោកអ្នកប្រាជ្ញមុស្លីមជាន់ខ្ពស់ ។

សូមបន្ថែមថាខ្ញុំបាទមិនបានតាមទស្សនៈអ៊ីស្លាមបញ្ឆោទេ មិនផ្គាប់ផ្គុនយោបល់ប៉ែកខាងលិចទេ ។ សេចក្ដីបារម្ភនិងអ្វីដែលសំខាន់ជាងគេសម្រាប់ខ្ញុំបាទនោះ តាំងពីមុនមកនិងរៀងរហូតតទៅទៀត គឺសច្ចធម៌និងស្មារតីទទួលខុសត្រូវចំពោះអល់ឡោះហ្ជ៏ នាថ្ងៃដែលប្រជានិករទាំងអស់នឹងបានជួបព្រះអង្គﷻ ។ ការពិតនិងចម្លើយនៅឯព្រះអង្គﷻដោយចៀសមិនបាន ។

សៃយីដ្ទ មុសត៏ហ្វា អាល់-កួស់វីនី (سيد مصطفى القزويني)
ស្មៅវ៉ាល់ ១៩២១/ខែ ធ្នូ ឆ្នាំ ២០០០
Orange County, California.

# អារម្ភកថារបស់លោកស្រី ហ្វាត់ម៉ាស់ ស៊្វលេស

بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ

រឿងស្រ្តីក្នុងអ៊ីស្លាមជារឿងមួយដែលធ្វើឲ្យនាងខ្ញុំទាស់ចិត្ត និងធ្វើឲ្យនាងខ្ញុំចាប់ចិត្តជានិច្ច ។ ក្នុងនាមជាស្ត្រី មានកំណើតជាមុស្លីម កាលពីមុន នាងខ្ញុំមិនទុកចិត្តហើយចូលចិត្តប្រកែកតវ៉ាជំនឿនាងខ្ញុំ ។ នាងខ្ញុំចាត់ទុកអ៊ីស្លាមជាសាសនាកៀបសង្កត់ ជាសាសនាឃុំឃាំង ហើយជាសាសនាលំអៀងចំពោះស្រ្តី ។ ដូចស្រ្តីមុស្លីមឯទៀតដែរ (និងស្ត្រីមិនមែនមុស្លីម) នាងខ្ញុំបានតាំងមូលដ្ឋាននៃជំនឿនាងខ្ញុំនៅលើទង្វើសាសនា ជាជាងនៅលើខ្លឹមសារសាសនា បណ្តាលឲ្យនាងខ្ញុំស្អប់អ៊ីស្លាម ។

នាងខ្ញុំបានចម្លងសម្តីចំអកនិងរំខានរបស់ស្ត្រីម្នាក់ ដែលនាងខ្ញុំបានប្រទះមួយភ្លែត គឺៈ "សូមអរគុណអល់ឡោះហ្ ។ ខ្ញុំបានរកឃើញអ៊ីស្លាម មុនបានរកឃើញមុស្លីម ។" នាងខ្ញុំមិនត្រឹមតែបានរកឃើញ "មុស្លីម" មុនអ៊ីស្លាមនោះទេ សំអប់ចំពោះជំនឿនាងខ្ញុំដែលត្រូវបានសាងឡើងនោះក៏ត្រូវបានសម្តែងយ៉ាងច្បាស់នៅលើផ្ទាំងសំណេរ នៅក្នុងការបង្ហាត់បង្រៀន និងនៅក្នុងសេចក្តីមានៈតាមគំនិតខ្លួនដែលផ្ទុយនោះដែរដែលជាច្រវ៉ាក់ចងស្រ្តីមុស្លីម ។

ដូច្នេះ នាងខ្ញុំបានរស់នៅមួយប៉ែកធំនៃជីវិតឆ្ងាយពីទ្រឹស្តីដែលស្មានទុកមុននិងដែលស្មានខុសអំពីអ៊ីស្លាមនិងអំពីស្រ្តីមុស្លីម លុះដល់ពេលនាងខ្ញុំបានចាប់ផ្តើមសួរនិងគិតគូរដោយរដាក់ដុបអំពីរឿងផ្សេងៗ ដែលនាងខ្ញុំយល់ឃើញថាគួរឲ្យបារម្ភនិងស្មុគស្មាញ ។ ដូច្នេះឯងដែលនាងខ្ញុំចាប់ផ្តើមស្រាវជ្រាវរឿងស្រ្តីនិងអំពីសិទ្ធិស្រ្តីនៅក្នុងអ៊ីស្លាម ។

ដោយភក្តីភាពឥតលំអៀង នាងខ្ញុំប្រកាន់ជាប់ថាអល់ឡោះហ្ទ៍ដែលប្រកបដោយព្រះសុភគតិជាទីបំផុតទ្រង់ព្រះយុត្តិធម៌ ។ ដូច្នេះ បើអល់ឡោះហ្ទ៍ជាព្រះដែលយុត្តិធម៌មែននោះ ហេតុអ្វីចំណែកមរតកមិនស្មើគ្នារវាងភេទទាំងអស់ក្នុងអ៊ីស្លាម ? ហេតុអ្វីសាក្សីស្ត្រីមានតម្លៃត្រឹមតែពាក់កណ្តាលសាក្សីបុរស ? តើអល់ឡោះហ្ទ៍ចង់រឹតត្បិតជីវភាពស្ត្រីមុស្លីម បើកសេរីភាពឲ្យបុរសមុស្លីមឬ ? តើមានសិទ្ធិពិតប្រាកដសម្រាប់ស្ត្រីមុស្លីមទេ ? តើអ៊ីស្លាមយល់ឃើញយ៉ាងណាអំពីសមត្ថភាពស្ត្រី ? តើព្រះដែលយុត្តិធម៌មែននោះ ប្រព្រឹត្តិមិនត្រឹមត្រូវចំពោះសត្វលោកព្រះអង្គឬ ?

ស្វែងរកការពិតសុទ្ធឥតល្បាយ នាងខ្ញុំបានសួរអំពីរឿងទាំងនេះ ។ នាងខ្ញុំឃើញមានសិទ្ធិស្ត្រីក្នុងអ៊ីស្លាមនៅពីក្រោយរូបប្រដូចបង្ខូចទាំងនេះ នៅពីក្រោយអត្ថបទនិពន្ធស្មានខុសនិងឆ្វេសប្រហែសទាំងនេះ ។ ពិតឥតសង្ស័យ ស្ត្រីមុស្លីមមានសិទ្ធិជ្រាលជ្រៅនៅក្នុងសាសនាអ៊ីស្លាម ។ តែដូចនៅក្នុងសម័យកាលជាច្រើននៃអរិយធម៌ ពេលណាបុរសកាន់អំណាចពេលនោះបុរសប៉ងរារាំង បដិសេធសិទ្ធិស្ត្រី ឬដកហូតសិទ្ធិពីស្ត្រី មិនថាស្ត្រីទាំងនោះមានសាសនា មានវណ្ណៈ ឬមានសាសន៍អ្វីក៏ដោយ ។

ក្នុងចំណោមសិទ្ធិសំខាន់បំផុតដែលគេឲ្យទៅស្ត្រីនៅក្នុងអ៊ីស្លាមនោះ គឺសេរីភាពពេញទីក្នុងការសិក្សា ស្ត្រីមុស្លីមមិនបានទទួលផលប្រយោជន៍ពីសិទ្ធិនេះទេ ជួនកាលស្ត្រីត្រូវបដិសេធមិនឲ្យមានឱកាសសិក្សាទេ ។ ការមិនស្គាល់អ៊ីស្លាមជាសត្រូវធំមួយសម្រាប់ស្ត្រីមុស្លីម ។

ជាពិសេស នាងខ្ញុំយកចិត្តទុកដាក់អំពីអាយ៉ាត់គួរអាន អំពីស៊ូណាស់ព្រះសាស្តាﷺនិងអំពីច្បាប់ស្ហារីអ៊ាស់ (គឺច្បាប់ដែលមានគួរអានជាមូលដ្ឋាន) មិនច្បាស់លាស់មួយចំនួនពាក់ព័ន្ធនឹងរឿងស្ត្រី ។ លទ្ធផលដែលនាងខ្ញុំ

ស្វែងរកបានខ្លះនោះមិនសមហេតុសមផលទេ លំអៀងពីការពិត ឬត្រូវការវិភាគបំភ្លឺបន្ថែម ។ នាងខ្ញុំបានរកឃើញថាអានអាយ៉ាត់គួរអានឬច្បាប់ស្វារីអ៊ុស់តែម្យ៉ាងដោយមិនស្គាល់ខ្លឹមសារនោះ មិនអាចវាយតម្លៃគោលដៅពិតប្រាកដរបស់អាយ៉ាត់និងច្បាប់ស្វារីអ៊ុស់ទាំងនោះបានទេ ហើយបទបញ្ញត្តិជាច្រើនជាប់ទាក់ទិននឹងច្បាប់ផ្សេងៗទៀត ។

ឧទាហរណ៍ នៅក្នុងច្បាប់ហ៊ូឌូដ (حدود) និងគីស្វស់ (قصاص) (គឺច្បាប់ធ្វើទណ្ឌកម្មធ្ងន់នឹងកំហុសនិងទណ្ឌកម្មផ្នែកកាយ) ស្ត្រីមានតម្លៃពាក់កណ្តាលបុរសខាងទូទាត់សងអ្នកត្រូវសម្លាប់ ។ បើមើលតាមលក្ខណៈក្រៅ ច្បាប់នេះមានន័យថាជីវិតស្ត្រីមានតម្លៃទាបជាងជីវិតបុរស ។ តែត្រូវដឹងថាច្បាប់នេះផ្អែកទៅលើនិងយោលទៅតាមភេទបុគ្គល ដែលមានភារកិច្ចទទួលបន្ទុកចិញ្ចឹមគ្រួសារ (ជាអ្នករកប្រាក់មកផ្គត់ផ្គង់គ្រួសារ) ។

ប្រសិនបើស្ត្រីត្រូវសម្លាប់ ហើយស្ត្រីនោះមានភារកិច្ចជាអ្នកចិញ្ចឹមគ្រួសារ ថ្លៃសងឈាមរបស់ស្ត្រីនោះ នឹងត្រូវគិតគូរទៅតាមអត្រាថ្លៃសងឈាមបុរស ។ អត្ថបទនិពន្ធផ្នែកសាសនាអ៊ីស្លាមដែលធ្វើឲ្យយល់ខុស ឬខុសអត្ថន័យនោះនៅតែធ្វើឲ្យស្ត្រីមុស្លីមប្រៀបបាននឹងស្រមោល ។

នៅក្នុងកិច្ចស្រាវជ្រាវរបស់នាងខ្ញុំ នាងខ្ញុំចាប់ផ្តើមដោយបើកឲ្យឃើញនូវការយល់ឃើញខុសដ៏ច្រើនដែលនាងខ្ញុំបានប្រព្រឹត្តិ ។ អ៊ីស្លាមមិនមែនត្រឹមតែជាការគោរពសក្ការៈព្រះតែម្យ៉ាងនោះទេ តែជាប្រព័ន្ធស្ថាប័នមួយដែរដែលគ្រប់គ្រងសហគមន៍មួយ បុរសនិងស្រីដូចគ្នា ដើម្បីនឹងឲ្យសហគមន៍នោះមានដំណើរការចុះសម្រុងគ្នាជាឯកភាព ។

ក៏ប៉ុន្តែនៅមានសល់បញ្ហាច្រើនដែលត្រូវការបំភ្លឺ និងច្រើនបទបញ្ញត្តិដែលត្រូវការវិភាគ ។ នាងខ្ញុំ ដែលនៅក្នុងអត្រាមធ្យមនៃស្ត្រីមុស្លីម មិនស្គាល់

សិទ្ធិអ៊ីស្លាមទាំងអស់ដែលពាក់ព័ន្ធនឹងរឿងស្ត្រីមុស្លីមទេ ។

ស្ត្រីមុស្លីមមានសិទ្ធិសំខាន់ៗផ្នែកសង្គមនិងផ្នែកសេដ្ឋកិច្ច ។ សាច់រឿងស្ត្រីក្នុងសាសនាអ៊ីស្លាមទាមទារការវិភាគ ទាមទារការអធិប្បាយបំភ្លឺនិងការចេញជាលាយលក្សណ៍អក្សរ ។ នៅក្នុងការសិក្សាដាច់ឡែករបស់នាងខ្ញុំ នាងខ្ញុំស្រង់បានការស្នើសូម និងការអត្ថាធិប្បាយជាច្រើនអំពីរឿងស្ត្រីនៅក្នុងអ៊ីស្លាម ។ នាងខ្ញុំមានសំណាងបានជួបលោកអ្នកប្រាជ្ញដែលមានចំណេះដឹងមិនត្រឹមតែជ្រៅជ្រះទេ ថែមទាំងសហាសម័យទៀតផង (គឺបច្ចុប្បន្ន) ។

នាងខ្ញុំស្គាល់សៃយីដ្ន មុស្ទត៏ហ្វា អាល់-ក្វស់វីនី បីឆ្នាំមុននាងខ្ញុំបានស្នើសូមសរសេរសៀវភៅស្តីអំពីសិទ្ធិស្ត្រីក្នុងអ៊ីស្លាម ។ នាងខ្ញុំបានចូលរួមក្នុងសន្និសីទរបស់លោក បានស្តាប់លោកបកស្រាយទស្សនៈរបស់លោកអំពីអ៊ីស្លាមដោយយកចិត្តទុកដាក់ ហើយបានពិភាក្សារឿងអ៊ីស្លាមជាមួយលោក ។ សៃយីដ្ន មុស្ទត៏ហ្វា ជាអ្នកមានវោហារកោសល្យ តែលើសពីនោះ លោកមានសមត្ថភាពឆ្នើមខាងពិចារណាបែបទៅមកៗអំពីទ្រឹស្តីអ៊ីស្លាម ។ លោកជាញាតាដែលយល់ធ្លុះជ្រៅនិងយល់ឃើញឆ្ងាយលើសពីបែបបទខាងការប្រតិបត្តិអ៊ីស្លាមទៅទៀត ។

នាងខ្ញុំមានបំណងស្រាវជ្រាវរឿងស្ត្រីនៅក្នុងអ៊ីស្លម តាមទស្សនៈស្ត្រីជាមួយកោសល្យវិច័យរបស់អ្នកប្រាជ្ញមុស្លីម ។ ពេលនាងខ្ញុំបានទាក់ទងសៃយីដ្ន មុស្ទត៏ហ្វា ដើម្បីសរសេរសៀវភៅដែលស្តីអំពីស្ត្រីមុស្លីម លោកបានទទួលសំណូមពរនេះដោយគាំទ្រ ។ នាងខ្ញុំបានសាកសួរអស់មួយឆ្នាំ សៃយីដ្ន មុស្ទត៏ហ្វាបានឆ្លើយតបនាងខ្ញុំ ។

នៅក្នុងកិច្ចសម្ភាសន៍និងនៅក្នុងសារឆ្លើយឆ្លងដ៏ច្រើន យើងបានពិភាក្សា

និងចរចាអំពីអាយ៉ាស់គួរអាន អំពីស៊ូណាស់ព្រះសាស្តាﷺ អំពីសិទ្ធស្ត្រី រឿងអាពាហ៍ពិពាហ៍ អំពីការលែងលះគ្នា អំពីការធ្វើសាក្សី និងអំពីរឿងពាក់ព័ន្ធច្រើនទៀត - មានសាច់រឿងច្រើនមិនអស់ - ទាក់ទងនឹងស្ត្រីមុស្លីម ។ ដ្បិតលោកចេះដឹងសាសនាអ៊ីស្លាម និងដោយបានលើកឡើងនូវប្រភពព័ត៌មានផ្សេងៗ លោកអាចបកស្រាយនិងបំភ្លឺបញ្ហាទាក់ទងនឹងស្ត្រីក្នុងអ៊ីស្លាមបាន ។ លទ្ធផលចុងក្រោយគឺសៀវភៅដែលមានចំណងជើងថា "ស្ត្រីក្នុងអ៊ីស្លាម" ។

សាច់រឿងដែលលើកមកបរិយាយនៅក្នុងសៀវភៅនេះមានកំណត់ (គឺមិនបានលើកមកនិយាយទាំងអស់ទេ) តែសាច់រឿងទាំងនោះផ្អែកទៅលើមតិរួមរបស់លោកអ្នកប្រាជ្ញមុស្លីម និងព្រភពព័ត៌មានដែលអាចទុកចិត្តបានឯទៀត ។ ក៏ប៉ុន្តែ សាច់រឿងដែលបានលើកមកបរិយាយនិងសាច់រឿងដែលមិនបានលើកមកបរិយាយទេនោះ នៅតែត្រូវការស្រាវជ្រាវជ្រាលជ្រៅ ។ មធ្យោបាយមួយដើម្បីពង្រឹងកម្លាំងស្ត្រីមុស្លីមនោះគឺការសិក្សា ការសាកសួរព័ត៌មាននិងការសន្ទនា ។

គោលបំណងនាងខ្ញុំក្នុងការសរសេរសៀវភៅនេះ មិនមែនត្រឹមតែឲ្យដំណឹងដល់តែស្ត្រីមុស្លីមអំពីសិទ្ធិស្ត្រីនោះទេ តែដល់ស្ត្រីមិនមែនមុស្លីមដែរ ។ ថ្ងៃមួយគ្រូពេទ្យម្នាក់បានសួរនាងខ្ញុំថា៖ "តើស្ត្រីមុស្លីមមានសិទ្ធិទេ ?" ចម្លើយនាងខ្ញុំគឺ៖ "ប្រាកដជាមានណាស់ ។"

សំណាងរបស់ស្ត្រីមុស្លីមនោះគឺ សិទ្ធិស្ត្រីត្រូវព្រះប្រទានឲ្យមក ។ ស្ត្រីមិនត្រូវតស៊ូដើម្បីទាមទារសិទ្ធិរបស់ខ្លួនឡើយ តែការតស៊ូរបស់ស្ត្រីនោះគឺការធ្វើឲ្យគេគោរពសិទ្ធិរបស់ខ្លួន ។

ហ្វាត់ម៉ាស់ ស្វ៍លេស្ហ

ខេរ៉ម៉ាដូន ១៤២១/វិច្ឆិកា ២០០០

## វគ្គ ១ - ស្វែងរកការបំភ្លឺ

يَـٰٓأَيُّهَا ٱلنَّاسُ ٱتَّقُوا۟ رَبَّكُمُ ٱلَّذِى خَلَقَكُم مِّن نَّفْسٍ وَٰحِدَةٍ وَخَلَقَ مِنْهَا زَوْجَهَا وَبَثَّ مِنْهُمَا رِجَالًا كَثِيرًا وَنِسَآءً ۚ وَٱتَّقُوا۟ ٱللَّهَ ٱلَّذِى تَسَآءَلُونَ بِهِۦ وَٱلْأَرْحَامَ ۚ إِنَّ ٱللَّهَ كَانَ عَلَيْكُمْ رَقِيبًا ۝١

*មនុស្សអើយ (ប្រុសនិងស្រី) ចូរពួកអ្នកខ្លាចក្រែងព្រះម្ចាស់ពួកអ្នកដែលបានបង្កើតពួកអ្នកមកពីជីវិតតែមួយ (គឺមកពីអាដាំ ឬ ធម្មជាតិដើម ឬ វត្ថុដើម) ព្រះអង្គបានបង្កើតគូគ្រងរបស់ជីវិតនោះ (គឺហាវ៉ា) មកពីវា (គឺមកពីធម្មជាតិដើមឬមកពីវត្ថុដើមតែមួយនោះ) ហើយព្រះអង្គបានធ្វើឲ្យសាយពូជពង្ស[នៅលើផែនដី]ចេញអំពីពួកគេទាំងពីរ នូវមនុស្សប្រុសនិងមនុស្សស្រីជាច្រើន ។ ចូរពួកអ្នកខ្លាចក្រែងអល់ឡោះហ្វ៍ដែលពួកអ្នកបួងសួងសូមឲ្យគ្នា និង[ចូរប្រយ័តកុំកាត់]សាលោហិត ។ អល់ឡោះហ្វ៍ឃ្លាំមើលពួកអ្នក [បំណងនិងទង្វើរបស់ពួកអ្នក] (៤:១) ។*

**លោកស្រី ហ្វាត់ម៉ាស់** - អល់ឡោះហ្វ៍ ﷻ មានព្រះបន្ទូលថាព្រះអង្គ ﷻ បានបង្កើតមនុស្ស "ពីជីវិតតែមួយ" បន្ទាប់មកបានបង្កើតគូគ្រងរបស់ជីវិតនោះ ។ តើ "គូគ្រងរបស់ជីវិតនោះ" មានន័យថាស្ត្រីដែលត្រូវបង្កើតមកពីវត្ថុធាតុរបស់បុរសមែនទេ ? ម្យ៉ាងទៀត តើគួរអានចែងមិនចំថាស្ត្រីត្រូវបង្កើតឡើងក្រោយបុរសមែនទេ ?

**សែយីដ្** - មានលោកអ្នកប្រាជ្ញមុស្លីមខ្លះអះអាងថាបុរសត្រូវបង្កើតឡើងមុនគេបង្អស់ បន្ទាប់មកស្ត្រីត្រូវបង្កើតឡើងពីវត្ថុធាតុដែលនៅសល់ពីបុរស ។ តែ ដោយពិនិត្យមើលអាយ៉ាស់ខាងលើនេះ អល់ឡោះហ្វ៍ ﷻ បានប្រាប់ថាស្ត្រីនិងបុរសត្រូវបង្កើតឡើងព្រមគ្នា ហើយអ្នកទាំងពីរត្រូវបង្កើត

ឡើងពីវត្ថុធាតុដូចគ្នា ។

នេះគឺអត្ថន័យរបស់ "ជីវិតតែមួយ (مِّن نَّفۡسٖ وَٰحِدَةٖ)" ។ ការបង្កើតមនុស្សគឺការបែងចែកជាពីរភាគស្មើគ្នា ពោលគឺ តួរូប ឬ ម៉ាស់មួយត្រូវបែងជាពីរភាគ ។ ដូច្នេះ ភេទទាំងពីរត្រូវបានបង្កើតឡើងមកពីវត្ថុធាតុដូចគ្នាត្រឹមព្រមៗគ្នា ដូច្នេះ ពុំមានសារធាតុណាមួយនៅក្នុងកំណើតភេទទាំងពីរនេះខ្ពស់ជាងភេទមួយទៀតឡើយ ។

**លោកស្រី ហ្វាត់ម៉ាស់** - ដូច្នេះ តើអល់ឡោះហ្ ﷻ ផ្តោតទៅលើអ្នកណាពេលព្រះអង្គ ﷻ មានព្រះបន្ទូលថា៖ "បង្កើតគូគ្រងរបស់ជីវិតនោះ" ?

**សៃយីដ** - "គូគ្រងរបស់ជីវិតនោះ" មានន័យថាភរិយានិងស្វាមីទាំងគូ ។ អល់ឡោះហ្ ﷻ មានព្រះបន្ទូលថា ព្រះអង្គ ﷻ បានបង្កើតស្វាមីភរិយាមកពីអង្គភាព (គឺជីវិត ឬ វត្ថុធាតុ) នោះ ។ គេមិនចង់និយាយថាចំពោះតែភរិយា ឬចំពោះតែស្វាមីនោះទេ ។ គួរអានឲ្យភ័ស្តុតាងឥតប្រកែកបានថាបុរសនិងស្ត្រីកើតមកពីវត្ថុធាតុដើមតែមួយនិងដូចគ្នា ។ អល់ឡោះហ្ ﷻ បានបែងភេទទាំងពីរជាពីប៉ែកស្មើគ្នា ។ ពុំមានអាទិភាព ពុំមានឧត្តមភាព ឬហិនភាពនៅក្នុងការបង្កើតភេទទាំងអស់ទេ ។ មានសមាភាព (គឺស្មើគ្នា) ។ គួរអានចែងថា៖

وَمِنۡ ءَايَٰتِهِۦٓ أَنۡ خَلَقَ لَكُم مِّنۡ أَنفُسِكُمۡ أَزۡوَٰجٗا لِّتَسۡكُنُوٓاْ إِلَيۡهَا وَجَعَلَ
بَيۡنَكُم مَّوَدَّةٗ وَرَحۡمَةًۚ إِنَّ فِي ذَٰلِكَ لَأٓيَٰتٖ لِّقَوۡمٖ يَتَفَكَّرُونَ ٢١

*សញ្ញាមួយក្នុងចំណោមសញ្ញាទាំងឡាយរបស់ព្រះអង្គនោះគឺ ព្រះអង្គបង្កើតគូគ្រងពីពួកអ្នក (គឺពីវត្ថុធាតុដើមតែមួយ) សម្រាប់ពួកអ្នក ដើម្បីពួកអ្នកនឹងបានស្រាកស្រាន្តផ្លូវស្រោលដោយសារគូគ្រងនោះ ។ ព្រះអង្គបាន*

*បង្កើតឲ្យមានសេចក្តីស្រឡាញ់និងសេចក្តីមេត្តារវាងពួកអ្នក [និងគូគ្រងពួកអ្នក] ។ ក្នុងអ្វីទាំងនេះមាននូវសញ្ញាសម្រាប់ជនទាំងឡាយណាដែលត្រិះរិះ (៣០:២១) ។*

**លោកស្រី ហ្វាត់ម៉ាស់** - នាងខ្ញុំធ្លាប់បានអានសៀវភៅអ៊ីស្លាមខ្លះដែលថា ហ្វាវ៉ាអ៊ុំﷺត្រូវបង្កើតមកពីឆ្អឹងជំនីររបស់អាដាំﷺ[2] ។ នាងខ្ញុំបានរាប់បញ្ចូលទ្រឹស្តីនេះជាមួយលទ្ធិគ្រិស្តជានិច្ច មិនរាប់បញ្ចូលក្នុងអ៊ីស្លាមទេ ។ តើអ៊ីស្លាមមានគោលជំហរយ៉ាងណាអំពីរឿងនេះ ?

**សៃយីដ្** - មានសៀវភៅអ៊ីស្លាមមិនច្បាស់លាស់ខ្លះដែលអះអាងថាហ្វាវ៉ាអ៊ុំﷺត្រូវបង្កើតមកពីឆ្អឹងជំនីរ ឬ មកពីសំណល់អាដាំﷺ តែពុំមានភ័ស្តុតាងជាក់ច្បាស់ណាមួយដែលបញ្ជាក់ថា សៀវភៅទាំងនោះនិយាយពិតទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើសៀវភៅមិនជាក់លាក់បែបនេះកើតឡើងនៅក្នុងប្រភពព័ត៌មានអ៊ីស្លាមបានដូចម្តេចទៅ ? តើអស់លោកអ្នកប្រាជ្ញអ៊ីស្លាមវែកញែកបែបណា ថាសៀវភៅទាំងនោះមាននូវភ័ស្តុតាងច្រើនគ្រប់គ្រាន់ដើម្បីចាត់ទុកថាគួរឲ្យទុកចិត្តបាននោះ ?

**សៃយីដ្** - បរិយាយនិងកំណត់ច្បាស់លាស់ប្រភពព័ត៌មានទាំងអស់ដែលអស់លោកអ្នកប្រាជ្ញទុកចិត្តនោះវែងឆ្ងាយណាស់ ។ និយាយឲ្យខ្លី ខ្ញុំបាទនឹងប្រាប់ប្រភពព័ត៌មានអ៊ីស្លាមសំខាន់កំពូលពីរគឺ៖ គួរអាននិងហាឌីស្ហ[3]

---

[2] សូមមើលសៀវភៅ صحيح البخاري ។

[3] ហាឌីស្ហ, ស៊ុនណាស់, ឬ ទំនៀមទម្លាប់ ជាសកម្មភាព សម្តីនិងការអនុញ្ញាតរបស់ព្រះសាស្តាមូហាំម៉ាដ្ﷺទាក់ទងនឹងន័យនិងទង្វើអ៊ីស្លាមដែលត្រូវប្រាប់បន្ត

(គឺទំនៀមទម្លាប់របស់ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺ)[4] ។

អ្នកប្រាជ្ញទាំងអស់ មិនថាម៉ាស្ហាប់ (مذهب) ណាទេ មូលមតិគ្នាថាគួរអានទៀងត្រូវមិនខុស ។ ម៉ាស្ហាប់ទាំងអស់មិនប្រកែកតវ៉ារឿងអវិរុទ្ធនិងបរិសុទ្ធរបស់គួរអានទេ[5] ។ អត្ថបទគួរអានសព្វថ្ងៃនេះដូចអត្ថបទកាលត្រូវ

---

មកតាមរយៈបណ្ដាញអ្នកនិយាយបន្ត ។

[4] ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺបានប្រកាសផ្សាយព្រះរាជសារអ៊ីស្លាម ។

[5] ស្រាវជ្រាវអំពីស្ហ៊ីអ៊ុស្ហ៊ីស្លាម ដោយសៃយីដ្ស មុស្ហ្ត៏ហ្វា អាល់-ក្ហ៊ស្ហ៊វីនី ។ ម៉ាស្ហាប់អ៊ីស្លាម គឺមុស្លីមតាមគួរអាននិងស៊ូណាស្ហ៊ព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺ ។ មាន ៥ ម៉ាស្ហាប់គឺ៖ ម៉ាស្ហាប់ យ៉ាក្ហ៊ហ្វារី ដែលមានអ្នកតាម ២៣% ក្នុងចំណោមមុស្លីមទាំងអស់ បង្កើតឡើងដោយអ៊ីម៉ាំ យ៉ាក្ហ៊ហ្វារ អ៊ីបនូ មូហ៊ាំម៉ាដ់ អាល់-ស្ហ៊ឌិក្ហ៊عليه والسلام صلوات الله នៅឯម៉ាឌីណាស្ហ៊ ទឹកដីហ៊ីយ៉ាស្ហ៊ ឆ្នាំ ១៤៨ ហ៊ីច្រ៉ោះត៏សករាជ; អ៊ីម៉ាំ យ៉ាក្ហ៊ហ្វារ អាល់-ស្ហ៊ឌិក្ហ៊عليه والسلام صلوات اللهជាអ៊ីម៉ាំទី ៦ នៃអ៊ីម៉ាំទាំង ១២ នៃម៉ាស្ហាប់របស់អាស្ហ៊លុល-បៃត៏ (គឺសមាជិកព្រះរាជវង្សព្រះសាស្ដាមូហ៊ាំម៉ាដ់ﷺ) ។ ម៉ាស្ហាប់ ហ៊ាណាហ្វី មានអ្នកតាម ៣១% ក្នុងចំណោមមុស្លីមទាំងអស់; បង្កើតឡើងដោយ អ៊ីម៉ាំ អាល់-នុអ៊ម៉ាន អ៊ីបនូ ស្ហាប៊ីត ដែលគេស្គាល់ឈ្មោះច្បាស់ថា អាប៊ូ ហ៊ាណាហ្វី នៅឯគូហ្វាស្ហ៊ ប្រទេសអ៊ីរ៉ាក្ហ៊ ក្នុងសម័យអ៊ាបាស៊ីយ៉ាស្ហ៊ ។ ម៉ាស្ហាប់ ម៉ាលីគី មានអ្នកតាម ២៥% ក្នុងចំណោមមុស្លីមទាំងអស់; បង្កើតឡើងដោយ អ៊ីម៉ាំ ម៉ាលិក អ៊ីបនូ អាណាស់ អាល់-អាស្ហ៊បាហ៊ី នៅឯម៉ាឌីណាស្ហ៊ ទឹកដីហ៊ីយ៉ាស្ហ៊ ក្នុងសម័យអ៊ាបាស៊ីយ៉ាស្ហ៊ ក្នុងឆ្នាំ ១៤៨ ហ៊ីច្រ៉ោះត៏សករាជ ។ ម៉ាស្ហាប់ ស្ហាហ្វីអ៊ី មានអ្នកតាម ១៦% ក្នុងចំណោមមុស្លីមទាំងអស់; បានផុសឡើងនៅឯប្រទេសអេស៊ីបត៏ បង្កើតដោយ អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អ៊ីបនូ អ៊ីដ្ហ៊រីស ក្នុងសម័យត្រកូលហ្វាទីមីយ៉ាស្ហ៊កាន់អំណាច ។ ម៉ាស្ហាប់ ហ៊ាន់បាលី មានអ្នកតាម ៤% ក្នុងចំណោមមុស្លីមទាំងអស់; បង្កើតឡើងដោយអ៊ីម៉ាំ អាស្ហ៊ម៉ាដ់ អ៊ីបនូ ហ៊ាន់បាល់ នៅឯស្រុកបាក្ហ៊ដាដ់ តែល្បីតែនៅឧបទ្វីបអារ៉ាប់ទេដោយសារទ្រឹស្ដីរបស់ មូហ៊ាំម៉ាដ់ អ៊ីបនូ អ៊ាប់ដ្ហាល់-វ៉ាហ្ហាប់ អ្នកបង្កើតនិកាយវ៉ាស្ហ៊ប៊ី ។

ដាក់មកឲ្យព្រះសាស្តាមូហាំម៉ាដ្ ﷺ កាលពី ១៤០០ ឆ្នាំម្លេះ។ ក៏ប៉ុន្តែការបកស្រាយទៅជាបញ្ហា ពេលលោកអ្នកប្រាជ្ញអ៊ីស្លាមប៉ុនប៉ងពន្យល់គួរអាន។ អ្នកប្រាជ្ញមួយអាចបំភ្លឺឬយល់អាយ៉ាស្ទ់មួយបែប រីឯអ្នកប្រាជ្ញមួយទៀតអាចយល់ឃើញអាយ៉ាស្ទ់នោះផ្សេង។

ចំណែកឯការពិនិត្យស៊្វណាស្ទ់ព្រះសាស្តា ﷺ អស់លោកអ្នកប្រាជ្ញប្រយ័តប្រយែងណាស់អំពីការធានា ថាស៊្វណាស្ទ់ទាំងនោះជាស៊្វណាស្ទ់ពិតប្រាកដ។ អស់លោកអ្នកប្រាជ្ញមិនទទួលស្គាល់ថាស៊្វណាស្ទ់ទាំងអស់ជាស៊្វណាស្ទ់ពិតឥតក្លែងក្លាយទេ។ ដំបូង អ្នកប្រាជ្ញសិក្សានិងពិនិត្យយ៉ាងហ្មត់ចត់ថាស៊្វណាស្ទ់គួរឲ្យជឿឬទេ ថាបណ្តាញអ្នករាយការណ៍គួរឲ្យទុកចិត្តបានឬទេ ថាអ្នករាយការណ៍ទាំងនេះថាចំៗអ្វីខ្លះ។

ប្រសិនបើអ្នកប្រាជ្ញឃើញអ្នកនិពន្ធឬអ្នករាយការណ៍ណាមួយដែលមិនគួរឲ្យទុកចិត្តបានទេឬមិនគួរឲ្យជឿបានទេ ស៊្វណាស្ទ់របស់អ្នករាយការណ៍នោះនឹងត្រូវចោល។ ទន្ទឹមនោះដែរ បើលោកអ្នកប្រាជ្ញឃើញថាអ្នកនិពន្ធឬអ្នករាយការណ៍គួរឲ្យសង្ស័យ លោកនឹងចាត់ទុកស៊្វណាស្ទ់របស់អស់លោកទាំងនោះជាស៊្វណាស្ទ់ "ខ្សោយ"។ ការទទួលស្គាល់ស៊្វណាស្ទ់ផ្អែកទៅលើប្រការពីរ។

ប្រការដំបូង ស៊្វណាស្ទ់ត្រូវបញ្ជាក់ថាពិតតាមរយៈព្រះរាជកុលដ្ឋានព្រះសាស្តា ﷺ គឺអ៊ីម៉ាំអរិរុទ្ធទាំង ១២ អង្គ[6] ឬតាមរយៈបណ្តាសាវកភ័ក្តីរបស់ព្រះសាស្តា ﷺ ។ ប្រការទីពីរ ស៊្វណាស្ទ់របស់អ្នកប្រាជ្ញឬអ្នករាយការណ៍នោះមិនត្រូវផ្ទុយពីគួរអានទេ។ កាលណាប្រការទាំងពីរនេះត្រឹមត្រូវ

[6] អ៊ីម៉ាំទាំង ១២ អង្គ عليهم السلام ជាព្រះរាជបុត្ររាជនត្តានិងជាអ្នកស្នងព្រះសាស្តា ﷺ យោលតាមម៉ាស្ទ់ហ្វាប់អាស្ទ់លុល-បៃត៍ عليهم السلام ។

ហើយ កាលនោះអស់លោកអ្នកប្រាជ្ញជឿជាក់ថាសុបិនណាស់នោះជាសុបិនណាស់ពិតឥតក្លែងក្លាយមែន ។

នៅក្នុងអក្សរសាស្ត្រអ៊ីស្លាម មានស៊ុនណាស់មិនពិតសន្ទឹកសន្ធាប់ដែលគេហៅថា ស៊ុនណាស់ "យ៉ាហ្វូឌី" ។[7] នៅក្នុងប្រវត្តិសាស្ត្រអ៊ីស្លាម មានមនុស្សមួយចំនួនដែល ពេលបានបែរមកកាន់សាសនាអ៊ីស្លាមនោះ មិនស្គាល់និងមិនយល់មនោគមវិជ្ជាអ៊ីស្លាមពិតៗទេ តែមនុស្សចំពូកនេះនៅតែសរសេរស៊ុនណាស់ដែលគ្មានហេតុផលសមរម្យ ។ មនុស្សខ្លះក្នុងចំពូកនេះចាប់ផ្តើមផ្សាយសុសសាយស៊ុនណាស់គ្មានហេតុផល ឧទាហរណ៍ ដោយបញ្ចុះបញ្ចូលស៊ុនណាស់ដែលថាព្រះសាស្តាខ្លះសាងបាប ប្រព្រឹត្តអំពើផឹកក្បត់និងស្រវឹង ជាដើម ។ សម្តីមុសាវិកលចរិតបែបនេះមិនមាននៅក្នុងគោលអ៊ីស្លាមទេ ។ អស់លោកអ្នកប្រាជ្ញបិទស្លាកលើបណ្តាអ្នករាយការណ៍និងស៊ុនណាស់របស់ពួកគេនេះថា ស៊ុនណាស់ "យ៉ាហ្វូឌី" ។

មានមុស្លីមអ្នករាយការណ៍មួយចំនួនដែរ ដែលនៅក្រោមឥទ្ធិពលបុគ្គលមិនមែនមុស្លីម បានសេពគប់ជាមួយបុគ្គលទាំងនោះ អានសៀវភៅពួកគេយល់ស្របជាមួយគំនិតមួយចំនួនរបស់ពួកគេ ។ ដូច្នេះ អស់លោកអ្នករាយការណ៍ទាំងនោះបានរើសយកគំរូ និងទំនៀមទម្លាប់មិនមែនអ៊ីស្លាមទាំងនោះមកអនុវត្តិជាស៊ុនណាស់អ៊ីស្លាម ។ ស៊ុនណាស់ដែលត្រូវបានរាយការណ៍មួយចំនួនផ្ទុយពីគម្ពីរអាន បន្ថែមទៅក្នុងស៊ុនណាស់ព្រះសាស្តា ﷺ ឬពុំមានទំនាក់ទំនងជាមួយទស្សនៈអ៊ីស្លាម ឬពុំអាចជឿបានថាវានៅក្នុងទស្សនៈអ៊ីស្លាមនោះទេ ។

[7] យ៉ាហ្វូឌីជាពាក្យដែលចង្អុលទៅរកឆាករឿងនិទាន នៅក្នុងគម្ពីរគ្រិស្តសាសនាដែលត្រូវបញ្ចុះបញ្ចូលទៅក្នុងស៊ុនណាស់អ៊ីស្លាម ។

នៅចន្លោះសាខាអ៊ីស្លាមសំខាន់ទាំងពីរ[8] មានការជំទាស់គ្នាឥតឈប់ឈរអំពីអ្នករាយការណ៍ហាឌីស្ហ (ឬស៊ុនណាស្ហ) អ៊ីស្លាមនិងអំពីសម្ដីអ្នករាយការណ៍។ ឧទាហរណ៍ បណ្ដាអ្នកឧបត្ថម្ភសំខាន់ៗមួយចំនួននៃហាឌីស្ហស៊ុន្នី មិនត្រូវគេទទួលស្គាល់ដូចគ្នាដែរនៅក្នុងហាឌីស្ហ (ឬស៊ុនណាស្ហ) ស្ហ៊ីអាស្ហទេ។

អស់លោកអ្នកប្រាជ្ញស្ហ៊ីអាស្ហ មិនអាចទទួលយកហាឌីស្ហទាំងអស់សរសេរដោយបណ្ដាអ្នករាយរាកណ៍ល្បីៗទាំងនោះបានទេ ឧទាហរណ៍ លោកអ្នករាយការណ៍ម្នាក់ត្រូវស្ដីបន្ទោស ព្រោះតែបានថ្លែងហាឌីស្ហហួសហេតុ[9] ចំណែកឯលោកអ្នករាយការណ៍ឯទៀតបានសរសេរហាឌីស្ហបន្ទាយតែមានតែសាច់រឿងដ៏តិចប៉ុណ្ណោះដែលអាចចាត់ទុកថាគួរជឿបាននោះ។ ជួនកាលអស់លោកអ្នកប្រាជ្ញខ្លះនឹងប្រើហាឌីស្ហរបស់លោកអ្នករាយការណ៍ទាំងនេះដើម្បីបញ្ជាក់ចំណុចនីមួយ ថាសេចក្ដីរាយការណ៍នេះជាសេចក្ដីរាយការណ៍ពិតឥតក្លែងក្លាយ បើគេបានបញ្ជាក់ចំណុចនេះដោយប្រើប្រភពរាយការណ៍ផ្សេងនោះ។

ដើម្បីនិយាយសង្ខេប លោកអ្នកប្រាជ្ញមិនចាត់ទុកហាឌីស្ហសរសេរទាំងអស់ជាហាឌីស្ហពិតឥតក្លែងក្លាយទេ។ ប្រសិនបើលោកអ្នកប្រាជ្ញសង្ស័យអ្នកថ្លែងការសរសេរហាឌីស្ហណាមួយ ដែលគេមិនបានពិនិត្យទេនោះ លោកនឹងពិនិត្យមើល យ៉ាងហ្មត់ចត់សម្ដីទាំងអស់របស់អ្នកថ្លែងការនោះមុននឹងទទួលស្គាល់ថាហាឌីស្ហនោះជាហាឌីស្ហពិតឥតក្លែងក្លាយ។

---

[8] ស្ហ៊ីអាស្ហ គឺបណ្ដាអ្នកតាមព្រះសាស្ដាﷺតាមរយៈព្រះរាជវង្សអរិទ្ធរបស់ព្រះអង្គﷺ (សូមមើលគួរអាន ស៊ូរ៉ោះត៏ ៣៣ អាយ៉ាស្ហ ៣៣)។ ស៊ុន្នី គឺបណ្ដាអ្នកតាមព្រះសាស្ដាﷺតាមរយៈបណ្ដាសាវកព្រះអង្គﷺ ។

[9] សូមមើលសៀវភៅ ស្ហារហ្ហ៍ អ៊ីបនូ អាល់-ហាឌីយ៉ា ជុំទី ១ ទំព័រ ៣៦០។

បែរមកកាន់សំណួរលោកស្រីវិញ ហាឌីស្ហអ៊ីស្លាមខ្លះដែលមានដើមកំណើតពីគម្ពីរមុនៗ ដែលអះអាងថាហាវ៉ាអ៊្ញ សلام الله عليها ត្រូវបង្កើតមកពីឆ្អឹងជំនីរ ឬមកពីសំណល់របស់អាដាំ عليه السلام នោះ តែប្រភពព័ត៌មានពិតបដិសេធថារឿងនេះមិនពិតទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - នាងខ្ញុំបានអានហាឌីស្ហដែលអះអាងថាហាវ៉ាអ៊្ញ سلام الله عليها បានញុះញង់អាដាំ عليه السلام ឲ្យប្រព្រឹត្តល្មើសព្រះបញ្ជាអល់ឡោះហ្វ៍ عز وجل ថាព្រះនាង سلام الله عليها ជាមូលហេតុ ដែលធ្វើឲ្យមនុស្សត្រូវបណ្ដេញចេញពីឋានសួគ៌ ។ តើនៅក្នុងហាឌីស្ហនេះមានការពិតខ្លះទេ ?

**សៃយីដ្** - អាដាំ عليه السلام និងហាវ៉ាអ៊្ញ سلام الله عليها ត្រូវចាកចេញពីឋានសួគ៌ព្រោះព្រះអង្គទាំងពីរ عليهم السلام បានប្រព្រឹត្តល្មើសព្រះបណ្ដាំអល់ឡោះហ្វ៍ عز وجل[10] ។ ក៏ប៉ុន្តែ គួរអានលើកឡើងនូវគំនិតមួយ ដែលថាអាដាំ عليه السلام ត្រូវស្តីបន្ទោសច្រើនជាងហាវ៉ាអ៊្ញ سلام الله عليها[11] ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអង្គទាំងពីរ عليهم السلام បានសូមខមាទោសអល់ឡោះហ្វ៍ عز وجل ហើយអល់ឡោះហ្វ៍ عز وجل បានលើកលែងទោសព្រះអង្គទាំងពីរ عليهم السلام[12] ។ ម្យ៉ាងទៀត "បាបដើម" ដែលជាទ្រឹស្តីគ្រិស្តនោះមិនមាននៅក្នុងអ៊ីស្លាមទេ ។ រឿងនេះផ្អែកទៅលើពាក្យពេជន៍គួរអានដែលចែងថាពុំមានអ្នកណាមួយលីរែកបាបរបស់អ្នកដទៃទេ ។[13]

---

[10] គួរអាន ២:៣៦; ៧:២០-២៤ ។ បទល្មើសរបស់អាដាំនិងហាវ៉ាអ៊្ញ عليهم السلام មិនត្រូវចាត់ទុកជាបាបទេពីព្រោះវាមិនមែនជាព្រះបញ្ជាចាំបាច់ខានមិនបាននោះទេ តែវាជាការណែនាំ យោលតាមម៉ាស្ហ៊ហ្វាប់អាស្ហ៍លុល-បៃត៍ ។

[11] គួរអាន ២០:១១៥-១២១ ។

[12] គួរអាន ៧:២៣; ២:៣៦ ។

[13] គួរអាន ១៧:១៥ ។

وَلَا تَكۡسِبُ كُلُّ نَفۡسٍ إِلَّا عَلَيۡهَاۚ وَلَا تَزِرُ وَازِرَةٞ وِزۡرَ أُخۡرَىٰۚ

*ពុំមានអ្នកណាមួយ នឹងលីរ៉ែកអម្រែក[បាបកម្ម]របស់អ្នកដទៃទេ (៦:១៦៤) ។*

**លោកស្រី ហ្វាត់ម៉ាស់** - អ្វីដែលនាងខ្ញុំស្ងើចនោះគឺ ក្នុងអំឡុងពេលដ៏ខ្លីដែលព្រះសាស្តាﷺផ្សាយសាសនានោះ ព្រះអង្គﷺមានសមត្ថភាពរំលំទម្លាប់សម័យមុនអ៊ីស្លាមជាច្រើនរបស់ពួកអារ៉ាប់គ្មានសាសនា ដូចជាទម្លាប់កប់កូនស្រីទាំងរស់ជាដើម ។ ព្រះអង្គﷺមានសមត្ថភាពដាក់ឲ្យអនុវត្តិសិទ្ធិស្ត្រីក្នុងសម័យដែលគេមិនដែលធ្លាប់បានដឹងឮទ្រឹស្តីសិទ្ធិស្ត្រី នៅក្នុងសង្គមឡើយ ។[14]

ព្រះអង្គﷺអាចកែប្រែអាកប្បកិរិយាសង្គមបានដែល កាលពីប៉ុន្មានឆ្នាំមុននោះ ជាសង្គមឃោរឃៅចំពោះស្ត្រី ។ អ្វីដែលនាងខ្ញុំភ្ញាក់ផ្អើលខ្លាំងនោះគឺបន្ទាប់ពីព្រះសាស្តាﷺសោយទិវង្គតភ្លាម សិទ្ធិស្ត្រីនិងការប្រព្រឹត្តិចំពោះស្ត្រីបែរជាវិលទៅរកស្ថានភាពអាក្រក់វិញគួរឲ្យឡកឡឺយ ។ សព្វថ្ងៃនេះស្ត្រីមុស្លីមនៅតែតស៊ូដើម្បីទាមទារសិទ្ធិរបស់ខ្លួន និងខិតខំយកជ័យជំនះលើមតិដែលមើលមកខ្លួនថាជាប្រជានិការីទាបជាងគេនៅក្នុងសង្គមរបស់ខ្លួននោះ ។ តើសៃយីដ្ធអាចសន្និដ្ឋានបានទេថាវាកើតឡើងបានដូចម្តេច ?

**សៃយីដ្ធ** - ផលដំបូងដែលលោកស្រីបានបង្ហាញនោះមិនត្រឹមត្រូវទាំងអស់ទេ ។ ពិតមែន ព្រះសាស្តាﷺបានរំលំអំពើមិនត្រឹមត្រូវដែលត្រូវប្រព្រឹត្តលើស្ត្រី ដូចជាសម្លាប់កូនស្រី[15] បង្ខំស្ត្រីឲ្យប្រព្រឹត្តអំពើពេស្យា[16] ធ្វើបាប

---

[14] ឧទាហរណ៍ សិទ្ធិទទួលមរតក, សិទ្ធិបោះឆ្នោត, សិទ្ធិមានសេរីភាពនិយាយ ស្តី, សិទ្ធិជួញដូរ និងសិទ្ធិសិក្សា ។

[15] គួរអាន ១៦:៥៨-៥៩; ១៧:៣១ ។

ស្រីដោយស្វាមី[17] ជាដើម ។

ក្នុងពេលនោះដែរ អ៊ីស្លាមបានបើកសិទ្ធិឲ្យស្ត្រីអាចបោះឆ្នោតបាននៅក្នុងការនយោបាយ[18] ឲ្យស្ត្រីអាចធ្វើធុរកិច្ចបាន[19] ឲ្យស្ត្រីអាចទាមទារមរតកបាន[20] ។ ក៏ប៉ុន្តែ មិនត្រឹមត្រូវទេដែលថាព្រះសាស្តាﷺអាចកែប្រែអាកប្បកិរិយារបស់សង្គមទាំងមូលបាននោះ ។

សូមលោកស្រីពិនិត្យមើលស៊ូរ៉ោះត៍ "អាត់-តៅបាស់" (ស៊ូរ៉ោះត៍ទី ៩) និង ស៊ូរ៉ោះត៍ "អាល់-មូណាហ្វីគួន" (ស៊ូរ៉ោះត៍ទី ៦៣) ក្នុងគួរអាន ។ ស៊ូរ៉ោះត៍ទាំងនេះពណ៌នាអំពីចរិតវៀចវេរ និងអាការមិនពេញចិត្តរបស់មនុស្សមួយចំនួននៅក្នុងសង្គម ។

សូមវិភាគមើលថា អល់ឡោះហ្ ﷻមានព្រះបន្ទូលចំពោះបុគ្គលមួយចំនួននៅក្នុងសង្គមដោយសេចក្តីស្អប់ម្តេចខ្លះ ។ សូមពិនិត្យមើលថាបុគ្គលខ្លះបានប្រព្រឹត្តបែបណាខ្លះចំពោះព្រះសាស្តាﷺ បានធ្វើឲ្យព្រះសាស្តាﷺកើតទុក្ខដូចម្តេចខ្លះ ព្រោះតែបុគ្គលទាំងនោះមិនគោរពនិងល្មើសបញ្ជា ។ សមាជិកខ្លះរបស់សង្គមនោះមិនស្មោះត្រង់ទេ មិនដឹងខ្លួនទេនិងទទឹងរឹងរូស ។

ក្រោយពេលព្រះសាស្តាﷺសោយទិវង្គតក៏ដោយ អ្នកស្នងដំបូង គឺ អាប៊ូបាការ បានចំណាយពេលច្រើនដើម្បីការពារទល់នឹងការវាយប្រហារ

[16] គួរអាន ២៤:៣៣ ។
[17] គួរអាន ២:២៣១-២៣២ ។
[18] គួរអាន ៦០:១២ ។
[19] គួរអាន ៤:៣២ ។
[20] គួរអាន ៤:៧ ។

របស់ពួកបោកប្រាស់ចុះចូលសាសនា ។ មិនត្រឹមត្រូវទេដែលសន្និដ្ឋានថា យុត្តិធម៌ សេចក្ដីគោរពនិងការចុះសម្រុងគ្នានោះប្រកបដោយជោគជ័យ ។

អ៊ីស្លាមប្រទានសិទ្ធិឲ្យស្ត្រីទទួលមរតកពីគ្រួសាររបស់ខ្លួន ។ ក៏ប៉ុន្តែ សូមលើកឡើងនូវតួយ៉ាងនៃសង្គមដែលផ្លាស់ប្ដូរឃើតគឺ មួយរយៈពេលដ៏ខ្លីបន្ទាប់ពីព្រះសាស្ដាﷺបានសោយទិវង្គត ព្រះនាង ហ្វាទីម៉ាស់سلام الله عليها ព្រះរាជបុត្រីជាទីស្រឡាញ់របស់ព្រះអង្គﷺ ត្រូវគេបដិសេធមរតករបស់ព្រះនាងسلام الله عليها ។ ទោះជាគេបានដកហូតយកមរតកព្រះនាងسلام الله عليهاដោយមូលហេតុនយោបាយនិងសេដ្ឋកិច្ចក៏ដោយ ក៏ការបដិសេធនេះមិនត្រឹមត្រូវទេដែរ ។ មនុស្សមួយចំនួននៅតែកាន់យកទំនៀមទម្លាប់នោះជាធំ ជាពិសេសពាក់ព័ន្ធនឹងរឿងស្ត្រីតែម្ដង ។

កាលពីមុននិងសព្វថ្ងៃ ស្ត្រីតស៊ូដើម្បីសិទ្ធិរបស់ខ្លួនក្នុងអ៊ីស្លាម ។ មិនអាចបន្ទោសអ៊ីស្លាមឬព្រះសាស្ដាﷺបានទេ ដែលគេប្រព្រឹត្តមិនត្រឹមត្រូវចំពោះស្ត្រីនោះ ។ គេមិនអាចរិះគន់សាសនាបានទេដែលគេដកហូតសិទ្ធិស្ត្រីនោះ ។ ពិតមែន ស្ត្រីមុស្លីមក្នុងសតវត្សរ៍ទី ២១ នៅក្នុងស្ថានភាពប្រសើរជាងស្ត្រីក្នុងសម័យមុន តែសព្វថ្ងៃនេះ ស្ត្រីមួយចំនួននៅតែប្រឈមនឹងសង្គមដែលប្រើទំនៀមទម្លាប់កុលសម្ព័ន្ធចាស់ដែលមិនស្គាល់សិក្ខាបទនិងការប្រតិបត្តិពិតប្រាកដរបស់អ៊ីស្លាមទេ ។

**អ្នកស្រី ហ្វាត់ម៉ាស់** - ដោយផ្ដោតទៅលើសម្ដីសៃឃីដ្ឋដែលថាព្រះសាស្ដាﷺមិនអាចកែប្រែចិត្តគំនិត និងទំនៀមទម្លាប់របស់មនុស្សមួយចំនួនដែលនៅជុំវិញព្រះអង្គﷺនោះបាន តើព្រះសាស្ដាﷺបានធ្វើអ្វីបានសម្រេចខ្លះ បើគេពុំបានគោរពច្បាប់គួរអានទេនោះ ?

**សៃឃីដ្ឋ** - ការដឹកនាំជាភារកិច្ចរបស់អល់ឡោះហ្ម៍عز وجلដែលនៅលើចំណង់ចិត្ត

របស់មនុស្ស ។ គួរអានចែងថា៖

إِنَّكَ لَا تَهۡدِى مَنۡ أَحۡبَبۡتَ وَلَـٰكِنَّ ٱللَّهَ يَهۡدِى مَن يَشَآءُۚ وَهُوَ أَعۡلَمُ بِٱلۡمُهۡتَدِينَ

*ការពិត [មូហាំម៉ាដ់អឺយ] អ្នកមិនអាចដឹកនាំអ្នកណាដែលអ្នកស្រឡាញ់បានទេ តែអល់ឡោះហ៍ទេជាអ្នកដឹកនាំអ្នកណាស្រេចតែលើព្រះអង្គ ។ ព្រះអង្គទ្រង់ញាណថាអ្នកណាខ្លះ [ដែលចង់]ឋិតនៅលើមាគ៌ាល្អ (២៨:៥៦) ។*

អ្វីដែលព្រះសាស្តាﷺបានអនុវត្តិបានសម្រេចនោះ គឺព្រះអង្គﷺបានផ្តួចផ្តើមបង្កើតច្បាប់ស្របទៅតាមគួរអានដើម្បីមនុស្សជាតិ ម្យ៉ាងទៀត ព្រះអង្គﷺបានកំណត់របៀបរស់នៅដែលជាគំរូ ដោយបង្ហាត់បង្រៀនមនុស្សឯទៀតឲ្យចេះគ្រប់គ្រងនិងចេះដោះស្រាយនៅក្នុងព្រឹត្តិការណ៍ និងស្ថានការណ៍ដែលកើតនៅក្នុងជីវិត ។

ច្បាប់គួរអានមិនសម្រាប់តែមនុស្សមួយក្រុមដែលរស់នៅឯម៉ាឌីណាស៊ ឬម៉ាក់កាស៊ុកាលពី ១៤០០ ឆ្នាំកន្លងមកហើយនោះទេ ។ ព្រះសាស្តាﷺដឹងច្បាស់ណាស់ ថាអ៊ុមម៉ាត់ព្រះអង្គﷺនឹងមិនអាចផ្លាស់ប្តូរបានយ៉ាងងាយៗទេ ។ បណ្តាអ្នកដែលបានចូលកាន់សាសនាអ៊ីស្លាមក្នុងសម័យព្រះសាស្តាﷺមានព្រះជន្មនៅឡើយនោះ ភាគច្រើនមានអាយុក្នុងចន្លោះសាមសិបឆ្នាំនិងហុកសិបឆ្នាំ ។ ពួកគេចាស់បុគ្គលលក្ខណៈ ចាស់ចរិតនិងចាស់ចិត្តចាស់គំនិតស្រេចហើយ ។

ព្រះសាស្តាﷺមិនអាចកែប្រែចិត្តគំនិតមនុស្សគ្រប់គ្នាបានក្នុងរយៈពេលដ៏ខ្លីនោះបានទេ ។ រយៈពេលនោះជាអន្តរៈកាលចាប់ពីយុគសម័យអវិជ្ជានិងលទ្ធិគ្មានសាសនា ទៅដល់យុគសម័យជំនឿនិងសច្ចធម៌ទៀងត្រង់ ។ ច្បាប់គួរអានត្រូវអនុវត្តិដោយមនុស្សជំនាន់ក្រោយៗ ក្នុងអនាគតកាល ។ ប្រៀបដូចយើងព្យាយាមអប់រំកូនៗយើងឲ្យបានល្អ ឯព្រះសាស្តាﷺក៏

ដូច្នោះដែរ ។ ព្រះសាស្តាﷺព្យាយាមបំពេញភារកិច្ចដើម្បីមនុស្សជំនាន់ក្រោយៗ សម្រាប់បណ្តាអ្នកដែលនឹងប្រកាន់យកនិងអនុវត្តិសិក្ខាបទអ៊ីស្លាម ។

**អ្នកស្រី ហ្វាត់ម៉ាស់** - *"ចូរពួកនាងនៅក្នុងផ្ទះសម្បែងពួកនាង ចូរពួកនាងកុំបង្ហាញខ្លួនឡើយ ដូច[បណ្តាស្ត្រី]ដែលធ្លាប់បានធ្វើក្នុងសម័យខ្លៅល្ងង់កាលពីមុន ។" (៣៣:៣៣)*

*"ចូរពួកនាងនៅក្នុងផ្ទះសម្បែងពួកនាង"* អាយ៉ាស់គួរអាននេះស្តីហាក់ដូចជាចែងអំពីមហេសីព្រះសាស្តាﷺ ក៏ប៉ុន្តែលោកអ្នកប្រាជ្ញមុស្លីមខ្លះដាក់ឲ្យប្រើអាយ៉ាស់នេះលើស្ត្រីមុស្លីមទាំងអស់ដែរ ។ តើអាយ៉ាស់នេះចែងផ្តោតចំពោះស្ត្រីមុស្លីមទាំងអស់ ឬចំពោះតែមហេសីព្រះសាស្តាﷺទេ ?

**សៃយីដ្** - អាយ៉ាស់ពិសេសនេះចែងសំដៅមហេសីព្រះសាស្តាﷺ តែមិនបានសេចក្តីទេថា រាល់គ្រាដែលគួរអានចែងដល់មហេសីព្រះសាស្តាﷺ គឺបានតែលើមហេសីព្រះអង្គﷺ មិនបានលើស្ត្រីដទៃនោះទេ ។ បើយើងសិក្សាគួរអាន យើងនឹងបានជួបអាយ៉ាស់ច្រើនដែលនៅក្នុងអាយ៉ាស់នោះអល់ឡោះហ្វ៍عزّ وجلّមានព្រះបន្ទូលសំដៅព្រះសាស្តាﷺ តែការពិតអល់ឡោះហ្វ៍عزّ وجلّមិនមានព្រះបន្ទូល ទៅកាន់តែព្រះសាស្តាﷺនោះទេ ។ អល់ឡោះហ្វ៍عزّ وجلّទាមទារឲ្យព្រះសាស្តាﷺ ទទួលស្គាល់ព្រះបន្ទូលព្រះអង្គعزّ وجلّដែលបានបើកឲ្យដឹងនោះ ហើយព្រះអង្គﷺចង់ឲ្យប៉ែកឯទៀតនៃសហាគមន៍មុស្លីមស្តាប់និងទទួលយកព្រះបន្ទូលទាំងនោះ ។

*"ចូរពួកនាងនៅក្នុងផ្ទះសម្បែងពួកនាង"* មិនមានន័យថាស្ត្រីមិនអាចចេញពីក្នុងផ្ទះបាននោះទេ ។ នេះគឺសេចក្តីប្រកាសប្រាប់ស្ត្រីអំពីការដើរទៅណាមកណាដែលមិនចាំបាច់ ឬអំពីការស្ថិតនៅទីកន្លែងដែលគួរឲ្យសង្ស័យ ។

ឲ្យខ្ញុំសូមបង្ហាញឧទាហរណ៍មួយ ។ ប្រសិនបើនៅក្នុងលានប្រយុទ្ធ មានបុរសគ្រប់គ្រាន់កំពុងបំពេញកិច្ចការនិងកំពុងប្រយុទ្ធហើយ មិនចាំបាច់ឲ្យស្ត្រីនៅក្នុងលានប្រយុទ្ធនោះទេ ។ ប្រាកដណាស់ ស្ត្រីអាចជួយជ្រោមជ្រែងបានក្នុងវិស័យផ្សេង តែមិនត្រូវនៅក្នុងសមរភូមិ ប្រយុទ្ធក្នុងជួរមុខទេ ។

លោកអ្នកប្រាជ្ញខ្លះបកស្រាយអាយ៉ាស់នេះ ថាវាជាការព្រមានចំពោះមហេសីមួយរបស់ព្រះសាស្តាﷺ ប្រាប់មហេសីនោះកុំឲ្យបង្កជម្លោះ ឲ្យនៅក្នុងផ្ទះ ។ ច្រើនឆ្នាំបន្ទាប់ពីព្រះសាស្តាﷺបានសោយទិវង្គត មហេសីមួយរបស់ព្រះអង្គﷺ បានចូលដៃក្នុងការបំបែរសង្គ្រាមមកទល់នឹងស្តេចខ៏លិហ្វស្របច្បាប់ អ៊ីម៉ាំអាលីصلوات الله عليه والسلام នៅក្នុងសមរភូមិយ៉ាំមីល (معركة الجمل) ដែលបង្កឲ្យមុស្លីមរាប់ពាន់នាក់បាត់បង់ជីវិត ។

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ីស្លាមយល់ឃើញយ៉ាងណាអំពីធម្មជាតិស្ត្រី ?

**សៃយីដ់** - ស្ត្រីនិងបុរសកើតមកដោយមានលក្ខណៈសម្បត្តិមនុស្សដូចគ្នា ជាដៃគូគ្នាក្នុងមនុស្សជាតិ យោលតាមអ៊ីស្លាម ។ ស្ត្រីជាមនុស្សពិតប្រាកដដូចបុរសដែរ ។ អាស្រ័យហេតុនេះ ស្ត្រីទទួលបាននូវសិទ្ធិដែលមិនអាចប្រកែកបាន មិនអាចបដិសេធបានដូចសត្វលោកទាំងឡាយរបស់អល់ឡោះហ្ ﷻដែរ ។

ស្ត្រីមិនកើតមកដោយមិនបរិបូរ ឬអន់ប្រាជ្ញាជាងសមភាគីបុរសឡើយគ្រប់ករណី ។

لَقَدْ خَلَقْنَا ٱلْإِنسَـٰنَ فِىٓ أَحْسَنِ تَقْوِيمٍ ٤

*ពិតណាស់ យើងបានបង្កើតមនុស្ស (បុរសនិងស្ត្រី) មកដោយមានទម្រង់*

*ល្អបំផុត (៩៥:៤) ។*

សមត្ថភាពពីកំណើតរបស់ស្ត្រីក្នុងការវែកញែករកខុសត្រូវនោះ ដូចសមត្ថភាពពីកំណើតក្នុងការវែកញែករកខុសត្រូវរបស់បុរសដែរ ។ ស្ត្រីមិនមាននិស្ស័យទេរទៅរកអំពើអាក្រក់ពីកំណើតលើសជាងបុរសឡើយ ។

وَنَفْسٍ وَمَا سَوَّىٰهَا ۞ فَأَلْهَمَهَا فُجُورَهَا وَتَقْوَىٰهَا ۞
*[អញសូមស្បថ]នឹងព្រលឹងនិងអ្នកដែលបានធ្វើឲ្យវាពេញលេញ ។ ហើយព្រះអង្គបានញ៉ាំងវាឲ្យដឹងសេចក្ដីអាក្រក់និងសេចក្ដីល្អ (៩១:៧-៨) ។*

យោលតាមគួរអាន អល់ឡោះហ្ជ៏កំណត់លក្ខណៈស្ត្រីថា "خَيْرًا كَثِيرًا *សេចក្ដីល្អប្រពៃធំមួយ (៤:១៩)" ។*

ស្ត្រីមកកាន់លោកនេះជាមួយវិញ្ញាណស្អាត បរិសុទ្ធនិងគ្មានអំពែកធ្ងន់ ។
وَلَا تَكْسِبُ كُلُّ نَفْسٍ إِلَّا عَلَيْهَا ۚ وَلَا تَزِرُ وَازِرَةٌ وِزْرَ أُخْرَىٰ ۚ
*អ្នកណាមួយសាងអំពើអាក្រក់ អ្នកនោះសាងអំពើអាក្រក់លើខ្លួនឯងទេ ។ ពុំមានអ្នកណាមួយនឹងលីវែក អម្រែក[បាបកម្ម]របស់អ្នកដទៃទេ (៤:១៦៤) ។*

កាតព្វកិច្ចរបស់ស្ត្រី ក្នុងការបំពេញមុខនាទីសាសនាដើម្បីអល់ឡោះហ្ជ៏ ស្មើនឹងកាតព្វកិច្ចរបស់បុរស ក្នុងការបំពេញមុខនាទីសាសនាដើម្បីអល់ឡោះហ្ជ៏ដែរ រីឯរង្វាន់និងទោសរបស់ស្ត្រីនោះក៏ស្មើគ្នានឹងរង្វាន់និងទោសរបស់បុរសដែរ ។
أَنِّي لَآ أُضِيعُ عَمَلَ عَٰمِلٍ مِّنكُم مِّن ذَكَرٍ أَوْ أُنثَىٰ ۖ
*អញមិនឲ្យទង្វើរបស់អ្នកណាមួយក្នុងចំណោមពួកអ្នក ប្រុសឬស្រី បាត់*

*បង់ឡើយ ។ ពួកអ្នកជាពំនាក់រវាងគ្នានិងគ្នា (៣:១៩៥) ។*

ស្ត្រីអាចទៅដល់ដំណាក់ការជិតស្និទ្ធនឹងអល់ឡោះហ្ ﷻដូចបុរសដែរ ។

وَمَن يَعۡمَلۡ مِنَ ٱلصَّٰلِحَٰتِ مِن ذَكَرٍ أَوۡ أُنثَىٰ وَهُوَ مُؤۡمِنٌ فَأُوْلَٰٓئِكَ يَدۡخُلُونَ ٱلۡجَنَّةَ

*បុគ្គលណាមួយ បុរសឬស្ត្រី ដែលប្រព្រឹត្តអំពើល្អ ព្រមទាំងមានសទ្ធា បុគ្គលនោះនឹងបានចូលឋានសួគ៌ (៤:១២៤) ។*

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ីស្លាមយល់ឃើញយ៉ាងណាអំពីឋានៈនិងអំពីសមត្ថភាពទទួលខុសត្រូវរបស់ស្ត្រី ?

**សៃយីដ្** - ស្ត្រីត្រូវបង្កើតមកដើម្បីជាពាក់កណ្តាលអ៊ុមម៉ាត់ ។ ស្ត្រីត្រូវជួយធានាសីលធម៌ រក្សាសុវត្ថិភាព ការពារសុខុមាលភាពមនុស្សជំនាន់ក្រោយៗ និងដើម្បីទៅជាមាតា ។ ស្ត្រីត្រូវបង្កើតមកដើម្បីជាមាតា ជាអ្នកអប់រំកូននិងមានមុខនាទីសំខាន់ៗច្រើនទៀត ។

នៅក្នុងសម័យយើង ស្ត្រីមួយចំនួនបាត់បង់មោទនភាពដែលជាមាតាឬដែលទៅជាមាតា ។ កិត្តិយស សេចក្តីថ្លៃថ្នូរនិងសេចក្តីស្ងើចសរសើរភាពជាមាតាបានធ្លាក់ចុះ ។ អ្នកខ្លះឃើញថា "មាតា" ឬ "មេផ្ទះ" ជាអ្វីដែលថោកថយ ។ ភាពជាមេផ្ទះ ឬជាមាតានោះមិនធ្វើឲ្យអាម៉ាស់មុខ មិនធ្វើឲ្យអាប់ឱនកិត្តិយសទេ ។ មិនអាក្រក់ទេដែលស្រឡាញ់និងផ្គត់ផ្គង់គ្រួសារនោះ ។

ផ្ទុយទៅវិញ ភាពជាម្តាយជាគ្រឹះសំខាន់បំផុតដែលជាពំនាក់អាស្រ័យរបស់កូន ។ ម្តាយជាអ្នកអប់រំកូនៗ ជាគ្រូរបស់កូន ។ កូនៗមើលមកម្តាយ

កោតសរសើរម្តាយ រៀនពីម្តាយ ទទួលចរិយាមារយាទ សម្បត្តិនិស្ស័យ និងការចេះអាណិតអាសូរមកពីម្តាយ ។ ភាពជាមាតាជាអ្វីដែលល្អប្រសើរ មានតម្លៃនិងសំខាន់ ។ ក្លាយទៅជាមាតាដ៏ល្អមានការលំបាកនិងត្រូវការពេលយូរ ។

ក៏ប៉ុន្តែ មិនត្រូវកាត់បន្ថយសារៈសំខាន់របស់បិតាទេដែរ ។ តួនាទីរបស់ឪពុកសំខាន់ណាស់សម្រាប់សុខុមាលភាពគ្រួសារ អត់ឪពុកនឹងមានការលំបាក ។ តែអត់ម្តាយអាចកើតមានអន្តរាយសម្រាប់គ្រួសារ ។ ម្តាយជាខ្សែចំណងចងគ្រួសារយ៉ាងជាប់ជាអង្គភាពមួយ ។

មាតាជាអ្នកកសាងអ៊ុមម៉ាត់ ។ មាតាជាអ្នកបំប៉នបណ្តាមេដឹកនាំដ៏ល្បីៗ បណ្តាអ្នកវិទ្យាសាស្ត្រ បណ្តាបណ្ឌិត បណ្តាស្វាមី បណ្តាភរិយា បណ្តាឪពុកនិងម្តាយ ។ ម្តាយអាចប្តូរអ៊ុមម៉ាត់ទាំងមូលបានដោយបណ្តុះបណ្តាលកូនម្នាក់ឲ្យធាត់ធំ ។ កូននេះអាចនឹងកែប្រែប្រទេសជាតិទាំងមូលបាន ។ ការពិត មាតាចារប្រវត្តិសាស្ត្រ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ីស្លាមជ្រោមជ្រែងស្ត្រីឲ្យចេះមានស្មារតីមិនពឹងពាក់អ្នកដទៃ ឲ្យចេះបំពេញសេចក្តីត្រូវការដោយខ្លួនឯងបានទេ ? តើស្ត្រីមានសេរីភាពជ្រើសរើស អាចទៅជាអ្នកណាមួយបានទេក្នុងជីវិត ?

**សៃយីដ់** - ស្ត្រីត្រូវតែចេះមិនពឹងពាក់គេនិងអាចបំពេញសេចក្តីត្រូវការដោយខ្លួនឯងបានយ៉ាងបរិបូរ ទាំងពេលមុនមានគ្រួសារ ទាំងក្នុងពេលមានគ្រួសារ ព្រមទាំងពេលលែងលះគ្នាឬពេលស្លាប់ ។ ស្ត្រីត្រូវតែត្រៀមខ្លួនជាស្រេច គ្រប់ពេល ក្នុងការពឹងពាក់តែលើខ្លួនឯង ។ ពុំមានអ្នកណាដឹងយ៉ាងពិតប្រាកដថាអនាគតនោះយ៉ាងណាទេ ។ ការចេះមិនពឹងពាក់គេនិងការអាចបំពេញសេចក្តីត្រូវការដោយខ្លួនឯងបាន អាចមាន

លទ្ធផលល្អច្រើន ដូចជាមានទំនុកចិត្តខ្លួនឯង ផុតភ័យនិងមានសេចក្តីក្លាហាន ជាដើម ។ ក៏ប៉ុន្តែអ៊ីស្លាមចង់ឲ្យស្ត្រីដឹងដែរថាការសម្រេចចិត្តខ្លះត្រូវតែធ្វើដោយប្រឹក្សាជាមួយបុគ្គលណាម្នាក់ក្នុងជីវិត ដូចជាឪពុកម្តាយជាដើម ។

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ីស្លាមល្អៀងទៅរកការបែងចែកភេទទេ ?

**សៃយីដ្** - ការបែងចែកភេទតម្រូវទៅលើឱកាស កាលៈទេសៈ ឬគ្រឹះស្ថាន ។ ឧទាហរណ៍ អ៊ីស្លាមប្រៀនប្រដៅឲ្យបែងចែកភេទពេលមានជំនុំមនុស្សក្នុងការសប្បាយរីករាយ ព្រោះវាអាចមានលទ្ធផលអាក្រក់ ។

ក៏ប៉ុន្តែ អ៊ីស្លាមមិនហាមការជំនុំរួមទេក្នុងការពិភាក្សារកការចេះដឹង ក្នុងការផ្តល់ព័ត៌មានឬទាក់ទងនឹងសាសនា ។ ចំណុចសំខាន់គឺ ប្រសិនបើគេមិនខ្លាចមានអំពើមិនគប្បីកើតឡើងទេនោះ យល់ព្រមឲ្យមានការជំនុំរួម ។

**លោកស្រី ហ្វាត់ម៉ាស់** - អំពីសិក្ខាបទរឿងស្ត្រីក្នុងអ៊ីស្លាម តើមានអត្ថបទអក្សរសាស្ត្រច្រើនទេ ដែលប្រាប់ស្ត្រីអំពីអ្វីដែលមិនគប្បីសម្រាប់ស្ត្រី ? ឧទាហរណ៍ ស្ត្រីមិនគប្បីទៅម៉ាស់ឃ្វិដ្ទេ មិនគប្បីសូត្រគម្ពីរអានក្នុងចំណោមបុរសទេ មិនគប្បីធ្វើសន្និសីទក្នុងចំណោមបុរសទេ ឬប្រកបកិច្ចការណាដែលសម្បូរតែបុរស ។ គេច្រើនតែឃើញមានកំហិតផ្សេងៗ ។ តើមតិរួម នៅក្នុងចំណោមអស់លោកអ្នកប្រាជ្ញនោះ យ៉ាងណាដែរអំពីរឿងទាំងនេះ ?

**សៃយីដ្** - ពុំមានមតិរួមទេ ក្នុងចំណោមអស់លោកអ្នកប្រាជ្ញអំពីរឿងទាំងនេះមកពីមូលហេតុចម្រូងចម្រាសគ្នា ។ ដំបូង ពេលអស់លោកអ្នកប្រាជ្ញនិយាយអំពីព្រំដែនស្ត្រី អស់លោកគិតដល់សហគមន៍ជាពិសេសដែល

ស្ត្រីរស់នៅ ។ ឧទាហរណ៍ មានសហគមន៍ខ្លះគេមិនឃើញមានស្ត្រីច្រើនជាសាធារណៈទេ ដូច្នេះបុរសមិនសូវធ្លាប់រស់នៅជុំជាមួយស្ត្រីទេ ។

នៅក្នុងសហគមន៍ដែលស្ត្រីភាគច្រើននៅក្នុងផ្ទះ ស្ត្រីទាំងនោះកម្រដើរចេញទៅខាងក្រៅណាស់ ទោះបីទៅផ្សារក៏ដោយ មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេដែលអស់លោកអ្នកប្រាជ្ញណែនាំស្ត្រី កុំឲ្យទៅម៉ាស់យ៉ូដូញឹកញយពេក ។ អស់លោកអ្នកប្រាជ្ញដែលបង្កើតគោលការណ៍បែបនេះមានបំណងការពារស្ត្រី ។

ស្រដៀងនេះដែរ នៅក្នុងសហគមន៍ដែលស្ត្រីចូលប្រលូកនិងចូលរួមក្នុងកិច្ចការជាសាធាណៈ (ដូចជាក្នុងការប្រកបអាជីព ឬក្នុងគ្រឹះស្ថានអប់រំ ជាដើម) នោះ មតិបែបនេះមិនអាចដាក់ឲ្យធ្វើបានទេ ហើយមិនសមរម្យទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - នាងខ្ញុំចង់អានឲ្យសៃឃីដូស្តាប់នូវអត្ថបទមួយសរសេរដោយនារីមុស្លីមម្នាក់នៅក្នុងកាសែត "London Times" អំពីស្ត្រីនៅក្នុងអ៊ីស្លាម ។

ថា៖ "សាសនាយើងមិនចាត់ទុកស្ត្រីជាមនុស្សមានសេចក្តីថ្លៃថ្នូរទេ ចាត់ទុកស្ត្រីជាទាសី ។ នាងខ្ញុំសរសេរជំទាស់សាសនាពីព្រោះប្រសិនបើស្ត្រីចង់រស់នៅដូចនមុស្ស ស្ត្រីត្រូវរស់នៅក្រៅច្បាប់សាសនាអ៊ីស្លាម ។"[21]

តើសៃឃីដូយល់ឃើញយ៉ាងណា ?

**សៃឃីដូ** - សម្តីនេះសម្បូរដោយការកាន់លទ្ធិហួសហេតុនិងអាការរំជួល

[21] London Times, 22 June 1994, Taslima Nasreen, a Bangladeshi author.

ចិត្តខ្លាំង ។ ម្ចាស់អត្ថបទមិនបង្ហាញគោលបំណងច្បាស់លាស់ មិនអធិប្បាយក្បោះក្បាយទេ ។ ច្បាប់អ៊ីស្លាមដែលត្រូវបានចារទុកនោះចែងផ្ទុយពីយោបល់របស់ម្ចាស់អត្ថបទ ។ អ៊ីស្លាមមិន ត្រឹមតែលើកស្ទួយកំពស់មនុស្សនិយមនៃស្ត្រីប៉ុណ្ណោះទេ ថែមទាំងធានាឋានៈស្ត្រីដោយប្រទានសិទ្ធិផ្នែកសង្គមឲ្យស្ត្រីទៀតផង ។

អកុសល ប្រទេសមួយចំនួនដែលអះអាងថាខ្លួនជាមុស្លីមនោះមិនប្រកាន់ខ្ជាប់នូវជំនឿអ៊ីស្លាមពិតប្រាកដទេ ។ បុគ្គលខាងលើនេះអាចធាត់ធំនៅក្នុងប្រទេសប្រភេទនេះដែលអះអាងថាជាតំណាងអ៊ីស្លាមនោះ តែការប្រតិបត្តិ និងតម្លៃអ៊ីស្លាមរបស់ប្រទេសនោះត្រូវបានបោះបង់ចោល ។ ប្រហែលជានៅក្នុងប្រទេសលោកស្រីនោះ អ៊ីស្លាមគ្រាន់តែជាពាក្យស្លោកជាងការអនុវត្តិសាសនា ។

ប្រទេសខ្លះថាខ្លួនប្រតិបត្តិអ៊ីស្លាម តែបិទមិនឲ្យស្ត្រីសិក្សាទេ ឃាត់មិនឲ្យស្ត្រីចូលរួមក្នុងកិច្ចការសហគមន៍ទេ ហើយមិនអនុញ្ញាតឲ្យស្ត្រីបញ្ចេញមតិនយោបាយទេ ។ ពួកគេដកហូតសិទ្ធិ កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ស្ត្រី ហើយនៅតែអះអាងថាខ្លួនជាតំណាងអ៊ីស្លាម ។ អកុសល សព្វថ្ងៃនេះយើងមាននូវអ្វីទាំងនេះ តែអ្វីទាំងនេះពុំមែនអ៊ីស្លាមទេ អ្វីទាំងនេះជាវប្បធម៌សង្គម ។

ម្យ៉ាងទៀត មានប្រទេសមុស្លីមខ្លះព្យាយាមផាត់ពណ៌ឲ្យទំនើបនិងស៊ីវិល័យដោយជ្រើសរើសស្ត្រីជានាយករដ្ឋមន្ត្រី ។ ទោះបីពួកគេអាចជ្រើសរើសស្ត្រីជាតំណាងប្រទេសពួកគេ ក្នុងតំណែងជាន់ខ្ពស់បំផុតក៏ដោយ ជាទូទៅ ពួកគេនៅតែគ្មានសេចក្តីគោរពស្ត្រីនៅក្នុងសហគមន៍ពួកគេ ។ បើគេពិនិត្យមើលសហគមន៍ទាំងនោះ គេនឹងឃើញថាស្ត្រីត្រូវគេធ្វើបាបឬរងអំពើអយុត្តិធម៌ ។

អ្នកខ្លះរៀបចំអាពាហ៍ពិពាហ៍កូនស្រីខ្លួន ដោយពុំបានទទួលការយល់ព្រមពីកូនស្រីខ្លួននោះទេ ។ ស្វាមីខ្លះចាត់ទុកភរិយាខ្លួនជាខ្ញុំបម្រើ ។ ទង្វើបែបនេះ (និងច្រើនទៀត) ជាទម្លាប់របស់សហាគមន៍ មិនមែនជាទម្លាប់ឬខ្លឹមសាររបស់អ៊ីស្លាមទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - អាកប្បកិរិយានិងទង្វើដែលប្រព្រឹត្តក្នុងនាមអ៊ីស្លាមការពិត ជាអាកប្បកិរិយានិងជាទង្វើដែលផ្ទុយពីខ្លឹមសារនៃពាក្យពេជន៍នៅក្នុងគួរអាន ។ បើគេពិនិត្យសហាគមន៍អារ៉ាប់មួយចំនួនដែលមានអ្នកកាន់សាសនាគ្រិស្តនិងមុស្លីមរស់នៅជាមួយគ្នានោះ គេមុខជានឹងឃើញថាស្ត្រីមុស្លីមដែលរស់នៅជាមួយប្រជាជាតិខ្លួននោះ មិនត្រូវគេគោរពដូចគ្នានឹងស្ត្រីគ្រិស្តដែលរស់នៅក្នុងចំណោមប្រជាជនខ្លួននោះទេ ។

ជាទូទៅ ស្ត្រីគ្រិស្តបានទទួលនូវសេចក្ដីគាប់ចិត្តនិងសេចក្ដីគោរពនៅក្នុងសហាគមន៍ខ្លួន ។ តើសៃយីដ្ឋយល់ឃើញយ៉ាងណាដែរ ថាហេតុអ្វីនៅក្នុងសហាគមន៍មុស្លីមខ្លះ គេមើលមកស្ត្រីមុស្លីមជាពលរដ្ឋថ្នាក់ទីពីរ ?

**សៃយីដ្** - សេចក្ដីគោរពចំពោះស្ត្រីគ្រិស្តដែលលោកស្រីថានោះមិនមែនមកពីសាសនាទេ តែមកពីទំនៀមទម្លាប់ (ឬប្រពៃណី) ។ ស្រដៀងនេះដែរកង្វះសេចក្ដីគោរពធៀប ដែលស្ត្រីមុស្លីមទទួលរងនៅក្នុងសហាគមន៍ខ្លួននោះក៏មិនចាប់កំណើតមកពីសាសនាទេដែរ តែចាប់កំណើតមកពីប្រពៃណី ។

មានអាយ៉ាស់គួរអានច្រើន ដែលចែងថាបុរសនិងស្ត្រីត្រូវរស់នៅជាមួយគ្នាដោយស្រុះគ្នា ។ មានអាយ៉ាស់គួរអានច្រើនណាស់ដែលចែងថាបុរសនិងស្ត្រីស្មើភាគគ្នា ។ សូម្បីតែព្រះសាស្តាﷺក៏បានរៀបរាប់ដែរថាបុរស

និងស្ត្រីជាភាគពាក់កណ្តាលគ្នា ។

តាមប្រពៃណី នៅក្នុងសហាគមន៍ខ្លះនៃប៉ែកខាងកើត គេមើលមកស្ត្រីជាបុគ្គលថ្នាក់ទីពីរ តែអ៊ីស្លាមប្រឆាំងទស្សនៈឬទង្វើអគប្បីនេះ ។ ក៏ប៉ុន្តែមនុស្សខ្លះអាចអានវគ្គខ្លះនៃគម្ពីរអានហើយយល់ខុស ដោយផ្អែកទៅលើច្បាប់ទទួលមរតកនិងច្បាប់ធ្វើជាសាក្សីនោះ ថាស្ត្រីជាបុគ្គលដែលមានលំដាប់ថ្នាក់ទាបជាងបុរស ។

ដើម្បីយល់ច្បាប់ គេត្រូវវិភាគដើមកំណើតវា រកហេតុផលជ្រៅនិងការសមហេតុផលដែលនៅពីខាងក្រោយច្បាប់នោះ ។ ភាគច្រើន ច្បាប់ផ្អែកលើមូលដ្ឋានសេដ្ឋកិច្ចនិងសង្គម មិនផ្អែកលើអ្វីផ្សេងពីនេះទេ ។ ច្បាប់មិនផ្អែកលើការសន្មតខុសទេដែលថាស្ត្រីជាបុគ្គលលំដាប់ថ្នាក់ទីពីរ ឬថ្នាក់ទាបនោះ ។ ច្បាប់អ៊ីស្លាមត្រូវធ្វើឡើង មិនត្រឹមតែដើម្បីផានាសិទ្ធិបុគ្គលនីមួយៗតែប៉ុណ្ណោះទេ តែដើម្បីធានាសិទ្ធិសហាគមន៍ទាំងមូលនោះដែរ ។

ត្រូវចាំជាប់ក្នុងចិត្តផងថា មិនត្រឹមតែសហាគមន៍អារ៉ាប់ឬមុស្លីមទេដែលធ្វើបាបស្ត្រីនោះ ។ អ្នកកាន់សាសនាគ្រិស្ត អ្នកកាន់សាសនាយ៉ាហ្វូឌី មនុស្សសាសន៍ប៉ែរ្ស៍ (Persian) មនុស្សសាសន៍ឥណ្ឌា ។ល ។ និងសហាគមន៍មិនកាន់សាសនាក៏ប្រមាថស្ត្រីដែរ ហើយនៅតាមទីកន្លែងខ្លះនៅតែប្រព្រឹត្តបែបនេះ ។ សព្វថ្ងៃក៏ដោយ នាប៉ែកខាងលិច គេធ្វើបាបស្ត្រីមិនគោរពស្ត្រីក្នុងច្រើនវិស័យ ។

**លោកស្រី ហ្វាត់ម៉ាស់** - សៃយីដ្ឋមានប្រសាសន៍មុននេះថាយើងនៅតែប្រឈមនឹងការនិយមបក្សពួក ហើយមនុស្សទាំងនោះនៅតែមិនដឹងសិក្ខាបទនិងការអនុវត្តិ (ឬការប្រតិបត្តិ) អ៊ីស្លាមទេ ។ ជាញឹកញយ គ្រឹះនៃគ្រួសារមុស្លីមនៅលើការឲ្យចំណូលចិត្ត ឲ្យឱកាសនិងឲ្យសេចក្តី

ស្រឡាញ់ទៅកូនប្រុសជាងកូនស្រី ។ ហេតុអ្វីបានជាដូច្នេះ ?

**សែយីដ្** - កាលពីមុន មនុស្សទេរទៅរកសហគមន៍ដែលមានអំណាចជាងគេដែលគិតឃើញថាបុរសប្រសើរជាងស្ត្រី ។ ទស្សនៈឧត្តមភាពនិយមនេះជ្រៀតចូលទៅដល់ភេទមនុស្សក្នុងគ្រួសារដែរ ។ ការចូលចិត្តកូនប្រុសជារឿងគ្រួសារដែលមិនដឹងការអនុវត្តិពិតរបស់អ៊ីស្លាម ។ រឿងនេះមិនកើតមាននៅក្នុងគ្រួសារមុស្លីមដែលដឹងច្បាស់នោះទេ ដែលតម្កល់ការចេះដឹងលើគួរ្អាននិងស៊្វូណាស់ព្រះសាស្តាﷺ ។

ទោះជាយ៉ាងណាក៏ដោយ យើងមិនអាចបន្ទោសអ៊ីស្លាមបានទេព្រោះតែឪពុកម្តាយធ្វើបាបកូនស្រីនោះ ។ អក្សរសាស្ត្រអ៊ីស្លាមគាំទ្រការស្រឡាញ់កូនស្រីជាងកូនប្រុស ។ អល់ឡោះហ្វ៉ូបង្គាត់មាតាបិតាឲ្យចេះយកចិត្តទុកដាក់នឹងកូនស្រីដោយបង្ហាញគូយ៉ាង ។

ឧទាហរណ៍ ពេលឪពុកម្តាយចេញដំណើរ អ្នកដែលត្រូវលាក្រោយគេគឺកូនស្រី ពេលមកដល់ផ្ទះវិញ ត្រូវទៅរកកូនស្រីមុនគេបង្អស់ ។ ព្រះសាស្តាﷺបានធ្វើបែបនេះឯងជាមួយហ្វាទីម៉ាស់ (عليها السلام) ព្រះរាជបុត្រីព្រះអង្គﷺ ។ រាល់ពេលដែលព្រះនាង (عليها السلام) ចូលមកក្នុងបន្ទប់ ព្រះសាស្តាﷺងើបឡើងថើបព្រះនាង (عليها السلام) ហើយឲ្យព្រះនាង (عليها السلام) អង្គុយកន្លែងព្រះអង្គﷺ ។

ព្រះអង្គﷺឲ្យព្រះនាង (عليها السلام) សោយជាមួយព្រះអង្គﷺ ។ ពេលព្រះសាស្តាﷺត្រឡប់មកដំណាក់វិញ ព្រះអង្គﷺឈប់នៅឯដំណាក់ព្រះរាជបុត្រីព្រះអង្គﷺមុននឹងទៅរកមហេសីព្រះអង្គﷺ ។

មានអាយ៉ាស់ច្រើននៅក្នុងគួរ្អាន និងស៊្វូណាស់ព្រះសាស្តាﷺរៀបរាប់អំពីរបៀបដែលត្រូវប្រព្រឹត្តចំពោះកូនស្រី ។ ខ្ញុំបាទនឹងលើកឡើងនូវ

ហ្វាឌីស្ហព្រះសាស្តាﷺខ្លះដែលស្តីអំពីការប្រព្រឹត្តចំពោះកូនស្រី ។

"កូនៗល្អបំផុតរបស់អស់លោកគឺកូនស្រីរបស់អស់លោក ។"[22]

"សញ្ញាសម្គាល់របស់ស្ត្រីមានសំណាង គឺកូនដំបូងបង្អស់របស់ស្ត្រីនោះជាកូនស្រី ។"[23]

"ដំបូងបង្អស់ត្រូវឲ្យទៅកូនស្រីមុនឲ្យទៅកូនប្រុស ។ អ្នកណាព្យាយាមធ្វើឲ្យកូនស្រីសប្បាយចិត្ត អ្នកនោះនឹងបានរង្វាន់ស្មើនឹងអ្នកដោះលែងទាសៈម្នាក់ដែលជាកូនចៅរបស់ព្រះសាស្តាអ៊ីសម៉ាអ៊ីលឲ្យមានសេរីភាព ។"[24]

"អ្នកណាចិញ្ចឹមកូនស្រីដែលមានសទ្ធា អប់រំកូនស្រីទាំងនោះ ធ្វើឲ្យកូនស្រីទាំងនោះចេះដឹងវិន័យ ហើយបានរៀបការឲ្យកូនស្រីទាំងនោះ អ្នកនោះនឹងបានទទួលឋានសួគ៌ជារង្វាន់ ។"[25]

**លោកស្រី ហ្វាត់ម៉ាស់** - ពេលរឿង ខ្ទាន់ស្ត្រី (ឬ ឃ្វីតាន់ خِتَان) ត្រូវលើកមកនិយាយ ពាក្យ "អ៊ីស្លាម" ជាប់ពាក់ព័ន្ធនឹងរឿងនេះជាញឹកញយ ។ តើអ៊ីស្លាមពាក់ព័ន្ធនឹងខ្ទាន់ស្ត្រីទេ ?

**សៃយីដ្** - មិនមានទំនាក់ទំនងគ្នាទេរវាងអ៊ីស្លាមនិងខ្ទាន់ស្ត្រីនោះ ។ សហគមន៍អាហ្វ្រិកខ្លះអាចប្រើខ្ទាន់ស្ត្រីជាធម្មតា ។ ទោះបីបណ្តាអ្នក

[22] សូមមើលសៀវភៅ مُستَدرَكُ الوَسائل ជុំទី ២ ទំព័រ ៦១៥ ។
[23] សូមមើលសៀវភៅ مُستَدرَكُ الوَسائل ជុំទី ២ ទំព័រ ៦១៤ ។
[24] សូមមើលសៀវភៅ مكارم الاخلاق រាយការណ៍ពី អ៊ីបនូ អុាប់បាស់ ។
[25] សូមមើលសៀវភៅ وسائل الشيعة ជុំទី ១៥ ទំព័រ ១០០ ។

ដែលប្រព្រឹត្តខ្ញុំតាន់ស្ត្រីនោះជាមុស្លីមក៏ដោយ ក៏វាមិនមែនជាហេតុផលត្រឹមត្រូវទេថាខ្ញុំតាន់ស្ត្រីនេះជាពិធីឬជាទង្វើមួយរបស់អ៊ីស្លាមនោះ ។

**លោកស្រី ហ្វាត់ម៉ាស់** - នៅក្នុងប្រទេសមុស្លីមខ្លះ ក្នុងករណីខ្លះ ពេលស្ត្រីមុស្លីមត្រូវគេសង្ស័យ ឬឮពាក្យចចាមអារ៉ាមថាបានប្រព្រឹត្តអំពើខុសច្បាប់ បុរសដែលជាសមាជិកគ្រួសារនឹងទទួលភារកិច្ចប្រហារជីវិតស្ត្រីនោះផ្ទាល់ដៃ ។ គេហៅទង្វើគួរឲ្យបារម្ភនេះថា "សម្លាប់ស្តារកិត្តិយស" ។ តាមធម្មតាឃាតករត្រូវកាត់ទោសជាប់ពន្ធនាគារតែពីរបីឆ្នាំទេ រួចហើយត្រូវដោះលែង ។ តើការផ្តន្ទាទោសបែបនេះជាការឆ្លុះបញ្ចាំងនៃច្បាប់អ៊ីស្លាមទេ ?

**សៃយីដ្** - បទឧក្រិដ្ឋឬបាបដែលបានប្រព្រឹត្តនៅក្នុងសហគមន៍អ៊ីស្លាមត្រូវតែដោះស្រាយតាមតុលាការអ៊ីស្លាមនិងតុលាការស៊ីវិល ។ ការផ្តន្ទាទោសដោយខ្លួនឯងជាអំពើដែលត្រូវហាម ។ អ៊ីស្លាមលើកតម្កើងជីវិតនិងជីវិតមនុស្សទាំងអស់ ។ យកជីវិតអ្នកដទៃជាបាបធំបំផុត ។ បុគ្គលម្នាក់គត់ដែលគេអនុញ្ញាតឲ្យអនុវត្តិច្បាប់នោះ គឺតុលាការអ៊ីស្លាមដែលមានលក្ខណៈគ្រប់គ្រាន់ មិនមែនសមាជិកគ្រួសារទេ ។

អាស្រ័យមូលហេតុនេះ អំពើ "សម្លាប់ស្តារកិត្តិយស" មិនមានឫសគល់នៅក្នុងហ្វាឌីស្ហ៍អ៊ីស្លាមទេ ។ ការពិត គួរអានចែងអំពីការផ្តន្ទាទោសបុគ្គលដែលចោទឬពោលពាក្យចចាមអារ៉ាមអំពីរឿងផិតក្បត់ ឬរឿងប្រព្រឹត្តខុសច្បាប់រវាងស្ត្រីនិងបុរសដោយគ្មានភ័ស្តុតាងពិតប្រាកដ ។

وَٱلَّذِينَ يَرۡمُونَ ٱلۡمُحۡصَنَٰتِ ثُمَّ لَمۡ يَأۡتُواْ بِأَرۡبَعَةِ شُهَدَآءَ فَٱجۡلِدُوهُمۡ ثَمَٰنِينَ جَلۡدَةً
وَلَا تَقۡبَلُواْ لَهُمۡ شَهَٰدَةً أَبَدٗاۚ وَأُوْلَٰٓئِكَ هُمُ ٱلۡفَٰسِقُونَ ٤

*ជនទាំងឡាយណាចោទបណ្តាស្រីបរិសុទ្ធដោយពុំមានសាក្សីបួននាក់ ចូរ*

*ពួកអ្នកវាយជនទាំងនោះម្នាក់ៗប៉ែតសិបរំពាត់ ហើយចូរពួកអ្នកកុំទទួលការធ្វើជាសាក្សីពីពួកគេចាប់ពីពេលនោះតទៅ ។ ជនទាំងនេះជាជនបំពារបំពាន (២៤:៤) ។*

## វគ្គ ២ - សិទ្ធិរបស់គូស្វាមីភរិយា, តរុណវ័យ, ម៉ាស្ទ័រ

**-សិទ្ធិរបស់គូស្វាមីភរិយា**

وَلَهُنَّ مِثْلُ ٱلَّذِى عَلَيْهِنَّ بِٱلْمَعْرُوفِ ۚ وَلِلرِّجَالِ عَلَيْهِنَّ دَرَجَةٌ ۗ

*ឯបណ្ដាពួកនាងមានសិទ្ធិ ស្មើនឹងអ្វីដែលជាកាតព្វកិច្ចរបស់ពួកនាង [ចំពោះស្វាមី]ដោយសមធម៌ ។ ឯបណ្ដាបុរស (ជាស្វាមី) នោះមាន [កាតព្វកិច្ចចំពោះភរិយា]មួយកម្រិតលើសពួកនាង ។ (២:២២៨) ។*

**លោកស្រី ហ្វាត់ម៉ាស្ទ** - មើលទៅ អាយ៉ាស្ទនេះជាអាយ៉ាស្ទដែលធ្វើឲ្យចម្រូងចម្រាសបំផុតនិងត្រូវបង្ខូចពីអត្ថន័យដើម ពាក់ព័ន្ធនឹងរឿងទំនាក់ទំនងស្វាមីភរិយា ។ តើអាយ៉ាស្ទនេះទាក់ទិនតែនឹងសិទ្ធិនៅក្នុងរង្វង់អាពាហ៍ពិពាហ៍ទេ ឬក៏ទាក់ទិននឹងសហគមន៍ទាំងមូលដែរ ? តើសៃយីដ្ អាចពិពណ៌នាអាយ៉ាស្ទទាំងមូល ហើយលើកឡើងនូវឧទាហរណ៍ខ្លះបានទេ ?

**សៃយីដ្** - អាយ៉ាស្ទដែលលោកស្រីនិយាយដល់នោះ អាចបកស្រាយមិនត្រឹមត្រូវទេ ។ ជួនកាលអាចពិបាកបកប្រែអត្ថន័យពិតប្រាកដរបស់ពាក្យអារ៉ាប់ជាភាសាអង់គ្លេស (ឬជាភាសាដទៃ) ។ មានពាក្យអារ៉ាប់ច្រើនដែលមិនអាចប្រែពីអត្ថន័យដើមឬអត្ថន័យជាភាសាផ្សេងៗបានទេ ។

អ្នកបកប្រែចម្លងត្រូវស្វែងរកពាក្យផ្សេងដើម្បីបកស្រាយន័យ ដែលជិតអត្ថន័យដើមបំផុតរបស់ពាក្យអារ៉ាប់ជាពិសេសនីមួយ ។ ក្នុងករណីខ្លះ អត្ថន័យច្បាស់របស់ពាក្យអាចបាត់បង់ អាចប្លែងឬបកប្រែខុសបាន ។ ខ្ញុំនឹងសាកល្បងប្រែអាយ៉ាស្ទនេះ ។

*ឯសិទ្ធិភរិយា - ដែលទាក់ទងនឹងស្វាមីខ្លួន - ស្មើនឹងកាតព្វកិច្ចរបស់ខ្លួន [ដែលសមរម្យ/ដែលច្បាប់អនុញ្ញាត] - ចំពោះស្វាមីខ្លួននោះ - តែបុរសក្នុងកាតព្វកិច្ចរបស់ខ្លួន - ចំពោះភរិយាខ្លួននោះ - លើសមួយកម្រិត ។*

ពាក់ព័ន្ធនឹងសំណួរដំបូងរបស់លោកស្រី លោកអ្នកប្រាជ្ញមុស្លីមអធិប្បាយថាអាយ៉ាស់នេះទាក់ទិនតែនឹងរឿងគ្រួសារទេ មិនទាក់ទិននឹងទំនាក់ទំនងបុរសនិងស្ត្រីក្នុងសហគមន៍ឬក្រៅរង្វង់ជីវិតគ្រួសារនោះទេ ។

ពាក់ព័ន្ធនឹងរឿងសហគមន៍ គួរអានថែងថាមុស្លីមប្រុសនិងមុស្លីមស្រីរួមចំណែកគ្នាក្នុងការទទួលខុសត្រូវផ្នែកសីលធម៌និងផ្នែកសង្គម ស្មើគ្នានិងរួមគ្នា ។ ម្យ៉ាងទៀត បុរសនិងស្ត្រីស្មើគ្នានៅពីមុខច្បាប់និងនៅពីមុខកាតព្វកិច្ច[1]សាសនានិងទណ្ឌកម្មទាំងឡាយ[2] ។

ព្រមនឹងអាយ៉ាស់ខាងលើនេះ មានអាយ៉ាស់មួយទៀតនៅក្នុងគួរអានដែលទាក់ទងគ្នា ដូច្នេះ សំខាន់គឺត្រូវអធិប្បាយអាយ៉ាស់ទាំងពីរនេះព្រមគ្នា ។

ٱلرِّجَالُ قَوَّٰمُونَ عَلَى ٱلنِّسَآءِ بِمَا فَضَّلَ ٱللَّهُ بَعْضَهُمْ عَلَىٰ بَعْضٍ وَبِمَآ أَنفَقُوا۟ مِنْ أَمْوَٰلِهِمْ ۚ فَٱلصَّٰلِحَٰتُ قَٰنِتَٰتٌ

*បណ្ដាបុរសជាអ្នកថែរក្សា (គឺទទួលខុសត្រូវ គ្រប់គ្រង ចិញ្ចឹម) បណ្ដាស្ត្រី ព្រោះអល់ឡោះប្រ៊ប្រោសប្រណីអ្នកខ្លះជាងអ្នកឯទៀត និងពីព្រោះពួកគេត្រូវចំណាយទ្រព្យសម្បត្តិរបស់ខ្លួន ។ ស្ត្រីត្រឹមត្រូវគឺស្ត្រីដែលគោរពបង្គាប់[អល់ឡោះប្រ៊] (៤:៣៤) ។*

---

[1] គួរអាន ៩:៧១ ។

[2] គួរអាន ២៤:២ ។

គួរអានថែងថា៖ وَلِلرِّجَالِ عَلَيْهِنَّ دَرَجَةٌ *តែបុរស ក្នុងកាតព្វកិច្ចរបស់ខ្លួន - ចំពោះភរិយាខ្លួននោះ - លើសមួយកម្រិត (២:២២៨)* ។

*"លើសមួយកម្រិត"* ដែលគួរអានថានោះមិនមែនលំដាប់ឋានៈខ្ពស់ជាងឬសេចក្ដីថ្លៃថ្នូរជាងនោះទេ ។ *"មួយកម្រិត"* គួរអានចង់និយាយអំពីករណីយកិច្ចចាំបាច់ដែលគេដាក់មកលើបុរសក្នុងការថែរក្សាស្ត្រី មិនមែនភាពថ្កើងថ្កានមួយកម្រិតទេ ។ អល់ឡោះហ្ ដាក់បញ្ញាឲ្យបុរសតែឯងទទួលខុសត្រូវក្នុងការថែទាំនិងផ្គត់ផ្គង់ស្ត្រី ។ រឿងនេះគាំទ្រដោយអាយ៉ាស់ដែលថែងថា៖

ٱلرِّجَالُ قَوَّٰمُونَ عَلَى ٱلنِّسَآءِ
*បណ្ដាបុរសជាអ្នកថែរក្សាបណ្ដាស្ត្រី (៤:៣៤)* ។

*"លើសមួយកម្រិត"* មិនមែនជាការមានអំណាចលើឬការស្រឡាញ់ចូលចិត្តជាងនោះជាដាច់ខាត ។

គួរអានរំលឹកយើងថាបុរសនិងស្ត្រីត្រូវបង្កើតមកពីវត្ថុធាតុដើមតែមួយ ។

خَلَقَكُم مِّن نَّفْسٍ وَٰحِدَةٍ
*[អល់ឡោះហ្]បានបង្កើតពួកអ្នកមកពីជីវិតតែមួយ (៤:១)* ។

គួរអានថែងយ៉ាងជាប់ឥតខានអំពីសមភាព អំពីភាពស្មើគ្នានិងអំពីតុល្យភាពរវាងភេទទាំងពីរ ។ គួរអានរៀបចំភេទទាំងអស់ មិនបែងចែកលំដាប់ថ្នាក់ខ្ពស់ឬទាបរវាងបុរសនិងស្ត្រីទេ ។ ផ្ទុយទៅវិញ សទ្ធាសិប់ចិត្ត

របស់បុគ្គលទេដែលបែងចែកលំដាប់ថ្នាក់ឬកម្រិតរបស់បុគ្គលប្រុស ឬបុគ្គលស្រីនោះ ហើយក៏មិនមែនភេទឬសាលោហិតឈាមជ័រទេដែរ ។

أَكْرَمَكُمْ عِندَ ٱللَّهِ أَتْقَىٰكُمْ

*ការពិត សម្រាប់អល់ឡោះប្ញ៉ា អ្នកថ្លៃថ្នូរបំផុតក្នុងចំណោមពួកអ្នកគឺអ្នកដែលជឿសិប់ចិត្តបំផុតក្នុងចំណោមពួកអ្នក (៤៩:១៣) ។*

អ៊ីស្លាមមិនគាំទ្របក្ខានុគ្រោះ (ការនិយមបក្សពួក) ឬលំអៀងឲ្យផលប្រយោជន៍ទៅខាងបុរសទេ ។ អាទិភាពត្រូវឲ្យទៅសុខុមាលភាពសហគមន៍ទូទៅ មិនមែនឲ្យទៅភេទណាមួយទេ ។ ផលប្រយោជន៍ថ្លឹងស្មើគ្នារវាងទាំងពីរភេទនោះទេ ដែលផ្តល់ផលប្រយោជន៍ឲ្យទាំងអស់គ្នាក្នុងសហគមន៍នោះ ។

ចំនួនសរុបនៃសហគមន៍លេបប៉ែកនីមួយនៃសហគមន៍ជានិច្ច ។ សិទ្ធិនិងសមត្ថភាពទទួលខុសត្រូវរបស់ស្ត្រីមានសមាមាត្រស្មើនឹងបុរស តែមិនចាំបាច់ដូចគ្នានោះទេ ។ ស្មើគ្នានិងដូចគ្នាជារឿងពីរខុសគ្នា ។

لَقَدْ أَرْسَلْنَا رُسُلَنَا بِٱلْبَيِّنَٰتِ وَأَنزَلْنَا مَعَهُمُ ٱلْكِتَٰبَ وَٱلْمِيزَانَ لِيَقُومَ ٱلنَّاسُ بِٱلْقِسْطِ

*ពិតណាស់ យើងបានចាត់បញ្ជូនព្រះសាស្តាទាំងឡាយរបស់យើងមកជាមួយភស្តុតាងដ៏ប្រចក្ស ហើយបានប្រទានព្រះគម្ពីរចុះមកជាមួយពួកគេនិងជញ្ជីង ដើម្បីនឹងឲ្យមនុស្សប្រព្រឹត្តខ្លួនតាមគន្លងធម៌ (៥៧:២៥) ។*

ស្ត្រីនិងបុរសស្មើគ្នាដោយសមប្បមាណ (គឺស្មើគ្នាត្រឹម មិនខ្វះ មិនលើស) ក្នុងរឿងទំនាក់ទំនងជាមួយអល់ឡោះប្ញ៉ា ។ ម្យ៉ាងទៀត ភាពស្មើគ្នា

ដោយសមប្បមាណនោះខុសគ្នា ត្រង់រឿងមុខនាទីនិងសមត្ថភាពទទួលខុសត្រូវរបស់បុរសនិងស្ត្រី មិនត្រឹមតែចំពោះខ្លួនឯងនិងចំពោះអ្នកដទៃទេ តែចំពោះសហគមន៍ទាំងអស់ដែរ ។ មិនដែលមានការថៃងមិនចំៗឡើយ ថាភេទនីមួយថ្កើងថ្កានលើសភេទមួយទៀត ។ ក្នុងសារធាតុដើម ភេទទាំងពីរត្រូវតែស្មើភាពគ្នា ភេទនីមួយៗត្រូវទទួលស្គាល់សារៈសំខាន់នៃការជួយឧបត្ថម្ភឥតលំអៀងរបស់ខ្លួនទាំងសងខាង ។

ស្ត្រីនិងបុរសក្នុងអ៊ីស្លាមជាដៃគូពឹងពាក់គ្នាទៅវិញទៅមក ។ ហាឌីស្សព្រះសាស្តាﷺមួយចែងថាៈ "បុរសនិងស្ត្រីជាបងប្អូនគ្នា ។"[3]

គួរអានចែងថាស្វាមីមានភារកិច្ចចិញ្ចឹមភរិយាទាំងស្រុង និងត្រូវការពារផលប្រយោជន៍គ្រួសារ ។ ក្នុងអ៊ីស្លាម ភរិយាមិនចាំបាច់ត្រូវបង់ប្រាក់ក្នុងការចាយវាយគ្រឿងទ្រទ្រង់ជីវិតទេ នេះជាភារកិច្ចរបស់ស្វាមីក្នុងការឧបត្ថម្ភភរិយាតាមសមត្ថភាពដែលអាចធ្វើបាន ។

ប្រសិនបើស្វាមីមានទ្រព្យធន ស្វាមីនោះត្រូវឧបត្ថម្ភភរិយានូវជីវិតរស់នៅដែលសម្បូរ ឬ បើស្វាមីក្រទ្រព្យ ភរិយាត្រូវបម្រុងជាមុននូវជីវិតរស់នៅដែលអន់ជាងមធ្យម ។[4]

ពិតប្រាកដណាស់ អាយ៉ាស្ទុំយោងទាំងពីរ (គឺ ២:២២៨ និង ៤:៣៤) ការពារកិត្តិយសនិងបូរណភាពស្ត្រី ។ ពេលស្ត្រីមុស្លីមរៀបការ ស្ត្រីនោះមាននូវឯកសិទ្ធិមិនប្រកបកិច្ចការនៅខាងក្រៅផ្ទះឡើយ ។ ស្ត្រីមិនបាច់បារម្ភអំពីការចិញ្ចឹមកូន ថែទាំផ្ទះសម្បែងនិងរកប្រាក់ចំណូលបន្ថែមដើម្បី

---

[3] សូមមើលសៀវភៅ موسوعة أطراف الحديث النبوي ជុំទី ៣ ទំព័រ ៥៥ និង ២៦៦ ។

[4] សូមមើលគួរអាន ៦៥:៧ ។

ផ្គត់ផ្គង់គ្រួសារទេ ។

អ៊ីស្លាមទទួលស្គាល់ការទទួលខុសត្រូវដ៏ថ្លៃថ្នូរ និងកិច្ចការដែលស្ត្រីត្រូវស៊ូទ្រាំក្នុងការចិញ្ចឹមគ្រួសារ ។ ដោយហេតុនេះ អ៊ីស្លាមដោះលែងស្ត្រីឲ្យរួចពីធារកិច្ចផ្គត់ផ្គង់គ្រួសារដោយថវិការបន្ថែម ។ ការពិត ស្ត្រីមិនចាំបាច់ត្រូវគិតគូរការផ្ទៃក្នុងទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើសែយីដ្ឋចង់ចោលសម្ដីថានៅក្នុងអ៊ីស្លាមមិនមានទ្រឹស្ដី "មេផ្ទះ" ទេមែនទេ ?

**សែយីដ្ឋ** - មិនមានពាក្យ "មេផ្ទះ" ទេនៅក្នុងអ៊ីស្លាម ។ ស្ត្រីក្នុងអ៊ីស្លាមមិនត្រូវបង្ខិតបង្ខំឲ្យដណ្ដាំស្ល បោសសំអាត បោកគក់ ឬបំពេញករណីយកិច្ចក្នុងផ្ទះឯទៀតទេ ។ បើភរិយាជ្រើសរើសធ្វើការនោះ ការនោះត្រូវចាត់ទុកជាការដែលថ្លៃថ្នូរនិងប្រកបដោយគំនិត ពុំនោះទេ ស្ត្រីមិនចាំបាច់ត្រូវធ្វើការនោះទេ ។

ម្យ៉ាងទៀត ស្ត្រីអាចទារថ្លៃឈ្នួលគ្រប់ការងារបាន សូម្បីតែថ្លៃបំបៅដោះកូនក៏អាចទារបានដែរ ។ ទោះជាយ៉ាងណាក៏ដោយ អ៊ីស្លាមមិនចង់បន្ទាបសារៈសំខាន់ឬសេចក្ដីត្រូវការរបស់ភរិយាទេ ដែលចង់ជួយជ្រោមជ្រែងកិច្ចការផ្ទះនោះ ។ មុខនាទីមេផ្ទះជាមុខនាទីថ្លៃថ្នូរ ឬថ្លៃថ្នូរបំផុតលើសអស់មុខនាទីទាំងអស់របស់ស្ត្រីទៅទៀត ។ ដើម្បីនឹងមិនបំបែរអារម្មណ៍ពីរឿងនេះ អ្វីដែលសំខាន់នោះគឺត្រូវដឹងហាឌីស្សព្រះសាស្ដាﷺសំខាន់ៗខ្លាំងមួយចំនួនដែលស្ដីអំពីករណីយកិច្ចក្នុងផ្ទះ ។

តើស្ត្រីមេផ្ទះបានរង្វាន់ច្រើនប៉ុណ្ណាខ្លះ ? ព្រះនាង អ៊ូម សាឡាម៉ាស់رضي الله عنها (ព្រះរាជមហេសីរបស់ព្រះសាស្ដាﷺ) បានសួរព្រះសាស្ដាﷺ ។ ព្រះ

សាស្តាﷺបានឆ្លើយថា ស្ត្រីមួយណាក៏ដោយដែលចង់ធ្វើឲ្យផ្ទះសម្បែងមានសណ្តាប់ធ្នាប់ យកពីនេះទៅដាក់ឯណោះ នឹងបានទទួលនូវព្រះគុណអល់ឡោះហ្ម័عزوجل អ្នកណាដែលទាក់ទាញនូវព្រះពរអល់ឡោះហ្ម័عزوجل អ្នកនោះនឹងមិនរងព្រះពិរោធអល់ឡោះហ្ម័عزوجلទេ ។[5]

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ស្ត្រីអឺយ អ្នកណាមួយក្នុងចំណោមពួកនាងដែលនឿយហត់ដោយសារកិច្ចការរៀបចំផ្ទះ បើអល់ឡោះហ្ម័عزوجلមានព្រះបំណង ស្ត្រីនោះនឹងបានទទួលរង្វាន់ស្មើនឹងរង្វាន់របស់យុទ្ធជននិងមូយ៉ាហ៊្ហីឌីន[6]អ៊ីស្លាម ។"[7]

ដោយសំអាងលើអាយ៉ាស់ទាំងពីរ អាយ៉ាស់ទាំងពីរនេះមិនត្រឹមតែគោរពកិត្យានុភាពរបស់ស្ត្រីទេ តែថែមទាំងចារទុកឲ្យនូវទំនាក់ទំនងពិសេសមួយដែលបានចិញ្ចឹមនិងថែទាំកូនដោយធានាថាម្តាយនឹងនៅផ្ទះ ហើយរួចផុតពីការផ្ទះលំបាក ។ ដូច្នេះ ស្ត្រីនឹងអាចឧទ្ទិសពេល ស្មារតីនិងសេចក្តីស្រឡាញ់ចំពោះការអប់រំគ្រួសារ ។

អ្នកខ្លះបានយកអាយ៉ាស់ទាំងពីរនេះមកបកស្រាយមិនល្អ ដោយចាត់ថាជាអំណាចមួយប្រភេទរបស់បុរស ឬថាជាសេចក្តីថ្កើងថ្កានមួយប្រភេទលើសស្ត្រី ថែមទាំងថាអាយ៉ាស់ទាំងនេះដាក់បញ្ហាឲ្យស្ត្រីនៅក្រោមក្បាលចិត្តរបស់ស្វាមីដោយឥតលក្ខណ្ឌ ។

ការបកស្រាយទាំងនេះផ្ទុយទាំងស្រុងពីមូលដ្ឋាន និងទ្រឹស្តីអ៊ីស្លាម ។

---

[5] សូមមើលសៀវភៅ أصول الكافي ជុំទី ៥ ទំព័រ ១១៣ ។

[6] មូយ៉ាហ៊្ហីឌីន (مجاهدين) គឺអ្នកតស៊ូដើម្បីមូលហេតុអល់ឡោះហ្ម័عزوجل ។

[7] សូមមើលសៀវភៅ نهج الفصاحة ។

អ៊ីស្លាមមិនអនុញ្ញាតឲ្យមានភាពថ្កើងថ្កានលើសអ្នកដទៃ ប្រភេទណាមួយជាដាច់ខាត ។ អ៊ីស្លាមប្រឆាំងដាច់អហង្ការអំពើសង្កត់សង្កិន របបផ្តាច់ការ អំពើបំពារបំពាន ឬអំពើរំលោភសិទ្ធិគេ ។ គួរអានចែងយ៉ាងច្បាស់ថា៖

وَلَهُنَّ مِثْلُ ٱلَّذِى عَلَيْهِنَّ بِٱلْمَعْرُوفِ ۚ

*ឯបណ្តាពួកនាងមានសិទ្ធិ ស្មើនឹងអ្វីដែលជាកាតព្វកិច្ចរបស់ពួកនាង ដោយសមធម៌ (ពោលគឺ ចូរប្រព្រឹត្តិចំពោះភរិយាដោយសមរម្យ) ។*

وَعَاشِرُوهُنَّ بِٱلْمَعْرُوفِ ۚ

*ចូរពួកអ្នករស់នៅជាមួយពួកនាងដោយវិធីល្អប្រពៃនិងសមធម៌ (៤:១៩) ។*

អាយ៉ាស់ទាំងនេះ ក្នុងចំណោមអាយ៉ាស់ច្រើនទៀតក្នុងគួរអាន និង ហាឌីស្ស្រល្បីៗរាប់រយរបស់ព្រះសាស្តាﷺ ជាមូលដ្ឋានរបស់អាពាហ៍ពិពាហ៍ ។

*ឯសិទ្ធិភរិយា - ដែលទាក់ទងនឹងស្វាមីខ្លួន - ស្មើនឹងកាតព្វកិច្ចរបស់ខ្លួន - ចំពោះស្វាមីខ្លួននោះ (២:២២៨) ។*

អាយ៉ាស់នេះចែងបញ្ជាក់ថាស្វាមីមិនមែនជាដៃគូកាន់អំណាចដែលពុំមានអ្នកណាអាចតវ៉ាបាន ហើយក៏ពុំមែនដៃគូដែលត្រូវស្តាប់បង្គាប់ជាដាច់ខាតទេ ។ អល់ឡោះហ្ ﷻបានរៀបរាប់ នៅក្នុងអាយ៉ាស់នេះ នូវសិទ្ធិរបស់ភរិយាដូចសិទ្ធិរបស់ស្វាមីដែរ ។

ដើម្បីបំភ្លឺ សិទ្ធិរបស់គូស្វាមីមានលក្ខណ្ឌ និងផ្អែកទៅលើការស្តាប់គ្នាទៅវិញទៅមក នៅក្នុងការស្តាប់គ្នាទៅវិញទៅមកនេះ គូស្វាមីភរិយាទាំងពីរ

ត្រូវបំពេញភារកិច្ចឬករណីយកិច្ចរៀងៗខ្លួន ។ ប្រសិនបើម្នាក់ឬគូស្វាមីទាំងពីរមិនប្រតិបត្តិតាមករណីយកិច្ចរបស់ខ្លួនទេ អធិបញ្ញានិងសេចក្ដីសម្រេចនឹងត្រូវធ្វើឡើង (ពោលគឺ នឹងត្រូវព្រមាន) ។

ٱلرِّجَالُ قَوَّٰمُونَ عَلَى ٱلنِّسَآءِ

*បណ្ដាបុរសជាអ្នកថែរក្សាបណ្ដាស្ត្រី (៤:៣៤) ។*

ٱلرِّجَالُ قَوَّٰمُونَ عَلَى ٱلنِّسَآءِ بِمَا فَضَّلَ ٱللَّهُ بَعۡضَهُمۡ عَلَىٰ بَعۡضٖ وَبِمَآ أَنفَقُواْ مِنۡ أَمۡوَٰلِهِمۡۚ فَٱلصَّٰلِحَٰتُ قَٰنِتَٰتٌ

*បណ្ដាបុរសជាអ្នកថែរក្សា (គឺទទួលខុសត្រូវ គ្រប់គ្រង ចិញ្ចឹម) បណ្ដាស្ត្រី ព្រោះអល់ឡោះហ្ទ៍ប្រោសប្រណីអ្នកខ្លះជាងអ្នកឯទៀត និងពីព្រោះពួកគេត្រូវចំណាយទ្រព្យសម្បត្តិរបស់ខ្លួន ។ ស្ត្រីត្រឹមត្រូវគឺស្ត្រីដែលគោរពបង្គាប់[អល់ឡោះហ្ទ៍] (៤:៣៤) ។*

**លោកស្រី ហ្វាត់ម៉ាស់** - នៅពេលក្រោយ នាងខ្ញុំចង់ឲ្យសៃយីដ្ធបរិយាយលក្ខណ្ឌទាំងនោះ តែដើម្បីនិយាយបន្តព្រះបន្ទូលអល់ឡោះហ្ទ៍ ៤:៣៤ គួរអានថ្លែងអំពីពីរប្រការដែលត្រូវការអធិប្បាយបំភ្លឺ ។ មួយគឺពាក្យ "ហ្វាដ្ធ៍ដ្ធ៍ឡា (فَضَّلَ)" ដែលគេប្រែថា "ប្រោសប្រណីអ្នកខ្លះជាងអ្នកឯទៀត ឬ ប្រទានផលប្រយោជន៍ឲ្យអ្នកខ្លះជាងអ្នកឯទៀត" ពីរគឺ "គោរពបង្គាប់ (قَٰنِتَٰتٌ)" ។ តើពាក្យទាំងពីរនេះមានន័យច្បាស់លាស់ថាអ្វី ?"

**សៃយីដ្ធ** - ពាក្យ "ហ្វាដ្ធ៍ដ្ធ៍ឡា" អាចមានន័យថា ឲ្យ ផ្ដល់ឲ្យ ស្រឡាញ់ជាងគេ ប្លែកពីគេក្នុងមុខងារណាមួយឬក្នុងករណីយកិច្ចណាមួយ អាស្រ័យទៅលើសេចក្ដីក្នុងអត្ថបទ ។ ដើម្បីនិយាយយោងទៅរកអាយ៉ាស់នេះជាពិសេស គប្បីប្រើពាក្យ ឲ្យ ផ្ដល់ឲ្យ ប្លែកពីគេ តែកុំប្រើស្រឡាញ់ជាងគេ ។

គេស្រាយពាក្យ "ហ្វាដ់ដ៏ឡា" ថាញែកបុរសដាច់ពីស្ត្រីក្នុងការបំពេញកិច្ចការនិងក្នុងការទទួលភារកិច្ចជ្រោមជ្រែង ចិញ្ចឹមនិងមើលថៃទាំគ្រួសារ ។ មិនមានន័យថាគេសឡាញ់ចូលចិត្តបុរសជាងគេ ឬបុរសថ្កើងថ្កាន ប្រសើរជាងស្ត្រីនោះទេ ។

ការពិត ពេលគេសិក្សាគួរអាននិងហាឌីស្ហព្រះសាស្តាﷺ គេអាចសម្រេចសេចក្តីបានថាជូនកាល ការស្ញើចសរសើរ ការសន្តោសអត់ឱននិងសេចក្តីស្រឡាញ់ចូលចិត្តត្រូវប្រទានឲ្យទៅស្ត្រី ។ មានហាឌីស្ហវិសាមញ្ញរបស់ព្រះសាស្តាﷺដែលថៃងសង្ខេបអំពីឧត្តមភាពរបស់ស្ត្រី ។ គ្រាមួយបុរសម្នាក់បានមកជួបព្រះសាស្តាﷺ សួរព្រះអង្គﷺថា៖

"ព្រះសាស្តាﷺអើយ នៅក្នុងចំនោមមនុស្ស អ្នកណាទៅដែលស័ក្តិសមជាមិត្តល្អដាច់គេរបស់ទូលបង្គំ ?" ព្រះសាស្តាﷺមានព្រះវចនៈថាម្តាយលោក ។ បុរសនោះបានសួរថាបន្ទាប់ពីម្តាយគឺអ្នកណា ? ព្រះសាស្តាﷺមានព្រះវចនៈថាម្តាយលោក ។ បុរសនោះបានសួរជាគ្រាទីបីថាបន្ទាប់ពីម្តាយគឺអ្នកណា ? ព្រះសាស្តាﷺមានព្រះវចនៈថាម្តាយលោក ។ បុរសនោះសួរទៀតថាបន្ទាប់ពីម្តាយគឺអ្នកណា ? ពេលនោះទើបព្រះសាស្តាﷺមានព្រះវចនៈថាឪពុកលោក ។"[8]

ព្រះសាស្តាﷺមានព្រះវចនៈដែរថា៖ "ឋានសួគ៌នៅក្រោមជើងម្តាយ ។"[9]

---

[8] សូមមើលសៀវភៅ وسائل الشيعة ជុំទី ៣ ទំព័រ ៦ ។

[9] រាយការណ៍ដោយលោក អាល់-នីសាអ៊ី, លោក អ៊ីបនូ ម៉ាយ៉ាស់ និងលោក អាស់ម៉ាដ់ ។

អល់ឡោះហ្ ﷻ មិនអនុញ្ញាតឲ្យមានអយុត្តិធម៌ ឬកង្វះប្រការណាមួយនៅក្នុងចំណោមសត្វលោកព្រះអង្គ ﷻ ទេ ។ អល់ឡោះហ្ ﷻ ប្រោសប្រទានលក្ខណៈសម្បត្តិដែលមានតែមួយគត់និងដាច់ឡែកពីគេឲ្យបុគ្គលនីមួយៗ - ផ្លូវចិត្ត ផ្លូវកាយនិងផ្លូវវិញ្ញាណ ។

وَلَا تَتَمَنَّوْا۟ مَا فَضَّلَ ٱللَّهُ بِهِۦ بَعْضَكُمْ عَلَىٰ بَعْضٍ ۚ

*ចូរពួកអ្នកកុំចង់បាន អ្វីដែលអល់ឡោះប្រ៉ាបានប្រទានឲ្យទៅបណ្ដាអ្នកខ្លះជាងបណ្ដាអ្នកឯទៀតក្នុងចំណោមពួកអ្នកឡើយ (៤:៣២) ។*

អាយ៉ាស់នេះបញ្ជាក់ថាបុរសនិងស្ត្រីគ្រប់រូបត្រូវបង្កើតមក ជាមួយគុណសម្បត្តិដែលគួរឲ្យកត់សម្គាល់ ។

**លោកស្រី ហ្វាត់ម៉ាស់** - ហេតុអ្វីអ៊ីស្លាមជ្រើសយកបុរសជាអ្នកថែទាំស្ត្រី ?

**សៃយីដ** - លោកអ្នកប្រាជ្ញលើកឡើងនូវសេចក្ដីអធិប្បាយយ៉ាងច្រើន ។ ក៏ប៉ុន្តែ លោកអ្នកប្រាជ្ញច្រើនតែផ្ដោតទៅរកលក្ខណៈជីវសាស្ត្រដែលថាបុរសមានរូបកាយខ្លាំងជាងស្ត្រី ដូច្នេះបុរសមានសមត្ថភាពជាងស្ត្រីក្នុងការប្រឹងប្រែងចិញ្ចឹមគ្រួសារ ។ អាស្រ័យហេតុនេះ បុរសទៅជាអ្នកថែរក្សាស្ត្រី ។ ម្យ៉ាងទៀត បុរសមានធម្មជាតិជាអ្នកមានសេចក្ដីអង់អាចនិងជាវរៈជនប្រកបដោយសេចក្ដីក្លាហាន ។

ពាក្យ "ក៏នីតាត (قَٰنِتَٰتٌ)" លោកអ្នកប្រាជ្ញខ្លះបានកត់ត្រាចម្លងថាពាក្យនេះមានន័យថាស្ដាប់បង្គាប់ តែពាក្យនោះមានន័យច្រើនទៀតក្នុងភាសាអារ៉ាប់ ។ ឧទាហរណ៍ អាចមានន័យមែនថាគោរព ឬលើកដៃឡើងក្នុងពេលស្វ៉ឡាត់ ឬចុះចូល ហើយពាក្យនេះអាចមានសេចក្ដីថាស្ដាប់បង្គាប់

តែសូមនិយាយសាឡើងវិញថា ស្តាប់បង្គាប់ស្វាមីមានកំណត់តែនៅក្នុងវង្វង់សាសនាទេ ។

ពោលគឺ ប្រសិនបើស្វាមីស្នើសូមភរិយា ហើយសំណូមពរនេះនៅក្នុងសិក្ខាបទឬទង្វើអ៊ីស្លាម ហើយប្រសិនបើភរិយាមានសមត្ថភាពបំពេញសំណូមពរនេះបាន ភរិយាត្រូវសហាប្រតិបត្តិការនិងធ្វើតាមសំណូមពរនោះ ។ម្យ៉ាងទៀត ប្រសិនបើស្វាមីស្នើសូមភរិយាឲ្យធ្វើអ្វីដែលខុសច្បាប់ ឬមិនត្រឹមត្រូវ ឬភរិយាមិនមានសមត្ថភាពធ្វើបានទេ ភរិយាមិនចាំបាច់ត្រូវស្តាប់បង្គាប់ស្វាមីនោះទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - នៅក្នុងឯកសារអក្សរសាស្ត្រអ៊ីស្លាម មានហ្កាឌីស្ហខ្លះទាក់ទងនឹងស្ត្រីដែលនាងខ្ញុំយល់ឃើញថា ជាហ្កាឌីស្ហដែលបន្ថោកស្ត្រី ហើយគួរឲ្យផ្តន្ទាទោសក្រៃលែង ។ នាងខ្ញុំចង់ដឹងយោបល់របស់សៃយីដ្ អំពីហ្កាឌីស្ហព្រះសាស្តាﷺមួយជាពិសេស ហើយចង់ដឹងអំពីការពិតរបស់ហ្កាឌីស្ហនោះ ។

"មិនត្រឹមត្រូវទេដែលមនុស្សក្រាបសំពះមនុស្សដូចគ្នានោះ ។ បើវាជាការត្រឹមត្រូវដែលមនុស្សក្រាបសំពះមនុស្សដូចគ្នានោះមែន ខ្ញុំនឹងដាក់បញ្ជាឲ្យស្ត្រីក្រាបសំពះស្វាមីខ្លួន ព្រោះស្វាមីមានសិទ្ធិធំណាស់លើភរិយា ។ សូមស្បថចំពោះព្រះដែលក្តាប់ជីវិតខ្ញុំក្នុងព្រះហត្ថព្រះអង្គ ប្រសិនបើពីលើក្បាលរហូតដល់ចុងជើងស្វាមីនោះមានរបួសចេញខ្ទុះ ហើយភរិយាលិតខ្ទុះនោះ ក៏ភរិយានោះមិនបានគោរពសិទ្ធិស្វាមីនោះពេញបរិបូរដែរ ។"[10]

**សៃយីដ្** - សូមចងចាំទុកក្នុងចិត្តពេលយើងបាននិយាយអំពីហ្កាឌីស្ហពិតឬ

---

[10] រាយការណ៍ដោយលោក អាស្ហ៍ម៉ាដ្ហ ។

មិនពិតនៅក្នុងវគ្គ "ស្វែងរកការបំភ្លឺ" ។ ខ្ញុំបាទបានពន្យល់ថាហាឌីស្ហ៍ដែលគេថាជាហាឌីស្ហ៍ព្រះសាស្តាﷺនោះ មិនមែនសុទ្ធតែពិតទាំងអស់ទេ ។ បន្ទាប់មក នៅដើមវគ្គនេះ ខ្ញុំបាទបានថាមិនអាចបកប្រែពាក្យអារ៉ាប់ទាំងអស់ឲ្យត្រឹមត្រូវបានទេ ។ ក៏ប៉ុន្តែ ខ្ញុំបាទស្គាល់ពាក់កណ្តាលដំបូងនៃហាឌីស្ហ៍នេះ តែខ្ញុំបាទមិន អាចពិនិត្យបានទេថាពាក់កណ្តាលទីពីរនោះពិតឬទេ (គឺ "លិតខ្ទុះ...") ។

ហាឌីស្ហ៍នេះនិយាយប្រៀបធៀប ក្នុងន័យថាប្រសិនបើស្ត្រីមានសំណាងបានរៀបអាពាហ៍ពិពាហ៍ជាមួយបុរស ដែលមានជំនឿស៊ប់ចិត្តប្រកបដោយគុណសម្បត្តិប្រសើរក្រៃលែងនោះ ដែលប្រព្រឹត្តិល្អបំផុតចំពោះស្ត្រីនោះ ដែលបំពេញបំណងផ្លូវកាយនិងផ្លូវចិត្តស្ត្រីនោះ ស្ត្រីរូបនោះនឹងប្រព្រឹត្តដូចគ្នាដែរចំពោះបុរសនោះ ។

**លោកស្រី ហ្វាត៉ុម៉ាស្ហ៍** - តើសៃយីដ្ហ៍មានយោបល់យ៉ាងណាអំពីហាឌីស្ហ៍របស់អ៊ីម៉ាំអាលីصلوات الله عليه والسلام ដែលមិនត្រឹមតែជាអភិបាលដឹកនាំត្រឹមត្រូវអ៊ីស្លាម[11] ប៉ុណ្ណោះទេ តែជាអ្នកមានសាលោហិតជិតព្រះសាស្តាﷺបំផុត[12] ?

"ប្រជារាស្ត្រអើយ ស្ត្រីខ្វះជំនឿ ខ្វះចំណែកនិងខ្វះប្រាជ្ញា ។ អំពីកង្វះជំនឿស្ត្រីចៀសវាងស្ហ៍ឡាត់និងកាន់សីលត្រណមពេលមានរដូវខែ ។

អំពីកង្វះប្រាជ្ញានោះ សាក្សីស្រីពីរនាក់ស្មើនឹងសាក្សីប្រុសម្នាក់ ។ អំពីកង្វះចំណែក ក្នុងការចែកមរតក ស្ត្រីបានពាក់កណ្តាលបុរស ។ ដូច្នេះ ចូរ

---

[11] អ៊ីម៉ាំអាលីصلوات الله عليه والسلامជាអ៊ីម៉ាំអវិរុទ្ធដំបូងបង្អស់ក្នុងចំណោមអ៊ីម៉ាំអវិរុទ្ធទាំង ១២ ដែលស្នងព្រះសាស្តាﷺ ។

[12] អ៊ីម៉ាំអាលីصلوات الله عليه والسلام បងប្អូនជីដូនមួយនិងកូនប្រសារបស់ព្រះសាស្តាﷺ (ស្វាមីរបស់ហ្វាទ៉ីម៉ាស្ហ៍عليها السلام) ។

ប្រយ័តអំពើអាក្រក់របស់ស្ត្រី ។ ចូរប្រយ័តខ្លួនអំពីស្ត្រី ទោះបីជាស្ត្រីល្អក៏ដោយ ។ ចូរកុំស្តាប់ស្ត្រី ទោះបីក្នុងអំពើល្អក៏ដោយដើម្បីនឹងកុំឲ្យស្ត្រីទេរទៅរកអំពើអាក្រក់ ។"[13]

**សៃយីដ្** - អ៊ីម៉ាំអាលីصلوات الله عليه والسلامមិនបញ្ចេះឬមិនអះអាងថាអល់ឡោះហ៊្វ៍عز وجلបង្កើតស្ត្រីមកដោយខ្វះលក្ខណៈនោះទេ ។ មិនមានកង្វះក្នុងការបង្កើតស្ត្រីទេ ។

لَقَدْ خَلَقْنَا ٱلْإِنسَـٰنَ فِىٓ أَحْسَنِ تَقْوِيمٍ ۝٤

*ពិតណាស់ យើងបានបង្កើតមនុស្ស (បុរសនិងស្ត្រី) មកដោយមានទម្រង់ល្អបំផុត (៩៥:៤) ។*

ឧទាហរណ៍ដែលអ៊ីម៉ាំអាលីصلوات الله عليه والسلامបានលើកឡើងនេះ ជាការនិយាយប្រៀបធៀប ហើយហ្វាឌីស្ទនេះដាច់បាត់ប៉ែកសំខាន់ដែលស្តីអំពីឧបត្តិហេតុមួយដែលបានបញ្ចូលពាក្យ ។ អ៊ីម៉ាំអាលីصلوات الله عليه والسلامនិយាយអំពីស្ត្រីម្នាក់ដែលបានបណ្តាលឲ្យមានការខូចខាតធំដល់សហគមន៍អ៊ីស្លាម នៅក្នុងចម្បាំងយ៉ាមីល (معركة الجمل) ។ តែចំណុចនេះឃាត់យើងមិនឲ្យចាប់អារម្មណ៍រឿងនេះទេ ។ បើចាប់អារម្មណ៍ អាចបែរទៅមើលប្រភពពត៌មានផ្សេងៗបាន ។[14]

**លោកស្រី ហ្វាត់ម៉ាស់** - *ឯសិទ្ធិករិយា - ដែលទាក់ទងនឹងស្វាមីខ្លួន - ស្មើនឹងកាតព្វកិច្ចរបស់ខ្លួន - ចំពោះស្វាមីខ្លួននោះ (២:២២៨) ។* សៃយីដ្បាននិយាយអំពីអាយ៉ាស់នេះខ្លីៗ គួរឲ្យចាប់អារម្មណ៍ ហើយបានប្រើពាក្យ "លក្ខខណ្ឌ" និងពាក្យ "ការស្តាប់គ្នាទៅវិញទៅមក" ។ តើសៃយីដ្អាច

[13] សូមមើលសៀវភៅ نَهْج الْبَلَاغَة ជុំទី ១ ឃ្លាត្តបាស់ ៨០ ។

[14] សូមមើលសៀវភៅ تَارِيخُ الطَّبَرِيِّ និងសេចក្តីរាយការណ៍របស់លោក អ៊ីបនូអាល់-អាស្ទៀរ ។

អធិប្បាយបំភ្លឺរឿងនេះបានទេ ?

**សៃយីដ្** - ពេលនិយាយអំពីសិទ្ធិបុរសនិងសិទ្ធិស្ត្រី គួរអានថៃងអំពីទំនាក់ទំនងទៅវិញទៅមក អំពីសហប្រតិបត្តិការនិងអំពីសេចក្តីគោរព ។ នេះគឺគោលការណ៍សំខាន់បំផុតនៅក្នុងការទាក់ទងរវាងស្វាមីភរិយា ។
គេប្រែ وَلَهُنَّ مِثْلُ ٱلَّذِى عَلَيْهِنَّ بِٱلْمَعْرُوفِ ថា *ឯសិទ្ធិភរិយា - ដែលទាក់ទងនឹងស្វាមីខ្លួន - ស្មើនឹងកាតព្វកិច្ចរបស់ខ្លួនចំពោះស្វាមីខ្លួននោះ (២:២២៨) ។*

អាយ៉ាស់នេះជាមូលដ្ឋាន គ្រឹះនៃទំនាក់ទំនងស្វាមីភរិយាត្រូវមានជោគជ័យអាស្រ័យអាយ៉ាស់នេះ ។ អល់ឡោះហ្វ៊ំកត់សម្គាល់ថាដោយរបៀបតែមួយ បុសរសមានសិទ្ធិលើស្ត្រី ឯស្ត្រីក៏មានសិទ្ធិលើបុរសដែរ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើស្វាមីមានសិទ្ធិអ្វីខ្លះលើស្ត្រី ?

**សៃយីដ្** - សំខាន់បំផុតត្រូវនិយាយអំពីសិទ្ធិរបស់ស្វាមីលើភរិយា និងអំពីសិទ្ធិរបស់ភរិយាលើស្វាមី ដើម្បីប្រៀបធៀបនិងយល់រឿងសិទ្ធិស្វាមីភរិយាដ៏ស្មុគស្មាញនៅក្នុងអ៊ីស្លាម ។ ចូរចងចាំទុកក្នុងអារម្មណ៍ថាទំនាក់ទំនងស្វាមីភរិយាស្ថិតនៅលើការទាក់ទងគ្នាទៅវិញទៅ នៅលើសហប្រតិបត្តិការនិងនៅលើសេចក្តីគោរព ។ សិទ្ធិក្នុងច្បាប់សាសនាដែលស្វាមីមានលើភរិយានោះ យោលតាមលោកអ្នកប្រាជ្ញមុស្លីមខាងច្បាប់ (فُقَهَاء) មានដូចតទៅៈ

១) ហ្ហាក់ អាល់-ត្ហ៊អាស់ (حق الطاعة) មានន័យថាសិទ្ធិស្តាប់ឱវាទដែលជាកាតព្វកិច្ចរបស់ភរិយា ។ ការស្តាប់ឱវាទ គឺស្វាមីអាចស្នើសូមឲ្យភរិយា

បំពេញករណីយរបស់ខ្លួនផ្លូវសាសនានិងសីលធម៌ ។ ម្យ៉ាងទៀត ភរិយាមិនត្រូវចេញពីផ្ទះដោយគ្មានការអនុញ្ញាតពីស្វាមីទេ ប្រសិនបើវាប៉ះពាល់ដល់សិទ្ធិស្វាមីនោះរឿង "តាំគីន (تمكين)" ។

២) តាំគីន មានន័យថាភរិយាត្រៀមខ្លួនសម្រាប់ស្វាមី បើភរិយានោះមានសុខភាពល្អផ្លូវកាយនិងផ្លូវចិត្ត ។ លោកអ្នកប្រាជ្ញខ្លះហៅប្រការនេះថា ហ្ក៉ាក្គ៎ អ៊ីសទីមតាក់ (حق استمتاع) ពោលគឺ សិទ្ធិត្រេកត្រអាលខ្លួននិងចិត្ត ។

៣) ហ្ក៉ាក្គ៎ អាល់-ម៉ាអ៊ីយ៉ាស្ញ់ មានន័យថាភរិយាចំណាយពេលជាមួយស្វាមីជាគូកនមួយប្រភេទ ។

សិទ្ធិរបស់ស្ត្រីលើស្វាមី គឺ៖

១) ណាហ្វាកោ្គះត៍ (نَفَقَة) មានន័យថាស្វាមីត្រូវចាយវាយលើជីវព្រឹត្តិទាំងអស់របស់ភរិយា ។ នេះគឺពាក្យទូលំទូលាយណាស់ ដែលជាប់ទាក់ទងនឹងបញ្ជីរាយឈ្មោះគ្រឿងត្រូវការសម្រាប់ជីវិតរស់នៅនានាដ៏ច្រើនអនេក ដូចជាជម្រកអាស្រ័យ សំលៀកបំពាក់ គ្រឿងប្រើប្រាស់ក្នុងផ្ទះនិងថវិកា ជាដើម ។

២) ហ្ក៉ាក្គ៎ អាល់-អ៊ៀរវ៉ាស្ញ់ អាល់-ឃ្ជីនស៊ី (الحق العروة الجنسي) មានន័យថាបំពេញសេចក្តីត្រូវផ្លូវកាយ ។ សិទ្ធិនេះមិនត្រឹមតែពាក់ព័ន្ធនឹងការរួមភេទប៉ុណ្ណោះទេ មានទាំងកាយវិការនិងការប្រលែងថ្នាក់ថ្នមដោយសេចក្តីស្នេហារបស់ស្វាមីចំពោះភរិយាផងដែរ ។

៣) មូស្ហ្ញាឃ៊ីអ្ក មានន័យថារួមគ្រែជាមួយភរិយាខ្លួន ។ មិនមានន័យជាចាំបាច់ថារួមភេទជាមួយភរិយានោះទេ តែចូលផ្ទះ នៅក្បែរភរិយា ដេក

នៅក្នុងផ្ទះតែមួយ នៅក្នុងគ្រែតែមួយ (វ៉ាយ៉ិប) យ៉ាងហោចណាស់បួនយប់ម្តង ។ គប្បីឲ្យនៅជាមួយភរិយាខ្លួនរាល់យប់ ។

៥) គួរអានថែងរឿងនេះដោយពាក្យពេជន៍ដ៏ពីរោះថា៖

وَعَاشِرُوهُنَّ بِٱلۡمَعۡرُوفِۚ

*ចូរពួកអ្នករស់នៅជាមួយពួកនាងដោយវិធីល្អប្រពៃនិងសមធម៌ (៤:១៩)* មានន័យថា សហាត្តិភាពរវាងគូស្វាមីភរិយា (គឺរស់នៅជាមួយគ្នាដោយសុវត្ថិភាព) ។

អាយ៉ាស់នេះទាក់ទិនជាប់គ្រប់វិស័យជីវិតរបស់ស្ត្រី ពោលគឺ វិស័យកាយ វិស័យចិត្ត វិស័យអារម្មណ៍ វិស័យថវិកានិងជំនឿ ។

សំខាន់ត្រូវកត់សម្គាល់ថា សិទ្ធិទាំងឡាយដែលបានរៀបរាប់ខាងលើនេះមានលក្ខខណ្ឌ មិនមែនដាច់ខាតទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - គួរឲ្យចាប់ចិត្តមែន ។ ថ្វីបើពិបាកអធិប្បាយជាពិស្តារសិទ្ធិនីមួយៗដែលសៃយីដ្ធបានរៀបរាប់ខាងលើក្តី នាងខ្ញុំយល់ឃើញថា សំខាន់ត្រូវពន្យល់លំអិតសិទ្ធិទាំងនេះ ។ ម្យ៉ាងទៀត សៃយីដ្ធបានប្រាប់ថា សិទ្ធិទាំងនេះនៅលើការស្តាប់គ្នាទៅវិញទៅមក បើល្មើសប្រការនេះគេនឹងចេញបញ្ញត្តិតុលាការនិងការកាត់ក្តី ។ តើសៃយីដ្ធអាចបំភ្លឺបានទេអំពីលក្ខខណ្ឌពាក់ព័ន្ធនឹងការអាចចេញបញ្ញត្តិតុលាការ តើគេអាចដាក់អនុវត្តិបានដូចម្តេចខ្លះ ?

**សៃយីដ្ធ** - អស់លោកអ្នកប្រាជ្ញមុស្លីមប្រើពាក្យអារ៉ាប់ នូស្ហ៊ុស (نُشُوز) និង ស្ហ៊ីក្ក៏ក៏ (شِقَاق) រាល់ពេលដែលមានស្ថានការណ៍លំបាក ឬមានការល្មើស

សិទ្ធិគូស្វាមីភរិយាជានិច្ចជាកាល ។ ហេតុដូច្នេះ គេបែងចែកជាពីរប្រភេទការមិនចុះសម្រុងគ្នាឬការមិនស្តាប់គ្នានេះ ។

១) ណាស្ហ៊ីស្យ ពាក់ព័ន្ធនឹងភាគី (គឺស្វាមី ឬ ភរិយា) ណាដែលមិនអើពើ ឬមិនយកចិត្តទុកដាក់នឹងការទទួលខុសត្រូវរបស់ខ្លួន នៅក្នុងជីវិតរស់នៅរបស់គូស្វាមីភរិយារបស់ខ្លួន ។

២) ស្ហ៊ីក្វក្ញ ពាក់ព័ន្ធនឹងគូស្វាមីភរិយាទាំងពីរដែលមិនចុះសម្រុងគ្នា ឬដែលគេចវេះបំពេញករណីយកិច្ចចាំបាច់របស់ខ្លួន ។

ពេលប្រភេទ (គឺណាស្ហ៊ីស្យ និង ស្ហ៊ីក្វក្ញ) ណាមួយត្រូវល្មើស គេនឹងសម្រេចក្តីក្រោយពីនោះ ។

**លោកស្រី ហ្វាត្មម៉ាស់** - តើនូស្ហ៊ីស្យមានអត្ថន័យយ៉ាងណា ?

**សៃយីដ្** - នូស្ហ៊ីស្យទាក់ទិនទៅលើខ្លួន ចរិកា កាតព្វកិច្ចផ្នែកអារម្មណ៍ឬផ្នែកសីលធម៌របស់ភាគីនីមួយៗ (គឺស្វាមីឬភរិយា)។ គេអាចប្រែនូស្ហ៊ីស្យបានថា មិនស្តាប់ឱវាទ ការបំពាន ការប្រព្រឹត្តមិនគប្បី ការរត់ចោល ការមិនត្រូវគ្នាឬការឈ្លោះគ្នា ប្រព្រឹត្តដោយស្វាមីឬដោយភរិយា ។

គួរអានរៀបរាប់លក្ខណៈខ្លះរបស់របស់នូស្ហ៊ីស្យ ។ ម្យ៉ាងទៀត គេបានចេញបញ្ញត្តិដែរដែលប៉ុនប៉ងដោះស្រាយឬចាត់ការស្ថានការណ៍ ។

وَٱلَّٰتِي تَخَافُونَ نُشُوزَهُنَّ فَعِظُوهُنَّ وَٱهۡجُرُوهُنَّ فِي ٱلۡمَضَاجِعِ وَٱضۡرِبُوهُنَّۖ فَإِنۡ أَطَعۡنَكُمۡ فَلَا تَبۡغُواْ عَلَيۡهِنَّ سَبِيلًاۗ

*រីឯបណ្តាស្ត្រី (គឺភរិយា) ដែលពួកអ្នកក្រែងថាពួកនាងប្រព្រឹត្តមិនត្រឹមត្រូវ ចូរពួកអ្នកអប់រំពួកនាង [បើមិនមានប្រសិទ្ធិភាពទេ] ចូរពួកអ្នកទុកពួកនាងចោលនៅកន្លែងដេក [បើមិនមានប្រសិទ្ធិភាពទេ] ចូរពួកអ្នកវាយ*[15] *ប្រដៅពួកនាង[ឲ្យស្របតាមច្បាប់អល់ឡោះប្រ៊ា]។ បើពួកនាងព្រមស្តាប់បង្គាប់ពួកអ្នក [ត្រឹមត្រូវតាមព្រះបញ្ញត្តិ] ពួកអ្នកចូរកុំសាងជម្លោះជាមួយពួកនាង (៤:៣៤)។*

وَإِنِ ٱمۡرَأَةٌ خَافَتۡ مِنۢ بَعۡلِهَا نُشُوزًا أَوۡ إِعۡرَاضًا فَلَا جُنَاحَ عَلَيۡهِمَآ أَن يُصۡلِحَا بَيۡنَهُمَا صُلۡحًاۚ وَٱلصُّلۡحُ خَيۡرٌۗ

*បើស្ត្រីខ្លាចស្វាមីខ្លួនកោងកាចឬទុកចោល ពុំមានទោសលើគេទាំងពីរទេ បើពួកគេជាគ្នាវិញដោយការសម្រុះសម្រួល។ ការសម្រុះសម្រួលជាប្រការប្រពៃបំផុត (៤:១២៨)។*

**លោកស្រី ហ្វាត្មម៉ាស់** - ការសម្រេចក្តីនោះអាស្រ័យទៅតាមប្រភេទនៃការមិនចុះសម្រុងគ្នានោះមែនទេ ? បើមែន តើអនុវត្តិដូចម្តេចខ្លះ ?

**សែយីដ្** - មិនមានអ្វីសង្ស័យទេ ការសម្រេចក្តីអាស្រ័យលើស្ថានភាព។ កន្លងមកហើយ ខ្ញុំបាទបាននិយាយថាសិទ្ធិទាំងនេះមានលក្ខណ្ឌនិងទៅវិញទៅមក (ពោលគឺ ភរិយាមានកាតព្វកិច្ចចំពោះស្វាមី ឯស្វាមីក៏មានកាតព្វកិច្ចចំពោះភរិយាដែរ)។ ឧទាហរណ៍ ប្រសិនបើស្វាមីខានបំពេញករណីយកិច្ចខ្លួន ចៅក្រមអ៊ីស្លាមអាចអារកាត់ឲ្យភរិយាដកហូតយកសិទ្ធិខ្លះដែលស្វាមីមានមកលើខ្លួនភរិយានោះ (ពោលគឺ ស្វាមីអាចលែងមានសិទ្ធិសូមឲ្យភរិយាខ្លួនធ្វើអ្វីនីមួយបានទៀត)។

---

[15] វាយ (وَٱضۡرِبُوهُنَّ) ព្រះសាស្តាﷺបានថែងកំណត់ថាការវាយនោះគឺការគោះ (គឺវាយថើរៗ)។

**លោកស្រី ហ្វាត់ម៉ាស៊ូ** - តើសៃយីដ្ធអាចប្រាប់ទោសដែលភរិយាអាចអនុវត្តិនោះបានទេ ?

**សៃយីដ្ធ** - ឧទាហរណ៍ស្វាមីមិនបំពេញកាតព្វកិច្ចដែលខ្លួនត្រូវបំពេញនោះទេ ឬស្វាមីនោះប្រព្រឹត្តិទង្វើខុសច្បាប់សាសនាឬទង្វើដែលធ្វើឲ្យមានអន្តរាយដែលជះឥទ្ធិពលអាក្រក់មកលើគ្រួសារដូចជាផឹកស្រា លេងល្បែងស៊ីសងឬធ្វើទុក្ខទោសដល់ភរិយាផ្លូវកាយឬផ្លូវចិត្តជាដើម ។

បើភរិយាបានហាមឃាត់ច្រើនដងហើយ ស្វាមីនោះនៅតែប្រព្រឹត្តអំពើនោះទៀត ភរិយាអាចអនុវត្តិញត្តិមួយក្នុងចំណោមញត្តិច្រើនទៀត ដោយបដិសេធរួមគ្រែជាមួយស្វាមីនោះ ជាឧទាហរណ៍ ។ បើនៅតែធ្វើអំពើនោះដដែល ភរិយាអាចនាំសំណុំរឿងនេះទៅសូមដំណោះស្រាយពីប្រព័ន្ធតុលាការអ៊ីស្លាម ។ បន្ទាប់ពីបានសិក្សាសំណុំរឿងហើយ ចៅក្រមអាចសម្រេចក្តីដាក់ទណ្ឌកម្មផ្សេងៗបាន ។

ចៅក្រមអាចបំភ័យស្វាមីនោះដោយទណ្ឌកម្មលើរូបកាយ ដោយពិន័យកម្មថវិកាស្វាមីនោះ ឬគំរាមបំបែកស្វាមីនោះពីភរិយា ។

**លោកស្រី ហ្វាត់ម៉ាស៊ូ** - តើញត្តិថែងអ្វីខ្លះពេលភរិយាជាណាស្ហ៊ូស្ហា (គឺល្មើសករណីយកិច្ចខ្លួន) មិនបំពេញករណីយរបស់ខ្លួនទេនោះ ?

**សៃយីដ្ធ** - ប្រសិនបើភរិយាមិនបំពេញករណីយកិច្ចខ្លួនទេ ឬប្រព្រឹត្តិទង្វើខុសច្បាប់សាសនា ឬទង្វើដែលធ្វើឲ្យមានអន្តរាយ ស្វាមីអាចប្រើញត្តិតែមួយនេះបានដូចគ្នានឹងភរិយាអនុវត្តិលើស្វាមីនោះដែរ ពេលស្វាមីនោះរឹងទទឹង ។ ខុសគ្នាតែត្រង់ស្វាមីមិនចាំបាច់ពឹងពាក់តុលាការភ្លាមៗនោះទេ ។

ដំបូង ស្វាមីត្រូវដាស់តឿនភរិយា ឬសូមជំនួយពីអ្នកជំនាញ។ បើនៅតែមានបញ្ហា ស្វាមីអាចបដិសេធរួមគ្រែជាមួយភរិយា។ បន្ទាប់ពីខិតខំព្យាយាមអស់ពីសមត្ថភាព ហើយស្វាមីខ្លាចភរិយាខ្លួននៅតែរឹងទទឹង នៅតែប្រមាថ ប្រសិនបើអាចបញ្ឈប់គ្រោះថ្នាក់ធំបានដែលភរិយាធ្វើទៅលើខ្លួនឯងឬលើគ្រួសារនោះ ស្វាមីអាចអនុវត្តិការសម្រេចចិត្តដ៏លំបាកបានពោលគឺ វាយថើរៗភរិយាខ្លួន។ តែត្រូវចងចាំក្នុងចិត្តថាភរិយាមានសិទ្ធិធ្វើទណ្ឌកម្មនេះដែរចំពោះស្វាមីខ្លួន។ ខ្ញុំបាទនឹងអធិប្បាយលំអិតអំពីរឿងនេះពេលក្រោយ។[16]

**លោកស្រី ហ្វាត់ម៉ាស់** - ពិតណាស់ត្រូវវិភាគជាលំអិតរឿងទាំងនេះ។ សូមបែរមករកពាក្យដែលលោកអ្នកប្រាជ្ញប្រើ គឺពាក្យ "ហ្ហាក់ អាល់-ត៏អាស់ (حق الطاعة) បានសេចក្តីថាការស្តាប់ឱវាទដែលជាកាតព្វកិច្ចរបស់ភរិយានោះជាសិទ្ធិមួយរបស់ស្វាមី។ ការស្តាប់ឱវាទនេះមានកម្រិតដែលផ្លាស់ប្តូរទៅតាមន័យកំណត់។ តើច្បាប់តម្រូវឲ្យស្តាប់ឱវាទដោយរបៀបណា និងក្នុងកម្រិតណា ?

**សៃយីដ់** - ពេលលោកអ្នកប្រាជ្ញនិយាយអំពីសិទ្ធិដែលស្វាមីមានលើភរិយានោះ លោកប្រើពាក្យ ហ្ហាក់ អាល់-ត៏អាស់ ដែលមានន័យថាសិទ្ធិស្តាប់ឱវាទដែលភរិយាត្រូវបំពេញ តែសូមរំលឹកម្តងទៀតថាការស្តាប់ឱវាទមិនមែនអ្វីដែលដាច់ខាតនោះទេ តែវាមានលក្ខខណ្ឌ។ ការស្តាប់ឱវាទនេះនៅក្នុងន័យថា ព្រមទទួលយកបញ្ជាទាំងអស់ដែលអល់ឡោះហ្ 
ដាក់មក។ ស្ត្រីត្រូវប្រតិបត្តិឲ្យត្រឹមត្រូវតាមព្រះបញ្ញត្តិទាំងអស់ដែលអល់ឡោះហ្ ថែងមក។

[16] សូមមើលវគ្គ "ការដាក់ពិន័យ"។

ពេលស្វាមីស្នើសូមភរិយាអ្វីមួយ ដែលអល់ឡោះហ្ ﷻបានបម្រុងទុកស្រេចហើយឬបានដាក់មកហើយនោះ ភរិយាត្រូវបំពេញការស្នើសូមនោះ ។ ពីរគឺ ស្វាមីជាអ្នកសម្រេចផ្ដាច់ព្រ័ត្ររឿងទាំងឡាយក្នុងគ្រួសារ ។ អនុវត្តិបែបនេះក្នុងច្រើនវិស័យទៀត ដូចជាចំនួនកូនដែលគូស្វាមីភរិយានឹងមាន កន្លែងដែលគូស្វាមីភរិយានឹងរស់នៅ កិច្ចការរបស់ភរិយានិងច្រើនទៀត ។ តែត្រង់នេះដែរ ការស្ដាប់ឱវាទមានលក្ខខណ្ឌ ។

**លោកស្រី ហ្វាត់ម៉ាស់** - ឧទាហរណ៍ថា ប្រសិនបើស្វាមីមិនបំពេញករណីយសាសនារបស់ខ្លួនទេ ស្នើសូមភរិយាខ្លួនឲ្យទទូរហ៊្ញឹយ៉ាប់[17]ថ្វីបើភរិយានោះមិនចង់ទទូរទេ តើស្វាមីនោះធ្វើដូច្នេះត្រឹមត្រូវទេ ? បើត្រឹមត្រូវ តើមិនមានអាយ៉ាស់គួរអានមួយចែងយ៉ាងច្បាស់លាស់ទេ ?

لَآ إِكۡرَاهَ فِي ٱلدِّينِۖ

*ពុំមានការបង្ខិតបង្ខំក្នុងសាសនាឡើយ (២:២៥៦) ។*

**សៃយីដ្** - ពេលគួរអាននិយាយអំពី "ពុំមានការបង្ខិតបង្ខំក្នុងសាសនាឡើយ" នោះគឺសំដៅទៅលើមនុស្សដែលមិនទទួលយកសាសនាអ៊ីស្លាមជាសាសនារបស់ខ្លួនទេ ។ អ៊ីស្លាមមិនមែនសាសនាដែលសង្កត់ញឬបង្ខំទេ គេអាចលះបង់ចោលពេលណាក៏បាន ។ ក៏ប៉ុន្តែ ពេលអ្នកណាមួយបានប្ដេជ្ញាខ្លួនថាមុស្លីមហើយ អ្នកនោះបានជ្រើសយកសាសនាអ៊ីស្លាមដោយសេរី ។

ន័យជ្រៅរបស់អ៊ីស្លាមគឺ តាស់លីម (تَسْلِيم) ប្រគល់ខ្លួន ។ ពេលមនុស្សហៅ

---

[17] សំលៀកបំពាក់ស្ត្រីដែលសមស្របតាមច្បាប់អ៊ីស្លាម; ការបិទបាំងខ្លួននិងសក់ ។

ខ្លួនឯងថាមុស្លីម ការពិត មនុស្សព្រមប្រគល់ខ្លួនក្នុងសិក្ខាបទនិងការអនុវត្តិអ៊ីស្លាម ។

មុស្លីមអនុវត្តិតាមគួរអាននិងស៊ូណាស់ព្រះសាស្តាﷺ គ្រប់ប្រការនិងគ្រប់គោលកាណ៍ណែនាំមិនដាច់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។ ខ្សែបន្ទាត់និងស៊ុនណាស់បែបនេះជ្រាបចូលទៅក្នុងវិស័យជីវិតច្រើនរបស់មុស្លីម ដូចជារបៀបគំនាប់គ្នា របៀបធ្វើធុរកិច្ច ការអប់រំ កិច្ចការគ្រួសារ ព្រឹត្តិការណ៍នយោបាយនិងសង្គម ព្រមទាំងសុជីវធម៌ដែលត្រូវមានពេលចូលផ្ទះអ្នកណាមួយ ។

សំពត់ទទូរក្បាលមិនមែនបញ្ហាដែលត្រូវដាក់មកដោយស្វាមីទេ តែដោយអល់ឡោះហ្ម៍ ។ ស្វាមីមានសិទ្ធិសូមឲ្យភរិយាខ្លួនប្រតិបត្តិការទទូរក្បាលដោយហ៊្ញីយ៉ាប់ពីព្រោះស្វាមីនោះសូមឲ្យភរិយានោះធ្វើអ្វីដែលអល់ឡោះហ្ម៍បានប្រាប់ឲ្យធ្វើស្រេចមកហើយ ។ បើស្វាមីស្នើសូមឲ្យភរិយាខ្លួនធ្វើអំពើឬទង្វើណាមួយដែលនៅក្នុងសាសនាឬស័ក្តិសម ភរិយានោះត្រូវធ្វើ ។

ទោះបីស្វាមីនោះ មិនប្រតិបត្តិយ៉ាងពេញលេញករណីយកិច្ចសាសនារបស់ខ្លួនក៏ដោយ ដូចជាស៊្វឡាត់ កាន់សីលត្រណម ឬបរិច្ចាគសទ្ធាទានក៏ដោយ ក៏ស្វាមីនោះនៅលើខ្សែបន្ទាត់សាសនាក្នុងការស្នើសូមឲ្យភរិយាខ្លួនបំពេញករណីយកិច្ចរបស់ខ្លួនដែរ ។ ដរាបណាស្វាមីមិនបង្គាប់ឲ្យភរិយាធ្វើទង្វើសាសនាខុសច្បាប់ឬមិនសមហេតុផលទេ ដរាបនោះភរិយាត្រូវគោរពតាម ។

ផ្ទុយពីនោះ ស្វាមីមិនត្រូវបញ្ជាឲ្យភរិយាកុំទទូរហ៊្ញីយ៉ាប់ជាដាច់ខាត ។ ស្វាមីមិនត្រូវបង្ខំភរិយាខ្លួន ឲ្យធ្វើមួយដែលផ្ទុយនឹងបទបញ្ញាអ៊ីស្លាមជាដាច់ខាត ។ ភរិយាមិនត្រូវបង្ខំឲ្យស្តាប់ស្វាមីទេពេលស្វាមីនោះឲ្យខ្លួនធ្វើ

ប្រការណាមួយដែលផ្ទុយនឹងព្រះបញ្ញាអល់ឡោះហ្វ៏ ទោះបីស្វាមីនោះគំរាមលែងលះភរិយានោះក៏ដោយ ។

**លោកស្រី ហ្វាត់ម៉ាស់** - នាងខ្ញុំសន្មត់បានថា មកពីមូលហេតុថវិកា ស្វាមីយកកូនដោយដាក់កំណត់ចំនួន តែស្វាមីអាចរឹតត្បឹតកិច្ចការភរិយាខ្លួនបានទេ ?

**សៃយីដ្** - ការសន្មត់របស់លោកស្រីមិនត្រូវទាំងអស់ទេ ។ ជាទូទៅ បញ្ហាទាំងពីរនេះនៅលើស្ថានការណ៍ ។ ប្រសិនបើស្វាមីមានការទុកចិត្តមាំរឿងថវិកាដោយរក្សារបៀបរស់នៅរបស់គ្រួសារឲ្យសមរម្យ ស្វាមីនោះជាអ្នកសម្រេចចំនួនកូនដែលអ្នកទាំងពីរចង់បាន ។

អ៊ីស្លាមដាក់បន្ទុកយ៉ាងធ្ងន់លើឪពុក ។ ឪពុកជាបុគ្គលតែមួយគត់និងជាអ្នកទទួលខុសត្រូវទាំងស្រុងក្នុងការចាយវាយថវិកាចិញ្ចឹមកូន លុះត្រាតែកូនៗមានសមត្ថភាពទ្រទ្រង់ខ្លួនឯងបាន ។ ម្យ៉ាងទៀត បើឪពុកមានកូនស្រីពេញវ័យហើយកូនស្រីនោះរស់នៅក្នុងផ្ទះខ្លួន ឪពុកនោះត្រូវនៅតែចិញ្ចឹមកូនស្រីនោះតទៅទៀតជាចាំបាច់ ។

សម្រាប់មាតា អាចមិនយុត្តិធម៌ទេដែលត្រូវពពោះហើយចិញ្ចឹមកូនច្រើនឆ្នាំនោះ ។ ពិតណាស់ ម្តាយរងការលំបាកខ្លាំងផ្លូវកាយនិងផ្លូវចិត្តក្នុងការចិញ្ចឹមកូន តែចូរនឹកឡើងវិញថាកូននឹងធំពេញវ័យ ។ កាតព្វកិច្ចម្តាយនឹងអស់ តែឪពុកនៅតែមានករណីយកិច្ចចាយវាយសម្រាប់គ្រួសារ ។

ផ្ទុយទៅវិញ នឹងមានជម្លោះឬការមិនចុះសម្រុងគ្នាបើឪពុកមិនអាចផ្តល់ការរស់នៅសាមញ្ញឬសក្តិសមឲ្យកូនបានទេ ដូចជាឈ្នួលសាលា មធ្យោបាយការពារសុខភាពឬលំនៅ ជាដើម ។ ក្នុងករណីបែបនេះ បើ

ស្វាមីនៅតែចង់បានកូនច្រើន ភរិយាមានសិទ្ធិមិនធ្វើតាមបំណងរបស់ស្វាមី ។

លក្ខខណ្ឌនៃការស្តាប់ឱវាទមួយទៀត គឺការសម្រេចចិត្តជ្រើសរើសកន្លែងរស់នៅរបស់គូស្វាមីភរិយា ។ បើភរិយាមិនបានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍អំពីកន្លែងរស់នៅទេ ស្វាមីមានសេរីភាពជ្រើសរើសស្រុក ឬប្រទេសជាលំនៅ ។ ដោយហេតុតែស្វាមីជាអ្នកឧបត្ថម្ភតែមួយរបស់គ្រួសារ ក្នុងច្រើនករណី ការសម្រេចរបស់ស្វាមីនៅលើសុវត្ថិភាពថវិកានៅលើសង្គមត្រឹមត្រូវ ឬនៅលើការបាននៅក្បែរសមាជិកគ្រួសារ ។

បើភរិយាបដិសេធរឿងកន្លែងរស់នៅ ការបដិសេធរបស់ភរិយាត្រូវផ្អែកទៅលើស្ថានការណ៍លំបាកដែលសក្តិសម ។ ឧទាហរណ៍ បើស្វាមីចង់រស់នៅក្បែរមាត់សមុទ្រ តែភរិយាមិនយល់ព្រមទេ ភរិយានោះលើកយកមូលហេតុបរិស្ថានដែលជះឥទ្ធិពលអាក្រក់មកលើកូនៗ ជាចម្លើយ ។ ភរិយាអាចសូមពន្យារពេលផ្លាស់ប្តូរកន្លែងរស់នៅ រង់ចាំឲ្យកូនៗពេញវ័យអាចរស់នៅដោយខ្លួនឯងបានសិន ។ ការបដិសេធរបស់ភរិយានឹងមានជោគជ័យ ។

ឯការរឹតត្បិតកិច្ចការរបស់ភរិយាក៏មានលក្ខខណ្ឌដែរ ។ បើភរិយាចង់សិក្សាសាសនា ស្វាមីមិនអាចហាមឃាត់ភរិយាមិនឲ្យសិក្សានោះបានទេ ។ ម្យ៉ាងទៀត បើភរិយាចង់ទៅបំពេញពិធីហ្ជាច់[18]ដោយប្រាក់ផ្ទាល់ខ្លួន អាចការពារខ្លួនឯងបាន ស្វាមីមិនអាចមិនអនុញ្ញាតឲ្យភរិយាទៅបានទេ ។

[18] ពិធីហ្ជាច់ គឺការទៅបំពេញពីធីដើរឆ្វែលដែលមុស្លីមទាំងអស់ត្រូវធ្វើ បើអាចធ្វើបាន មួយដងក្នុងមួយជីវិត នៅឯព្រះមហាគ្រឹះអល់ឡោះហ៍عز وجلដែលគេហៅថាកាក់បាស់ នៅឯម៉ាក់កាស់ តំបន់ហ៊ីយ៉ាស់ ។

**លោកស្រី ហ្វាត្ម៉ាស់** - នាងខ្ញុំបានអានប្រភពព័ត៌មានច្រើនដែលសរសេរថាភរិយាត្រូវតែសូមអនុញ្ញាតពីស្វាមីសិនមុននឹងចេញពីផ្ទះ ។ តើត្រូវទេ ?

**សៃយីដ្** - សូមរំលឹកម្តងទៀត រឿងនេះផ្អែកទៅលើកាលៈទេសៈ ។ ធម្មតាគេកម្រប្រើច្បាប់នេះណាស់ គេប្រើវានៅពេលដែលចាំបាច់ ។ បើស្វាមីពេញចិត្តនឹងកិច្ចការរបស់ភរិយា មិនបាច់សូមអនុញ្ញាតពីស្វាមីនោះទេ ។ បើភរិយាឃើញថាស្វាមីបារម្ភឬជំទាស់ ភរិយាត្រូវចៀសវាងធ្វើបែបនេះ ឬត្រូវខំដោះស្រាយបញ្ហាជាមួយស្វាមី ។

ក្នុងករណីច្រើន ច្បាប់នេះមិនមានន័យថារាល់ពេលដែលចេញពីផ្ទះភរិយាត្រូវប្រាប់ស្វាមីនិងសូមអនុញ្ញាតនោះទេ លើកលែងតែពេលមានអ្វីមួយដែលលោកអ្នកប្រាជ្ញហៅថា មុសតាស្មា មានន័យថាបំណងខុសច្បាប់ អន្តរាយឬលទ្ធផលលំបាក ។ នៅក្នុងវិស័យទាំងនេះឯងដែលស្វាមីអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីរឹតត្បិតកិច្ចការក្រៅផ្ទះរបស់ភរិយា ។

ឧទាហរណ៍ ភរិយាមានមិត្តច្រើនដែលមានកេរ្តិ៍ឈ្មោះអាស្រូវហើយភរិយានោះចំណាយពេលសេពគប់ជាមួយពួកមិត្តទាំងនោះ ។ បើស្វាមីមិនយល់ព្រមទេ ស្វាមីនោះមានសិទ្ធិហាមភរិយាសេពគប់ជាមួយមនុស្សបែបនេះ ។ ឬភរិយាអាចចោលផ្ទះឬកូនដោយធ្វេសប្រហែស ឬស្វាមីអាចសង្ស័យភរិយាខ្លួនដោយសមហេតុផលថាប្រព្រឹត្តិអំពើអសីលធម៌ ។ ទាំងនេះជាតួយ៉ាង ដែលជាមូលហេតុធ្វើឲ្យស្វាមីអាចប្រើសិទ្ធិរឹតត្បិតការងាររបស់ភរិយាបាន ។ ក៏ប៉ុន្តែ អ្វីដែលសំខាន់នោះ ត្រូវកត់សម្គាល់ថាភរិយាអាចបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍បានថា គេនឹងមិនត្រូវហាមខ្លួនភរិយានោះចេញទៅក្រៅផ្ទះទេ ក្នុងឱកាសសមរម្យឬក្នុងពេលដែលត្រូវការផ្នែកសេដ្ឋកិច្ច (គឺត្រូវការប្រកបកិច្ចការ) ឬផ្នែកសង្គម (គឺជួប

មិត្តភ័ក្តិ) ដោយមានលក្ខខណ្ឌថាទង្វើទាំងនេះនឹងពុំមានឥទ្ធិពលអាក្រក់ដល់សិទ្ធិស្វាមីឬកូនទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើភរិយាអាចប្រើបញ្ញត្តិដូចគ្នានេះបានទេ ដោយរឹតត្បិតការងាររបស់ស្វាមីខ្លួន ?

**សៃយីដ្** - ទាំងអស់នេះ សុទ្ធិផ្អែកទៅលើកាលៈទេសៈ (គឺមូលហេតុ) ។ ប្រសិនបើកិច្ចការរបស់ស្វាមីមានអន្តរាយដល់ជីវភាពគ្រួសារ ហើយភរិយាមិនអាចផ្លាស់ប្តូរទង្វើរបស់ស្វាមីបានទេ ភរិយាត្រូវសូមជំនួយពីអ្នកដឹកនាំសហគមន៍ ពីអ៊ីម៉ាំ[19] ឬពីតុលាការអ៊ីស្លាមដើម្បីកែប្រែខ្លួនស្វាមីរបស់ភរិយានោះ ។

**លោកស្រី ហ្វាត់ម៉ាស់** - ក្នុងករណីយច្រើន អាពាហ៍ពិពាហ៍ស្ថិតនៅលើគោលការណ៍សំខាន់ៗបីដែលសៃយីដ្ធមានប្រសាសន៍រួចមកហើយ គឺៈ ភាពទៅវិញទៅមក សហប្រតិបត្តិការ និងសេចក្តីគោរព ។ ហេតុអ្វីចាំបាច់បង្កើតច្បាប់ដែលចែងថាភរិយាត្រូវសូមអនុញ្ញាតចេញពីផ្ទះ ?

សៃយីដ្ធយល់ស្របមែនទេថា ជាទូទៅ ភរិយាដែលលើកកិត្តិយសស្វាមីនឹងចៀសវាងស្ថានការណ៍ណាដែលអាចមិនគាប់ចិត្តស្វាមី ឬដែលបណ្តាលឲ្យកើតមាននូវព្រឹត្តិការណ៍មិនស្របច្បាប់ ?

**សៃយីដ្** - ពិតប្រាកដណាស់ ភរិយាដែលស្រឡាញ់និងគោរពស្វាមីខ្លួននោះនឹងចៀសវាងធ្វើឲ្យស្វាមីខ្លួនឃ្នើសចិត្តជាស្វ័យប្រវត្តិ តែទោះជាយ៉ាងណាក៏ដោយ សំខាន់ត្រូវកត់សម្គាល់ពេលដែលមានការមិនចុះសម្រុង

[19] គឺអ្នកចេះដឹងខាងសាសនា/អ្នកដឹកនាំអ៊ីស្លាម ។

គ្នា ។

ដើម្បីលើកជាតួយ៉ាងរឿងនេះ មានច្បាប់ប្រចាំទំនៀមទម្លាប់ ច្បាប់ដែលគេគិតថាជាច្បាប់សាធារណៈដូចជា បើកបរដោយប្រយ័តប្រយែងនៅក្នុងបរិវេណសាលារៀន ដែលគេនឹងបង្អន់ល្បឿនជាស្វ័យប្រវត្តិដោយមិនបាច់មើលស្លាកសរសេរកំណត់ល្បឿន ។ ថ្វីបើមានច្បាប់ដាក់បង្ហាញឲ្យឃើញដែលកំណត់ល្បឿនបើកបរក្តី អ្នកបើកបរបង្អន់ល្បឿនជាទូទៅ ។

មានតែពេលមួយគត់ដែលច្បាប់ត្រូវប្រើ គឺពេលដែលគេល្មើសច្បាប់ ។ ស្រដៀងគ្នាដែរ ភរិយា (មុនចេញពីផ្ទះ) ដឹងច្បាស់ថាស្ថានការណ៍ណាមួយដែលផ្ទុយពីបំណងរបស់ស្វាមីខ្លួន ហើយភរិយានោះនឹងចៀសវាងស្ថានការណ៍នោះជាស្វ័យប្រវត្តិ ។ បើចាំបាច់ គេនឹងប្រើបញ្ញត្តិនេះ ត្រង់នេះទៀត ដើម្បីបំភ្លឺ ។

**លោកស្រី ហ្វាត្មម៉ាស៊ុ** - បើស្ត្រីមុស្លីមចង់បំពេញពិធីហ្កាច្ច ហេតុអ្វីចាំបាច់សូមការអនុញ្ញាតសរសេរពីស្វាមី ហេតុអ្វីស្ត្រីត្រូវមានអ្នកតាមមើល (មូហ្ការ៉ម) ដើម្បីធ្វើដំណើរជាមួយស្ត្រីនោះ ?

**សៃយីដ្** - ដើម្បីសេចក្តីច្បាស់លាស់ សំបុត្រយល់ព្រមរបស់ស្វាមីសម្រាប់ភរិយាធ្វើពិធីហ្កាច្ចឬធ្វើដំណើរនោះ គ្រាន់តែជាការបង្គ្រប់កិច្ចទេដែលប្រទេសមុស្លីមខ្លះដាក់ឲ្យអនុវត្តិ ។ អ៊ីស្លាមមិនដែលចែងថាត្រូវតែសរសេរសំបុត្រយល់ព្រមសម្រាប់ភរិយាធ្វើដំណើរឡើយ ។ ក៏ប៉ុន្តែ អ៊ីស្លាមតម្រូវឲ្យស្វាមីយល់ព្រមដោយពេញចិត្ត និងយល់ព្រមឲ្យភរិយាធ្វើដំណើរឬប្រកបការងារ ។

មូលហេតុដែលស្ត្រីត្រូវការអ្នកតាមមើលពេលធ្វើដំណើរនោះ គឺដើម្បី

ការពារស្ត្រីនោះពីអំពើវិសមធម៌វាលដាលក្នុងសហគមន៍ខ្លះ ។ អ៊ីស្លាមមិនមែនសាសនាដែលគាបសង្កត់ឬហាមឃាត់ស្ត្រីទេ ផ្ទុយទៅវិញ អ៊ីស្លាមជាសាសនាដែលចង់ការពារស្ត្រី ដោយទប់ស្កាត់អំពើបំពារបំពាន ឬការបៀតបៀនពីសហគមន៍អសីលធម៌ ។ អ៊ីស្លាមបានដាក់វិធានការប្រុងប្រយ័តជាមុនដើម្បីការពារស្ត្រីពេលធ្វើដំណើរ ដោយឲ្យមានបុរសអ្នកតាមមើលទៅជាមួយផង ។

**លោកស្រី ហ្វាត់ម៉ាស់** - តើច្បាប់ធ្វើដំណើរមានចែងនៅក្នុងគួរអាន ឬនៅក្នុងហាឌីស្សព្រះសាស្តាﷺទេ ?

**សៃយីដ្** - គោលការណ៍ណែនាំស្ត្រីធ្វើដំណើរមានចែងនៅក្នុងហាឌីស្សព្រះសាស្តាﷺយ៉ាងច្រើន ។[20]

**លោកស្រី ហ្វាត់ម៉ាស់** - លោកអ្នកប្រាជ្ញខ្លះមានប្រសាសន៍ថាស្វាមីត្រូវប្រើសិទ្ធិរបស់ខ្លួនដើម្បីហាមភរិយាកុំឲ្យទៅលេងគ្រួសារខ្លួន ។ តើត្រូវទេ ?

**សៃយីដ្** - មែន បើវារំលោភលើសិទ្ធិស្របច្បាប់របស់ស្វាមី ដូចជាការរួមរស់ជាមួយគ្នាជាមួយភរិយាជាដើម ។ ក៏ប៉ុន្តែ ស្វាមីត្រូវចងចាំថាភរិយាខ្លួនជាមនុស្សម្នាក់ដែលមានអារម្មណ៍ និងមានទំនោរទៅរកជីវិតសង្គម (គឺត្រូវការជួបមិត្តឬសាច់ញាតិ) ។ ជួបជុំគ្រួសាររបស់ភរិយាមានសារៈសំខាន់ណាស់ ដើម្បីបំពេញសេចក្តីត្រូវការផ្លូវចិត្តរបស់ភរិយា ។

**លោកស្រី ហ្វាត់ម៉ាស់** - តើអ្វីកើតឡើងពេលស្វាមីហាមភរិយាចេញពីផ្ទះដោយគ្មានមូលហេតុ ? តើភរិយាអាចការពារខ្លួនបានដូចម្តេចពីស្វាមី

---

[20] រាយការណ៍ដោយលោក អ៊ីបនូ អ៊ុាប់បាស់ ។

ដែលបំពារបំពានសិទ្ធិរបស់ភរិយានោះយ៉ាងគឃ្លើន ដោយឥតការអប់រំ ?

**សៃយីដ្** - ស្ថានការណ៍លើកឡើងខាងលើនេះ ជាទូទៅ កើតមកពីសម្តីប្រកែកគ្នាពេលគូស្វាមីភរិយាឈ្លោះគ្នា ។ តាមធម្មតា បើស្វាមីជាអ្នកកាន់សាសនាម៉ឺងម៉ាត់ ស្វាមីនោះប្រាកដជាមិនប្រព្រឹត្តិបែបមិនទាន់សម័យទេ ព្រោះស្វាមីនោះនឹងរំលោភកិច្ចសន្យាមួយ ។[21]

ម្យ៉ាងទៀត បើស្វាមីប្រើសិទ្ធិខ្លួនឯងខុសដោយមិនអាចយល់ជម្រៅចិត្តបានទេ ហើយភរិយាយល់ថាស្វាមីនោះប្រព្រឹត្តិមិនគប្បីមកលើខ្លួន នេះគឺករណីដែលតម្រូវឲ្យមានអាជ្ញាកណ្តាល ។ គួរអានអធិប្បាយត្រង់ៗអំពីរបៀបដោះស្រាយបញ្ហានេះ ។

وَإِنۡ خِفۡتُمۡ شِقَاقَ بَيۡنِهِمَا فَٱبۡعَثُواْ حَكَمٗا مِّنۡ أَهۡلِهِۦ وَحَكَمٗا مِّنۡ أَهۡلِهَآ إِن يُرِيدَآ إِصۡلَٰحٗا يُوَفِّقِ ٱللَّهُ بَيۡنَهُمَآۗ

*បើពួកអ្នកក្រែងអ្នកទាំងពីរបែកបាក់គ្នា (គឺស្វាមីភរិយា) ចូរពួកអ្នកតែងតាំងអាជ្ញាកណ្តាលម្នាក់ ក្នុងគ្រួសាររបស់បុរស (គឺស្វាមី) និងអាជ្ញាកណ្តាលម្នាក់ទៀតក្នុងគ្រួសាររបស់នាង (គឺភរិយា) ។ បើអ្នកទាំងពីរប្រាថ្នាជានឹងគ្នាវិញ អល់ឡោះប្រាកដនឹងឲ្យមានការស្រុះស្រួលគ្នាវិញបានរវាងអ្នកទាំងពីរ (៤:៣៥) ។*

សូមរំលឹកម្តងទៀត មិនត្រូវបណ្តោយឲ្យស្វាមីធ្វើអ្វីបានតាមតែក្បាលចិត្តជាដាច់ខាត ។ បើស្វាមីនោះជាមនុស្សមានជំនឿ មានកិត្តិយសល្អមែននោះ គាត់ប្រាកដជាមិនរំលោភច្បាប់អ៊ីស្លាមទេ ។ ស្វាមីត្រូវចងចាំជានិច្ចថាភរិយាក៏មានសិទ្ធិមួយចំនួនដែរដែលគ្រប់គ្រង ដែលការពារនិងដឹកនាំ

[21] សូមមើលគួរអាន ៤:១៩; ២:២២៨ ។

ភរិយានោះ ។ ភរិយា គ្រប់ពេលវេលា មានសិទ្ធិមិនប្រើសិទ្ធិឬប្រើសិទ្ធិរបស់ខ្លួន ពេលណាអំពើអយុត្តិធម៌ប្រភេទណាមួយត្រូវប្រព្រឹត្តិមកលើខ្លួនភរិយានោះ ។

**លោកស្រី ហ្វាត់ម៉ាស់** - មានហាឌីស្ហ៍ល្បីមួយដែលមុស្លីមទាំងអស់ត្រូវសិក្សា ។ សៃយីដ្ធបានបញ្ជាក់ថាស្វាមីមិនអាចហាមភរិយាចេញពីផ្ទះបានទេកាលណាភរិយានោះទៅរកការសិក្សាអ៊ីស្លាម ។

តើយ៉ាងណាដែរក្នុងករណីដែលពុំមានដាក់លក្ខខណ្ឌ ក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ទេនោះ ពេលភរិយាចង់បន្តការសិក្សាឯមហាវិទ្យាល័យ ឬប្រកបមុខរបរដែលត្រូវនឹងមុខវិជ្ជាសិក្សារបស់ភរិយានោះ ? តើស្វាមីអាចហាមភរិយាបានទេ បើភរិយាធ្វើដូច្នេះដោយមិនបានទទួលការយល់ព្រមពីស្វាមីទេនោះ តើទង្វើនេះត្រូវចាត់ទុកជាបទល្មើសទេ ?

**សៃយីដ្ធ** - ស្វាមីត្រូវជួយជ្រោមជ្រែងភរិយាឲ្យបានល្អបំផុតតាមដែលអាចធ្វើបាន ។ ភរិយាមិនគប្បីបន្តការសិក្សា ឬប្រកបការងារដោយគ្មានការយល់ព្រមពីស្វាមីទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - គួរអានបង្ហាញហេតុផលថាហេតុអ្វីភរិយាត្រូវធ្វើតាមបំណងស្វាមី

ٱللَّهُ بَعۡضَهُمۡ عَلَىٰ بَعۡضٖ وَبِمَآ أَنفَقُواْ مِنۡ أَمۡوَٰلِهِمۡۚ

*អល់ឡោះបុាប្រោសប្រណីអ្នកខ្លះជាងអ្នកឯទៀត និងពីព្រោះពួកគេត្រូវចំណាយទ្រព្យសម្បត្តិរបស់ខ្លួន (៤:៣៤) ។*

ហេតុផលដែលគួរអានបង្ហាញ ថាភរិយាត្រូវធ្វើតាមបំណងស្វាមីនោះ

ព្រោះតែស្វាមីមានសមត្ថភាពផ្លូវកាយ ផ្លូវចិត្ត និងផ្លូវថវិកាក្នុងការផ្គត់ផ្គង់ភរិយាមែនទេ ? បើមែន តើនេះមិនមែនការប្រកាន់ភេទ ឬការដាក់ក្នុងចំណុះគេទេ ?

ដើម្បីបញ្ជាក់ម្តងទៀត តើគម្ពីរអានផ្តល់ហេតុផលស្តាប់ឱវាទនោះដោយផ្អែកលើការផ្គត់ផ្គង់ដោយថវិកាទេ ? ម្យ៉ាងទៀត ការទទួលខុសត្រូវរបស់ភរិយានោះមិនមែនតុល្យភាពត្រឹមត្រូវរវាងការទទួលខុសត្រូវផ្សេងៗទេ ?

**សៃយីដ៍** - សូមរំលឹកម្តងទៀត សូមថ្លែងសាឡើងវិញអ្វីដែលគម្ពីរអានចែង

وَعَاشِرُوهُنَّ بِٱلۡمَعۡرُوفِۚ

*ចូរពួកអ្នករស់នៅជាមួយពួកនាងដោយវិធីល្អប្រពៃនិងសមធម៌ (៤:១៩) ។*

وَلَهُنَّ مِثۡلُ ٱلَّذِى عَلَيۡهِنَّ بِٱلۡمَعۡرُوفِۚ

*ឯបណ្តាពួកនាងមានសិទ្ធិ ស្មើនឹងអ្វីដែលជាកាតព្វកិច្ចរបស់ពួកនាងដោយសមធម៌ (ពោលគឺ ចូរប្រព្រឹត្តិចំពោះភរិយាដោយសមរម្យ) (២:២២៨) ។*

អាយ៉ាស់ទាំងនេះជាខ្លឹមនៃបទបញ្ជា ដែលដឹកនាំរបៀបប្រព្រឹត្តិចំពោះស្ត្រី ។ អ៊ីស្លាមស្ថិតនៅលើ មូអាមាឡាស់ (مُعَامَلَة) សុជីវធម៌ចំពោះអ្នកដទៃ និងស្ថិតលើ អាក់ឡាក់ (أخلاق) មារយាទល្អប្រពៃ ។ បើគេប្រព្រឹត្តិល្អប្រពៃ និងសមរម្យចំពោះស្ត្រី មិនមានអ្វីគួរសង្ស័យថាមានកាប្រកាន់ភេទ មានអយុត្តិធម៌ ហើយពិសេស ការដាក់ឲ្យនៅក្នុងចំណុះគេនោះទេ ។

មានហាឌីស្ហច្រើនស្តីអំពីសុជីវធម៌ដែលស្វាមីត្រូវមាន ក្នុងការប្រព្រឹត្តិចំពោះភរិយាខ្លួន ។ ខ្ញុំបាទសូមបង្ហាញជូនខ្លះ ។

ថ្ងៃមួយ បុរសម្នាក់បានសួរអ៊ីម៉ាំស្ស៉ាឌិក្ញصلوات الله عليه والسلام[22]អំពីសិទ្ធិស្ត្រីលើស្វាមី ។ ព្រះអង្គصلوات الله عليه والسلامបានតបថា៖ "ស្វាមីត្រូវបំពេញសេចក្តីត្រូវការសំខាន់ៗរបស់ភរិយា មិនត្រូវធ្វើឲ្យភរិយាភ័យខ្លាចដោយទោសៈឥតឈប់ឈរទេ ។ បើក្រោយពីបានធ្វើតាមសេចក្តីត្រូវការរបស់ភរិយាហើយ ស្វាមីនោះចិត្តល្អស្រឡាញ់ភរិយា ខ្ញុំសូមស្បថចំពោះអល់ឡោះហ្ស៍عز وجلថាស្វាមីនោះបានគោរពសិទ្ធិភរិយាខ្លួន ។"[23] ព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "អ្នកមានសទ្ធាប្រសើរដាច់គេគឺបុគ្គលដែលមានសុជីវធម៌ប្រសើរបំផុត ឯបុគ្គលប្រសើរដាច់គេក្នុងចំណោមអស់លោក គឺបុគ្គលដែលល្អប្រពៃបំផុតចំពោះគ្រួសារខ្លួន ។"[24]

អាពាហ៍ពិពាហ៍មិនគ្រាន់តែជាការទ្រទ្រង់ជីវិតប៉ុណ្ណោះទេ ។ សម្រាប់អ៊ីស្លាម អាពាហ៍ពិពាហ៍ដែលប្រកបដោយជោគជ័យនោះស្ថិតនៅលើសហប្រតិបត្តិការទៅវិញទៅមក ស្ថិតនៅលើសេចក្តីគោរព ស្ថិតនៅលើសេចក្តីស្រឡាញ់ ស្ថិតនៅលើការទុកចិត្ត ស្ថិតនៅលើការយោគយល់ ស្ថិតនៅលើការប្រណីសន្តោសនិងការអត់ធ្មត់ ។ អ៊ីស្លាមចាត់ទុកទំនៀមអាពាហ៍ពិពាហ៍ជាការបន្តពូជពង្សមនុស្សជាតិ ជាការអភិរក្សនិងជាការបំពេញកិច្ចផ្នែកចិត្តសាស្ត្រ ផ្នែកអារម្មណ៍និងផ្នែកតម្រេកផ្លូវកាយ ដែលស្ថិតនៅលើជំនឿនិងគុណធម៌ ។ ព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "ពុំមានគោលអ៊ីស្លាមណាមួយ ដែលជាទីស្រឡាញ់និងសម្បើមជាងគ្រឹះនិងទំនៀមអាពាហ៍ពិពាហ៍ឡើយ ។"[25]

---

[22] អ៊ីម៉ាំយ៉ាក់ហ្វារ អាស្ស៍-ស្ស៉ាឌិក្ញصلوات الله عليه والسلامជាអ៊ីម៉ាំទី ៦ នៃអាស្ស៍លុល-បៃត៍عليهم السلام និងជាអ្នកស្នងព្រះសាស្តាصلى الله عليه وآله وسلم ។

[23] សូមមើលសៀវភៅ អ៊ូស្ស៊ូល អាល់-កាហ្វី (اصول الكافي) ។

[24] សូមមើលសៀវភៅ ប៊ីហ្ការ អាល់-អាន់វ៉ារ (بِحَار ٱلْأَنْوَار) ។

[25] សូមមើលសៀវភៅ مُستَدرَكُ الوَسائل ។

وَمِنْ ءَايَٰتِهِۦٓ أَنْ خَلَقَ لَكُم مِّنْ أَنفُسِكُمْ أَزْوَٰجًا لِّتَسْكُنُوٓا۟ إِلَيْهَا وَجَعَلَ
بَيْنَكُم مَّوَدَّةً وَرَحْمَةً ۚ إِنَّ فِى ذَٰلِكَ لَءَايَٰتٍ لِّقَوْمٍ يَتَفَكَّرُونَ ﴿٢١﴾

*សញ្ញាមួយក្នុងចំណោមសញ្ញាទាំងឡាយរបស់ព្រះអង្គនោះគឺ ព្រះអង្គបង្កើតគូគ្រងពីពួកអ្នក (គឺពីវត្ថុធាតុដើមតែមួយ) សម្រាប់ពួកអ្នក ដើម្បីពួកអ្នកនឹងបានស្រាកស្រាន្តផ្លូវស្រោលដោយសារគូគ្រងនោះ។ ព្រះអង្គបានបង្កើតឲ្យមានសេចក្តីស្រឡាញ់និងសេចក្តីមេត្តារវាងពួកអ្នក [និងគូគ្រងពួកអ្នក]។ ក្នុងអ្វីទាំងនេះមាននូវសញ្ញាសម្រាប់ជនទាំងឡាយណាដែលត្រិះរិះ (៣០:២១)។*

هُنَّ لِبَاسٌ لَّكُمْ وَأَنتُمْ لِبَاسٌ لَّهُنَّ ۗ

*ពួកនាងជាអាភរណៈ (គឺគ្រឿងប្រដាប់កាយ) សម្រាប់ពួកអ្នក រីឯពួកអ្នកក៏ជាអាភរណៈសម្រាប់ពួកនាងដែរ (២:១៨៧)។*

هُوَ ٱلَّذِى خَلَقَكُم مِّن نَّفْسٍ وَٰحِدَةٍ وَجَعَلَ مِنْهَا زَوْجَهَا لِيَسْكُنَ إِلَيْهَا ۖ

*ព្រះអង្គបានបង្កើតពួកអ្នកមកពីជីវិតតែមួយ ហើយព្រះអង្គបានបង្កើតគូគ្រងរបស់ជីវិតនោះមកពីវា (គឺមកពីធម្មជាតិដើម ឬមកពីវត្ថុដើមតែមួយនោះ) ដើម្បីឲ្យគេរួមរស់ជាមួយនាងដោយសេចក្តីស្រឡាញ់ (៧:១៨៩)។*

រីឯប្រការចុងក្រោយរបស់លោកស្រី ដោយមិនប៉ះពាល់ភារកិច្ចរបស់ស្ត្រីទេ អ៊ីស្លាមបានដាក់បន្ទុកលើបុរសច្រើនជាង ដូចជាផ្គត់ផ្គង់និងឧបត្ថម្ភគ្រួសារជាដើម។ ចំពោះចំណុចនេះ ធ្វើតាមបំណងស្វាមីមិនមែនជាតុល្យភាពមួយភេទទេសម្រាប់រឿងផ្គត់ផ្គង់នោះ។ គួរអានអធិប្បាយហេតុផលល្អជាងនេះ។

وَٱلۡمُؤۡمِنُونَ وَٱلۡمُؤۡمِنَٰتُ بَعۡضُهُمۡ أَوۡلِيَآءُ بَعۡضٖۚ

*បណ្ដាបុរសអ្នកមានសទ្ធានិងបណ្ដានារីអ្នកមានសទ្ធា ជាអ្នកការពារគ្នា [និងជាសម្ព័ន្ធមិត្តដ៏ស្មោះ] (៩:៧១) ។*

**លោកស្រី ហ្វាត់ម៉ាស់** - កន្លងមកហើយនេះ សែយីដ្ធមានប្រសាសន៍អំពីសិទ្ធិដែលគូស្វាមីភរិយាមានលើគ្នាទៅវិញទៅមក ។ ដោយចាប់ផ្ដើមជាមួយភរិយាមុនគេ តើសែយីដ្ធអាចអធិប្បាយលំអិតអំពីទ្រឹស្ដីរឿងសិទ្ធិរបស់ភរិយានៅក្នុងអាពាហ៍ពិពាហ៍បានទេ ?

**សែយីដ្ធ** - សិទ្ធិមួយ ក្នុងចំណោមសិទ្ធិដ៏សម្បើមនិងក្នុងចំណោមអំណោយដ៏ធំបំផុតដែលគេប្រទានឲ្យស្ត្រីក្នុងអ៊ីស្លាមនោះ គឺការមានថវិកាផ្ទាល់ខ្លួន នីហ្វ៊ីកោះត៍ (نفقة) ។ ស្វាមីទទួលខុសត្រូវទាំងស្រុងការចិញ្ចឹមភរិយានិងកូន ។ មានគោលសំខាន់ធំៗពីរដែលដឹកនាំបទបញ្ញត្តិនិងសេចក្ដីចង់បានជីវព្រឹត្តិរបស់បុគ្គល ។

لِيُنفِقۡ ذُو سَعَةٖ مِّن سَعَتِهِۦۖ وَمَن قُدِرَ عَلَيۡهِ رِزۡقُهُۥ فَلۡيُنفِقۡ مِمَّآ ءَاتَىٰهُ ٱللَّهُۚ

*បុគ្គលណាដែលមានទ្រព្យធន ចូរចាយវាយតាមទំហំទ្រព្យធនរបស់ខ្លួន ។ រីឯបុគ្គលណាដែលមានទ្រព្យធនស្ដួចស្ដើង ចូរចាយវាយតាមដែលអល់ឡោះប្រទានឲ្យអ្នកនោះចុះ (៦៥:៧) ។*

នីហ្វ៊ីកោះត៍ ក្នុងភាសាអារ៉ាប់ ប្រែថា "ចំណាយលើជីវភាពរស់នៅ" ។ ជាពាក្យទូលំទូលាយដែលរាប់បញ្ចូលមធ្យោបាយទ្រទ្រង់ជីវិតផ្សេងៗ ដូចជាសំលៀកបំពាក់ លំនៅ គ្រឿងសង្ហារឹម ប្រាក់ផ្ទាល់ខ្លួន ជាដើម ។ មានប្រជុំសៀវភៅយ៉ាងច្រើនដែលរាយការណ៍រឿងនេះ រៀបរាប់លំអិតគ្រឿងទ្រទ្រង់ជីវិតចាំបាច់ដែលស្វាមីត្រូវផ្ដល់ឲ្យគ្រួសារ ។

សៀវភៅខ្លះល្អិតល្អន់ណាស់ ដល់ថ្នាក់បញ្ជាក់អំពីអ្វីៗដែលត្រូវស្តុកទុកក្នុងកន្លែងទុកស្បៀង ឧទាហរណ៍ ប្រេងឆា ស្ករ ម្សៅនិងអាហារសម្រាប់បរិភោគក្នុងឱកាសបុណ្យមុស្លីម ។

**លោកស្រី ហ្វាត់ម៉ាស់** - តើការចាយវាយពាក់ព័ន្ធតែនឹងស្វាមីទេដែលជាអ្នកផ្គត់ផ្គង់ភរិយានោះ ?

**សៃយីដ្** - ស្ត្រីក្នុងអ៊ីស្លាម រៀបការហើយក្តី មិនទាន់រៀបការក្តី លែងលះស្វាមីក្តី មេម៉ាយក្តី មិនចាំបាច់ប្រកបការងារឡើយដើម្បីចិញ្ចឹមជីវិត ។ បើស្ត្រីនោះនៅលីវឬលែងលះស្វាមី ឪពុកស្ត្រីទាំងនោះជាអ្នកឧបត្ថម្ភគ្រឿងទ្រទ្រង់ជីវិតស្ត្រីនោះ ។ បើឪពុកស្លាប់ បងប្អូនប្រុសជាអ្នកផ្គត់ផ្គង់គ្រឿងទ្រទ្រង់ជីវិតស្ត្រីនោះ ។ បើស្ត្រីនោះជាស្ត្រីមេម៉ាយ មរតករបស់ស្វាមីឬកូនប្រុសរបស់ស្ត្រីនោះជាមធ្យោបាយទ្រទ្រង់ជីវិតស្ត្រីនោះ ។

បើមិនគ្រប់គ្រាន់ទេ ឪពុក បងប្អូនប្រុសឬឪពុកមាឪពុកធំខាងឪពុកស្ត្រីនោះជាអ្នកឧបត្ថម្ភស្ត្រីនោះ ។ នេះមិនមានន័យថាស្ត្រីមុស្លីមមិនអាចស្វែងរកការងារបាននោះទេ ឬមិនត្រូវបន្តគោលបំណងប្រកបមុខរបរនោះទេ ។ នេះគឺជម្រើស សិទ្ធិពិសេសរបស់ស្ត្រីមុស្លីមគ្រប់រូប ។

បើស្ត្រីចង់ប្រើសិទ្ធិពឹងផ្អែកលើការជួយឧបត្ថម្ភជីវិតរស់នៅ តាមច្បាប់អ៊ីស្លាម ស្ត្រីនោះមានសិទ្ធិពេញទីធ្វើដូច្នេះបាន ។ បើស្ត្រីមានការទទួលខុសត្រូវលើខ្លួនឯង មានបំណងផ្គត់ផ្គង់ខ្លួនឯង នេះក៏អាចទទួលយកបានដែរ ។

**លោកស្រី ហ្វាត់ម៉ាស់** - ហេតុអ្វីអ៊ីស្លាមបន្ទូរឲ្យស្ត្រីដល់ថ្នាក់នេះរឿងថវិកា ?

**សេយីដ្** - អ៊ីស្លាមចាត់ទុកស្ត្រីសក្តិសមជាបុគ្គលមានកិត្តិយសនិងសក្តិសមជាបុគ្គលគួរឲ្យគោរព ។ អ៊ីស្លាមការពារសេចក្តីថ្លៃថ្នូររបស់ស្ត្រីដោយឲ្យស្ត្រីរួចផុតពីកិច្ចការធ្ងន់ដែលធ្វើឲ្យលំបាកកាយឬចិត្តដើម្បីរស់ ។ ក៏ប៉ុន្តែគោលបំណងនិងចេតនាពិតរបស់អ៊ីស្លាមនោះ គឺជួយឲ្យស្ត្រីបន្តមុខការដែលសំខាន់បំផុត ពោលគឺ ចិញ្ចឹមគ្រួសារទៀងត្រង់ គ្រួសារមានសីលធម៌ និងគ្រួសារគួរឲ្យគោរព ។

ជាទូទៅ ស្ត្រីនិងបុរសរង់ចាំថ្ងៃណាមួយនឹងបានរៀបការ មានគ្រួសារមួយ ។ ពេលស្ត្រីសម្រេចចិត្តរៀបការនិងក្លាយទៅជាមាតាមួយរូប ស្ត្រីអាចរងការផ្លាស់ប្តូរយ៉ាងវិសាមញ្ញផ្នែកកាយនិងផ្នែកចិត្ត - នេះគឺអ្វីដែលស្ត្រីមិនអាចគ្រប់គ្រងបានទេ ។ អ៊ីស្លាមគិតគូរដល់កោសល្លរបស់ស្ត្រី ហើយបានបន្ធូរឲ្យយ៉ាងសម្បើម មិនបន្ថែមបន្ទុកធ្ងន់លើស្ត្រីទេ ដោយផ្តល់ឲ្យនិងធានាលទ្ធភាពទ្រទ្រង់ជីវិត ។

មិននិយាយបញ្ឆៀងថាស្ត្រីមិនមានសមត្ថភាពគ្រប់គ្រាន់ផ្នែកចិត្ត ឬផ្នែកកាយក្នុងការចិញ្ចឹមខ្លួនឯងនោះទេ ។ ស្ត្រីខ្លះបានបញ្ជាក់ឲ្យឃើញថាអាចពុះពារលើការលំបាកបានដូចបុរសខ្លះដែរ ហើយលើសពីនោះ ស្ត្រីបានសម្តែងឲ្យឃើញថាមានលក្ខណៈជាមេដឹកនាំ ។

ទោះជាយ៉ាងណាក៏ដោយ ឯកលក្ខណៈនៃកោសល្លរបស់ស្ត្រីដាក់ស្ត្រីនៅលើឋានៈពិសេសមួយ ។ នៅក្នុងករណីច្រើន ស្ត្រីជាប់ចំណងទម្រង់រាងកាយ ដែលមិនត្រឹមតែរឹតត្បិតផ្នែកកាយទេ ថែមទាំងប៉ះពាល់ដល់អារម្មណ៍ទៀតផង ។

ស្ត្រី ជាទូទៅ មានគុណសម្បត្តិពីរដែលអស់ឡោះហ្វ៎ធ្វើឲ្យប្លែកពីបុរស ។

មួយគឺ ស្ត្រីមានសារៈសំខាន់បំផុតក្នុងការបង្កើតនិងសាយពូជមនុស្ស ។ ពីរគឺ ស្ត្រីមានរាងកាយមិនមាំមួនតែក៏មិនខ្សោយទេ ហើយមានការដឹងមុត ។ លក្ខណៈផ្ទើមនេះលើកតម្កល់ស្ត្រីលើឋានៈគ្មានពីរដែលទាមទារគោលការណ៍ដឹកនាំពិសេសពាក់ព័ន្ធនឹងជីវិតស្ត្រីនោះ ។

ធម្មតា អ៊ីស្លាមមិនតម្រូវតាមបុគ្គលទេ ។ ច្បាប់ឬបទបញ្ញត្តិស្ថិតនៅលើសុខុមាលភាពនៃសហគមន៍ ។ អ៊ីស្លាមចែងគាំទ្រថាបុរសសក្តិសមនឹងកិច្ចការក្រៅផ្ទះ ចំណែកឯស្ត្រីសក្តិសមនឹងមើលថែទាំគ្រួសារ ។

អ៊ីស្លាមមិនបង្គាប់ ឬបង្ខំអ្នកណាមួយឲ្យគោរពតាមគោលការណ៍ទាំងស្រុងទេ មានជម្រើសសម្រាប់រឿងនីមួយ ។ បើគូស្វាមីភរិយាមូលមតិគ្នាអំពីការរស់នៅ អ្នកទាំងពីមានសិទ្ធិសាងជីវិតរស់នៅតាមចិត្តចង់ដរាបណាមិនផ្ទុយនឹងបទបញ្ញត្តិអ៊ីស្លាមទេនោះ ។

**លោកស្រី ហ្វាត់ម៉ាស៊ុំ** - សេយីដ្ធបានលើកឡើងនូវចំណុចមួយគួរចាប់អារម្មណ៍ទាក់ទងនឹងជម្រើសគោលការណ៍ណែនាំ ។ ត្រូវបំភ្លឺរឿងនេះនៅពេលក្រោយ ។ សូមបែរមកចាប់អារម្មណ៍រឿងសិទ្ធិភរិយាលើស្វាមីវិញ ជាញឹកញយណាស់ គេប្រាប់ស្ត្រីមុស្លីមអំពីភារកិច្ចរបស់ភរិយាចំពោះស្វាមី ។ តើសេយីដ្ធអាចអធិប្បាយបានទេ អំពីការស្និទ្ធស្នាលផ្លូវភេទបែបណាខ្លះដែលភរិយាអាចចង់បានពីស្វាមីនោះ ?

**សេយីដ្ធ** - អ៊ីស្លាមមានពាក្យស្លោកល្បីមួយថា៖ "មិនមានការខ្មាស់អៀនទេពេលមានសំណួររឿងជំនឿ ។" មានន័យថាដាក់ឲ្យពិភាក្សាគ្រប់រឿង ។ មិនមានរឿងណាមួយត្រូវទាត់ចេញពីការពិភាក្សាទេ ទោះជាសាច់រឿងនោះមានលក្ខណៈអាថិកំបាំង មានគោលដៅពិតឬចំរូងចម្រាសប៉ុណ្ណាណាក៏ដោយ ។

អ៊ីស្លាមឆាប់ចាប់អារម្មណ៍និងឆាប់អើពើអំពីសេចក្តីត្រូវការផ្លូវកាយ និងផ្លូវចិត្តរបស់ស្ត្រីណាស់ ។ សិទ្ធិធំមួយដែលស្ត្រីមានលើស្វាមីហៅជាភាសាអារ៉ាប់ថា ហ្វាក់ អាល់-អៀរ វ៉ាល់-ឃិនស៊ី (حق العير والجنس) ពោលគឺ បំពេញកិច្ចផ្លូវកាយនិងការប្រលែងលេងមុននិងរួមភេទ ។ លោកអ្នកប្រាជ្ញថ្លែងលំអិតអំពីការស្និទ្ធស្នាលផ្លូវភេទនិងអំពីបែបបទរបស់ហ្វាក់ អាល់-អៀរ វ៉ាល់-ឃិនស៊ី ។ ខ្ញុំបាទនឹងរៀបរាប់ជូននូវហ្វាឌីស្សរបស់ព្រះសាស្តាﷺ ។

ដូចភរិយាត្រូវត្រៀមខ្លួនសម្រាប់ស្វាមីដែរ ស្វាមីក៏ត្រូវត្រៀមខ្លួនសម្រាប់ភរិយាដែរ ។ ច្បាប់ហាមស្វាមីចោលខ្លួនភរិយាលើសពីបួនខែ ។[26]

ទោះបីស្វាមីកំពុងធ្វើដំណើរក៏ដោយ ក៏ត្រូវផ្អាកដំណើរ ត្រឡប់មកផ្ទះវិញ លើកលែងតែត្រូវអាក់ខានមកបានដោយខ្លួនប្រាណតែម្តង ឧទាហរណ៍ ត្រូវជាប់ពន្ធនាគារ ។ បើភរិយាត្រូវការការស្និទ្ធស្នាលផ្លូវភេទខ្លាំង តែស្វាមីបានបោះបង់ចោលករណីយកិច្ចខ្លួន ស្វាមីនោះប្រព្រឹត្តិល្មើសច្បាប់ ។

**លោកស្រី ហ្វាត់ម៉ាស់** - សូមសៃយីដ្ធកែតម្រង់នាងខ្ញុំបើអ្វីដែលនាងខ្ញុំបានអាននោះខុស គឺៈ "បើភរិយាមិនព្រមរួមភេទជាមួយស្វាមីទេព្រោះតែឈឺក្បាល ឬអស់កម្លាំង ឬមានអារម្មណ៍មិនល្អ ទេវតានឹងដាក់បណ្តាសាភរិយានោះ ។"

**សៃយីដ្ធ** - ទោះជាភរិយាឈឺក្បាល ឈឺខ្នង ឬឈឺកន្លែងណាមួយក្នុងខ្លួនក៏ដោយ ខ្ញុំសូមបបួលប្រកួតអ្នកណាមួយឲ្យលើកឡើងនូវហ្វាឌីស្សមួយដែលអាចទុកចិត្តបាន ដែលថាបើភរិយាមិនស្រួលខ្លួននោះមិនព្រមរួម

[26] សូមមើលសៀវភៅ អាល់-តាស្ហ៊ីប (التهذيب) ជុំទី ៧ ។

ភេទជាមួយស្វាមីទេ ទេវតានឹងដាក់បណ្តាសាភរិយានោះ។ បើភរិយាមិនស្រួលខ្លួនមែន មិនធ្វើពុតទេ ចូលទៅជិតខ្លួនភរិយានោះជាអំពើដែលគ្មានការពិចារណាពីសំណាក់ស្វាមី។

សិទ្ធិស្វាមីភរិយាជាតម្រូវការ និងជាកាតព្វកិច្ចលើគូស្វាមីភរិយាទាំងពីរ។ បើភរិយាបដិសេធស្វាមីព្រោះតែខ្ជិលតែម្តង ឬព្រោះតែមិនមានអារម្មណ៍ទេនោះ ភរិយានោះមិនបំពេញកាតព្វកិច្ចអាពាហ៍ពិពាហ៍របស់ខ្លួនទេ។ ដូចគ្នាដែរ បើស្វាមីមិនព្រមរួមភេទជាមួយភរិយាទេ ស្វាមីនោះមិនបំពេញកាតព្វកិច្ចខ្លួនទេដែរ។

យើងបែរមកកាន់សាច់រឿងដើមវិញ ពាក្យអារ៉ាប់មួយថា មូដ្ហាអុបាស់ (مُدَاعَبَة)។ ពាក្យនេះរៀបរាប់អំពីរបៀបម្តាយលេងជាមួយកូន ពោលគឺដោយសេចក្តីស្រឡាញ់ ដោយប្រលែងលេង ដោយអាណិតស្រឡាញ់។ គេប្រើពាក្យនេះដែរសម្រាប់និយាយអំពីទំនាក់ទំនងរវាងស្វាមី និងភរិយា។ គេបានអនុសាសន៍ជាទមូន់ថាឲ្យស្វាមីសម្តែងនូវមនោសញ្ចេតនាចំពោះភរិយា ដោយអាកប្បកិរិយាប្រកបដោយសេចក្តីស្រឡាញ់។

មានហាឌីស្ស៍អ៊ីម៉ាំស្វ៏ឌិក្ញ صلوات الله عليه والسلام មួយដែលមានសារៈសំខាន់ គឺ៖ "អ្នកណាមួយ ក្នុងចំណោមអស់លោក ដែលទៅរកភរិយា បានស្រេចជាមួយភរិយា តែភរិយាមិនស្កប់ចិត្តទេ។ ភរិយានោះដកខ្លួនចេញពីក្រោមអ្នកនោះ បើភរិយារកបានទាសៈម្នាក់ ភរិយានោះយកទាសៈនោះ។"[27] ន័យរបស់ហាឌីស្ស៍នេះ គឺចង់បំភ្លឺស្វាមីអំពីសារៈសំខាន់នៃការបំពេញសេចក្តីត្រូវការរបស់ភរិយាមុនដកខ្លួនចេញពីភរិយានោះ។

---

[27] សូមមើលសៀវភៅ مَنْ لَا يَحْضُرُهُ الْفَقِيه ជុំទី ៣ ទំព័រ ៣៦៤។

**លោកស្រី ហ្វាត់ម៉ាស់** - ហេតុអ្វីយកទាសៈជាសំអាង ។

**សៃយីដ** - ទាសៈភាពតែងតែមានមុនសម័យព្រះសាស្តាﷺ ក្នុងសម័យព្រះសាស្តាﷺនិងក្រោយសម័យព្រះសាស្តាﷺ ។ ទោះជាទាសៈភាពកំពុងតែត្រូវលុបបំបាត់ដោយអ៊ីស្លាមក្តី វានៅតែមានអស់មួយរយៈពេលតូចក្រោយសម័យព្រះសាស្តាﷺ ។ ទាសៈមិនមានសិទ្ធិឬយសស័ក្តិដូចមនុស្សមានសេរីភាពទេ ។ អាស្រ័យហេតុនេះឯងបានជាគេមើលមកទាសៈជាពលរដ្ឋថ្នាក់លេខពីរ (គឺថ្នាក់អន់) ។

លើកទាសៈជាសំអាងដើម្បីបញ្ជាក់ថា ពេលគូស្វាមីភរិយារួមភេទ ស្វាមីបានស្កប់ស្កល់ចិត្ត ទុកចោលភរិយាដែលមិនស្កប់ចិត្តទេ ដូច្នេះ សំខាន់គឺស្វាមីនោះបានចោលភរិយាក្នុងសភាពទន់ខ្សោយ ហើយនៅក្នុងសភាពទន់ខ្សោយនេះ ភរិយានោះខំប្រឹងធ្វើឲ្យខ្លួនឯងអាចស្កប់ស្កល់បានជាមួយបុរសដទៃ ទោះជាបុរសថ្នាក់អន់ក៏ដោយ ដូចតួយ៉ាងទាសៈនៅក្នុងហ្វាឌីស្ស៍ដែរ ។

អ៊ីម៉ាំស្វ៊ឌិក្វ صلوات الله عليه والسلام មានវចនៈថា៖ "ពេលស្វាមីរួមភេទជាមួយភរិយា ចូរស្វាមីនោះកុំទៅរកភរិយាដូចសត្វស្លាប ពោលគឺ វាយហើយរត់គេចបាត់ ។ ស្វាមីត្រូវបន្ថយទាល់តែភរិយាបានសម្រេចសេចក្តីត្រូវការ ។"[28]

ថ្ងៃមួយព្រះសាស្តាﷺមានព្រះវចនៈថា៖ "ពេលបុរសទៅរកភរិយា បុរសនោះមិនត្រូវប្រញាប់ប្រញាល់ទេ លុះត្រាតែភរិយាស្កប់ស្កល់សិនព្រោះ

[28] សូមមើលសៀវភៅ أصول الكافي ជុំទី ៥ ។

ស្ត្រីមានសេចក្តីត្រូវការ ។"[29]

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "បើបុរសមានភរិយាច្រើន មិនបានប៉ះពាល់ខ្លួនភរិយានោះទេ ហើយភរិយានោះប្រព្រឹត្តិអំពើផិតក្បត់ បាប[ធំ] និងធ្លាក់លើបុរសព្រោះបុរសនោះមិនបានបំពេញករណីយកិច្ចខ្លួនទេ ។"[30]

សិទ្ធិលើស្វាមីមួយទៀតដែលភរិយាចង់បាននោះគឺ ស្វាមីត្រូវស្អាតខ្លួន ។ បានសេចក្តីថាខ្លួនស្វាមីនោះត្រូវស្អាត រោមមុខត្រូវកាត់ឲ្យសមរម្យ មានក្លិនល្អ មានសំលៀកបំពាក់ស្អាតបាត ។ល ។ អ៊ីម៉ាំរីដ្ឋ៍صلوات الله عليه والسلام[31]មានវចនៈតមកពីព្រះសាស្តាﷺថា៖ "ស្ត្រី បានី អ៊ីសរ៉ាអ៊ីល បានលំអៀងចេញពីមាគ៌ាព្រហ្មចរិយភាពព្រោះស្វាមីខ្លួនមិនបារម្ភអំពីការសម្អាតខ្លួន និងអំពីអាការក្រៅខ្លួនឲ្យល្អប្រពៃទេ ។ អ្វីដែលអស់លោកចង់បានពីភរិយា ភរិយាក៏ចង់បានអ្វីនោះពីអស់លោកដែរ ។"[32]

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "អស់លោក ដែលជាបុរស ត្រូវតែរៀបចំខ្លួនឲ្យមានរបៀបនិងត្រៀមខ្លួនសម្រាប់ភរិយាអស់លោក ឲ្យដូចអស់លោកចង់ឲ្យភរិយាអស់លោកត្រៀមខ្លួនសម្រាប់អស់លោកនោះដែរ ។"[33]

ថ្ងៃមួយបុរសម្នាក់បាននិយាយប្រាប់បុរសម្នាក់ទៀត នូវព្រឹត្តិការណ៍មួយដែលបានកើតឡើងរវាងគាត់និងអ៊ីម៉ាំអាុលីصلوات الله عليه والسلام ថា៖ "ខ្ញុំបានឃើញអ៊ីម៉ាំ

---

[29] សូមមើលសៀវភៅ أصول الكافي ជុំទី ៥ ។

[30] សូមមើលសៀវភៅ أصول الكافي ជុំទី ៥ ។

[31] អាុលី អាល់-រីដ្ឋ៍ ជាអ៊ីម៉ាំទី ៨ ក្នុងចំណោមសន្តតិវង្សអាស្ល់លុល-បៃត៍ទាំង ១២ អង្គعليهم السلام ។

[32] សូមមើលសៀវភៅ ប៊ីហ្ារ អាល់-អាន់វ៉ារ (بِحَار ٱلْأَنْوَار) ជុំទី ៧៦ ទំព័រ ១០២ ។

[33] សូមមើលសៀវភៅ مُستَدرَكُ الوَسائل ជុំទី ២ ទំព័រ ៥៥៩ ។

អ៊ាលីصلوات الله عليه والسلامលាបសក់ ។ ខ្ញុំបានសួរព្រះអង្គصلوات الله عليه والسلامថាព្រះអង្គصلوات الله عليه والسلامបានលាបពិតមែនឬទេ ។ អ៊ីម៉ាំអ៊ាលីصلوات الله عليه والسلامមានវចនៈថា៖ "មែន ។ បុរសដែលសំអិតសំអាងខ្លួន ដើម្បីភរិយាខ្លួននោះជួយឲ្យភរិយានោះរក្សាព្រហ្មចរិយភាព ។ ស្ត្រីដែលលំអៀងចេញពីមាគ៌ាព្រហ្មចរិយភាពនោះ បានប្រព្រឹត្តិខ្លួនដូច្នេះដោយសារការមិនអើពើនិងកំហុសរបស់ស្វាមី ។ តើលោកចង់ឃើញភរិយាលោកមិនស្អាតបាតទេ ?" បុរសនោះបានតបថា៖ "ទេ ។" អ៊ីម៉ាំអ៊ាលីصلوات الله عليه والسلامមានវចនៈថែមថា៖ "ភរិយាគិតដូចលោកដែរ ។"[34]

សិទ្ធិទីបីដែលភរិយាចង់បានពីស្វាមីនោះគឺ មូស្ជាយ៉ាអ៊ាស់ ភាពជាគូកននិងការសេពគប់ជិតស្និទ្ធមួយប្រភេទ ។ បានសេចក្តីថាស្វាមីចំណាយពេលយប់នៅជាមួយភរិយា មិនចាំបាច់រួមភេទជាមួយភរិយាទេ តែនៅជាមួយគ្នាក្នុងគ្រែតែមួយ ។

ក្រោយបង្អស់ ដូចគួរអានចែងយ៉ាងពីរោះថា៖

وَعَاشِرُوهُنَّ بِٱلْمَعْرُوفِ ۚ

*ចូរពួកអ្នករស់នៅជាមួយពួកនាងដោយវិធីល្អប្រពៃនិងសមធម៌ (៤:១៩) ។*

អាយ៉ាស់នេះអធិប្បាយបំភ្លឺដោយខ្លួនឯង និងចែងយ៉ាងមាំមួនដល់ការប្រព្រឹត្តិរាល់លក្ខណៈចំពោះស្ត្រី ។

**លោកស្រី ហ្វាត់ម៉ាស់** - តាំគីន ឬ ហាក់ អ៊ីសទីមតាក់ (حق استمتاع) គឺភរិយាត្រៀមខ្លួនសម្រាប់ស្វាមី ។ ទាំងនេះគឺសិទ្ធិដែលស្វាមីអាចស្នើឲ្យភរិយាគោរព ។ តើសៃយីដូអាចអធិប្បាយបំភ្លឺលក្ខណៈរបស់សិទ្ធិទាំងនេះបានទេ ?

[34] សូមមើលសៀវភៅ وسائل الشيعة ជុំទី ១៤ ទំព័រ ១៨៣ ។

**សែយីដ្** - ការប្រតិបត្តិសំខាន់បំផុតមួយរបស់ភរិយាក្នុងអាពាហ៍ពិពាហ៍គឺ តាំគីន ឬ ហ្វាក់ អ៊ីសទីមតាក់ (حق استمتاع) ។ នេះគឺពេលភរិយាត្រៀមខ្លួន រៀបចំខ្លួនស្អាតបាតនិងគួរឲ្យស្រឡាញ់សម្រាប់ស្វាមី ។

តែមានករណីលើកលែងក្នុងច្បាប់នេះ ដូចជាពេលភរិយាមានរដូវខែ ក្រោយពីសម្រាលកូនរួច ពេលឈឺ ពេលបំពេញពិធីហាជ្ជ់ ពេលកាន់សីលត្រណមនិងពេលស្វ៍ឡាត់ហ្វារឌូ ជាដើម ។ ពុំនោះទេ (គឺក្រៅពីករណីនេះ) ភរិយាត្រូវត្រៀមខ្លួននិងចិត្តសម្រាប់ស្វាមី ។

ថ្ងៃមួយ ស្ត្រីម្នាក់បានមកជួបព្រះសាស្តាﷺ ដើម្បីប្តឹងអំពីស្វាមីគាត់ ។ បន្ទាប់ពីបានស្តាប់ពាក្យបណ្តឹងស្ត្រីនោះ ព្រះសាស្តាﷺបានសម្រេចថាស្ត្រីនោះមានកំហុសមួយប៉ែក ។ ព្រះអង្គﷺមានវចនៈថា៖ "ប្រហែលជាលោកស្រីជាអ្នកបន្លាយ ។" ស្ត្រីបានសួរថា៖ "អ្នកបន្លាយគឺអ្នកណា ?" ព្រះសាស្តាﷺបានតបថា៖ "អ្នកបន្លាយគឺភរិយាដែលស្វាមីស្នើសូមឲ្យនៅជាមួយខ្លួន តែភរិយានោះបន្លាយពេលទាល់តែស្វាមីនោះជិនណាយ ហើយក៏ដេកលក់ ។"[35]

ហាឌីស្ទនេះមានន័យជ្រៅ ។ ជួនកាលស្ត្រីរវល់នឹងការផ្ទះ រវល់នឹងប្រកបអាជីពឬកិច្ចការសង្គមពេលស្វាមីត្រូវការរួមរ័កជាមួយភរិយា តែភរិយាទុកចោលស្វាមីនោះ ។ ថ្វីបើការមួយចំនួននេះជាការសំខាន់ក្តី តែវាមិនស្មើនឹងទំនាក់ទំនងដែលភាគីម្ខាងត្រូវមានជាមួយភាគីម្ខាងទៀតដែរ ។ សូមរំលឹកថាអាពាហ៍ពិពាហ៍ជាសម្ព័ន្ធរវាងដៃគូទាំងពីរ (គឺស្វាមីនិងភរិយា) ។

---

35 សូមមើលសៀវភៅ أصول الكافي ជុំទី ៥ ។

ស្រដៀងគ្នាដែរ អនុសាសន៍រាយរាប់សម្រាប់សិទ្ធិស្វាមីនៅក្នុងតាំគីននោះស្មើនឹងសិទ្ធិភរិយានៅក្នុងហ្វាក់ អាល់-អៀរវ៉ាស់ អាល់-យ៉ូនស៊ី ។ ភរិយាត្រូវសំអិតសំអាងខ្លួនសម្រាប់តែស្វាមីមួយគត់ ឧទាហរណ៍ ងូតទឹក ផាត់ម្សៅមុខ លាបគ្រឿងក្រអូប ពាក់គ្រឿងអលង្ការនិងស្លៀកពាក់គួរឲ្យទាក់ទាញចិត្ត ។ ទោះបីស្វាមីជាមនុស្សពិការភ្នែកមើលមិនឃើញឬថ្លង់ក៏ដោយ តែឃានវិញ្ញាណ (ការធុំក្លិន) និងកាយវិញ្ញាណ (ការប៉ះ) មានកម្រិតខ្ពស់លើសធម្មតា ។

ហ្វាក់ អាល់-ម៉ាអ៊ីយ៉ាស់ (គឺគ្រឹះពិតនៃទំនាក់ទំនងមាំ) គឺភាពជាគូកនគ្នា និងមិត្តភាពមួយប្រភេទ ។ ស្វាមីត្រូវស្នើសូមឲ្យភរិយានៅអមជាមួយខ្លួន ឬនៅផ្ទះពេលខ្លួនមកដល់ផ្ទះ ឬនៅជាមួយគ្នាពេលយប់ ។

នេះគឺសិទ្ធិដែលស្វាមីប្រើទៅលើភរិយា ហើយភរិយាប្រើទៅលើស្វាមី ទៅវិញទៅ ដូចគ្នាបាន ។ សម្រាប់គូស្វាមីភរិយាខ្លះសិទ្ធិនេះមិនស្រួលអនុវត្តទេ ឬកម្រយកមកអនុវត្ត ឬមិនចាំបាច់និយាយដល់ទេ ។ តែសម្រាប់គូស្វាមីភរិយាឯទៀត សិទ្ធិនេះជាគ្រឹះនៃទំនាក់ទំនងរបស់ពួកគេ ។

អ៊ីស្លាមមិនបង្ខំឲ្យគូស្វាមីអនុវត្តសិទ្ធិទាំងអស់ដោយត្រង់ៗ តាមពាក្យទេ ។ អ៊ីស្លាមចែងសិទ្ធិទាំងនេះក្រៅលោមិនស្របគ្នា មិនចុះសម្រុងគ្នា ឬជាការដឹកនាំដើម្បីឲ្យឱវាទ ដើម្បីបង្ហាញទិសដៅ ដើម្បីផ្ដែផ្ដាំ ឬដើម្បីដោះស្រាយបញ្ហាខ្លះ ។ បុគ្គលម្នាក់ៗ មុនធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍មានសិទ្ធិយល់ព្រមឬបដិសេធសិទ្ធិណាមួយក៏បាន ។

**លោកស្រី ហ្វាត់ម៉ាស់** - សៃយីដ្ឋមានប្រសាសន៍មុននេះថាស្ត្រីមានជម្រើសគោលការណ៍ណែនាំ ។ តើសៃយីដ្ឋមានប្រសាសន៍ថាសិទ្ធិដែលសៃយីដ្ឋបានលើកឡើងខាងលើនេះជាសិទ្ធិឥតបង្ខំមែនទេ ?

**សៃយីដុ** - ពេលធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ សិទ្ធិទាំងឡាយដែលបានពោលហើយនោះត្រូវសន្មតថារាប់បញ្ចូល ក្នុងកិច្ចព្រមព្រៀងនោះស្រេចហើយ ។ គូស្វាមីភរិយាមិនត្រូវពិនិត្យសើរើឡើងវិញគ្រប់សិទ្ធិទាំងនោះហើយយល់ព្រមជាចាំបាច់នោះទេ ។ សិទ្ធិទាំងនោះត្រូវកំណត់ជាកម្មវិធីស្រេចហើយ ដើម្បីការពារសិទ្ធិរបស់គូស្វាមីនៅក្នុងអាពាហ៍ពិពាហ៍ ឬដើម្បីដាក់កំហិតឲ្យគោរពសិទ្ធិទាំងនោះ ។ តែអ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ បើភាគីណាមួយ ឬភាគីទាំងពីរតែម្តង ចង់ផ្លាស់ផ្តូរឬលះបង់ចោលសិទ្ធិអាពាហ៍ពិពាហ៍មួយចំនួន ដោយបានទទួលការយល់ព្រមពីភាគីមួយទៀត ពួកគេមានសិទ្ធិធ្វើដូច្នេះបាន ។

**លោកស្រី ហ្វាត់ម៉ាស់** - នាងខ្ញុំសន្និដ្ឋានថាច្បាប់គួរអានជួសជានិច្ចការកែប្រែឬការផ្លាស់ដោយមនុស្ស ។

**សៃយីដុ** - ការពិត ច្បាប់គួរអានមិនអាចផ្លាស់ប្តូរឬបោះបង់ចោលបានជាដាច់ខាត តែសិទ្ធិអាចផ្លាស់ប្តូរឬបោះចោលបាន ។ នៅក្នុងអ៊ីស្លាមមានច្បាប់ដំណើរការនិងចរិយាធម៌ផ្សេងៗពីរ ។ មួយហៅថា ហ៊្វកុម (حكم) មួយទៀតហៅថា ហ៊ាក់ (حقّ) ។

ហ៊្វកុមគឺការវិនិច្ឆ័យ ពោលគឺ បទបញ្ញត្តិរបស់ព្រះ គឺព្រះបញ្ជាដែលអល់ឡោះហ្វ៍عز وجلដាក់មក ។ ពុំមានអ្នកណាមួយអាចបំភ្លៃ ផ្លាស់ប្តូរ បោះបង់ចោលឬពន្យារបានជាដាច់ខាត ។ ឧទាហរណ៍ ការទទូរក្បាល គេមិនត្រូវគាំទ្រឡើយថាក្នុងសម័យយើងនេះ ឬព្រោះតែស្ត្រីរស់នៅក្នុងតំបន់នេះស្ត្រីមិនត្រូវទទូរក្បាលទេ ឬស្វាមីរបស់ស្ត្រីនោះមិនចង់ឲ្យស្ត្រីនោះទទូរក្បាលទេ ។

ការទទូរក្បាលមិនអាស្រ័យលើបុគ្គលណាម្នាក់ឡើយ ព្រោះតែបុគ្គលនោះប្រុសឬស្រី មិនឃើញមានហេតុផល ។ ការទទូរក្បាលការទង្វើចាំបាច់ ជាបទបញ្ញត្តិដាក់មកដោយអល់ឡោះហ្វ៍ ។ ពុំមានអ្នកណាមួយអាចបំពានច្បាប់បែបនេះបានឡើយ ដូចស្ម័ឡាត់ សីលកាន់ត្រណម បរិច្ចាគទាន ធ្វើពិធីហ្វាច់ មិនផឹកគ្រឿងស្រវឹងឬលេងល្បែងស៊ីសង ។ល ។ នោះដែរ ។ ទាំងនេះគឺបទបញ្ញត្តិ ច្បាប់ដែលមុស្លីមគ្រប់រូបត្រូវអនុវត្តិ ។

ហ្វាក្ញ នៅក្នុងវិស័យច្បាប់អាពាហ៍ពិពាហ៍និងការទទួលខុសត្រូវនោះ ក៏ត្រូវចាត់ទុកជាច្បាប់ចាំបាច់ដែរដែលអាចបំភ្លៃ អាចបដិសេធ អាចផ្លាស់ប្តូរឬដាក់លក្ខខណ្ឌបាន ឲ្យតែភាគីទាំងពីរ (គឺស្វាមីនិងភរិយា) យល់ព្រមហើយការផ្លាស់ប្តូរនេះមិនប្រឆាំងនឹងច្បាប់អ៊ីស្លាមទេ (ស្ហារីអ៊ុស្ញ) ។ ត្រង់នេះហើយដែលគួរអានមានព្រហ្មវិហារធមិដ៏ទូលំទូលាយនោះ ។ គួរអានបើកសេរីភាពឲ្យមនុស្សអាចរស់នៅតាមចិត្តបាន ។

សិទ្ធិអាពាហ៍ពិពាហ៍រាយរាប់ខាងលើនេះ មិនមែនមិនអាចបំបែកបានទេ អាចផ្លាស់ប្តូរបាន ។ ច្បាប់អ៊ីស្លាម (ស្ហារីអ៊ុស្ញ) អនុញ្ញាតឲ្យគូស្វាមីភរិយាដាក់ខបាន ឲ្យដាក់កិច្ចសន្យាបាន ឬអាចលះបង់ចោលមួយប៉ែកណាមួយនៃលក្ខខណ្ឌអាពាហ៍ពិពាហ៍នោះបានឲ្យតែអ្នកទាំងពីរយល់ព្រមមូលមតិគ្នា ហើយការផ្លាស់ប្តូរនោះមិនប្រឆាំងនឹងច្បាប់អ៊ីស្លាមទេ ។

អល់ឡោះហ្វ៍ចង់ឲ្យមនុស្សមានជីវិតរស់នៅ ដែលស្ថិតនៅលើការពឹងពាក់គ្នាទៅវិញទៅមកនៅក្នុងរង្វង់ច្បាប់ (ហ្វ៊ុកុម) ដែលត្រូវដាក់មកនោះ ។ អល់ឡោះហ្វ៍មិនចង់ដាក់បង្គាប់លើមនុស្ស ថាត្រូវរស់នៅត្រង់ៗនោះទេ ។ អល់ឡោះហ្វ៍ចង់ឲ្យគូស្វាមីភរិយាយល់ស្របមូលមតិគ្នាអំពីអ្វីដែលកំណត់ឲ្យមានរបៀបរស់នៅត្រឹមត្រូវបំផុត ។ ការយល់ស្របមូលមតិគ្នាសហាប្រតិបត្តិការនិងផលប្រយោជន៍រួមនោះ គឺអ្វីដែលអាចកសាងទំនាក់

ទំនងល្អនិងឋិតថេរបាន ។

គេផ្តាំផ្ញើយ៉ាងខ្លាំងថាមុនអាពាហ៍ពិពាហ៍ ឲ្យគូស្វាមីភរិយាព្រមព្រៀងគ្នារឿងដែលខ្លួនចាត់ទុកថាសំខាន់និងទាក់ទង ។ បើគូស្វាមីភរិយាព្រមព្រៀងគ្នា ហើយការព្រមព្រៀងនោះនៅក្នុងរង្វង់ច្បាប់អ៊ីស្លាម មិនចាំបាច់និយាយដល់សិទ្ធិអាពាហ៍ពិពាហ៍ចែងរួចមកហើយនោះទេ ។ លោកអ្នកប្រាជ្ញនិយាយដល់សិទ្ធិអាពាហ៍ពិពាហ៍នេះ តែពេលណាដែលគេសន្មត់ថាគូស្វាមីភរិយាបានយល់ព្រមគោរពសិទ្ធិទាំងនេះហើយ តែបន្ទាប់មកភាគីណាមួយ (ឬភាគីទាំងពីរ) បំពានសិទ្ធិនោះ ។

ឧទាហរណ៍ មានករណីច្រើនដែលភរិយាខ្លះ ជាពិសេសស្ត្រីវ័យចំណាស់បានដាក់ខលក្ខខណ្ឌអាពាហ៍ពិពាហ៍ថាមិនរួមភេទជាមួយស្វាមីទេ ។ បើបុរសយល់ព្រម កិច្ចព្រមព្រៀងនឹងត្រឹមត្រូវតាមរបៀប ។ ទោះបីវាខុសធម្មតាក៏ដោយ តែស្ត្រីមានសិទ្ធិដាក់លក្ខខណ្ឌបែបនេះ ឲ្យតែបុរសយល់ព្រម ។

គោលបំណងអាពាហ៍ពិពាហ៍របស់ស្ត្រីអាចពុំមែនដើម្បីខ្លួនឯង ។ អាពាហ៍ពិពាហ៍អាចជាកិច្ចព្រមព្រៀងធុរកិច្ច ជាការមានសិទ្ធិចូលរួមក្នុងសង្គម ឬជាសុវត្ថិភាពមួយប្រភេទ ។ ស្ត្រីមានសិទ្ធិដាក់លក្ខខណ្ឌបែបនេះនិងលក្ខខណ្ឌផ្សេងៗទៀត ឲ្យតែទាំងពីរភាគីយល់ព្រមមូលមតិគ្នានឹងការផ្លាស់ប្តូរនោះ ហើយការផ្លាស់ប្តូរនោះមិនប្រឆាំងនឹងច្បាប់អ៊ីស្លាមទេ (គឺមិនរឹតបន្តឹងទេ) ។

ឧទាហរណ៍មួយទៀត បុរសដែលចង់រៀបការអាចដាក់លក្ខខណ្ឌលើស្រីបាន ។ បុរសនោះអាចប្រាប់ស្ត្រីថា៖ "ខ្ញុំនឹងរៀបជាមួយអ្នក ឲ្យតែអ្នកយល់ព្រមទទួលយកផ្ទះធុនកណ្តាលនេះជាផ្ទះអ្នក ព្រមទទួលយករថយន្តមិន

ស្ងួរស៊ីសាំងនេះជារថយន្តរបស់អ្នក និងព្រមទទួលយកប្រាក់ចំនួនប៉ុននេះជាប្រាក់ប្រចាំខែរបស់អ្នក ។" បើស្ត្រីយល់ព្រម កិច្ចសន្យានោះនឹងរៀបរយតាមរបៀប ទោះបីបុរសនោះមានសមត្ថភាពផ្តល់ឲ្យស្ត្រីនោះនូវជីវភាពរស់នៅប្រសើរជាងនេះតែមិនព្រមធ្វើដូច្នេះក៏ដោយ អាចមកពីមូលហេតុផ្ទាល់ខ្លួនក៏អាចថាបាន ។

ឧទាហរណ៍ បុរសនោះអាចខ្លាចថាស្ត្រីនឹងបោះបង់ខ្លួនចោលថ្ងៃណាមួយ ឬថាស្ត្រីនោះប្រើប្រាស់ប្រាក់នេះ ឬគ្រឿងទ្រទ្រង់ជីវិតនេះទៅលើសាច់ញាតិខ្លួន ។ បុរសមានសិទ្ធិអភិរក្សនិយមឬប្រយ័តប្រយែងក្នុងការចាយវាយ ។

**លោកស្រី ហ្វាត់ម៉ាស់** - សៃយីដ្ធមានប្រសាសន៍មែនទេថាមានគោលសំខាន់ធំដែលដឹកនាំច្បាប់នៃជីវព្រឹត្តិរបស់បុគ្គល ?

لِيُنفِقْ ذُو سَعَةٍ مِّن سَعَتِهِۦۖ وَمَن قُدِرَ عَلَيْهِ رِزْقُهُۥ فَلْيُنفِقْ مِمَّآ ءَاتَىٰهُ ٱللَّهُۚ

*បុគ្គលណាដែលមានទ្រព្យធន ចូរចាយវាយតាមទំហំទ្រព្យធនរបស់ខ្លួន ។ រីឯបុគ្គលណាដែលមានទ្រព្យធនស្តួចស្តើង ចូរចាយវាយតាមដែលអល់ឡោះប្រទានឲ្យអ្នកនោះចុះ (៦៥:៧) ។*

អាយ៉ាស់នេះជាបទបញ្ញត្តិ (ហ៊្វុកុម) មែនទេ ? តើអាយ៉ាស់នេះមិនការពារស្ត្រីពីបុរសកំណាញ់ទេ ?

**សៃយីដ្ធ** - អាយ៉ាស់ដែលលោកស្រីលើកមកនិយាយនេះជាបទបញ្ញត្តិពិសេសចែងនៅក្នុងគួរអាន ក្នុងស៊ូរ៉ោះត៍ "អាត់-ត៍ឡាក់" ដែលដាក់បញ្ជាឲ្យស្វាមីផ្គត់ផ្គង់ជីវព្រឹត្តិដល់អតីតភរិយារបស់ខ្លួនដែលកំពុងចិញ្ចឹមកូនតូច

ដែលមិនទាន់ដាច់ដោះ ។ ក៏ប៉ុន្តែអាយ៉ាស្ទុនេះអាចដាក់ឲ្យអនុវត្តិទៅលើច្រើនវិស័យនៃជីវិតដែរ ឧទាហរណ៍ ការចាយវាយសម្រាប់គូស្វាមីភរិយា ។

អាយ៉ាស្ទុនេះជាបទបញ្ញត្តិ តែអាយ៉ាស្ទុនេះពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដែលមិនមានការផ្លាស់ប្តូរ មិនមានកិច្ចសន្យា មិនមានលក្ខខណ្ឌ និងមិនមានការកែប្រែ នោះដែរ ។ អាយ៉ាស្ទុនេះទាក់ទងនឹងកិច្ចព្រមព្រៀងរបស់អាពាហ៍ពិពាហ៍ធម្មតាដែលគេពុំបានធ្វើកិច្ចសន្យាទេ ហេតុដូច្នេះ គេសន្មត់ថាសិទ្ធិសាមញ្ញត្រូវដាក់ឲ្យប្រើនៅក្នុងអាពាហ៍ពិពាហ៍នោះ ។

បើយើងលើកយកឧទាហរណ៍ខាងលើនោះ ដែលបុរសចង់រៀបការតែបានដាក់លក្ខខណ្ឌមុនធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ។ ការពិតបុរសនេះដាក់ជម្រើស ឲ្យស្ត្រីអាចជ្រើសយករៀបការដោយព្រមទទួលយកលក្ខខណ្ឌបាន អាចមិនរៀបការជាមួយខ្លួនបាន ។

បុរសនោះមិនបានដាក់កំហិត ក្រោយពីបានធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ទេ តែគាត់បាននិយាយមុន ។ ស្ត្រីមិនចាំបាច់ត្រូវតែរៀបការជាមួយបុរសបែបនេះឡើយ ។ ស្ត្រីមានសិទ្ធិព្រមទទួលលក្ខខណ្ឌបែបនេះ ឬមានសិទ្ធិបដិសេធការស្នើនេះ ។

**លោកស្រី ហ្វាត់ម៉ាស្ទុ** - នៅពេលធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ គេសន្មត់ថាភាគីទាំងពីរមានសិទ្ធិដែលខ្លួនត្រូវបាននោះស្រេចហើយ ទោះបីភាគីទាំងពីរមិនស្គាល់សិទ្ធិ (ហ្ញាក់្ញ) ដែលខ្លួនចង់បាននោះក៏ដោយ ត្រូវទេ ?

**សៃយីដ្** - ត្រូវ ។ ចាប់ពីបានធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ដែលច្បាប់ដាក់មកនោះភ្លាម គេបានយល់ព្រមទទួលយកសិទ្ធិ (ហ្ញុគ្មុក្វ) ទាំងអស់

ភ្លាមដោយស្វ័យប្រវត្តិ ទោះបីភាគីណាមួយ (ឬភាគីទាំងពីរ) មិនស្គាល់សិទ្ធិទាំងនោះយ៉ាងល្អិតល្អន់ក៏ដោយ ។

**លោកស្រី ហ្វាត់ម៉ាស់** - ប្រសិនបើគូស្វាមីភរិយាសម្រេចចិត្ត ពួកគេអាចថែម ឬលុបសិទ្ធិ (ហ៊ាគ្កុក) ចោលបាន ត្រូវទេ ?

**សៃយីដ** - បើការផ្លាស់ប្តូរនោះនៅក្នុងរង្វង់សាសនា ហើយបុគ្គលម្នាក់ៗយល់ព្រម ។ ដរាបណាប្រការនោះមិនត្រូវសាសនាហាមទេ ដរាបនោះគូស្វាមីភរិយាអាចថែមឬលុបចោលប្រការណាមួយក៏បាន ដែលខ្លួនចង់នោះ ។

**លោកស្រី ហ្វាត់ម៉ាស់** - គូរអានបានថែងហើយថាបុរសដែលមានសមត្ថភាពត្រូវតែឧបត្ថម្ភឲ្យតាមសមត្ថភាពនោះ ។ តើលោកអ្នកប្រាជ្ញដឹងបានដូចម្តេចថាអាយ៉ាស់ណាមួយជាអាយ៉ាស់ដាក់បញ្ញត្តិ ឬជាអាយ៉ាស់រឹតបន្តឹង (ហ៊ូកុម) ថាជាអាយ៉ាស់ដែលអនុញ្ញាតឲ្យកែប្រែ (ហាក់) ?

**សៃយីដ** - ដំបូង លោកអ្នកប្រាជ្ញវែកញែកឲ្យឃើញខុសគ្នារវាងបទបញ្ញត្តិដែលជាកាតព្វកិច្ច (ហ៊ូកុម) ដូចជាស្ហ៊ូឡាត់ សីលត្រណម បរិច្ចាគទាន ជាដើម និងសិទ្ធិមួយចំនួន (ហាក់) ដែលគេអាចកែប្រែបានពេលសិទ្ធិទាំងនោះផ្អែកលើកិច្ចព្រមព្រៀងរវាងបុគ្គល ដូចជាអាពាហ៍ពិពាហ៍ ការលែងលះគ្នា ឬកិច្ចសន្យាក្នុងធុរកិច្ច ។

ឧទាហរណ៍អាយ៉ាស់

ٱلرِّجَالُ قَوَّٰمُونَ عَلَى ٱلنِّسَآءِ

*បណ្តាបុរសជាអ្នកថែរក្សាបណ្តាស្ត្រី (៤:៣៤) ។*

អាយ៉ាស់នេះដាក់បន្ទុកលើស្វាមីឲ្យទទួលខុសត្រូវផ្នែកចាយវាយ និងថែទាំភរិយាខ្លួន ។ តែអាយ៉ាស់នេះមិនមែនជាកាតព្វកិច្ចខានមិនបាននោះទេ (ហ្វ៊ូកុម) វាជាសិទ្ធិ (ហ្វាក់) ។ ឧទាហរណ៍ បើស្ត្រីមានទ្រព្យសុខចិត្តទ្រទ្រង់ស្វាមី ស្ត្រីនោះអាចធ្វើដូច្នេះបាន ។ អ៊ីស្លាមមិនហាមឃាត់ស្ត្រីនោះ មិនឲ្យទ្រទ្រង់ស្វាមីខ្លួនដោយថវិកាទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើស្ត្រីអាចដាក់លក្ខខណ្ឌបានទេថាកុំឲ្យស្វាមីខ្លួនមានភរិយាទីពីរ ?

**សៃយីដ** - ស្ត្រីមានសិទ្ធិយកច្បាប់បែបនេះមកប្រើបាន ឲ្យតែស្វាមីគាត់យល់ព្រម ។

**លោកស្រី ហ្វាត់ម៉ាស់** - តែសៃយីដមានប្រសាសន៍ថាការធ្វើលក្ខខណ្ឌនោះមិនត្រូវប្រឆាំងនឹងទ្រឹស្តីសាសនាទេ តែអ៊ីស្លាមអនុញ្ញាតឲ្យបុរសអាចមានភរិយាដល់ទៅបួននាក់បាន ។

**សៃយីដ** - ពាក្យគន្លឹះគឺអនុញ្ញាត បានសេចក្តីថាបើកសិទ្ធិឲ្យ ។ សំខាន់គឺត្រូវដឹងថារៀបការជាមួយភរិយាទីពីរមិនមែនជាការចាំបាច់ (វ៉ាយ៉ិប) ទេ គេអនុញ្ញាតឲ្យធ្វើបែបនេះបាន (មូបាស់ ٤٥)។ ការចេញច្បាប់ដែលជាកាតព្វកិច្ចខុសគ្នានឹងទង្វើដែលគេអនុញ្ញាត ។ ប្រសិនបើការមានភរិយាច្រើនជាកំហិតចាំបាច់នោះមែន គេប្រាកដជាមិនបើកសិទ្ធិឲ្យស្ត្រីដាក់លក្ខខណ្ឌរឹតបន្តឹងបែបនេះទេ ។

ពេលភរិយាដាក់លក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ថាគាត់មិនចង់ឲ្យស្វាមីគាត់រៀបការជាមួយភរិយាម្នាក់ទៀតទេនោះ ជាសំខាន់

គាត់បានថ្លែងថាៈ "ដរាបណាលោកនៅតែរៀបការជាមួយខ្ញុំ ដរាបនោះ លោកមិនត្រូវធ្វើទង្វើដែលគេអនុញ្ញានេះទេ ។ បើលោកចង់រៀបការ ជាមួយភរិយាម្នាក់ទៀត លោកត្រូវលែងលះខ្ញុំជាមុនសិន ។" ស្ត្រីនោះមិន បានថ្លែងថាស្វាមីគាត់មិនត្រូវរៀបការជាមួយស្ត្រីផ្សេងនោះទេ ។

ស្ត្រីជាភរិយានោះមិនបានសារភាពទេថាគេហាម (ហ្វារ៉ាំ) ស្វាមីធ្វើបែប នេះ តែគេអនុញ្ញាតឲ្យធ្វើបែបនេះបាន (ហ្វាឡាល់) ។ ស្វាមីអាចរៀបការ ជាមួយស្ត្រីមួយទៀតបាន តែកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍របស់ស្ត្រីជា ភារិយានោះចែងថាបើស្វាមីចង់រៀបការជាមួយស្ត្រីមួយទៀត ស្វាមីនោះ ចាំបាច់ត្រូវតែលែងលះស្ត្រីជាភរិយានោះជាមុនសិន ។

**លោកស្រី ហ្វាត់ម៉ាស់** - ពេលគូស្វាមីភរិយាកែប្រែកិច្ចព្រមព្រៀងអាពាហ៍ ពិពាហ៍ តើចាំបាច់ត្រូវចុះឯកសារដោយអ៊ីម៉ាំ (គឺអ្នកចេះដឹងអ៊ីស្លាម) ឬ ដោយតុលាការអ៊ីស្លាមទេ ?

**សៃយីដ្** - គេធ្វើអនុសាសន៍យ៉ាងខ្លាំងថាគូស្វាមីភរិយាគប្បីចុះឯកសារឲ្យ ត្រឹមត្រូវការកែប្រែកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ឲ្យមានសាក្សីត្រឹមត្រូវ ពីរនាក់ ។ ឯកសារទុកធ្វើជាសេចក្តីរំលឹកនិងជាវត្ថុធានាប្រសិនបើមាន បញ្ហាកើតឡើង ។

**លោកស្រី ហ្វាត់ម៉ាស់** - ហ្វាឌីស្ហ្វខ្លះចែងថាគេចាត់ទុកអាពាហ៍ពិពាហ៍ជា ការប្រតិបត្តិរបស់បុគ្គល ដែលបានប្រតិបត្តិសាសនាបានពាក់កណ្តាល ។ ហ្វាឌីស្ហ្វធ្វើឲ្យចាប់អារម្មណ៍ថាអាពាហ៍ពិពាហ៍ជាកាតព្វកិច្ចលើមុស្លីមទាំង អស់ ។ តើដូច្នេះមែនទេ ?

**សៃយីដ្** - អាពាហ៍ពិពាហ៍ ក្នុងអ៊ីស្លាម ត្រូវចាត់ទុកជាការប្រតិបត្តិក្នុងជំនឿ

សាសនា មិនមែនជាបញ្ហាចាំបាច់ទេ ។ អ៊ីស្លាមចាត់ទុកទំនៀមអាពាហ៍ពិពាហ៍ជាការការពារខ្លួននិងជាការធានាសុខុមាលភាពរបស់បុគ្គល ដូចជាផ្នែកសីលធម៌ ផ្នែកអារម្មណ៍ ផ្នែកកាយនិងផ្នែកចិត្ត ជាដើម ។ អាស្រ័យហេតុនេះ អាពាហ៍ពិពាហ៍ទៅជារឿងចាំបាច់ ។ ព្រះសាស្តាﷺមានព្រះវចនៈថា៖ "អ្នកណារៀបការ អ្នកនោះថែរក្សាសាសនារបស់ខ្លួនបានពាក់កណ្តាល ។"[36] ដូច្នេះ ដើម្បីធានានិងការពារព្រហ្មចរិយភាពរបស់បខ្លួន វាទៅជាការចាំបាច់ឲ្យមុស្លីមរៀបអាពាហ៍ពិពាហ៍ ។ រីឯមនុស្សខ្លះដែលមិនរៀបការទេនោះ មិនត្រូវចាត់ទុកជាបាបទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើអាពាហ៍ពិពាហ៍តម្រូវឲ្យមានសាក្សីទេ ?

**សៃយីដ្** - ក្នុងម៉ាស់ហ្ហាប់ អាស់លុល-បៃត៍ សាក្សីជាមុសតាហ្ហាប់ តែមិនចាំបាច់ទេ ។ បើគូស្វាមីភរិយាសូត្ររូបមន្តសម្រាប់អាពាហ៍ពិពាហ៍ (صيغة) រវាងខ្លួនឯងទាំងពីរ ដោយពុំមានសាក្សីទេ អាពាហ៍ពិពាហ៍នោះនឹងមានសុពលភាព (គឺត្រឹមត្រូវ ទុកជាការបាន) ។ ផ្ទុយពីការលែងលះ ដែលត្រូវមានសាក្សីនិងមានលក្ខខណ្ឌរាំងនោះ អាពាហ៍ពិពាហ៍ពុំមានទេ ។ អ៊ីស្លាមគាំទ្រអាពាហ៍ពិពាហ៍ និងជួយឲ្យគូស្វាមីភរិយាមានការងាយស្រួលក្នុងការរៀបអាពាហ៍ពិពាហ៍ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើចាំបាច់ត្រូវសូត្ររូបមន្តអាពាហ៍ពិពាហ៍ជាភាសាអារ៉ាប់ទេ ?

**សៃយីដ្** - លោកអ្នកប្រាជ្ញសម័យនេះចង់ឲ្យសូត្ររូបមន្តអាពាហ៍ពិពាហ៍ជាភាសាអារ៉ាប់ តែបើមិនអាចធ្វើដូច្នេះបានទេ អាចសូត្រជាភាសាផ្សេងបាន

---

36 សូមមើលសៀវភៅ وسائل الشيعة ជុំទី ៥ ។

ទុកជាការគ្រប់គ្រាន់ ។

**លោកស្រី ហ្វាត់ម៉ាស់** - ពេលស្ត្រីមុស្លីមរៀបការ ស្ត្រីនោះមានសិទ្ធិទុកឈ្មោះកំណើត ។ ស្ត្រីនោះមិនបាច់ផ្លាស់ឈ្មោះឪពុកខ្លួនដោយឈ្មោះស្វាមីទេ ។ តើត្រឹមត្រូវទេ ?

**សៃយីដ** - បើភរិយាចង់ ភរិយាអាចទុកឈ្មោះកំណើតបាន អាចមានអត្តសញ្ញាណដោយឡែកបាន ។

**លោកស្រី ហ្វាត់ម៉ាស់** - គេដឹងច្បាស់ស្រាប់ហើយថាមុស្លីមមិនអាចរៀបការជាមួយអ្នកមិនមែនមុស្លីមបានទេ តែមានពាក្យជំទាស់ទាក់ទងនឹងបុរសមុស្លីមរៀបការជាមួយស្ត្រីគ្រិស្តឬស្ត្រីយ៉ាហ្វូឌី ។ បណ្ដាអ្នកដែលយល់ស្របនឹងអាពាហ៍ពិពាហ៍បែបនេះផ្អែកទៅលើអាយ៉ាស់មួយដែលថែងថាៈ

وَٱلْمُحْصَنَـٰتُ مِنَ ٱلْمُؤْمِنَـٰتِ وَٱلْمُحْصَنَـٰتُ مِنَ ٱلَّذِينَ أُوتُوا۟ ٱلْكِتَـٰبَ مِن قَبْلِكُمْ

*[អនុញ្ញាតឲ្យរៀបការជាមួយ]បណ្ដាស្ត្រី ដែលប្រកបដោយព្រហ្មចរិយធម៌ដែលជាបណ្ដាស្ត្រីមានសទ្ធា[ដែលពុំមានស្វាមី] និងបណ្ដាស្ត្រីដែលប្រកបដោយព្រហ្មចរិយធម៌[ឥតស្វាមី] ក្នុងចំណោមបណ្ដាស្ត្រីដែលបានទទួលគម្ពីរកាលពីមុនពួកអ្នក (៥:៥) ។*

តើបុរសមុស្លីមអាចរៀបការជាមួយស្ត្រីគ្រិស្តឬស្ត្រីយ៉ាហ្វូឌី ដោយមិនបាច់ចូលសាសនាអ៊ីស្លាមបានទេ ?

**សៃយីដ** - អាយ៉ាស់ដែលលោកស្រីលើកមកនិយាយនោះទាក់ទងនឹងព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងសម័យព្រះសាស្ដាﷺ ។ កាល

សាសនាអ៊ីស្លាមមានឥទ្ធិពលនិងល្បីខ្លាំងនៅក្នុងតំបន់អារ៉ាប់ បុរសមុស្លីមមួយចំនួនមានមោទនភាពនឹងមរតកសាសនារបស់ខ្លួន ។ ហេតុដូច្នេះបុរសទាំងនេះចង់រៀបការជាមួយតែស្ត្រីមុស្លីមពីកំណើតទេ ។

បុរសទាំងនោះមិនបើកឱកាសឲ្យស្ត្រីអ្នកមានសទ្ធា ស្ត្រីមុស្លីមដែលធ្លាប់កាន់សាសនាយ៉ាហ្វូឌីឬសាសនាគ្រិស្តនោះទេ ។ អ៊ីស្លាមចង់ឲ្យបុរសមុស្លីមរៀបការជាមួយស្ត្រីដែលមិនត្រឹមតែជាមុស្លីមពីកំណើត ប៉ុណ្ណោះទេ តែឲ្យរៀបការជាមួយស្ត្រីដែលចោលគម្ពីរមុនៗ មកកាន់សាសនាអ៊ីស្លាមថ្មីៗនោះដែរ ។

អ៊ីស្លាមជាតំណានិងជាសមិទ្ធិកម្មនៃសាសនាទាំងបី ដែលមានព្រះតែមួយ ។ អ៊ីស្លាមមានជំនឿលើអត្ថបទគម្ពីរតៅរ៉ែតនិងគម្ពីរសាសនាគ្រិស្តច្បាប់ដើម ហើយចាត់ទុកអ្នកតាមព្រះសាស្តាមូសាﷺនិងព្រះសាស្តាអ៊ីសាﷺជាជនគម្ពីរ (គឺបណ្តាអ្នកដែលបានទទួលគម្ពីរកាលពីមុន) ។

គោលការណ៍មួយរបស់អាពាហ៍ពិពាហ៍ គឺតម្លៃគ្រួសារដ៏មាំនិងប្រយោជន៍រួម ។ អ្នកប្រាជ្ញអាស្វ់លុល-បៃត៍សម័យនេះមានប្រសាសន៍ ជាការប្រយ័ត្នចាំបាច់ ថាគេមិនផ្តាំឲ្យបុរសមុស្លីមរៀបការជាមួយស្ត្រីយ៉ាហ្វូឌីឬស្ត្រីគ្រិស្តជាប់គេ ។

ហេតុផលរឿងនេះគឺដើម្បីចៀសវាងជម្លោះរឿងសាសនា និងដើម្បីមានរបៀបរស់នៅរួមគ្នាដែលត្រូវគ្នា ជាពិសេសរឿងចិញ្ចឹមកូន ។ ដើម្បីផលប្រយោជន៍និងសេចក្តីសុខមិនត្រឹមតែរបស់គូស្វាមីភរិយាប៉ុណ្ណោះទេ តែរបស់កូនៗដែរ ដែលឪពុកម្តាយចូលរួមគ្នាក្នុងសាសនាតែមួយ ។

**-តរុណវ័យ (ភាពពេញក្រមុំ)**

**លាកស្រី ហ្វាត់ម៉ាស់** - ពេលក្មេងស្រីមានអាយុជិតដប់ឆ្នាំតាមប្រក្រតិទិនអ៊ីស្លាម ក្មេងស្រីនោះគ្រប់វ័យបំពេញករណីយកិច្ចសាសនាដោយខ្លួន (مكلف) ។ តើគេចាត់ទុកអាយុប៉ុណ្ណោះអាចរៀបការបានស្របច្បាប់ទេ ?

**សៃយីដ្** - សម្រាប់លោកអ្នកប្រាជ្ញខ្លះ ក្មេងស្រីដែលជិតផុតអាយុប្រាំបួនឆ្នាំ តាមប្រក្រទិនអ៊ីស្លាម គ្រប់អាយុបំពេញករណីយកិច្ចសាសនា ដូចជាស្ម័គ្រឡាត់និងសីលត្រណមជាដើម ។ លោកអ្នកប្រាជ្ញមួយចំនួនទៀតមានប្រសាសន៍ថា ក្មេងស្រីគ្រប់អាយុបំពេញភារកិច្ចសាសនាពេលចាប់ផ្ដើមមានរដូវខែ ។ ទោះជាយ៉ាងណាក៏ដោយ មតិទូទៅរបស់លោកអ្នកប្រាជ្ញសម័យសព្វថ្ងៃថែងថា ការមានរដូវខែជាលក្ខខណ្ឌដំបូងសម្រាប់អាពាហ៍ពិពាហ៍ អាយុមិនមែនលក្ខខណ្ឌចាំបាច់ទេ ដែលជាកត្តាចម្បងនោះ ។

ថ្វីបើមតិទូទៅថាដូច្នេះក៏ដោយ ក្នុងយុគសម័យយើង ខ្ញុំបាទមិនណែនាំឲ្យរៀបការមុនចាស់គំនិតនិងចាស់ខ្លួន និងមុនមានសមត្ថភាពជាដៃគូបំពេញភារកិច្ចក្នុងគ្រួសារទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ីស្លាមផ្អែកលើភ័ស្តុតាងអ្វីដែលថារៀបការក្នុង "វ័យក្មេង" នោះជាការសមហេតុផល ខណៈដែលគេឃើញមានករណីយច្រើន ក្មេងស្រីមិនទាន់មានបក្កភាព (គឺមិនទាន់ចាស់គំនិត) ទេ មិនមានសមត្ថភាពបំពេញភារកិច្ចអាពាហ៍ពិពាហ៍ដ៏ធ្ងន់ទេ ?

**សៃយីដ្** - ចូរដឹងឲ្យច្បាស់ថាអ៊ីស្លាមមិនរើសអើងពូជសាសន៍ឬទំនៀមទម្លាប់របស់បុគ្គលទេ ហើយអ៊ីស្លាមមិនជាប់ទាក់ទិននឹងយុគសម័យទេ ។ អ៊ីស្លាមត្រូវចាត់បញ្ជូនមកសម្រាប់យុគសម័យ និងមនុស្សជាតិទាំងអស់ ។ ថ្វីបើមានក្មេងស្រីច្រើននៅក្នុងពិភពលោកដែលក្មេង និងខ្ចីចិត្តគំនិតពេកសម្រាប់អាពាហ៍ពិពាហ៍ក្ដី មានតរុណីគ្រប់វ័យ (គឺយុវតីអាយុ ១៣-១៩ ឆ្នាំ)

ច្រើនដែលអាចស្រេចបាច់សម្រាប់អាពាហ៍ពិពាហ៍ ។ អាចធ្វើឲ្យខូចខាតបានដោយថាតុរុណីទាំងអស់នោះនៅខ្ចីពេកសម្រាប់អាពាហ៍ពិពាហ៍ ។

ក្នុងច្រើនករណី បើយើងប្រៀបធៀបកម្រិតបក្កភាពនៃក្មេងស្រីក្នុងសហាគមន៍ប៉ែកខាងលិចនិងកម្រិតបក្កភាពនៃក្មេងស្រីក្នុងសហាគមន៍ប៉ែកខាងកើត គេឃើញថាកម្រិតនៃភាពពេញលក្ខណៈនិងសមត្ថភាពសម្រាប់អាពាហ៍ពិពាហ៍នៃយុវតីប៉ែកខាងកើត មានកម្រិតលើសយុវតីប៉ែកខាងលិច ។

**លោកស្រី ហ្វាត់ម៉ាស់** - អ៊ីស្លាមតម្រូវឲ្យសាសនិកជនបំពេញពិធីរបស់សាសនា[37]ដោយកាយដែលទាមទារការយល់ដឹងផ្នែកចិត្តសាស្ត្រ និងផ្នែកធម្មារម្មណ៍ ។ គេគិតថា ជាទូទៅ យុវតីភាគច្រើននៅខ្ចីនៅឡើយក្នុងការយល់ដឹងភារកិច្ចសាសនាដែលគេដាក់មកលើខ្លួន ហេតុអ្វីអ៊ីស្លាមពន្យល់ថាកម្រិតភារកិច្ចសាសនារបស់យុវតី ស្មើគ្នានឹងកម្រិតភារកិច្ចរបស់ស្ត្រីដែរ ព្រោះទាំងពីរត្រូវបំពេញករណីយកិច្ចដែលសាសនាដាក់មកលើខ្លួន ?

**សៃយីដ** - ថាកម្រិតសាសនារបស់ក្មេងស្រីដែលគេសង្ឃឹមចង់បាននេះស្មើនឹងស្ត្រីវ័យចំណាស់នោះមិនត្រឹមត្រូវទេ ។ គួរអានលើកឡើង តាមរយៈនៃការថែងប្រៀបធៀប នូវលំដាប់ថ្នាក់ភារកិច្ចជាតួយ៉ាងដ៏ច្រើន ហើយថែងថាមនុស្សនឹងមិនត្រូវវិនិច្ឆ័យដូចគ្នាទេ ។

لَا يُكَلِّفُ ٱللَّهُ نَفْسًا إِلَّا وُسْعَهَا

[37] ពិធីរបស់សាសនា ឧទាហរណ៍ ស្វ័ឡាត់ប្រចាំថ្ងៃទាំងប្រាំ, សីលត្រណម, ស្នានពិធី (គឺការសម្អាតខ្លួន) និងច្រើនទៀត

*អល់ឡោះហាម៉ដាក់កាតព្វកិច្ច លើបុគ្គលសមស្របតែតាមសមត្ថភាពបុគ្គលនោះទេ (២:២៨៦) ។*

ពេលក្មេងស្រីចាប់ផ្តើមមានការផ្លាស់ប្តូរក្នុងខ្លួន និងចិត្តគំនិត នេះគឺការឈានចូលដំណាក់ការជាស្ត្រីភាព ។ នៅក្នុងដំណាក់ការនេះឯងដែលអ៊ីស្លាមផុសឡើងដែរ ។ ការកកើតនូវចម្មារម្មណ៍ជាគ្រឹះដែលធ្វើឲ្យបុគ្គលទៅជាមនុស្សពេញច្បាប់ ។

**លោកស្រី ហ្វាត់ម៉ាស៊ុំ** - ក្នុងសាសនាអ៊ីស្លាម ពេលក្មេងស្រីចាស់កាយ ចាស់ចិត្តគំនិតនិងផ្នែកសង្គម នាងមានសិទ្ធិគ្រប់គ្រងនិងមានសិទ្ធិមានទ្រព្យផ្ទាល់ខ្លួនបាន ឬមានសិទ្ធិធ្វើធុរកិច្ចតាមចិត្តបាន មែនទេ ?

**សៃយីដ្** - មែន បើឃើញថានាងមានបក្កភាព (គឺចាស់ចិត្តគំនិត អាចជាម្ចាស់ការបាន) គ្រប់វិស័យដែលលោកស្រីមានប្រសាសន៍នោះមែន ។

**លោកស្រី ហ្វាត់ម៉ាស៊ុំ** - ដោយផ្តោតទៅលើចំណុចដែលអ៊ីស្លាមទទួលស្គាល់នាង (គឺយុវតី) ជាម្ចាស់ការ ហេតុអ្វីនាងចាំបាច់ត្រូវសូមអនុញ្ញាតពីឪពុកដើម្បីរៀបការ (លើកដំបូង) ?

**សៃយីដ្** - មិនត្រូវគិតរឿងអាពាហ៍ពិពាហ៍យ៉ាងប្រញាប់ប្រញាល់ទេ ។ ត្រូវគិតឲ្យហ្មត់ចត់ ។ ពាក្យស្លោកថា៖ "ស្រឡាញ់ខ្វាក់" ។ អាពាហ៍ពិពាហ៍មិនត្រូវផ្អែកតែលើសេចក្តីស្រឡាញ់ទេ តែអកុសល ចិត្តរវើរវាយជម្រុញមនុស្សចាស់ខ្ចីគំនិតឲ្យគិតគូរមិនប្រយ័ត ។

ជាទូទៅ ពេលណាស្ត្រីក្មេងជំពាក់អារម្មណ៍លើបុរស ពេលនោះគំនិតបែរជាលំអៀងបន្តិច ។ នៅក្នុងពេលនេះឯងដែលឪពុកដែលបានចិញ្ចឹមកូន

ស្រីខ្លួនតាំងពីតូចមក ដែលព្រួយបារម្ភអំពីកូនស្រីខ្លួន ដែលអាណិតស្រឡាញ់កូនស្រីខ្លួននោះ វិភាគគិតគូរយ៉ាងប្រយត្នប្រយែងថាតើបុរសនោះសក្តិសមនឹងកូនស្រីឬទេ ។ ជាធម្មតា ឪពុកចង់ឲ្យកូនស្រីខ្លួនបាននូវអ្វីដែលល្អប្រសើរ ។

បើកូនកម្លោះជាបុរសដែលខ្លាចក្រែងនិងគោរពអល់ឡោះហ្ទ៍ កូនកម្លោះនោះអាចផ្តល់ឲ្យកូនស្រីខ្លួននូវជីវភាពរស់នៅស្រួល ដូច្នេះឪពុកនឹងមិនជំទាស់អាពាហ៍ពិពាហ៍នោះទេ ។ ការពិត ឪពុកភាគច្រើនយល់ព្រមតាំងពីបានចៃចូវតាមសាសនាពីដំបូងម្ល៉េះ ។

ស្ត្រីខ្លះអាចក្រោធច្បាប់ពិសេសនេះ តែចូរកុំចាត់ទុកថាជាប្រការមិនល្អឬថយកិត្តិយស ។ នេះជាវិធីការពារមួយប្រភេទ ។ ច្បាប់នេះការពារក្មេងស្រីពីការបំពារបំពាននិងពីការសម្រេចចិត្តអវិចារណ៍ ។

ឧទាហរណ៍ថាលោកស្រីមានកូនស្រីអាយុ ២០ ឆ្នាំ នាងស្រឡាញ់បុរសដែលផឹកស្រា រវល់តែប្រកបកិច្ចការ ។ តើលោកស្រីយល់ព្រម ឬជំទាស់អាពាហ៍ពិពាហ៍នោះ ? ទោះបីកូនស្រីលោកស្រីអាយុ ២០ ឆ្នាំក៏ដោយ តើលោកស្រីគិតថាកូនស្រីលោកស្រីគិតគូរត្រូវទេ ? អាយុមិនមែនជាលក្ខខណ្ឌតែម្យ៉ាងទេសម្រាប់រៀបការ បក្កភាពក៏ជាកត្តាសំខាន់ដែរ ។

**លោកស្រី ហ្វាត់ម៉ាស់** - ការសូមអនុញ្ញាតពីឪពុកជាការតម្រូវតាមសាសនាសម្រាប់ស្ត្រីក្មេងដែលរៀបការគ្រាដំបូង ។ ច្បាប់នេះត្រូវប្រើសម្រាប់កំណត់អាយុប៉ុណ្ណា ? ស្ត្រីដែលមានអាយុសាមសិបឆ្នាំ លើសបន្តិចបន្តួចនោះយ៉ាងណាដែរ ? តើស្ត្រីនោះត្រូវសូមអនុញ្ញាតពីឪពុកទេ ?

**សៃយីដ្** - លោកអ្នកប្រាជ្ញអ៊ីស្លាមមានប្រសាសន៍ថា ជាការប្រុងប្រយ័ត្ន

ចាំបាច់និងជាសេចក្ដីគោរពឪពុក ស្ត្រីត្រូវសូមការយល់ព្រមពីឪពុក ។

**លោកស្រី ហ្វាត្ទុំម៉ាស់** - យោលតាមម៉ាស្ហ៊ហ្វាប់ខ្លះ គេអនុញ្ញាតឲ្យឪពុកឬតាធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ឲ្យក្មេងមិនទាន់គ្រប់អាយុបាន ស្រីក្ដីប្រុសក្ដី ។ បន្ទាប់មក ពេលគ្រប់អាយុ (បាលិគ្ុ) ត្រូវតែប្រតិបត្តិតាមកិច្ចព្រមព្រៀងនោះជាចាំបាច់ លើកលែងតែភាគីណាមួយជំទាស់អាពាហ៍ពិពាហ៍នោះ ។ ហ្គាឌ្ទីស្ស៍បានឲ្យដឹងថា៖

ក្មេងស្រីម្នាក់បានមកជួបព្រះសាស្ដាﷺទាំងភ័យព្រួយ ស្រែកថា៖ "ព្រះសាស្ដាﷺអើយ" ពីដៃឪពុកនោះ ។ ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "តើឪពុកនាងធ្វើអ្វីនាង ?" ក្មេងស្រីនោះទូលថា៖ "គាត់ឲ្យខ្ញុំម្ចាស់រៀបការមុនសួរខ្ញុំម្ចាស់រឿងនេះ ។"

ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ពេលនេះឪពុកបានរៀបការឲ្យនាងហើយ ចូរនាងយល់ព្រមជាភរិយាគេចុះ ។" ក្មេងស្រីនោះទូលថា៖ "ឲ្យខ្ញុំម្ចាស់ទៅជាភរិយារបស់បុរស ដែលខ្ញុំម្ចាស់មិនស្រឡាញ់នោះបានម្ដេចទៅ ?" ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "បើនាងមិនស្រឡាញ់បុរសនោះទេ រឿងនេះចប់ហើយ ។ នាងមានសិទ្ធិពេញទី ។ ចូរជ្រើសយកបុរសណាដែលនាងចង់រៀបការជាមួយចុះ ។"[38]

ម៉ាស្ហ៊ហ្វាប់ទាំងអស់មូលមតិគ្នាថា កិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ដែលមានសុពលភាពពេលណាភាគីទាំងពីរយល់ព្រម តែនាងខ្ញុំចង់ដឹងថាហេតុអ្វីអ៊ីស្លាមអនុញ្ញាតឲ្យឪពុក ឬជីតាធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍មុនក្មេងស្រីឬក្មេងប្រុសគ្រប់អាយុ ថ្វីបើការយល់ព្រមរបស់ក្មេងនោះជាខលក្ខខណ្ឌចាំបាច់ដើម្បីភ្ជាប់កិច្ចសន្យានោះ ?

---

[38] The Rights of Women in Islam, Murtaza Mutahhari (مرتضی مطهری).

**សៃយីដ្** - ក្នុងដើមសម័យអ៊ីស្លាម បុគ្គលខ្លះធ្លាប់តែរៀបការពីក្មេង ។ ឪពុកម្ដាយតែងតែរៀបចំអាពាហ៍ពិពាហ៍ឲ្យកូន ។ នេះជាទំនៀមទម្លាប់ ។ អ៊ីស្លាមជ្រោមជ្រែងឪពុកម្ដាយ ឲ្យស្វែងរកគូស្រករដែលសក្តិសមឲ្យកូន តែហាមឪពុកម្ដាយធ្វើកិច្ចសន្យាអាពាហ៍ពិពាហ៍ដែលភាគីណាមួយឬទាំងពីរភាគី (កូនស្រ្តីឬកូនប្រុស) ជំទាស់ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើអ្វីនឹងកើតឡើងក្នុងករណីយដែលឪពុកបដិសេធគូដណ្ដឹងរបស់កូនស្រីដោយគ្មានហេតុផល ហើយកូនស្រីនោះសម្រេចចិត្តរត់ចេញពីផ្ទះ ? តើអាពាហ៍ពិពាហ៍នោះត្រូវមោឃ: (បាទិ្វល) ទេ ?

**សៃយីដ្** - ដើម្បីឆ្លើយតបសំណួរនេះយ៉ាងត្រឹមត្រូវ យើងត្រូវអធិប្បាយបំភ្លឺថាអ្វីគឺ "គ្មានហេតុផល" នោះ ។ បើគូដណ្ដឹងនោះជាបុរសមានសទ្ធាត្រឹមត្រូវ ជាមុស្លីមដែលអនុវត្តិសាសនា សមស្របនឹងឋានៈសីលធម៌និងសាសនារបស់គ្រួសារស្រ្តី ហើយមានសមត្ថភាពចិញ្ចឹមស្រ្តីនោះ ការបដិសេធរបស់ឪពុកស្រ្តីនោះមិនសមហេតុផលទេ ។ បើកូនស្រីរត់ចេញពីផ្ទះ អាពាហ៍ពិពាហ៍របស់កូនស្រីនោះត្រឹមត្រូវតាមច្បាប់ ។ ព្រមនឹងនេះដែរ អ៊ីស្លាមណែនាំឲ្យស្រ្តីបន្តការសូមពរពីឪពុកជាដរាប ។

**-ម៉ាស្ហ៍រ៍ (ខាន់ស្លា)**

**លោកស្រី ហ្វាត់ម៉ាស់** - តើម៉ាស្ហ៍រ៍ (ខាន់ស្លា) ជាការចាំបាច់ទេនៅក្នុងអាពាហ៍ពិពាហ៍ ?

**សៃយីដ្** - បើគ្មានការដាក់លក្ខខណ្ឌខាន់ស្លាទេ អាពាហ៍ពិពាហ៍មិនមានសុពលភាពទេ (គឺមិនត្រឹមត្រូវទេ) ។ អ្នកខ្លះថាម៉ាស្ហ៍រ៍ (ខាន់ស្លា) ជាការ

ទិញដូរកូនក្រមុំមួយប្រភេទ តែមិនមែនទេ ។ ម៉ាស្ង៉រ៍ (ខាន់ស្លា) ជាអំណោយ ។ តាមទម្លាប់ម៉ាស្ង៉រ៍ជាទឹកប្រាក់ (ថវិកា) តែម៉ាស្ង៉រ៍មិនចាំបាច់ជាទឹកប្រាក់ទេ ។ ម៉ាស្ង៉រ៍អាចជាអ្វីមួយដែលជាអំណោយមានតម្លៃខ្ពស់ ដូចជាការបញ្ជូនភរិយាទៅបំពេញពិធីហាជ្ជ៍ ឬជូនគម្ពីរអានដល់ភរិយាជាអំណោយជាដើម ។

**លោកស្រី ហ្វាត់ម៉ាស៊ុ** - តាមទម្លាប់ម៉ាស្ង៉រ៍ជាទឹកប្រាក់ បានសេចក្ដីថាមានមូលហេតុប្រាក់រឿងម៉ាស្ង៉រ៍ ។ តើអ៊ីស្លាមមានទ្រឹស្ដីយ៉ាងណាដែររឿងម៉ាស្ង៉រ៍ ?

**សៃយីដុ** - ខាន់ស្លាប្រាក់អាចជាការឧបត្ថម្ភស្ត្រីកុំឲ្យខ្វះខាតមួយប្រភេទបាន ។ កាលពីមុន ព្រមទាំងក្នុងសម័យបច្ចុប្បន្នដែរ ស្ត្រីជាច្រើនតស៊ូដើម្បីកុំឲ្យខ្វះខាត ។ ខាន់ស្លាប្រាក់អាចទៅជាមធ្យោបាយមួយបានដើម្បីកុំឲ្យស្ត្រីខ្វះខាត ពេលត្រូវការជំនួយផ្នែកជីវភាពរស់នៅក្នុងអនាគត ។ ខាន់ស្លាប្រាក់អាចផ្ដល់ឱកាសជួញដូរប្រាក់បានដែរ ដើម្បីបាននូវកម្លាំងសេដ្ឋកិច្ច ។

**លោកស្រី ហ្វាត់ម៉ាស៊ុ** - ក្នុងករណីដែលគេមិនបានដាក់ចំនួនប្រាក់ខាន់ស្លានោះទេ នឹងមានអ្វីកើតឡើង ? តើភរិយានឹងមានសិទ្ធិទទួលបាននូវខាន់ស្លាដែលសក្ដិសមនឹងឋានៈសង្គមនិងសេដ្ឋកិច្ចខ្លួនទេ (مَهْرُ الْمِثْلِ) ?

**សៃយីដុ** - ខាន់ស្លានឹងត្រូវកំណត់ស្មើនឹងខាន់ស្លារបស់ស្ត្រីស្រករស្ត្រីនោះដែរ ។ ឧទាហរណ៍ថា ប្រាក់ខាន់ស្លារបស់កូនស្រីនីមួយមានចំនួន ១០០០០$ ប្រាក់ខាន់ស្លារបស់កូនស្រីឯទៀតត្រូវមានចំនួនដូចគ្នា ។

**លោកស្រី ហ្វាត់ម៉ាស៊ុ** - តើនឹងមានអ្វីកើតឡើងបើភរិយាស្លាប់ ហើយស្វាមី

មិនទាន់បានប្រគល់ប្រាក់ខាន់ស្លាឲ្យគ្រប់ចំនួននៅឡើយនោះ ? តើស្វាមីត្រូវបង់ប្រាក់ខាន់ស្លានោះទៅក្នុងទ្រព្យមរតករបស់ភរិយាស្លាប់ ដើម្បីនឹងឲ្យឪពុកម្ដាយនិងកូនភរិយានោះបានទទួលវាជាមរតក ?

**សៃយីដ្** - បើភរិយាស្លាប់ ស្វាមីមិនទាន់បានបង់ប្រាក់ខាន់ស្លាឲ្យគ្រប់ទេ ស្វាមីនោះត្រូវបង់សងភោគទ្រព្យរបស់ភរិយាស្លាប់នោះ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើភរិយានឹងទទួលបានប្រាក់ខាន់ស្លាដូចម្ដេច បើស្វាមីស្លាប់មុនបានឲ្យប្រាក់ខាន់ស្លាគ្រប់ចំនួននោះ ?

**សៃយីដ្** - បើបង់ប្រាក់ខាន់ស្លាមិនគ្រប់ចំនួនទេ ត្រូវចាត់ទុកថាស្វាមីជំពាក់បំណុលភរិយាឬភរិយាឲ្យស្វាមីខ្ចី ។ ភរិយា ក្នុងអំឡុងពេលរៀបការនោះ អាចទារឲ្យស្វាមីបង់ប្រាក់ខាន់ស្លានោះបាន ពេលណាក៏បាន ។ បើស្វាមីស្លាប់មុនបានបង់ប្រាក់ខាន់ស្លាគ្រប់ចំនួន ប្រាក់ខាន់ស្លានោះត្រូវចាត់ទុកជាបំណុល ។ ត្រូវបង់ប្រាក់ខាន់ស្លានេះឲ្យគ្រប់ចំនួនពីទ្រព្យសំណល់របស់ស្វាមីនោះ ឲ្យបានមុនគេទាមទារចែកទ្រព្យមរតកនោះតាមបណ្ដាំស្វាមីដែលស្លាប់នោះ ។

**លោកស្រី ហ្វាត់ម៉ាស់** - ឧទាហរណ៍ថា គូស្វាមីភរិយាយល់ព្រមដាក់ប្រាក់ខាន់ស្លា ១០ ០០០$ ។ នៅពេលរៀបការ ស្វាមីបានប្រគល់ឲ្យ ៣០០០$ ដោយសន្យាថានឹងឲ្យភរិយា ៧០០០$ ដែលនៅសល់នោះនៅពេលក្រោយ ។ តើត្រូវបង់ប្រាក់ខាន់ស្លាដែលនៅសល់នោះ (៧០០០$) គ្រប់ចំនួនត្រឹម ឬក៏ត្រូវគិតតាមអត្រាប្រាក់នៃកាលៈទេសៈនោះ ដូចជា គិតតាមតម្លៃជីវភាពរស់នៅឡើងចុះ គិតតាមអត្រាឡើងចុះរបស់ប្រាក់ ស្ថានភាពថវិការបស់ស្វាមីនៅពេលបង់ប្រាក់ខាន់ស្លានោះ ជាដើម ?

**សៃយីដុ** - ប្រាក់ខាន់ស្លាដែលនៅសល់នោះត្រូវបង់ដោយគិតតាមតម្លៃប្រាក់នៃទីផ្សារបច្ចុប្បន្ន ។ អាចនិយាយឲ្យស្រួលស្តាប់បានថា ប្រសិនបើចំនួនប្រាក់ខាន់ស្លា ៧០០០$ កាលពីដប់ឆ្នាំមុននោះស្មើនឹង ១៥០០០$ បច្ចុប្បន្ននេះ ស្វាមីត្រូវបង់ប្រាក់ខាន់ស្លានោះតាមអត្រាប្រាក់នៃទីផ្សារបច្ចុប្បន្ននេះ (ពោលគឺ ត្រូវបង់ ១៥០០០$) ។

ស្វាមីត្រូវដឹងច្បាស់ថាបើខាន់ស្លាជាសាច់ប្រាក់ ហើយមិនបានបង់គ្រប់ទេ នឹងត្រូវចាត់ទុកជាប្រាក់ដែលគេឲ្យខ្ចី ហើយចាំបាច់ត្រូវតែសងប្រាក់កំចីនេះ ។ នេះជាលិខិតសន្យាដែលត្រូវតែបង់ឲ្យគ្រប់តាមចំនួនជាចាំបាច់ ។ ស្វាមីត្រូវគិតថាបើពន្យារពេលបង់ប្រាក់ខាន់ស្លា ចំនួនទឹកប្រាក់ខាន់ស្លានោះអាចនឹងកើនឡើងតាមអត្រាប្រាក់នៃទីផ្សារ ។

អ៊ីស្លាមមិនបង្ខំឲ្យបុរសដាក់ប្រាក់ខាន់ស្លាថ្លៃពេកទេ ។ បុរសគប្បីដាក់ខាន់ស្លាតាមលទ្ធភាព ។ ខាន់ស្លាមិនចាំបាច់ជាទឹកប្រាក់ទេ ។ ខាន់ស្លាអាចជាអ្វីៗដែលមានតម្លៃ ទោះជាអំណោយដែលមានតម្លៃផ្នែកមនោសញ្ចេតនា ឬជាប្រាក់ក្តី ។

**លោកស្រី ហ្វាត់ម៉ាស់** - ដូច្នេះ អត្រាប្រាក់របស់ប្រទេស ឬស្ថានភាពថវិការបស់ស្វាមី មិនអាចជាលេសបានទេដើម្បីកែប្រែចំនួនទឹកប្រាក់ខាន់ស្លាដែលនៅសល់នោះ មែនទេ ?

**សៃយីដុ** - ប្រសិនបើស្វាមីមិនមានសមត្ថភាពបង់ប្រាក់ខាន់ស្លាដែលនៅសល់នោះបានទេ ត្រូវយកច្បាប់ចែងអំពីការជំពាក់បំណុលមកប្រើ ។

وَإِن كَانَ ذُو عُسْرَةٍ فَنَظِرَةٌ إِلَىٰ مَيْسَرَةٍ ۚ وَأَن تَصَدَّقُوا۟ خَيْرٌ لَّكُمْ إِن كُنتُمْ

تَعۡلَمُونَ ٢٨٠

*បើគេ (គឺអ្នកជំពាក់បំណុល) ទាល់ (គឺខ្វះប្រាក់) ចូរពន្យារពេលឲ្យគេសិនលុះត្រាគេមានលទ្ធភាពប្រសើរឡើង[ដើម្បីសងបំណុល]។ បើពួកអ្នកឲ្យជាទាន (គឺឈប់ទារប្រាក់ជំពាក់) វាប្រសើរជាងសម្រាប់ខ្លួនពួកអ្នកផ្ទាល់បើពួកអ្នកដឹង (២:២៨០)។*

## វគ្គ ៣ - ការលែងលះ, ការលែងលះនិងម៉ាស្ល៉រ៍, ម្ចាស់ទ្រព្យ

**-ការលែងលះ**

**លោកស្រី ហ្វាត់ម៉ាស្ង** - ក្នុងសាសនាអ៊ីស្លាម ហេតុអ្វីអាជ្ញារឿងលែងលះត្រូវប្រគល់ឲ្យទៅស្វាមីជាស្វ័យប្រវត្តិ ?

**សៃយីដ្ទ** - ក្នុងសាសនាអ៊ីស្លាម ការលែងលះគ្នាជាទង្វើគួរឲ្យស្អប់ខ្ពើមបំផុតសម្រាប់អល់ឡោះហ្ទ៍عزّوجلّ ។ អ៊ីម៉ាំស្វ៍ឌិក្វصلوات الله عليه والسلامមានវចនៈថាព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "ចូររៀបការ តែចូរកុំលែងលះគ្នា ព្រោះការលែងលះគ្នានឹងធ្វើឲ្យអារ៉ស្វ៍អល់ឡោះហ្វ៍عزّوجلّរញ្ជួយ ។"[1]

ខុសពីសាសនាឯទៀត ក្នុងសាសនាអ៊ីស្លាម គេអនុញ្ញាតឲ្យលែងលះគ្នាបានតែត្រូវគោរពវិធីការយ៉ាងតឹងរ៉ឹង ។ បញ្ចប់សព្វគ្រប់ការលែងលះគ្នាក្នុងសាសនាអ៊ីស្លាមមិនមែនជាការងាយស្រួលដូចគិតនោះទេ ។ វាមានដំណើរការយូរនិងវែងឆ្ងាយ ។

ស្វាមីអាចជាអ្នកសម្រេចការលែងលះគ្នាផ្តាច់ព្រ័ត្រជាស្វ័យប្រវត្តិ តែការលែងលះគ្នានោះមានដំណើរការលំបាកនិងមានលក្ខខណ្ឌ ។ មូលហេតុគឺការលែងលះគ្នាមានផលវិបត្តិនិងការទង្គុកទង្គិច មិនត្រឹមតែលើគូស្វាមីភរិយាប៉ុណ្ណោះទេ ថែមទាំងមានផលវិបត្តិនិងការទង្គុកទង្គិចលើកូនដែរដោយចៀសមិនបាន លើញាតិនិងសង្គមទៀតផង ។

លោកអ្នកប្រាជ្ញសំអាងលើហេតុផលផ្សេងៗ រឿងបុរសជាអ្នកមានសិទ្ធិលែងលះ ។ ហេតុផលរបស់អស់លោកអ្នកប្រាជ្ញទាំងនោះមិនដូចបុគ្គល

---

[1] សូមមើលសៀវភៅ مكارم الاخلاق ទំព័រ ២២៥ ។

ខ្លះគិតទេ ពោលគឺ ថាបុរសឧត្តុង្គឧត្តមជាងស្ត្រី ឬថាបុរសជាអ្នកថែរក្សាស្ត្រីជាដើម ។ លោកអ្នកប្រាជ្ញភាគច្រើនសម្រេចថាមូលហេតុចម្បងនោះគឺមកពីរចនាសម្ព័ន្ធផ្នែកចិត្តសាស្ត្ររបស់ស្ត្រី និងមកពីបុរសជាអ្នកចាយវាយក្នុងការចិញ្ចឹមស្ត្រី ។

ជាទូទៅ ស្ត្រីឆាប់មានប្រតិកម្មផ្លូវអារម្មណ៍ក្នុងស្ថានការណ៍ដែលធ្វើឲ្យតក់ស្លុតឬក្នុងស្ថានការណ៍ខ្លោចផ្សារ ។ មិនបានសេចក្ដីថាបុរសមិនមានប្រតិកម្មចំពោះព្រឹត្តិការណ៍រំភើបនោះទេ ។ បុរសពិតជាមានប្រតិកម្មផ្លូវចិត្ត ។ ក៏ប៉ុន្តែ ជាទូទៅ បុរសអាចទប់ចិត្តបានជាងស្ត្រីបន្តិច និងប្រុងប្រយ័តពេលត្រូវគ្រប់គ្រងស្ថានការណ៍មិនប្រាកដប្រជា ។

**លោកស្រី ហ្វាត់ម៉ាស៊ុំ** - តើអ៊ីស្លាមចង់និយាយបញ្ជៀងថាស្ត្រីទន់ខ្សោយផ្នែកអារម្មណ៍មែនទេ ?

**សៃយីដ្** - បើស្ត្រីមិនអាចគ្រប់គ្រងស្ថានការណ៍មិនប្រាកដប្រជាបាននោះទេ អល់ឡោះហ្ ប្រាកដជាមិនប្រោសប្រណីស្ត្រីដោយឲ្យស្ត្រីទៅជាមាតានោះទេ ។ ភាពជាមាតាតម្រូវឲ្យមានការតស៊ូផ្លូវចិត្តនិងផ្លូវកាយក្នុងការពពោះនិងក្នុងការចិញ្ចឹមកូន ។

ជាទូទៅ ពេលលោកអ្នកប្រាជ្ញថាស្ត្រីឆាប់មានប្រតិកម្មផ្លូវចិត្តពេលពើបពះស្ថានការណ៍មិនប្រាកដប្រជានោះ លោកចង់និយាយដល់រឿងជម្លោះផ្ទាល់ខ្លួន ដែលកើតឡើងក្នុងគូស្វាមីភរិយា ។ និយាយដល់រឿងផ្ទាល់ខ្លួនពាក់ព័ន្ធនឹងគូស្វាមីភរិយា ជាទូទៅ ភរិយាច្រើនតែនៅក្រោមឥទ្ធិពល

អារម្មណ៍ ។[2]

អំពើសំខាន់ ដូចជាការលែងលះគ្នាជាដើមនោះ មិនត្រូវផ្អែកទៅលើអារម្មណ៍ប្រែប្រួលនោះទេ ។ ការលែងលះគ្នាក្នុងសាសនាអ៊ីស្លាមជារឿងធំណាស់ ។ រឿងនេះមិនមែនជារឿងដែលត្រូវគិតគូសើៗបានទេ ។ ដើមកំណើតនៃការលែងលះគ្នា មិនត្រូវនៅក្រោមឥទ្ធិពលមនោសញ្ចេតនាមិននឹងននោះទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - មូលហេតុជ្រៅនៃការលែងលះរបស់គូស្វាមីភរិយានោះគឺការរំជួលចិត្ត ។ តើអ៊ីស្លាមថែងថាគ្មានឱកាសរំជួលចិត្តទេ មែនទេ ?

**សៃយីដ្** - វាអាស្រ័យទៅលើប្រភេទនៃការរំជួលចិត្តដែលលោកស្រីថានោះ ។ បើមូលហេតុនៃការលែងលះគ្នាស្ថិតនៅលើការមិនពេញចិត្តបណ្ដោះអាសន្នរបស់ស្វាមីឬភរិយា វាមិនសមជាមូលហេតុបណ្ដាលឲ្យលែងលះគ្នាទេ ។

فَإِن كَرِهْتُمُوهُنَّ فَعَسَىٰٓ أَن تَكْرَهُوا۟ شَيْـًٔا وَيَجْعَلَ ٱللَّهُ فِيهِ خَيْرًا كَثِيرًا

*បើពួកអ្នកស្អប់ខ្ពើមពួកនាង ពួកអ្នកអាចស្អប់ខ្ពើមអ្វីមួយដែលអល់ឡោះប្រ៊ាបានដាក់នៅក្នុងនោះនូវសេចក្ដីល្អប្រពៃធំមួយ (៤:១៩) ។*

ទោះជាស្វាមីក្ដី ទោះជាភរិយាក្ដីជាអ្នកសូមលែងលះនោះ ជាពិសេសបើមានកូន ដំបូង ការលែងលះគ្នាត្រូវបដិសេធ ។ គេនឹងសិក្សាវិភាគករណីនេះយ៉ាងហ្មត់ចត់មុននឹងសម្រេចផ្ដាច់ព្រ័ត្រ ។ ក្នុងករណីជាច្រើន ការលែងលះគ្នាដែលមិនផ្អែកលើមូលហេតុអារម្មណ៍មិននឹងនទេនោះ អាច

[2] លោកអ្នកប្រាជ្ញលើកឡើងនូវកត្តាអារម្មណ៍ ដូចជាការកើតកូននិងការមានរដូវខែ ជាដើម ។

ដោះស្រាយបានដោយប្រើពេលវេលា ឬតាមរយៈនៃការប្រឹក្សាឲ្យយោបល់ ។

អ៊ីស្លាមផ្តន្ទាទោសបុរសនិងស្ត្រីណា ដែលយកសិទ្ធិលែងលះគ្នាជាលេសលើកលែងតែការលែងលះដែលសមហេតុសមផល និងដែលនៅក្នុងស្ថានភាពគ្រោះថ្នាក់ធំ ។ ហេតុផលលែងលះគ្នាមិនអាចទ្បេះទ្បោះ យកជាការពុំបាននោះទេ ត្រូវផ្អែកលើអំណះអំណាងដែលពិតប្រាកដ ដែលសមហេតុសមផល ដែលសមទំនង ។

ថ្ងៃមួយព្រះសាស្តាﷺមានព្រះវចនៈថា៖ "យ៉ីបរ៉អ៊ីល﵇គាំទ្រមូលហេតុស្ត្រីខ្លាំងណាស់ បានណែនាំខ្ញុំﷺច្រើនណាស់ ហើយបានធ្វើឲ្យខ្ញុំﷺចាប់អារម្មណ៍ថាមិនសក្តិសមឲ្យលែងលះភរិយាទេ លើកលែងតែដឹងច្បាស់ថាភរិយានោះបានផឹតក្បត់មែន ។"[3]

**លោកស្រី ហ្វាត់ម៉ាស់** - តើសៃយីដអាចអធិប្បាយបំភ្លឺអំពីហេតុផលសេដ្ឋកិច្ចដែលលោកអ្នកប្រាជ្ញលើកមកជាអំណះអំណាង ថាស្វាមីមានសិទ្ធិលែងលះនោះបានទេ ?

**សៃយីដ** - ជាទូទៅ បុរសត្រូវមានមធ្យោបាយថវិកាដើម្បីរៀបការ ។ បុរសភាគច្រើនចំណាយទ្រព្យមួយភាគធំសម្រាប់រៀបអាពាហ៍ពិពាហ៍ សម្រាប់លំនៅដ្ឋាន ទីបំផុតគឺសម្រាប់ទ្រទ្រង់ជីវិតគ្រួសារ ។ ហេតុដូច្នេះ លោកអ្នកប្រាជ្ញកំណត់ថាពេលស្វាមីកាន់ក្តាប់សិទ្ធិលែងលះ ស្វាមីនោះនឹងថ្លឹងមើលយ៉ាងប្រយត្នប្រយែងគ្រប់កត្តាមុននឹងសម្រេចចិត្តលែងលះ ។ ពុំនោះទេ បុរសអាចបាត់បង់ទ្រព្យខ្លះ ហើយរៀបការម្តងទៀតអាចថ្លៃ ។

[3] សូមមើលសៀវភៅ إرشاد المحتاج & الحقوق العزوي ។

ម្យ៉ាងទៀត ភរិយាអាចបាត់បង់ថវិកាមិនច្រើនដូចស្វាមីទេ ។ ក្នុងសាសនាអ៊ីស្លាម ភរិយាមិនត្រូវធ្វើការឬរកប្រាក់ដើម្បីចិញ្ចឹមគ្រួសារទេ ។ នេះជាភារកិច្ចរបស់ស្វាមី អាស្រ័យហេតុនេះឯង ក្រៅពីលក្ខខណៈចិត្តសាស្ត្ររបស់ស្ត្រី បានជាច្បាប់អ៊ីស្លាម (ស្ហរីអ៊ុាស់) ធ្វើអនុសាសន៍ថាសិទ្ធិលែងលះនៅលើស្វាមី ។

**លោកស្រី ហ្វាត់ម៉ាស់** - អ្នកទិតៀននិយាយជាទូទៅថាអ្នកច្បាប់អាស៊ូលុល-បៃត៍ថាកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍តឹងរ៉ឹង និងគ្មានដំណោះស្រាយសម្រាប់ស្ត្រី ។ តើការអះអាងបែបនេះត្រូវទេ ?

**សៃយីដ្** - សេចក្តីថ្លែងការណ៍នេះផ្ទុយនឹងច្បាប់អ៊ីស្លាម ។ ស្ត្រីក្នុងសាសនាអ៊ីស្លាមមិនមែនជាទំនិញឬជាទាសីរបស់អ្នកណាមួយទេ ពោលគឺ មិនមែនរបស់ឪពុក របស់ស្វាមី របស់ជីតា របស់ឪពុកមា ឪពុកធំ ឬបងប្អូនប្រុសនោះទេ ។ ស្ត្រីជាបុគ្គលឯករាជ មានសមត្ថភាពរក្សាអត្តសញ្ញាណ ទ្រព្យ និងជម្រើសខ្លួនឯងបាន ។

សំខាន់ ត្រូវដឹងថានៅក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ជាទូទៅស្វាមីមានសិទ្ធិលែងលះ ក៏ប៉ុន្តែស្វាមីអាចផ្ទេរសិទ្ធិលែងលះរបស់ខ្លួនឲ្យភរិយាប្រើបានតាមខសន្យាចុះនៅក្នុងកិច្ចយល់ព្រមអាពាហ៍ពិពាហ៍ ។

**លោកស្រី ហ្វាត់ម៉ាស់** - សៃយីដ្ចង់និយាយថាសិទ្ធិលែងលះអាចយកមកដាក់ជាខសន្យាបាននៅក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍មែនទេ ?

**សៃយីដ្** - ពិតប្រាកដណាស់ សិទ្ធិអាចលែងលះគ្នាបានអាចយកមកធ្វើជាខសន្យាក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍បាន ។ ត្រូវគិតអំពីការលែងលះ

ប្អូនខ ។ គូស្វាមីភរិយាមានជម្រើសខុសគ្នាដែលខ្លួនចង់យកមកប្រើក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ប្រសិនបើការលែងលះគ្នាដោយមិនអាចចៀសបាននោះនឹងកើតឡើង គឺៈ

១) សិទ្ធិអាចលែងលះបានត្រូវប្រគល់ឲ្យទៅស្វាមីជាស្វ័យប្រវត្តិ លើកលែងតែស្វាមីនោះទៅគ្មានសមត្ថផ្នែកចិត្តសាស្ត្រ (គឺខូចអារម្មណ៍) យ៉ាងជាក់ស្តែង ។ ក្នុងករណីនេះ ចៅក្រមអ៊ីស្លាម (الحاكم الشرعي) ជាអ្នកសម្រេចការលែងលះគ្នា ។

២) ស្វាមីសូមលះបង់ចោលសិទ្ធិអាចលែងលះគ្នាបាន ដែលបានមកខ្លួនជាស្វ័យប្រវត្តិនោះ ហើយប្រគល់សិទ្ធិអាចលែងលះគ្នាបាននេះឲ្យទៅភរិយាខ្លួន ។

៣) គូស្វាមីភរិយាសូមប្រគល់វិធីការលែងលះគ្នាឲ្យទៅតុលាការ ឬឲ្យទៅលោកអ្នកប្រាជ្ញ/អ្នកដឹកនាំ (គឺអ៊ីម៉ាំ) ។

៤) ឲ្យសិទ្ធិអាចលែងលះគ្នាបានទៅអ្នកទាំងពីរស្មើគ្នា ពោលគឺ ឲ្យទៅស្វាមីនិងភរិយា ។

សូមនិយាយអំពីខទីបី ។ ជាការហួសវិស័យដែលផ្អែកទាំងស្រុងទៅលើចៅក្រមអ៊ីស្លាម ដែលមិនស្គាល់លក្ខណៈបុគ្គលគូស្វាមីភរិយានីយមួយៗជាមុន ដែលមិនស្គាល់ជីវិតឬរឿងអ្នកទាំងពីរទេនោះ ហើយជាការហួសវិស័យដែលបុគ្គលនោះមានអំណាចសម្រេចក្តីដែល នៅទីបំផុត អាចធ្វើឲ្យជីវិតអ្នកដទៃដូរ ។ ការលែងលះគ្នាជារឿងផ្ទាល់ខ្លួន នៅក្នុងការលែងលះគ្នានេះមានតែភាគីពីរពាក់ព័ន្ធទេ ដែលអាចសម្រេចចិត្តពេញច្បាប់បានដែលចុះសម្រុងនឹងជីវិតខ្លួន ។

ស្រដៀងគ្នាដែរ ខទីបួន ភាគីទាំងសងខាងមានសិទ្ធិអាចលែងលះគ្នាបាន ស្មើគ្នានោះអាចពិបាករៀបចំធ្វើ ។ ឧទាហរណ៍ ភាគីម្ខាងចង់លែងលះ តែភាគីម្ខាងទៀតជំទាស់ អាពាហ៍ពិពាហ៍ឬការលែងលះគ្នានឹងគាំងព្រោះ ភាគីទាំងសងខាងស្មើគ្នាក្នុងការសម្រេចចិត្ត ។ មិនគប្បីធ្វើកិច្ចសន្យាលែងលះគ្នាប្រភេទនេះទេ ។

ខពីរដែលនៅសល់ជាជម្រើសសេរី៖ ឬមួយសិទ្ធិជាស្វ័យប្រវត្តិនោះនៅលើស្វាមី ឬមួយស្វាមីប្រគល់សិទ្ធិអាចលែងលះបានរបស់ខ្លួននោះឲ្យទៅភរិយា ។ យើងបាននិយាយរួចមកហើយ ច្បាប់អ៊ីស្លាមនឹងមិនសម្រេចទេថាសិទ្ធិអាចលែងលះគ្នាបាននោះ នឹងត្រូវប្រគល់ឲ្យទៅភាគីភរិយាតែម្ខាង ។ នៅសល់តែជម្រើសក្រោយគេ គឺសិទ្ធិអាចលែងលះគ្នាបាននៅលើស្វាមី (ដោយមានការឲ្យយោបល់គ្នាទៅវិញទៅមក និងមានការប្រឹក្សាជាមួយភរិយា) ។[4]

**លោកស្រី ហ្វាត់ម៉ាស់** - បើច្បាប់អ៊ីស្លាមមិនអនុគ្រោះស្ត្រីឲ្យមានសិទ្ធិលែងលះទេ តើអ៊ីស្លាមនឹងការពារស្ត្រីដូចម្ដេចពីស្វាមីដែលយកសាសនាជាលេសដើម្បីអះអាងថាទង្វើខ្លួនដែលគួរឲ្យសង្ស័យនោះជាទង្វើត្រឹមត្រូវ ?

**សៃយីដ់** - អ៊ីស្លាមមិនបានដាក់បង្គាប់ថាស្វាមីត្រូវតែក្ដាប់សិទ្ធិលែងលះទាំងស្រុងទេ ។ អំពីកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍របស់ស្ត្រី គេអាចប្រឹក្សាជាមួយភរិយាបាន គេអាចប្រាប់ភរិយាអំពីសិទ្ធិនិងជម្រើសរបស់ភរិយានោះបាន ។ បន្ទាប់ពីនោះ គេទុកឲ្យគូស្វាមីភរិយាជាអ្នកសម្រេចចិត្ត

[4] សូមមើលគូរអាន ២:២៣៣ ។ ទោះជាអាយ៉ាស់នេះស្ដីអំពីការបំបៅកូនក្ដី វាសមស្របនឹងវិស័យច្រើនទៀតនៃជីវិតគូស្វាមីភរិយា ។

ជ្រើសយកអ្វីដែលប្រសើរសម្រាប់ខ្លួន ។

គេត្រូវចងចាំថាទោះបីស្វាមីមានសិទ្ធិអាចលែងលះបាន ជាស្វ័យប្រវត្តិក៏ដោយ វានៅតែមានលក្ខខណ្ឌ ដូចយើងបាននិយាយរួចមកហើយ ។ ទោះជាសិទ្ធិអាចលែងលះបាននោះអាចនៅក្នុងកណ្ដាប់ដៃស្វាមីក្ដី ភរិយានៅតែមានឱកាសលែងលះស្វាមីបាន ។

**លោកស្រី ហ្វាត់ម៉ាស់** - តើភរិយាអាចលែងលះស្វាមីបានដូចម្ដេច បើសិទ្ធិលែងលះនៅក្នុងកណ្ដាប់ដៃស្វាមីនោះ ?

**សៃយីដ** - ទោះបីស្វាមីជាអ្នកក្ដាប់អំណាចលែងលះក៏ដោយ ភរិយានៅតែមានមធ្យោបាយសូមលែងលះជានិច្ច ។ គេហៅមធ្យោបាយទាំងនោះថា ឃ្វុលអ៊ុ (خُلْع), មូបារ៉ោះត៊ូ (مباراة), អាល់-ហ្វាគីម អាល់-ស្ហារអ៊ី (الحاكِم الشَرْع) ហើយមធ្យោបាយលែងលះទាំងអស់នេះ ត្រូវការជំនួយការពីចៅក្រមអ៊ីស្លាម ឬអ្នកដឹកនាំអ៊ីស្លាម (គឺអ៊ីម៉ាំ) ដើម្បីសម្រេចរឿងលែងលះគ្នា ។

ឃ្វុលអ៊ុ (បោះបង់ចោល) ពាក្យសម្រាប់ប្រើចំពោះភរិយាដែលកើតមានការមិនចូលចិត្តនិងស្អប់ខ្ពើមស្វាមីខ្លាំង ដល់ថ្នាក់មិនបំពេញករណីយកិច្ចរួមដំណេកជាមួយស្វាមី ។ ក្នុងការលែងលះពិសេសនេះ ភរិយានឹងត្រូវលះបង់ខាន់ស្លា អាចត្រូវបង់ទឹកប្រាក់មួយចំនួនថែមពីលើខាន់ស្លានោះទៀតផងដើម្បីមានសេរីភាពវិញ ។

មូបារ៉ោះត៊ូ គឺពេលភរិយានិងស្វាមីកើតមានការស្អប់ខ្ពើមគ្នាទៅវិញទៅមក ។ ហេតុដូច្នេះ ដើម្បីនឹងឲ្យភរិយាមានស្វ័យភាព ភរិយានោះនឹងត្រូវឲ្យទ្រព្យមួយចំនួនរបស់ខ្លួនទៅស្វាមី ។ រវាងឃ្វុលអ៊ុនិងមូបារ៉ោះត៊ូ ខុសគ្នាត្រង់ថ្លៃដែលត្រូវបង់នោះមិនត្រូវលើសតម្លៃខាន់ស្លាទេ ព្រោះវាជាការ

ស្អប់គ្នាទៅវិញទៅមក ។

អាល់-ហ៊ាគីម អាល់-ស្វារអ៊ី ជាការលែងលះគ្នាដោយមានចៅក្រមអ៊ីស្លាម ឬអ៊ីម៉ាំជាអធិបតីដោយមានឬដោយពុំមានការយល់ព្រមពីស្វាមី ។ ការលែងលះពិសេសនេះត្រូវប្រព្រឹត្តិឡើងក្នុងករណីដែលភរិយា ដែលពុំមានអំណាចលែងលះនោះ សូមលែងលះដោយសមហេតុសមផលតែស្វាមីមិនព្រមឲ្យលែងលះទេ ។

ពេលស្វាមីមិនព្រមឲ្យលែងលះទេ ហើយការទាមទារសូមលែងលះរបស់ភរិយានោះសមហេតុសមផលមែន តុលាការអ៊ីស្លាមឬអ៊ីម៉ាំអាចធ្វើអន្តរាគមន៍បាន ។ តុលាការអ៊ីស្លាមឬអ៊ីម៉ាំអាចព្រមានស្វាមី ដាក់ឲ្យបញ្ជាឲ្យស្វាមីនោះលែងលះភរិយា ឬបញ្ចប់ការលែងលះដោយមានការយល់ព្រមឬដោយមិនមានការយល់ព្រមពីស្វាមី ។ ការលែងលះប្រភេទនេះហៅថា អាល់-ហ៊ាគីម អាល់-ស្វារអ៊ី ។

បើភរិយាមិនមានអំណាចលែងលះទេ ភរិយានោះចង់បែកផ្លូវគ្នា ត្រូវតែធានាការទាមទាររបស់ភរិយានោះ (ពោលគឺ ត្រូវឲ្យភរិយានោះលែងលះ) ។ លោកអ្នកប្រាជ្ញបានបញ្ជាក់លក្ខខណ្ឌសម្រាប់ករណីបែបនេះ ។ ម្យ៉ាងទៀត ក្នុងករណីខ្លះអាពាហ៍ពិពាហ៍ត្រូវមោឃៈជាស្វ័យប្រវត្តិដោយគ្មានការថ្លែងប្រកាសឬគ្មានវិធីការតាមច្បាប់ ។ ករណីទាំងនោះគឺ៖

១) អាពាហ៍ពិពាហ៍ត្រូវមោឃៈ - ប្រសិនបើស្វាមីលាក់រោគវិកលចរិតមុនធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ។
២) អាពាហ៍ពិពាហ៍ត្រូវមោឃៈ - ប្រសិនបើស្វាមីលាក់រោគចម្លងឬរោគធ្ងន់មុនធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ។
៣) អាពាហ៍ពិពាហ៍ត្រូវមោឃៈ - ប្រសិនបើស្វាមីលាក់មិនឲ្យដឹងថាខ្លួនជា

មនុស្សកម្រៀវ ។
៤) អាពាហ៍ពិពាហ៍ត្រូវមោឃៈ - ប្រសិនបើស្វាមីបោះបង់សាសនា ។ ចាប់ពីពេលស្វាមីបោះបង់សាសនាភ្លាម អាពាហ៍ពិពាហ៍ត្រូវមោឃៈភ្លាមមួយរំពេច ។

៥) វិធីការលែងលះត្រូវអនុវត្តិ - ប្រសិនបើស្វាមីចាប់ផ្តើមមានរោគវិកលចរិតក្នុងពេលរៀបការ ។
៦) វិធីការលែងលះត្រូវអនុវត្តិ - ប្រសិនបើស្វាមីធ្វើបាបដល់រាងកាយភរិយា ឬហិង្សាទៅលើភរិយា ។
៧) វិធីការលែងលះត្រូវអនុវត្តិ - ប្រសិនបើស្វាមីលែងចិញ្ចឹមភរិយា ។
៨) វិធីការលែងលះត្រូវអនុវត្តិ - ប្រសិនបើស្វាមីចោលភរិយាព្រោះតែត្រូវជាប់ពន្ធនាគារយ៉ាងយូរ ព្រោះតែបាត់ខ្លួន ឬព្រោះតែបោះបង់ចោលភរិយា ។
៩) វិធីការលែងលះត្រូវអនុវត្តិ - ប្រសិនបើស្វាមីកើតរោគឆ្លង ។
១០) វិធីការលែងលះត្រូវអនុវត្តិ - ប្រសិនបើស្វាមីទៅជាមនុស្សកម្រៀវក្នុងពេលរៀបការ ហើយភរិយាមិនអាចអត់ទ្រាំរឿងនេះបាន ។

មានករណីមួយដែលលោកអ្នកប្រាជ្ញខ្វែងមតិគ្នា គឺអសមត្ថភាពផ្លូវភេទ (គឺងាប់លិង្គ) ។ លោកអ្នកប្រាជ្ញខ្លះថាបើស្វាមីដឹងថាខ្លួនអសមត្ថភាពផ្លូវភេទមុនរៀបការ ហើយបិទរឿងនេះមិនឲ្យខាងស្រីដឹងទេដោយចេតនា នេះជាហេតុផលឲ្យលែងលះឬឲ្យមោឃៈអាពាហ៍ពិពាហ៍ ។ ម្យ៉ាងទៀត បើភរិយាបិទរឿងនេះ ច្រើនឆ្នាំក្រោយមកប្តឹងហើយលើកហេតុផលអសមត្ថភាពផ្លូវភេទនេះក្នុងការសូមលែងលះគ្នា ស្វាមីនោះត្រូវលែងលះភរិយានោះ ។

លោកអ្នកប្រាជ្ញឯទៀតថា បើស្វាមីមានសមត្ថភាពរួមភេទជាមួយភរិយា

មួយដង ហើយក្រោយមកទៅជាអសមត្ថភាពផ្លូវភេទ នេះមិនមែនជាហេតុផលតែមួយគត់សម្រាប់លែងលះទេ ។ លោកអ្នកប្រាជ្ញទាំងនេះសូមណែនាំឲ្យគូស្វាមីភរិយាស្វែងរកជំនួយវិជ្ជាពេទ្យឬចិត្តសាស្ត្រ ដើម្បីដោះស្រាយបញ្ហានេះជាជាងលែងលះគ្នា ។ តែបើភរិយាមិនអាចស៊ូទ្រាំបានទេ លោកអ្នកប្រាជ្ញនឹងឲ្យលែងលះគ្នា ។

**លោកស្រី ហ្វាត់ម៉ាស់** - តើវិធីការលែងលះនោះយ៉ាងម៉េច ?

**សៃយីដ្** - គម្ពីរអានចែងប្រាប់របៀបលែងលះគ្នាដែលត្រឹមត្រូវគឺ៖

فَأَمۡسِكُوهُنَّ بِمَعۡرُوفٍ أَوۡ فَارِقُوهُنَّ بِمَعۡرُوفٖ

*ចូរពួកអ្នកឃាត់ឲ្យពួកនាងនៅដោយយុត្តិធម៌ ឬពួកអ្នកបែកពីពួកនាងដោយយុត្តិធម៌ (៦៥:២) ។*

وَإِنۡ خِفۡتُمۡ شِقَاقَ بَيۡنِهِمَا فَٱبۡعَثُواْ حَكَمٗا مِّنۡ أَهۡلِهِۦ وَحَكَمٗا مِّنۡ أَهۡلِهَآ إِن يُرِيدَآ إِصۡلَٰحٗا يُوَفِّقِ ٱللَّهُ بَيۡنَهُمَآۗ

*បើពួកអ្នកក្រែងអ្នកទាំងពីរបែកបាក់គ្នា (គឺស្វាមីភរិយា) ចូរពួកអ្នកតែងតាំងអាជ្ញាកណ្តាលម្នាក់ ក្នុងគ្រួសាររបស់បុរស (គឺស្វាមី) និងអាជ្ញាកណ្តាលម្នាក់ទៀតក្នុងគ្រួសាររបស់នាង (គឺភរិយា) ។ បើអ្នកទាំងពីរប្រាថ្នាជានឹងគ្នាវិញ អល់ឡោះហ៍នឹងឲ្យមានការស្រុះស្រួលគ្នាវិញបានរវាងអ្នកទាំងពីរ (៤:៣៥) ។*

ការលែងលះទាំងអស់សុទ្ធតែមានលក្ខខណ្ឌ និងអាស្រ័យលើស្ថានភាព ។ គម្ពីរអានរៀបរាប់អំពីវិធីការសម្រាប់ការលែងលះសាមញ្ញ ថា៖

وَإِذَا طَلَّقْتُمُ ٱلنِّسَآءَ فَبَلَغْنَ أَجَلَهُنَّ فَأَمْسِكُوهُنَّ بِمَعْرُوفٍ أَوْ سَرِّحُوهُنَّ بِمَعْرُوفٍۚ وَلَا تُمْسِكُوهُنَّ ضِرَارًا لِّتَعْتَدُواْۚ وَمَن يَفْعَلْ ذَٰلِكَ فَقَدْ ظَلَمَ نَفْسَهُۥۚ

*ពេលពួកអ្នកលែងលះស្ត្រី (ជាភរិយា) ហើយពួកនាងបានរង់ចាំដល់ពេលកំណត់ហើយ (គឺគ្រប់អ៊ិដ្ដដាស្ង់) បន្ទាប់ពីនោះពួកអ្នកនឹងយកនាងវិញបាន [ដោយរៀបការជាមួយនាងជាថ្មី] ដោយគុណធម៌ ឬពួកអ្នកឲ្យនាងមានសេរីភាពដោយគុណធម៌ ។ តែពួកអ្នកកុំឃាត់ខ្លួននាងទុកក្នុងបំណងធ្វើអាក្រក់លើពួកនាងឡើយ ព្រោះពួកអ្នកនឹងប្រព្រឹត្តល្មើស[ច្បាប់] ។ អ្នកណាមួយធ្វើបែបនេះ អ្នកនោះធ្វើកំហុសចំពោះខ្លួនឯងផ្ទាល់ (២:២៣១) ។*

وَإِذَا طَلَّقْتُمُ ٱلنِّسَآءَ فَبَلَغْنَ أَجَلَهُنَّ فَلَا تَعْضُلُوهُنَّ أَن يَنكِحْنَ أَزْوَٰجَهُنَّ إِذَا تَرَٰضَوْاْ بَيْنَهُم بِٱلْمَعْرُوفِۗ

*ពេលពួកអ្នកលែងលះស្ត្រី ហើយពួកនាងបានរង់ចាំដល់ពេលកំណត់ហើយ (គឺគ្រប់អ៊ិដ្ដដាស្ង់) ចូរពួកអ្នកកុំឃាត់ឃាំងពួកនាងមិនឲ្យពួកនាងទៅរៀបការជាមួយស្វាមីពួកនាងឡើយ (គឺស្វាមីមុន) បើពួកគេបានយល់ព្រមមូលមតិគ្នាដោយគុណធម៌ (២:២៣២) ។*

لَّا جُنَاحَ عَلَيْكُمْ إِن طَلَّقْتُمُ ٱلنِّسَآءَ مَا لَمْ تَمَسُّوهُنَّ أَوْ تَفْرِضُواْ لَهُنَّ فَرِيضَةًۚ وَمَتِّعُوهُنَّ

*ពុំមានទោសលើពួកអ្នកទេ បើពួកអ្នកលែងលះភរិយាក្នុងករណីដែលពួកអ្នកពុំទាន់បានប៉ះពាល់ពួកនាង (គឺរួមដំណេក) ឬពួកអ្នកពុំទាន់បានកំណត់តម្លៃប្រាក់ខាន់ស្លាឲ្យពួកនាងនៅឡើយទេនោះ ។ ពួកអ្នកចូរឲ្យទៅពួកនាងនូវអំណោយនីមួយដែលប្រកបដោយគុណធម៌ (២:២៣៦) ។*

وَلِلْمُطَلَّقَٰتِ مَتَٰعٌۢ بِٱلْمَعْرُوفِۖ

*បណ្តាស្ត្រីដែលត្រូវលែងលះមានសិទ្ធិបាននូវគ្រឿងផ្គត់ផ្គង់ជីវិតយ៉ាងសមរម្យ [ដែលខាងប្តីប្រគល់ឲ្យ] (២:២៤១) ។*

وَٱلْمُطَلَّقَٰتُ يَتَرَبَّصْنَ بِأَنفُسِهِنَّ ثَلَٰثَةَ قُرُوٓءٍۚ وَلَا يَحِلُّ لَهُنَّ أَن يَكْتُمْنَ مَا خَلَقَ ٱللَّهُ فِىٓ أَرْحَامِهِنَّ

*បណ្តាស្ត្រីដែលត្រូវលែងលះគ្នា (ពីប្តី) នឹងរង់ចាំអស់រយៈពេលបីរដូវខែ (គឺមានប្រចាំខែបីដង) ។ មិនអនុញ្ញាតឲ្យពួកនាងបិទបាំងនូវអ្វីដែលអល់ឡោះហ៍បានបង្កើតក្នុងផ្ទៃពួកនាងទេ (២:២២៨))*

មិនថាឡើយភាគីណាមួយមានអំណាចលែងលះក៏ដោយ ពេលចាប់ផ្តើមអនុវត្តិការលែងលះ ភាគីទាំងពីរត្រូវគោរពវិធីការដើម្បីនឹងឲ្យការលែងលះសមស្របតាមសាសនា ។

ការលែងលះមានពីរប្រភេទ ការលែងលះដែលដកវិញបាន (الطلاق الرجعي) ការលែងលះដែលមិនអាចដកវិញបាន (الطلاق البائن) ។ ការលែងលះដែលដកវិញបានប្រៀបបាននឹងរយៈពេលឲ្យយោបល់ (អ៊ីដ្ហ្ទាស្ហ) បីខែ ។ នៅក្នុងអំឡុងពេលនេះ គូស្វាមីភរិយាអាចជាគ្នាវិញបានដោយមិនបាច់ធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍សាថ្មីទេ (ពោលគឺ មិនបាច់រៀបការសាថ្មីទេ ។

មួយទៀត ការលែងលះដែលមិនអាចដកវិញបានរំលាយអាពាហ៍ពិពាហ៍ភ្លាមៗ ។ តែនៅតែមានរយៈពេលត្រឡប់វិញបាន (អ៊ីដ្ហ្ទាស្ហ) បីខែសម្រាប់ភរិយា ។ បើគូស្វាមីភរិយាសម្រេចចិត្តជាគ្នាវិញ ត្រូវតែធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍សាថ្មី (ពោលគឺ ត្រូវតែរៀបការសាថ្មី) ។

**លោកស្រី ហ្វាត់ម៉ាស្ហ** - តើការលែងលះដែលអាចដកវិញបាននិងការលែង

លះដែលមិនអាចដកវិញបាននោះមានវិធីការប្លែកគ្នាទេ ?

**សៃយីដ្** - ពិតជាប្លែកគ្នា ។ ការលែងលះដែលអាចដកវិញបានភាគច្រើនមានវិធីការដូចតទៅ គឺៈ ភរិយាត្រូវបាត់ធ្លាក់ឈាមក្រោយពីសម្រាលកូនរួចសិន ឬត្រូវជ្រះស្អាតពីរដូវខែ ឬត្រូវចាំឲ្យផុតពីរដូវខែសិនបើបានរួមភេទ ។ នេះមានន័យថា បើភរិយាកំពុងតែមានរដូវខែ ឬធ្លាក់ឈាមក្រោយពីសម្រាលកូនរួច គូស្វាមីភរិយាត្រូវរង់ចាំឲ្យខួបរបស់ភរិយាកន្លងផុតសិនមុននឹងចាប់សម្រេចការលែងលះ ។ ឬ បើគូស្វាមីភរិយាបានរួមភេទ គូស្វាមីភរិយាត្រូវតែរង់ចាំឲ្យរដូវខែ ដែលភរិយានឹងមានពេលខាងមុខនោះឲ្យចប់សិន មុននឹងចាប់អនុវត្តិវិធីការលែងលះគ្នា ។

១) ត្រូវតែប្រកាសបំណងចង់លែងលះ ឬត្រូវចាត់បញ្ជូនអ្នកតំណាង (وكيل) បុគ្គលដែលចង់លែងលះ ។
២) ឲ្យមានសាក្សីត្រឹមត្រូវពីរនាក់ (عادل) ជាអ្នកពិនិត្យមើលនៅក្នុងការលែងលះនោះ ឬស្តាប់ការណ៍នៅក្នុងអង្គប្រជុំនោះ ។

ពុំមានឃ្លាជាក់លាក់សម្រាប់ថាក្នុងវិធីការលែងលះទេ ។ ក៏ប៉ុន្តែគប្បីស្វាមីឬភរិយាប្រកាសជាភាសាអារ៉ាប់ ។ បើមិនអាចធ្វើបានទេ ប្រើភាសាផ្សេងបាន ។ ស្វាមីឬភរិយានោះអាចថាៈ "ខ្ញុំលែងលះអ្នក" នៅចំពោះមុខសាក្សី ឬអ្នកតំណាងអាចធ្វើការលែងលះជំនួសស្វាមីឬភរិយានោះបាន ។ បន្ទាប់ពីនោះត្រូវគោរពរយៈពេលរង់ចាំ (អ៊ីដ្ឌដ្ហាស្ស់) គឺឲ្យមានរដូវខែបីដងឬបីខែ (បើរដូវខែរបស់ភរិយានោះមិនធម្មតា) ។

នៅក្នុងអំឡុងពេលរង់ចាំ (អ៊ីដ្ឌដ្ហាស្ស់) ក្នុងការលែងលះដែលដកវិញបាននោះ ស្វាមីត្រូវចាយវាយដើម្បីចិញ្ចឹមភរិយា ។ ស្វាមីនោះមិនត្រូវធ្វើទុក្ខភរិយាឬរឹតត្បឹតគ្រឿងទ្រទ្រង់ភរិយាទេ ។ ភរិយាត្រូវនៅជាមួយស្វាមីក្នុង

លំនៅដ្ឋានតែមួយ ហើយមិនចាំបាច់បិទបាំងមុខដោយសំពត់ឃ្លុំមុខនៅចំពោះមុខស្វាមីក្នុងផ្ទះនោះទេ ។ ស្វាមីមិនមានសិទ្ធិដេញភរិយានោះចេញពីផ្ទះទេ ។

لَا تُخْرِجُوهُنَّ مِنْ بُيُوتِهِنَّ وَلَا يَخْرُجْنَ

*ចូរពួកអ្នកកុំបណ្តេញពួកនាងចេញពីលំនៅដ្ឋានរបស់ពួកនាង និងកុំឲ្យពួកនាងចេញពីលំនៅដ្ឋាន (៦៥:១) ។*

ពេលភរិយារង់ចាំអស់រយៈពេលបីរដូវខែពេញហើយ ឬបីខែបានកន្លងផុតហើយ ភរិយានោះបានលែងលះជាស្រេច ។ បើភរិយានោះមានផ្ទៃពោះត្រូវចិញ្ចឹមបន្តលុះត្រាតែភរិយានោះសម្រាលកូនរួច ។

**លោកស្រី ហ្វាត់ម៉ាស់** - តើការលែងលះដែលមិនអាចដកវិញបាននោះត្រូវអនុវត្តិដូចម្តេច ?

**សៃយីដ** - គួយ៉ាងការលែងលះដែលមិនអាចដកវិញបាននោះគឺ ឃុលអ៊ុ (خُلْع), មូបារ៉ោះត៍ (مبارة), អាល់-ហ៊ាគីម អាល់-ស្ហារអ៊ី (الحاكِم الشَرْع តុលាការអ៊ីស្លាម) ។[5]

ការលែងលះដែលមិនអាចដកវិញបាននោះ រំលាយអាពាហ៍ពិពាហ៍ភ្លាមចាប់ពីពេលហាមាត់ថាភ្លាម វាជាការសម្រេចផ្តាច់ព្រ័ត្រ ឥតបកក្រោយបាន ។ ក៏ប៉ុន្តែភរិយានៅតែត្រូវរង់ចាំមួយរយៈពេល តែស្វាមីមិនចាំបាច់ចិញ្ចឹមភរិយានោះទេក្នុងអំឡុងពេលរង់ចាំអ៊ីដ្ឌដ្ហាស់នោះ ។

---

[5] *សូមមើលសៀវភៅច្បាប់អ៊ីស្លាម វគ្គស្តីអំពីការលែងលះដាច់ ។*

លើសពីនោះ បុគ្គលទាំងគូមិនអាចរស់នៅជាមួយគ្នាបានទៀតទេ ហើយអតីតភរិយានោះត្រូវទទូរមុខនៅចំពោះមុខអតីតស្វាមី ។ ប្រសិនបើអ្នកទាំងពីរចង់ត្រឡប់មកជាគូស្វាមីភរិយាវិញ ត្រូវតែរៀបអាពាហ៍ពិពាហ៍សាថ្មី ។

**លោកស្រី ហ្វាត់ម៉ាស់** - រឿងរយៈពេលរង់ចាំអ៊ីដ្ដដ្ឋាស់ ក្នុងករណីអាពាហ៍ពិពាហ៍មិនបានរួមដំណេកទេនោះ ភរិយាមិនបាច់រង់ចាំទេ មែនទេ ?

**សៃយីដ្** -អាពាហ៍ពិពាហ៍ខ្លះត្រូវរំលាយមុនរួមដំណេក ។ គួរអានឆ្លើយតបសំណួរលោកស្រីរឿងរយៈពេលរង់ចាំអ៊ីដ្ដដ្ឋាស់ ។

إِذَا نَكَحْتُمُ ٱلْمُؤْمِنَٰتِ ثُمَّ طَلَّقْتُمُوهُنَّ مِن قَبْلِ أَن تَمَسُّوهُنَّ فَمَا لَكُمْ عَلَيْهِنَّ مِنْ عِدَّةٍ تَعْتَدُّونَهَا ۖ فَمَتِّعُوهُنَّ وَسَرِّحُوهُنَّ سَرَاحًا جَمِيلًا

*កាលណាពួកអ្នកបានរៀបការជាមួយស្ត្រីមានសទ្ធា ហើយពួកអ្នកបានលែងលះពួកនាងមុនពួកអ្នកបានប៉ះពាល់ពួកនាង កាលនោះពួកអ្នកមិនបាច់ឲ្យពួកនាងរង់ចាំសិនទេ ។ ចូរពួកអ្នកផ្ដត់ផ្គង់ពួកនាង ហើយចូរឲ្យពួកនាងមានសេរីភាពវិញដោយវិធីល្អប្រសើរ (៣៣:៤៩) ។*

**លោកស្រី ហ្វាត់ម៉ាស់** - ហេតុអ្វីគួរអានយកចិត្តទុកដាក់ខ្លាំងអំពីរយៈពេលបីខែស្ត្រីមានរដូវខែនោះដើម្បីនឹងឲ្យការលែងលះបានដាច់ស្រេច ?

**សៃយីដ្** - មូលហេតុរឿងនេះមានពីរ ។ មូលហេតុទីមួយ ពាក្យស្លោកថា "ពេលវេលាអាចព្យាបាលចិត្តបាន" នោះឆ្លើយបញ្ជាក់រឿងនេះបានយ៉ាងល្អ ។ មូលហេតុទីពីរ រយៈពេលរង់ចាំធានាសុខមាលភាពនិងកំណើតកូនដែលមិនទាន់កើត ។

រយៈពេលរង់ចាំបីខែ (សម្រាប់ការលែងលះដែលអាចដកវិញបាន) ជា

ឧបសគ្គសម្រាប់គូស្វាមីភរិយាមុនការកាត់ក្ដីដាច់ស្រេច ។ រយៈពេលនេះ ជាឱកាសសម្រាប់គិតនិងសម្រាប់សម្រុះសម្រួលគ្នាវិញ ។ រយៈពេលនេះ អនុញ្ញាតឲ្យគូស្វាមីភរិយាពិចារណា ពិនិត្យពិច័យយ៉ាងហ្មត់ចត់អំពីការសម្រេចចិត្តរៀងៗខ្លួន ។ រយៈពេលនេះធ្វើឲ្យអ្នកទាំងពីរនឹកគ្នានិងធ្វើឲ្យអ្នកទាំងពីរដោះស្រាយទំនាស់ខ្លួន ។

រយៈពេលរងចាំរបស់ស្រ្តី នៅក្នុងការលែងលះដែលមិនអាចដកវិញបាន នោះមានគោលបំណងទុកពេលវេលាឲ្យស្រ្តីបានធូរស្បើយចិត្ត មុននឹងសាងជីវិតថ្មី ។

អ៊ីស្លាមបារម្ភជាទីបំផុតអំពីការការពារសិទ្ធិជនគ្មានកំហុស ដូចជាកូនមិនទាន់កើតជាដើម ។ អ៊ីស្លាមដាក់បង្គាប់ថាដរាបណាភរិយានៅក្នុងរយៈពេលរង់ចាំបីខែ ក្នុងការលែងលះដែលអាចដកវិញបាននោះ ដរាបនោះស្វាមីត្រូវឧបត្ថម្ភភរិយាដូចបាននិយាយរួចមកហើយ ។

បើភរិយាមានផ្ទៃពោះ ស្វាមីត្រូវបន្តការឧបត្ថម្ភភរិយានោះដូចមុនលុះត្រាបានសម្រាលកូន ។ ដូចគ្នាដែរ នៅក្នុងការលែងលះដែលមិនអាចដកវិញបាននោះ បើភរិយាដឹងថាមានផ្ទៃពោះ អតីតស្វាមីត្រូវបន្តការចិញ្ចឹមភរិយានោះលុះបានសម្រាលកូន ។

ចុងក្រោយ បើគូស្វាមីភរិយាលែងលះគ្នាហើយមូលមតិគ្នាថាម្ដាយនឹងបំបៅដោះកូន អតីតស្វាមីត្រូវតែបន្តការចាយវាយចិញ្ចឹមអតីតភរិយានិងកូនលុះកូនដាច់ដោះ ពោលគឺ បានបំបៅដោះកូនបានពីរឆ្នាំ ឬលុះដល់អាយុដែលឪពុកម្ដាយជាអ្នកសម្រេច ។

أَسْكِنُوهُنَّ مِنْ حَيْثُ سَكَنتُم مِّن وُجْدِكُمْ وَلَا تُضَآرُّوهُنَّ لِتُضَيِّقُوا۟ عَلَيْهِنَّ ۚ وَإِن

كُنَّ أُوْلَٰتِ حَمۡلٖ فَأَنفِقُواْ عَلَيۡهِنَّ حَتَّىٰ يَضَعۡنَ حَمۡلَهُنَّۚ فَإِنۡ أَرۡضَعۡنَ لَكُمۡ فَـَٔاتُوهُنَّ أُجُورَهُنَّ وَأۡتَمِرُواْ بَيۡنَكُم بِمَعۡرُوفٖۖ

*ចូរពួកអ្នកឲ្យពួកនាង (បណ្តាស្ត្រីលែងលះ) ស្នាក់នៅនាលំនៅដ្ឋានពួកអ្នក តាមសមត្ថភាពពួកអ្នក ។ ចូរពួកអ្នកកុំព្យាបាទពួកនាងដោយធ្វើឲ្យពួកនាងចង្អៀតចង្អល់ចិត្ត ។ បើពួកនាងមានផ្ទៃពោះ ចូរពួកអ្នកផ្គត់ផ្គង់ពួកនាងលុះត្រាពួកនាងបានសម្រាលកូនរួច ។ បើពួកនាងបំបៅកូនពួកអ្នក ចូរពួកអ្នកប្រគល់ថ្លៃឈ្នួលឲ្យពួកនាង ហើយចូរពួកអ្នកពិភាក្សាគ្នាដោយស្របតាមគន្លងធម៌ (៦៥:៦) ។*

**លោកស្រី ហ្វាត់ម៉ាស់** - ពាក់ព័ន្ធនឹងស្វាមី ដរាបណាសិទ្ធិលែងលះនៅក្នុងកណ្តាប់ដៃស្វាមី យោលតាមបច្ចេកទេសសម្រាប់អនុវត្ត ដរាបនោះស្វាមីនោះមិនចាំបាច់ធ្វើតាមបញ្ញើខលក្ខខណ្ឌ ឬត្រូវការជំនួយពីតុលាការដើម្បីលែងលះទេ មែនទេ ?

**សៃយីដ្** - តាមបច្ចេកទេសសម្រាប់អនុវត្ត អ្នកណាក៏ដោយដែលមានសិទ្ធិលែងលះ អ្នកនោះមិនចាំបាច់ធ្វើតាមបញ្ញើខលក្ខខណ្ឌទេ ពេលអ្នកនោះអះអាងថាខ្លួនមានហេតុផលត្រឹមត្រូវសម្រាប់លែងលះ ។ ក៏ប៉ុន្តែ ពេលណាមានការសូមលែងលះ ពេលនោះត្រូវគោរពតាមវិធីការ មិនថាភាគីណាមួយជាអ្នកមានអំណាចលែងលះក៏ដោយ ។

**លោកស្រី ហ្វាត់ម៉ាស់** - បើភរិយាមានអំណាចលែងលះ តើភរិយានោះនឹងត្រូវគេដាក់កម្រិតលក្ខខណ្ឌឬហេតុផលទេដើម្បីសូមលែងលះ ?

**សៃយីដ្** - បើភរិយាមានអំណាចលែងលះ ហើយសន្មត់ថាអាពាហ៍ពិពាហ៍របស់ភរិយានោះមានកិច្ចព្រមព្រៀងសាមញ្ញ ពុំមានការកែប្រែឬពុំបាន

ដាក់ខសន្យាទេ (ដូចយើងបាននិយាយរួចមកហើយនៅក្នុងវគ្គ "សិទ្ធិរបស់គូស្វាមីភរិយា") អំណាចលែងលះរបស់ភរិយាបានត្រឹមតែ "សិទ្ធិរបស់គូស្វាមីភរិយា" នេះប៉ុណ្ណោះ ថែមទាំងខលក្ខខណ្ឌលែងលះ/មោឃៈដែលបាននិយាយរួចមកហើយ ដែលថា បើអ្នកទាំងពីរបានប្រព្រឹត្តិល្មើសខលក្ខខណ្ឌនោះវាជាហេតុផលស្របច្បាប់សម្រាប់ធ្វើវិធីការលែងលះគ្នា ។

ក៏ប៉ុន្តែ ភរិយាមានមធ្យោបាយបំពេញតាមបំណង ។ ភរិយាមានជម្រើសពិសេស ដរាបណាភរិយានោះមិនប្រព្រឹត្តល្មើសច្បាប់អ៊ីស្លាមទេ ។ ឧទាហរណ៍ថាភរិយាមិនមានអំណាចលែងលះទេ វានៅតែមានមធ្យោបាយបំពេញតាមសេចក្ដីត្រូវការរបស់ភរិយានោះ ។

ភរិយាអាចបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ក្រោមការយល់ព្រមរបស់ស្វាមី នូវខលក្ខខណ្ឌខ្លះដែលស្វាមីត្រូវតែព្រមធ្វើតាម ។ អាស្រ័យហេតុនេះ បើល្មើសខសន្យានេះភរិយានឹងមានជម្រើសបន្តអាពាហ៍ពិពាហ៍ឬរំលាយអាពាហ៍ពិពាហ៍នោះចោល ។

**លោកស្រី ហ្វាត់ម៉ាស់** - សៃឃីដ្ធអាចលើកតួយ៉ាងមកអធិប្បាយបំភ្លឺបានទេ ?

**សៃឃីដ្ធ** - ឧទាហរណ៍ ស្ត្រីនឹងដាក់លក្ខខណ្ឌបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ថាខ្លួនមិនចង់ឲ្យស្វាមីខ្លួនប្រើសិទ្ធិដែលច្បាប់អនុញ្ញាតឲ្យស្វាមីខ្លួននោះដើម្បីរៀបការភរិយាមួយទៀតទេ ដរាបណាស្វាមីខ្លួននៅតែរៀបការជាមួយខ្លួន ។ បើស្វាមីខ្លួនរៀបការភរិយាមួយទៀត ស្ត្រីនោះមានសិទ្ធិលែងលះស្វាមីនោះ ទោះបីស្វាមីជាម្ចាស់ឯកសិទ្ធិលែងលះក៏ដោយ ។ ស្ត្រីអាចមានសិទ្ធិជាអ្នកតំណាងស្វាមី (វ៉ាគីល) សម្រាប់សូមលែងលះក្នុងការលែងលះរបស់ខ្លួនឯងផ្ទាល់តែម្ដង តាមរយៈតុលាការ

អ៊ីស្លាម ។

មានការដាក់លក្ខខណ្ឌផ្សេងៗ ស្រេចតែលើស្ត្រីដែលចង់រស់នៅតាមរបៀបដែលខ្លួនចង់ ។ ស្ត្រីជាអ្នកសម្រេចចិត្តថាអ្វីដែលល្អប្រសើរសម្រាប់ខ្លួន ។ ស្ត្រីខ្លះចុះលក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងអពាហ៍ពិពាហ៍ថាខ្លួនចង់រស់នៅឯស្រុកកំណើតរបស់ខ្លួនឬបន្តការសិក្សានិងប្រកបមុខរបរ ។

អ៊ីស្លាមប្រគល់សិទ្ធិនិងជម្រើសពិសេសឲ្យស្ត្រី ដើម្បីរស់នៅតាមចំណង់ បើវាមិនផ្ទុយនឹងបទបញ្ញត្តិច្បាប់អ៊ីស្លាមទេ ហើយស្វាមីយល់ព្រមជាមុនផងនោះ ។

**លោកស្រី ហ្វាត់ម៉ាស៊ុំ** យើងបានឃើញហើយថាភរិយាអាចការពារផលប្រយោជន៍របស់ខ្លួនបាន ដោយដាក់លក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ។ ហេតុដូច្នេះ តើមានប្រយោជន៍អ្វីដែលភរិយាជាអ្នកក្តាប់សិទ្ធិលែងលះឬមិនមែនជាអ្នកក្តាប់សិទ្ធិលែងនោះ ?

**សៃយីដ្** - អាចខុសគ្នាត្រង់ការឆ្លៀតឱកាសទាញយកផលប្រយោជន៍ ។ បើភរិយាក្តាប់សិទ្ធិលែងលះ ការលែងលះអាចចប់បានលឿន ។ ភរិយាមិនចាំបាច់ឡើងតុលាការឬសូមជំនួយពីអ៊ីម៉ាំទេដើម្បីលែងលះ ឲ្យតែដឹងវិធីការលែងលះនិងការអនុវត្តន៍ ។

ម្យ៉ាងទៀត បើភរិយាមិនមានអំណាចលែងលះទេ ភរិយាត្រូវការជំនួយពីតុលាការអ៊ីស្លាមឬអ៊ីម៉ាំដើម្បីអនុវត្តិការលែងលះ វាអាចប្រើពេលយូរ ។

**លោកស្រី ហ្វាត់ម៉ាស៊ុំ** ពេលស្ត្រីទារលែងលះ តើគេចាត់ទុកការលែងលះនេះជាការលែងលះដែលមិនអាចដកវិញបានទេ ទោះបីសិទ្ធិលែងលះជា

របស់ស្ត្រីក៏ដោយ ?

**សៃយីដ្** - ទេ ការលែងលះនោះនឹងមិនត្រូវចាត់ទុកជាការលែងលះដាច់ទេ លើកលែងតែសិទ្ធិលែងលះនោះមិនមែនរបស់ស្ត្រី ស្ត្រីនោះសូមលែងតែស្វាមីមិនព្រម ដូច្នេះការលែងលះនោះនឹងត្រូវចាត់ទុកជាការលែងលះដាច់ពីព្រោះស្ត្រីនោះនឹងត្រូវការ អាល់-ហ្វាគីម អាល់-ស្ហារអ៊ុី ដើម្បីអនុវត្តិការលែងលះ ។

**លោកស្រី ហ្វាត់ម៉ាស្ញុ** បើស្វាមីជាម្ចាស់សិទ្ធិលែងលះ ភរិយាសូមលែងព្រោះភរិយានោះមិនអើពើស្វាមីនោះទៀតទេ ដល់ថ្នាក់ស្អប់ស្វាមីនោះទាំងកាយទាំងចិត្ត តែស្វាមីនោះមិនព្រមឲ្យលែងជាដាច់ខាត ។ តើភរិយានោះអាចលែងលះស្វាមីនោះបានទេ ?

**សៃយីដ្** - ដោយផ្អែកលើអះណះអំណាងថាភរិយាស្អប់ស្វាមីខ្លួនក្រៃលែងទាំងផ្លូវកាយ ទាំងផ្លូវចិត្ត មិនអាចអត់ទ្រាំតទៅទៀតបាន (عُسْر و حَرَج) ហេតុដូច្នេះ វាមិនអាចអត់ផ្លូវទេ ។ នៅក្នុងស្ថានភាពពិសេសនេះ ភរិយានឹងត្រូវពឹងតុលាការឬអ្នកចេះច្បាប់ជំនាញរឿងនេះ ដើម្បីធ្វើឲ្យករណីនេះមានសុពលភាព (គឺធ្វើឲ្យរឿងនេះអាចប្រព្រឹត្តទៅបានតាមច្បាប់) ។

នៅក្នុងករណីបែបនេះ ភរិយាប្រហែលជាត្រូវលះបង់ខាន់ស្លា ថែមទាំងត្រូវបង់ថ្លៃសំណងដើម្បីមានសេរីភាព ។ គេហៅការលែងលះប្រភេទនេះថាឃុលអ៊ុ (الطلاق الخُلْع) វាជាការលែងលះដាច់ (ពោលគឺ មិនអាចដកវិញបានទេ) ។

មកពីមូលហេតុដូចនេះឯងបានជាស្ត្រីត្រូវប្រយ័តប្រយែងជាបន្ថែម ពេលធ្វើកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ។ ស្ត្រីមុស្លីមត្រូវស្គាល់សិទ្ធិខ្លួនឯងនិង

ជម្រើសឲ្យច្បាស់លាស់ ។

**លោកស្រី ហ្វាត់ម៉ាស់** ម៉ាស់ហ្វាប់ខ្លះដាក់បង្គាប់ឲ្យស្វាមីសូត្រឃ្លាលែងលះយូរៗម្តង មួយខែម្តងក្នុងអំឡុងពេលរង់ចាំ ។ តើម៉ាស់ហ្វាប់ អាស្វ៉លុល-បៃត៍អនុវត្តិច្បាប់នេះដែរទេ ?

**សៃយីដ្** - យោលតាមម៉ាស់ហ្វាប់អាស្វ៉លុល-បៃត៍ គេមិនអនុវត្តិប្រការនេះទេ (សូមមើលគួរអាន ២:២២៩) ។

**លោកស្រី ហ្វាត់ម៉ាស់** បើស្វាមីទារលែងលះដែលអាចដកវិញបាន ហើយនៅក្នុងពេលរង់ចាំគាត់រស់នៅជាមួយភរិយា ។ តើការប្រកាសលែងលះនោះនឹងត្រូវរំលាយជាស្វ័យប្រវត្តិដោយមិនបាច់ថាដោយពាក្យសម្តីទេ ?

**សៃយីដ្** - បើនៅក្នុងអំឡុងពេលរង់ចាំអ៊ីដ្ដាស្វ ហើយការលែងលះនោះអាចដកវិញបាន ហេតុដូច្នេះ ការរស់នៅជាមួយគ្នានឹងរំលាយការប្រកាសលែងលះដោយមិនបាច់និយាយតាមផ្លូវការ ។

ឧទាហរណ៍ថា ស្វាមីជាអ្នកទារលែង ស្វាមីនោះអាចមិនធ្វើឲ្យការលែងលះនោះដាច់ស្រេចបាន ។ ស្វាមីនោះអាចប្រាប់ដោយនិយាយ ឬដោយកាយវិការបានថាខ្លួនមិនចង់លែងលះវិញទេ (អាចធ្វើបែបនេះបានដោយដឹងឮ ឬដោយស្ងាត់ៗជាមួយភរិយា) ឬបើគូស្វាមីភរិយានៅជាមួយគ្នា វានឹងរំលាយការលែងលះជាស្វ័យប្រវត្តិដោយមិនបាច់និយាយ ។ ក៏ប៉ុន្តែនៅក្នុងការលែងលះដែលមិនអាចដកវិញបាននោះ គូស្វាមីភរិយាមិនត្រូវមានទំនាក់ទងប្តីប្រពន្ធប្រភេទណាមួយទេ ទាល់តែបានរៀបការគ្នាជាថ្មីសិន ។

**លោកស្រី ហ្វាត់ម៉ាស់** មិនចាំបាច់មានសាក្សីទេបើស្វាមីឬភរិយាបញ្ឈប់វិធីការលែងលះគ្នា មែនទេ ?

**សៃយីដ** - មែន ។ អាចប្រព្រឹត្តទៅបានដោយសម្ងាត់ ដោយគ្មានសាក្សី តែយកល្អអ្នកទាំងពីរគួរឲ្យគេដឹងឮការជាគ្នាវិញនេះ ។

អ៊ីស្លាមព្យាយាមទប់ស្កាត់ការលែងលះគ្នាដោយដាក់ឧបសគ្គ ។ ចំណែកឯអាពាហ៍ពិពាហ៍វិញ ពុំមានដាក់ឧបសគ្គជំទាស់ទេ ។ អ៊ីស្លាមគាំទ្រអាពាហ៍ពិពាហ៍ ព្យាយាមរារាំងការលែងលះគ្នា ។

**លោកស្រី ហ្វាត់ម៉ាស់** អ្វីទៅសារណែនាំនៅពីក្រោយអាយ៉ាស់ខ្លាំងៗទាំងនេះដែលស្តីអំពីអាពាហ៍ពិពាហ៍ ?

ٱلطَّلَٰقُ مَرَّتَانِ ۖ فَإِمۡسَاكُۢ بِمَعۡرُوفٍ أَوۡ تَسۡرِيحُۢ بِإِحۡسَٰنٍ ۗ

*ការលែងលះគ្នា [ដែលអាចជាគ្នាវិញបាន] មានតែពីរដង[គឺះ] ឃាត់ទុក (គឺអាចជាគ្នាវិញបាន) ដោយត្រឹមត្រូវ ឬលែងដោយគុណធម៌ (២:២២៩) ។*

فَإِن طَلَّقَهَا فَلَا تَحِلُّ لَهُۥ مِنۢ بَعۡدُ حَتَّىٰ تَنكِحَ زَوۡجًا

*បើគេ (គឺប្តី) លែងលះនាង[ជាលើកទីបី] គេមិនអនុញ្ញាតឲ្យជានឹងនាងវិញទេក្រោយពីនេះ លុះណាតែនាងបានរៀបការជាមួយស្វាមីម្នាក់ទៀត (២:២៣០) ។*

**សៃយីដ** - អាយ៉ាស់ទាំងនេះជាការដាស់តឿនរំលឹកស្វាមីថាភរិយាមិនមែនជារបស់សម្រាប់លេងទេ ។ បើស្វាមីមិនចូលចិត្តភរិយានោះទេ បុរសម្នាក់ទៀតអាចចូលចិត្តស្ត្រីនោះ ។ វាជាឱកាសមួយដែរសម្រាប់ស្ត្រីដើម្បីនឹង

ដឹងថាស្វាមីថ្មីអាចប្រសើរជាងស្វាមីមុន ។

**លោកស្រី ហ្វាត្មុំម៉ាស៊ុំ** គួរអានថែងថា៖

وَكَيْفَ تَأْخُذُونَهُۥ وَقَدْ أَفْضَىٰ بَعْضُكُمْ إِلَىٰ بَعْضٍ وَأَخَذْنَ مِنكُم مِّيثَٰقًا غَلِيظًا ﴿٢١﴾

*ពួកអ្នកនឹងអាចយកវាមកវិញបានដូចម្តេច បើពួកអ្នកនិងពួកនាងធ្លាប់ស្និទ្ធស្នាលនឹងគ្នាមកហើយ ហើយពួកនាងបានទទួលកិច្ចសន្យា [សម្ព័ន្ធមេត្រី]ដ៏មុឹងម៉ាត់ពីពួកអ្នកហើយនោះ [ក្នុងពេលរៀបអាពាហ៍ពិពាហ៍] (៤:២១) ?*

តើពាក្យថា "កិច្ចសន្យាដ៏មុឹងម៉ាត់" មានន័យថាអ្វី ?

**សៃយីដ្** - "កិច្ចសន្យាដ៏មុឹងម៉ាត់" មិនត្រឹមតែផ្តោតអត្ថន័យទៅលើខាន់ស្លាប៉ុណ្ណោះទេ តែផ្តោតអត្ថន័យទៅលើការសន្យាថានឹងផ្តល់និងការពារសិទ្ធិនិងកាតព្វកិច្ចរបស់គូស្វាមីភរិយា នៅក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍នោះដែរ ។ អាយ៉ាស៊ុំទាំងនេះថែងផ្តោតទៅរកស្វាមីណាដែលមិនព្រមបង់ប្រាក់ខាន់ស្លាឲ្យភរិយា ឬដែលមិនអើពើអំពីករណីកិច្ចស្វាមីភរិយាដែលខ្លួនត្រូវបំពេញចំពោះភរិយា ។

**លោកស្រី ហ្វាត្មុំម៉ាស៊ុំ** -

وَإِنِ ٱمْرَأَةٌ خَافَتْ مِنۢ بَعْلِهَا نُشُوزًا أَوْ إِعْرَاضًا فَلَا جُنَاحَ عَلَيْهِمَآ أَن يُصْلِحَا بَيْنَهُمَا صُلْحًا ۚ وَٱلصُّلْحُ خَيْرٌ ۗ

*បើស្ត្រីខ្លាចស្វាមីខ្លួនកោងកាចឬទុកចោល ពុំមានទោសលើគេទាំងពីរទេ បើពួកគេជាគ្នាវិញដោយការសម្រុះសម្រួល ។ ការសម្រុះសម្រួលជាប្រការប្រពៃបំផុត (៤:១២៨) ។*

តើអាយ៉ាស់ពាក់ព័ន្ធនឹងការលែងលះមូបារ៉ោះត៍ (طلاق المبارة) ទេ ?

**សៃយីដ** - អាយ៉ាស់នេះស្តីអំពីការលែងលះជាទូទៅ ។

**លោកស្រី ហ្វាត់ម៉ាស់** - លោកអ្នកប្រាជ្ញខ្លះថារយៈពេលពិសោធន៍ (គឺ អ៊ីដ្ឌដ្ឋាស់) ចាប់ផ្តើមពីពេលនិយាយថាលែងលះភ្លាមម្ល៉េះ ទោះបីភរិយាដឹង ឬមិនដឹងក៏ដោយ ។ តើអ៊ីស្លាមអនុញ្ញាតឲ្យស្វាមីលែងលះភរិយាដោយមិន ប្រាប់ភរិយានោះឲ្យដឹងទេ ។

**សៃយីដ** - ស្ទើរតែមិនអាចអនុវត្តិច្បាប់ (ហ្វាត់វ៉ា) នេះបានទេ ។ គេចាត់ថា ការលែងលះគ្នាជាវិធីការរួមគ្នា ។ នៅក្នុងករណីលែងលះស្ទើរតែទាំងអស់ ចៅក្រមអ៊ីស្លាមឬអ៊ីម៉ាំទាមទារឲ្យជួបភរិយា ដើម្បីសូមការយល់ព្រមពី ភរិយានោះ ។ ម្យ៉ាងទៀត គួរអានឲ្យដំបូន្មានអ្នកដែលផ្តើមសូមលែងលះ នោះឲ្យបែកផ្លូវពីស្វាមីភរិយាដោយស្រុះស្រួលគ្នា ។

**លោកស្រី ហ្វាត់ម៉ាស់** - តើចាំបាច់ត្រូវមានអាជ្ញាកណ្តាលទេក្នុងការធ្វើឲ្យ ការលែងលះគ្នាបានសម្រេច ឬវាគ្រាន់តែជាសូណាត់ ? (៤:៣៥)

**សៃយីដ** - អាជ្ញាកណ្តាជាវិធានការប្រុងប្រយត្នសូណាត់សំខាន់បំផុតដើម្បី ព្យាយាមរារាំងវិធីការលែងលះគ្នា ។ ទោះបីអាជ្ញាកណ្តាលមិនត្រូវដាក់មក ជាបទបញ្ញត្តិទេក៏ដោយ តែដំបូន្មានសូណាត់របស់អាជ្ញាកណ្តាលនោះ មានមុខនាទីដូចកាតព្វកិច្ចមួយប្រភេទដែរក្នុងសាសនា ។

**លោកស្រី ហ្វាត់ម៉ាស់** - តើសាក្សីត្រឹមត្រូវ (អាឌីល) ចាំបាច់ត្រូវដឹងនិងទាក់

ទិននឹងរឿងលែងលះទេ ?

**សៃយីដ្** - សាក្សីគ្រាន់តែជាអ្នកមើលដែលធ្វើវិញ្ញាបនកម្មការលែងលះគ្នាប៉ុណ្ណោះ (ពោលគឺ គ្រាន់តែជាអ្នកបញ្ជាក់ថាអ្នកទាំងពីរបានលែងលះគ្នា)។ បើចាំបាច់ សាក្សីទាំងនោះអាចត្រូវសូមឲ្យផ្ញើកសិណក្នុងការដាក់បញ្ញត្តិលែងលះ ។ សាក្សីមិនចាំបាច់ជាបក្សពួករបស់ករណីលែងលះទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - ជាទូទៅ ពេលបុរសចង់លែងលះភរិយា អ៊ីម៉ាំ (គឺអ្នកដឹកនាំសាសនា) ជាបុគ្គលដែលបុរសស្គាល់ ។ តើភរិយាអាចធានាបានដូចម្តេចថាអ៊ីម៉ាំនោះមិនលំអៀង មានសមត្ថភាព គោរពវិធីការដែលចាំបាច់សម្រាប់ការលែងលះត្រឹមត្រូវ ?

**សៃយីដ្** - ភរិយាមានសិទ្ធិជ្រើសរើសអ៊ីម៉ាំឬចៅក្រមដែលខ្លួនជឿជាក់ថាមានសមត្ថភាពនិងត្រឹមត្រូវ ។ ភរិយាមានសិទ្ធិបដិសេធអ៊ីម៉ាំឬចៅក្រមដែរបើដឹងច្បាស់ថាអ៊ីម៉ាំឬចៅក្រមនោះអាចធ្វើឲ្យខូចប្រយោជន៍ឬលំអៀងក្នុងរឿងលែងលះ ។

នៅក្នុងការលែងលះសាមញ្ញ អ៊ីម៉ាំឬតុលាការអ៊ីស្លាមនឹងមិនបន្តក្តីលែងលះដោយមិនប្រឹក្សាជាមួយភរិយានោះទេ ។ ម្យ៉ាងទៀត ក្នុងប្រទេសមុស្លីមខ្លះ ស្វាមីឬភរិយាត្រូវសូមលែងលះនៅឯតុលាការអ៊ីស្លាមជាមុនសិន ។

ត្រូវដឹងដែរថា បើភរិយាបានដាក់លក្ខខណ្ឌឬបានកែប្រែកិច្ចសន្យាអាពាហ៍ពិពាហ៍តែស្វាមីមិនគោរពតាមលក្ខខណ្ឌ ឬការកែប្រែនោះទេ ភរិយានោះត្រូវការពារសិទ្ធិរបស់ខ្លួនដោយប្រាប់អ៊ីម៉ាំ ឬតុលាការអ៊ីស្លាមឲ្យដឹងអំពីកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍នោះ ឲ្យបានមុនការលែងលះនឹង

ចប់ ។ ពុំនោះទេ អ៊ីមុាំឬតុលាការអ៊ីស្លាមនឹងសន្មត់ប្រភេទអាពាហ៍ពិពាហ៍មុស្លីម ហើយនឹងសម្រេចបញ្ចប់ការលែងលះតាមប្រភេទអាពាហ៍ពិពាហ៍នោះ ។

**លោកស្រី ហ្វាត់ម៉ាស់** - បើស្វាមីបាត់ខ្លួន តើភរិយាត្រូវរង់ចាំអ៊ីដ្ធាស់ទេមុននឹងសូមលែងលះ ?

**សៃយីដ្** - វានៅលើស្ថានភាពនិងស្ត្រី ។ លោកអ្នកប្រាជ្ញចាស់កំណត់ពេលតែលោកអ្នកប្រាជ្ញសម័យនេះ ដោយផ្អែកលើបច្ចេកទេសទំនើប នឹងមិនសម្រេចបែបនេះទេ ។

មុនសម័យបច្ចេកទេស (គឺសម័យទំនើប) គេត្រូវធ្វើដំណើរផ្ទាល់តែម្ដងដើម្បីស្វែងរកមនុស្សបាត់ខ្លួន ។ សម័យនេះងាយស្រួលក្នុងការកំណត់ជោគវាសនារបស់បុគ្គល ។ អាស្រ័យលើប្រព័ន្ធទូរគមនាគមន៍ដ៏ទូលំទូលាយ យន្តស្វ័យប្រវត្តិ និងធនធានដែលមានស្រាប់សម្រាប់អ្នកស៊ើបអង្កេតនោះ គេមិនចាំបាច់ពន្យារពេល ផ្អាកពេល ឬបន្លាយពេលដើម្បីរង់ចាំចម្លើយពីជនបាត់ខ្លួនទេ ។

តែបើស្វាមីចោលភរិយាដោយពុំមានគ្រឿងទ្រទ្រង់ជីវិត ពុំមានការថែរក្សាជីវិតរស់នៅរបស់ភរិយានោះច្របូកច្របល់ ពិបាកអត់ទ្រាំ (عُسْر و حَرَج) និងគ្មានសង្ឃឹម តុលាការអ៊ីស្លាមឬអ៊ីមុាំអាចដាក់បញ្ជាឲ្យលែងលះយ៉ាងរហ័សបាន ។

**លោកស្រី ហ្វាត់ម៉ាស់** - ហេតុអ្វីលោកអ្នកប្រាជ្ញខ្លះដាក់ពេលឲ្យរង់ចាំមុនភរិយាអាចចាប់ផ្ដើមធ្វើវិធីការលែងលះថ្មីបើគេមិនអនុញ្ញាតឲ្យស្វាមីចោលភរិយាលើសពីបួនខែដោយមិនបានសូមអនុញ្ញាតពីភរិយានោះទេ ?

**សៃយីដុ** - លោកអ្នកប្រាជ្ញចាស់ដែលដាក់រយៈពេលនោះចង់និយាយអំពីស្វាមីដែមបាត់ខ្លួន មិនមែននិយាយអំពីស្វាមីដែលបោះបង់ចោលឬរត់ចោលភរិយាដោយចិត្តឯងទេ ។ តែស្រេចតែលើភរិយាទេ ។ ភរិយាម្នាក់ៗខុសគ្នា ។ ភរិយាខ្លះទ្រាំរង់ចាំស្វាមីត្រឡប់វិញ រីឯភរិយាឯទៀតមិនអាចរង់ចាំបានទេ ។ ស្រេចតែលើស្ត្រីនិងស្ថានភាពខ្លួនស្ត្រីនោះទេ ។

បើភរិយាមិនអាចទ្រាំរស់នៅដោយឥតស្វាមីបានទេ ភរិយានោះត្រូវនាំរឿងខ្លួននេះទៅជួបតុលាការអ៊ីស្លាមឬអ៊ីម៉ាំ ពួកគេនឹងពិនិត្យយ៉ាងហ្មត់ចត់សំណុំរឿងគាត់ ។ គេអាចនឹងធ្វើការស៊ើបអង្កេតផ្សេងៗ ។ តើភរិយាត្រូវចោលឲ្យនៅដោយឥតមានគ្រឿងទ្រទ្រង់ជីវិតទេ ? តើឪពុកម្តាយក្មេកបានជួយឧបត្ថម្ភស្ត្រីនោះទេ ? គេអាចកោះហៅនិងសាកសួរសាក្សីរបស់ភរិយានោះនិងសាក្សីរបស់ស្វាមី ។

គេអាចណែនាំឲ្យភរិយានោះអត់ទ្រាំរង់ចាំមួយរយៈពេលសិន ឬអាចឲ្យគាត់លែងលះភ្លាមៗ ។ វាអាស្រ័យលើស្ថានភាពនិងអាស្រ័យលើស្ត្រី ។ មិនមានវិធីដោះស្រាយចំៗរឿងនេះតែមួយទេ ។ វាជារឿងផ្ទាល់ខ្លួន ត្រូវអនុវត្តិទៅតាមស្ថានភាពផ្ទាល់ខ្លួននោះ ម្តងមួយករណីៗ ។

តុលាការអ៊ីស្លាមឬអ៊ីម៉ាំត្រូវយកចិត្តទុកដាក់យ៉ាងខ្លាំងអំពីកត្តាពីរ មុននឹងសម្រេចឲ្យលែងលះ ។ មួយគឺសារៈសំខាន់នៃគ្រួសារ ជាពិសេសបើមានកូនជាប់ពាក់ព័ន្ធ ។ ពីរគឺសុខុមាលភាពរបស់ស្ត្រី ទោះជាយ៉ាងណាក៏ដោយ ស្ត្រីជាមនុស្សមួយរូបដែលមានសេចក្តីត្រូវការ ។ បន្ទាប់ពីបានពិនិត្យគ្រប់សព្វហើយ បើតុលាការឬអ៊ីម៉ាំសម្រេចដោយផ្អែកលើមូលហេតុដែលសមហេតុផល គេអាចនឹងប្រកាសឲ្យលែងលះបាន ។

-ការលែងលះនិងម៉ាស្ហ៍

**លោកស្រី ហ្វាត្ម៉ាស្ហ៊** - បើហេតុផលលែងលះរបស់ភរិយានៅលើខលក្ខខណ្ឌរំលាយអាពាហ៍ពិពាហ៍ឬលែងលះមួយ ដែលបាននិយាយរួចមកហើយនោះ តើភរិយានោះនឹងត្រូវលះបង់ខាន់ស្លាខ្លះឬទាំងអស់ទេ ?

**សៃយីដ្** - ភរិយាមានសិទ្ធិយកខាន់ស្លាទាំងអស់ លើកលែងតែក្នុងអាពាហ៍ពិពាហ៍ដែលមិនបានរួមដំណេក ។ បើមិនបានរួមដំណេកទេក្នុងអាពាហ៍ពិពាហ៍ ភរិយាមានសិទ្ធិយកខាន់ស្លាពាក់កណ្ដាល ត្រូវប្រគល់ពាក់កណ្ដាលទៀតឲ្យទៅអតីតស្វាមីវិញ ។

សំខាន់ត្រូវដឹងថា បើអាពាហ៍ពិពាហ៍មិនស្របតាមលក្ខខណ្ឌណាមួយទេ (ដូចជាអាពាហ៍ពិពាហ៍មិនបានរួមដំណេកជាដើម) អាពាហ៍ពិពាហ៍បានចាប់ផ្ដើមហើយ ហេតុដូច្នេះអាពាហ៍ពិពាហ៍នោះត្រូវចាត់ទុកជាអាពាហ៍ពិពាហ៍សាមញ្ញឬធម្មតា ។

បន្ទាប់មក បើស្វាមីសូមលែងលះ គាត់មិនអាចយកខាន់ស្លាវិញបានជាដាច់ខាត ទោះជាមួយប៉ែកក៏ដោយ ។ ខាន់ស្លាជាអំណោយឲ្យទៅភរិយា ទោះបីនៅពេលក្រោយ នឹងបន្តអាពាហ៍ពិពាហ៍នោះតទៅទៀតឬនឹងរំលាយអាពាហ៍ពិពាហ៍នោះក៏ដោយ ។ បើស្វាមីមិនបានបង់ប្រាក់ខាន់ស្លាគ្រប់ចំនួនទេ គាត់នៅតែចំពាក់អតីតភរិយាចំនួនប្រាក់ខាន់ស្លាដែលនៅសល់នោះដដែល មិនអាចយកការលែងលះគ្នាជាលេសមិនសងស្ត្រីបានទេ ។

**លោកស្រី ហ្វាត្ម៉ាស្ហ៊** - អាយ៉ាស្ហ៊ដែលចែងថា៖

لَا يَحِلُّ لَكُمْ أَن تَرِثُواْ ٱلنِّسَآءَ كَرْهًاۖ وَلَا تَعْضُلُوهُنَّ لِتَذْهَبُواْ بِبَعْضِ مَآ ءَاتَيْتُمُوهُنَّ إِلَّآ أَن يَأْتِينَ بِفَٰحِشَةٍ مُّبَيِّنَةٍۚ

*មិនអនុញ្ញាតឲ្យពួកអ្នកស្នងមរតកពីបណ្ដាស្ត្រី ដោយពួកនាងមិនព្រមផងនោះទេ (គឺទាំងបង្ខំ) ។ ចូរពួកអ្នកកុំបង្ខិតបង្ខំពួកនាងដើម្បីរឹបអូសយកមួយចំណែកនៃអ្វីដែលពួកអ្នកបានឲ្យទៅពួកនាងឡើយ វៀរលែងតែពួកនាងបានប្រព្រឹត្តអំពើលាមកយ៉ាងជាក់ស្ដែង (៤:១៩) ។*

តើអាយ៉ាស់នេះលើកលែងខាន់ស្លាមែនទេ ?

**សៃយីដ្** - មិនព្រមបង់ថ្លៃខាន់ស្លាព្រោះតែភរិយាបានប្រព្រឹត្តិអំពើអតិចរិយាអាចមកពីមូលហេតុដ៏ធ្ងន់ធ្ងរដែលនាំឲ្យរឿងកើតឡើង ។ មិនមែនមិនចង់ថាអំពើអាក្រក់នៃបទអតិចរិយាជារឿងតូចតាច ឬមិនអើពើទង្វើនេះទេដែរ តែជួនកាលគេពើបពះនឹងហេតុការណ៍ខុសពីប្រក្រតីដែលទាមទារការវិភាគស្ថានការណ៍យ៉ាងហ្មត់ចត់ មុននឹងអាចសម្រេចសេចក្ដីបាន ។

អ៊ីស្លាមថែងថាពេលណារឿងអតិចរិយាត្រូវក្ដីក្ដាំតាមសាសនា ពេលនោះព្រោះវាជាមធ្យោបាយផ្ដាញ់តបដែលទើសទាល់ ជាមធ្យោបាយចុងក្រោយ ស្វាមីអាចមិនបង់ថ្លៃខាន់ស្លាដែលនៅសល់នោះបាន តែមិនគប្បីធ្វើបែបនេះទេ (ពោលគឺ គេមិនណែនាំឲ្យធ្វើបែបនេះទេ) ។

**-ម្ចាស់ទ្រព្យ**

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ីស្លាមមានទ្រឹស្ដីយ៉ាងណាអំពីការចែកទ្រព្យរបស់គូស្វាមីភរិយា ?

**សៃយីដុ** - ជាធម្មតា ម្នាក់ៗ ប្រុសឬស្រី ទាមទារអ្វីដែលខ្លួនបានយកមកដាក់រួមក្នុងអាពាហ៍ពិពាហ៍ ។ ការចែកទ្រព្យនឹងត្រូវប្រព្រឹត្តឡើងដោយគិតតាមអ្វីដែលម្នាក់ៗបានផ្តល់ឲ្យគូស្វាមីភរិយាជារួម ។ ឧទាហរណ៍ នៅប្រទេសប៉ែកខាងកើតខ្លះ តាមទំនៀមទម្លាប់ ភរិយាផ្តល់គុទ្ទ ។ បើភរិយាលែងលះ ភរិយាមានសិទ្ធិយកគុទ្ទទាំងអស់ដែលខ្លួនបានផ្តល់ឲ្យ ។

**លោកស្រី ហ្វាត់ម៉ាស់** - ជំនួសអ្វីៗដែលភរិយាបានយកមកចូលក្នុងអាពាហ៍ពិពាហ៍នោះ តើភរិយាអាចទារថ្លៃបម្រើដែលខ្លួនបានផ្តល់ឲ្យស្វាមីអស់រយៈពេលច្រើនឆ្នាំនោះបានទេ ដូចជាការបោសសម្អាតផ្ទះ ការដាំស្លនិងការចិញ្ចឹមកូន ?

**សៃយីដុ** - ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ភរិយាអាចទារថ្លៃដែលខ្លួនបានបម្រើការផ្ទះនោះបានរាល់ពេល រាប់បញ្ចូលការចិញ្ចឹមកូនដែរ ។ តែពិបាកទារបៀវត្សក្នុងពេលលែងលះគ្នា ដោយមិនបានធ្វើការយល់ព្រមជាមុននៅក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍ ។ ក៏ប៉ុន្តែអ៊ីស្លាមណែនាំឲ្យស្វាមីប្រគល់អំណោយឲ្យទៅអតីតភរិយា ដើម្បីនឹងធ្វើឲ្យជីវភាពរស់នៅរបស់អតីតភរិយានោះនឹងមានការងាយស្រួល ក្រោយពីបានលែងលះគ្នាទោះបីស្វាមីនោះបានប្រគល់ខាន់ស្លាទាំងអស់ ឲ្យទៅអតីតភរិយានោះហើយក៏ដោយ ។ ក្នុងពេលលែងលះគ្នា អ៊ីស្លាមដាស់តឿនស្វាមីឲ្យសងអតីតភរិយាដោយវិធីនីមួយ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើអ្វីនឹងកើតឡើង នៅក្នុងអាពាហ៍ពីពាហ៍សាមញ្ញបើភរិយាបានលះបង់ខ្លួនអស់រយៈពេលច្រើនឆ្នាំ បានសន្សំប្រាក់ បានចាយវាយដោយប្រុងប្រយត្ន បានជួយគាំទ្រនិងបានធ្វើការផ្ទះ ក្នុងគោលបំណងឲ្យស្វាមីខ្លួន រួចផុតពីភារកិច្ចដែលគេដាក់មកលើខ្លួនស្វាមីនោះដើម្បីនឹងឲ្យស្វាមីនោះបន្តការប្រកបមុខរបរ ហើយនឹងមានជោគជ័យផ្នែក

ថវិកា ? តើអ៊ីស្លាមទទួលស្គាល់ឬទទួលការពិតទេ ថាភរិយាមានមុខនាទីសំខាន់ក្នុងការជ្រោមជ្រែងស្វាមីឲ្យមានជោគជ័យ ? ម្យ៉ាងទៀត តើអ៊ីស្លាមមិនបង់ថ្លៃសំណងភរិយាទេដែលបានលះបង់ខ្លួនដល់ថ្នាក់នេះ ?

**សៃយីដ្** - មិនអាចឆ្លើយតបភ្លាមៗឧទាហរណ៍ដែលលោកបានរៀបរាប់នោះបានទេ ។ ករណីបែបនេះទាមទារការស៊ើបអង្កេតយ៉ាងជ្រាលជ្រៅដើម្បីនឹងដឹងថាភរិយាបានផ្តល់ឲ្យអ្វីខ្លះ បានបំពេញអ្វីខ្លះ បានលះបង់អ្វីខ្លះ ពីដើមអាពាហ៍ពិពាហ៍ដល់ចប់អាពាហ៍ពិពាហ៍ ។ តុលាការអ៊ីស្លាមត្រូវស៊ើបអង្កេតច្រើនរឿង ដូចជាអ្នកណាខ្លះបានធ្វើកិច្ចការហើយអស់រយៈពេលប៉ុណ្ណា ម្នាក់ៗបាននាំអ្វីខ្លះមកចូលរួមឬបានលះបង់អ្វីខ្លះ អ្នកណាខ្លះបានធ្វើការដោយផ្ទាល់ដៃ ឬតើបានគ្រប់គ្រងការចាយវាយដូចម្តេចខ្លះជាដើម ។ ប្រការទាំងអស់នេះខុសគ្នា ហើយជាការសម្រេចដោយពិនិត្យករណីម្តងមួយៗ ។

ជួនកាលភរិយាជួយស្វាមីជាជំនួយការឬជាស្មៀននៅឯការិយាល័យ ឬនៅឯសហគ្រាស ។ ភរិយាអាចទារថ្លៃបម្រើកិច្ចការទាំងនេះបានក្នុងពេលកំពុងរំលាយអាពាហ៍ពិពាហ៍រ ឬក្រោយពីអាពាហ៍ពិពាហ៍ត្រូវរំលាយហើយ ។

បើភរិយាទារឲ្យសងថ្លៃដែលបានធ្វើជាស្មៀន ឬជាជំនួយការរបស់ស្វាមីអស់ច្រើនឆ្នាំ ភរិយានោះនឹងមានសិទ្ធិទទួលថ្លៃសងស្មើនឹងថ្លៃឈ្នួលដែលស្វាមីជួលស្មៀនឬជំនួយការដែរ ។ ក៏ប៉ុន្តែ បើគេដឹងច្បាស់ថាភរិយាជាដៃគូក្នុងធុរកិច្ចពេញលក្ខណៈ ពិតប្រាកដណាស់ ភរិយានោះនឹងមានសិទ្ធិបានចំណែកក្រុមហ៊ុន ។

## វគ្គ ៤ - ហ៊ីយ៉ាប់ (សំពត់ទទូរក្បាល)

**លោកស្រី ហ្វាត់ម៉ាស់** - ហេតុអ្វីស្ត្រីមុស្លីមត្រូវបិទបាំងខ្លួន ?

**សៃយីដ** - លោកអ្នកប្រាជ្ញបានអធិប្បាយបំភ្លឺផ្សេងៗរឿងស្ត្រីបិទបាំងខ្លួន ។ មូលហេតុសំខាន់ពីរដែលស្ត្រីមុស្លីមត្រូវបិទបាំងខ្លួននោះគឺ ដើម្បីការពារ និងរក្សាស្ត្រី ព្រមទាំងសង្គមដែរ ។

បិទបាំងខ្លួនជាវិធីការពារនិងជាវិធីរក្សាព្រហ្មចរិយភាពមួយបែប ហើយជាជំនួយដើម្បីចៀសវាងចំណង់អាក្រក់នៅក្នុងសង្គមសម្រាប់ស្ត្រី និងសម្រាប់បុរសដែរ ។ ពេលស្ត្រីបិទបាំងខ្លួន ស្ត្រីនោះនាំមកនូវលក្ខណៈសីលធម៌និងសេចក្តីថ្លៃថ្នូរ មិនត្រឹមតែសម្រាប់ខ្លួនឯងទេ តែសម្រាប់សង្គមទៀតផង ។

ជាទូទៅ បុរសតែងតែជាអ្នកទន់ទេរផ្លូវសភាវគតិមុនគេ ទៅរកសម្រស់កាយរបស់ស្ត្រី ។ ស្ត្រីក៏ទាក់ទាញទៅរកបុរសដែរ តែទម្រង់ខ្លួនស្ត្រីគួរឲ្យស្រឡាញ់ជាងទម្រង់ខ្លួនបុរស ។ នេះគឺមូលហេតុមួយដែលស្ត្រីមុស្លីមត្រូវបិទបាំងខ្លួន ។ ក៏ប៉ុន្តែ ជាពិសេស វាការពារស្ត្រីពីការរងគ្រោះ ។

គេដឹងច្បាស់ស្រាប់ហើយថាពេញប្រវត្តិសាស្ត្រ ស្ត្រីរងគ្រោះផ្លូវកាយនិងផ្លូវចិត្តនៅក្នុងសង្គម ។ សហគមន៍ជាច្រើនទាញយកផលប្រយោជន៍ពីស្ត្រី និងបំបាក់កិត្តិយសស្ត្រី ។ ហេតុដូច្នេះ កាលពីមុន (និងក្នុងបច្ចុប្បន្ន) អ៊ីស្លាមចង់ការពារកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់ស្ត្រី ដោយការពារធម្មជាតិកាយរបស់ស្ត្រី ។
លើសពីការពារកិត្តិយសស្ត្រី អ៊ីស្លាមចង់បណ្តុះនៅក្នុងគំនិតបុរសនូវសារៈសំខាន់របស់ស្ត្រីនៅក្នុងរង្វង់ជីវិត ។ បុរសត្រូវចាត់ទុកស្ត្រីជាបុគ្គលប្រកប

ដោយសេចក្ដីថ្លៃថ្នូរនិងមានតម្លៃស្មើនឹងមនុស្សដែរ ។ ការទទួលស្គាល់ស្ត្រីមិនត្រឹមតែនៅលើអាការក្រៅឬនៅលើទម្រង់ខ្លួនទេ ត្រូវយកចិត្តទុកដាក់អំពីសេចក្ដីគោរព និងការព្រមទទួលស្គាល់ស្ត្រីនៅលើបុគ្គលលក្ខណៈរបស់ស្ត្រី នៅលើប្រាជ្ញានិងនៅលើគុណសម្បត្តិសីលធម៌របស់ស្ត្រី ។

រឿងបិទបាំងខ្លួនមិនមែនជារឿងចំឡែកដូចអ្នកខ្លះគិតនោះទេ ។ អ៊ីស្លាមមិនមែនសាសនាតែមួយដែលទាមទារឲ្យស្ត្រីបិទបាំងខ្លួនទេ ។ តាមទម្លាប់ស្ត្រីដែលគោរពព្រះគម្ពីរទាំងឡាយបិទបាំងខ្លួន តាំងពីច្រើនរយឆ្នាំមុនអ៊ីស្លាមផុសឡើងម្ល៉េះ ។

ស្ត្រីមានជំនឿជាច្រើននៅក្នុងប្រវត្តិសាសនាយ៉ាហ្វូឌី និងសាសនាគ្រិស្តតែងតែបិទបាំងខ្លួន ស្ត្រីមួយចំនួននៅតែធ្វើបែបនេះរហូតមកដល់សព្វថ្ងៃនេះ ។ អ៊ីស្លាមកាន់ទម្លាប់នេះជាបន្តមក តែបានបន្ថែមលក្ខណៈមួយទៀតគឺទស្សនៈ

يَغُضُّواْ مِنْ أَبْصَٰرِهِمْ

*ឲ្យពួកគេដាក់ភ្នែក (២៤:៣០) ។*

គេអាចបកស្រាយបានថា សម្ដែងសេចក្ដីគោរពនិងភាពរាបសាគ្រប់វិស័យ ទាំងផ្នែកចិត្ត ទាំងក្នុងខ្លួន ។

**លោកស្រី ហ្វាត់ម៉ាស់** - អ្នកខ្លះអះអាងថាគួរអានមិនដាក់បញ្ហាយ៉ាងច្បាស់លាស់ឲ្យស្ត្រីបិទបាំងខ្លួនទេ ថាសាសនានិយាយស្រពេចស្រពិលហើយបើកឲ្យធ្វើតាមតែចិត្តបុគ្គល ។ តើគួរអានចែងថាអ្វីខ្លះយ៉ាងពិតប្រាកដអំពីរបៀបស្លៀកពាក់សម្រាប់ស្ត្រីមុស្លីម ?

**សៃយីដ៑** - មានអាយ៉ាស្ទ់ពីរនៅក្នុងគួរអានដាក់បញ្ហាយ៉ាងច្បាស់លាស់ និងពិពណ៌នាលំអិតអំពីការស្លៀកពាក់របស់ស្ត្រី ។ គេអាចបញ្ជាក់រឿងនេះបានដោយពិនិត្យហាឌីស្ទ៍ជាច្រើនរបស់ព្រះសាស្តា ﷺ ដែលរៀបរាប់អំពីការបិទបាំងខ្លួនពិសេស ។ អាយ៉ាស្ទ់មួយចែងថា៖

وَقُل لِّلْمُؤْمِنَـٰتِ يَغْضُضْنَ مِنْ أَبْصَـٰرِهِنَّ وَيَحْفَظْنَ فُرُوجَهُنَّ وَلَا يُبْدِينَ زِينَتَهُنَّ إِلَّا مَا ظَهَرَ مِنْهَا ۖ وَلْيَضْرِبْنَ بِخُمُرِهِنَّ عَلَىٰ جُيُوبِهِنَّ ۖ وَلَا يُبْدِينَ زِينَتَهُنَّ إِلَّا لِبُعُولَتِهِنَّ أَوْ ءَابَآئِهِنَّ أَوْ ءَابَآءِ بُعُولَتِهِنَّ أَوْ أَبْنَآئِهِنَّ أَوْ أَبْنَآءِ بُعُولَتِهِنَّ أَوْ إِخْوَٰنِهِنَّ أَوْ بَنِىٓ إِخْوَٰنِهِنَّ أَوْ بَنِىٓ أَخَوَٰتِهِنَّ أَوْ نِسَآئِهِنَّ أَوْ مَا مَلَكَتْ أَيْمَـٰنُهُنَّ أَوِ ٱلتَّـٰبِعِينَ غَيْرِ أُو۟لِى ٱلْإِرْبَةِ مِنَ ٱلرِّجَالِ أَوِ ٱلطِّفْلِ ٱلَّذِينَ لَمْ يَظْهَرُوا۟ عَلَىٰ عَوْرَٰتِ ٱلنِّسَآءِ ۖ وَلَا يَضْرِبْنَ بِأَرْجُلِهِنَّ لِيُعْلَمَ مَا يُخْفِينَ مِن زِينَتِهِنَّ ۚ

*ចូរអ្នកថ្លែងប្រាប់ស្ត្រីដែលមានសទ្ធាទាំងឡាយឲ្យពួកនាងដាក់ភ្នែក (កុំសម្លឹងមើលអ្វីដែលត្រូវហាម ដែលឲ្យទោស ដោយសេចក្តីត្រេកត្រអាលឡើយ) ឲ្យពួកនាងការពារខ្មាស (វៀរចាកមេថុន) ពួកនាង មិនឲ្យពួកនាងបង្ហាញគ្រឿងលំអរបស់ពួកនាងទេ លើកលែងតែគ្រឿងលំអផ្នែកក្រៅប៉ុណ្ណោះ [ដែលមិនអាចចៀសវាងបាន] ឲ្យពួកនាងគ្របដើមទ្រូងដោយសំពត់ទទូរ កុំឲ្យពួកនាងបង្ហាញគ្រឿងលំអពួកនាងចំពោះអ្នកណាក្រៅពីស្វាមីពួកនាង ក្រៅពីបិតាពួកនាង ក្រៅពីបិតាក្មេករបស់ពួកនាង ក្រៅពីកូនប្រុសៗរបស់ពួកនាង ក្រៅពីកូនប្រុសៗរបស់ស្វាមីពួកនាង ក្រៅពីបងប្អូនប្រុសរបស់ពួកនាង ក្រៅពីកូនប្រុសៗរបស់បងប្អូនប្រុសរបស់ពួកនាង ក្រៅពីកូនប្រុសៗរបស់បងប្អូនស្រីរបស់ពួកនាង ក្រៅពីបណ្តាស្ត្រីភេទដូចពួកនាង ក្រៅពីទាសីទាំងឡាយរបស់ពួកនាង ក្រៅពីទាសៈដែលពុំមានកាមរាគ ក្រៅពីក្មេងប្រុសៗមិនទាន់គ្រប់អាយុដែលមិន ទាន់ដឹងរឿងផ្នែក*

*លាក់បាំងរបស់ស្ត្រី និងចូរកុំឲ្យពួកនាងតន្ត្រំជើងក្នុងបំណងបើកឲ្យគេដឹងដល់គ្រឿងលំអដែលពួកនាងបិទបាំង (២៤:៣១)* ។

ពាក្យ "សំពត់ទទូរ" ប្រែមកពីពាក្យអារ៉ាប់ "ឃុ្ខុមូរ" ឃុ្ខុមូរជារបស់មួយដែលគេធ្លាប់តែប្រើសម្រាប់បិទបាំងខ្លួនក្នុងសម័យព្រះសាស្តាﷺ ។

អាយ៉ាស់ទីពីរគឺ៖

يَـٰٓأَيُّهَا ٱلنَّبِىُّ قُل لِّأَزْوَٰجِكَ وَبَنَاتِكَ وَنِسَآءِ ٱلْمُؤْمِنِينَ يُدْنِينَ عَلَيْهِنَّ مِن جَلَـٰبِيبِهِنَّ ۚ ذَٰلِكَ أَدْنَىٰٓ أَن يُعْرَفْنَ فَلَا يُؤْذَيْنَ ۗ

*សាស្តាអើយ ចូរអ្នកថ្លែងប្រាប់ភរិយាទាំងឡាយរបស់អ្នក កូនស្រីទាំងឡាយរបស់អ្នកនិងបណ្តាស្ត្រីរបស់អ្នកមានសទ្ធាទាំងឡាយ ឲ្យពួកនាងឃ្លុំខ្លួនដោយសំលៀកបំពាក់ក្រៅរបស់ពួកនាង [ដោយដណ្តប់សព្វខ្លួនប្រាណនៅចំពោះមុខមនុស្សប្រុស ដែលមិនមែនជាក្រុមគ្រួសារពួកនាង] ។ នេះជាវិធីប្រសើរសម្រាប់ពួកនាងដើម្បីនឹងឲ្យគេស្គាល់ពួកនាង និងដើម្បីនឹងមិនឲ្យគេប្រមាថពួកនាង (៣៣:៥៩)* ។

"សំលៀកបំពាក់ក្រៅ" ក្នុងអាយ៉ាស់នេះប្រែមកពីពាក្យអារ៉ាប់ "ឃុ្ខុលបាប់" ។ ឃុ្ខុលបាប់ជារបស់ស្លៀកពាក់មួយទៀតដែលគេតែងតែប្រើសម្រាប់បិទបាំងខ្លួនក្នុងសម័យព្រះសាស្តាﷺ ។ គួរអានរាយការណ៍អំពីលក្ខខណ្ឌដោះសំលៀកបំពាក់ដែរថា៖

وَٱلْقَوَٰعِدُ مِنَ ٱلنِّسَآءِ ٱلَّـٰتِى لَا يَرْجُونَ نِكَاحًا فَلَيْسَ عَلَيْهِنَّ جُنَاحٌ أَن يَضَعْنَ ثِيَابَهُنَّ غَيْرَ مُتَبَرِّجَـٰتٍۭ بِزِينَةٍ ۖ وَأَن يَسْتَعْفِفْنَ خَيْرٌ لَّهُنَّ ۗ

*រីឯបណ្តាស្ត្រីដែលអស់រដូវ (គឺលែងមានកូនទៀតបាន) ហើយមិនសង្ឃឹមនឹងរៀបការទេ ពួកនាងនឹងពុំមានកំហុសទេបើពួកនាងដោះសំលៀក*

*បំពាក់[ក្រៅ] ដោយមិនឲ្យគេឃើញគ្រឿងលំអ [ឬ សម្រស់ខ្លួន] ។ បើពួកនាងទប់ខ្លួន ជាការប្រសើរបំផុតសម្រាប់ពួកនាង (២៤:៦០) ។*

**លោកស្រី ហ្វាត៉ុម៉ាស្ស** - តើសៃយីដ្អាចអធិប្បាយលំអិតអំពីសំលៀកបំពាក់ឃុ្មលបាប់ និង ឃុម្វូរ បានទេ ?

**សៃយីដ្** - ឃុ្មលបាប់ជាវត្ថុដែលគេពាក់ពីលើសំលៀកបំពាក់នាសម័យព្រះសាស្តាﷺ ។ សម័យសព្វថ្ងៃនេះ វាដូចអាវធំឬអាវវែងរលុង ។ ឃុម្វូរគឺកន្សែងធំដែលគេប្រើសម័យព្រះសាស្តាﷺ តែស្ត្រីពាក់វាមិនត្រឹមត្រូវតាមបែបបទទេ ។ ដូច្នេះស្ត្រីប្រើឃុម្វូរសម្រាប់តែគ្របពីលើសក់ទេ ទុកឲ្យដើមទ្រូងនៅទទេ ។ ពេលអល់ឡោះហ៍ﷻដាក់ឲ្យស្ត្រីមានសទ្ធា "គ្របដើមទ្រូងដោយសំពត់ទទូរ" នោះ ព្រះអង្គﷻចង់ឲ្យពួកនាងមិនត្រឹមតែគ្របសក់ទេ តែចង់ឲ្យពួកនាងឃ្លុំដើមទ្រូងដោយកន្សែងផងដែរ ។

**លោកស្រី ហ្វាត៉ុម៉ាស្ស** - ពាក្យ "ហ៊ីយ៉ាប់" មិនមាននៅក្នុងគួរអាន ២៤:៣១ និង ៣៣:៥៩ ទេ ។ ក៏ប៉ុន្តែលោកអ្នកប្រាជ្ញលើកអាយ៉ាស្សទាំងនេះមកសំអាងរឿងតែងខ្លួនដោយហ៊ីយ៉ាប់ ។ តើហ៊ីយ៉ាប់មានន័យថាអ្វី ហើយត្រូវប្រើនៅក្នុងគួរអានបែបណា ?

**សៃយីដ្** - ពាក្យហ៊ីយ៉ាប់ក្នុងភាសាអារ៉ាប់មានន័យថាកាត់បន្ថយ បាំងភ្នែកឬរូបភាព ឬធ្វើជារបាំង ដូចវាំងនន ។ ពាក្យនេះមានប្រើនៅក្នុងគួរអានច្រើនដង ។[1]

وَإِذَا سَأَلْتُمُوهُنَّ مَتَـٰعًا فَسْـَٔلُوهُنَّ مِن وَرَآءِ حِجَابٍ ۚ

[1] សូមមើលគួរអាន ៧:៤៦, ៤២:៥១, ៣៨:៣២, ៤១:៥ ។

*ពេលពួកអ្នកសូមអ្វីមួយពីពួកនាង(បណ្ដាភរិយារបស់ព្រះសាស្តា) ចូរពួកអ្នកសូមពីក្រោយរបាំង (៣៣:៥៣) ។*

ពាក្យហ៊្មីយ៉ាប់ប្រើចំពោះស្ត្រីមុស្លីមដែលអនុវត្តិច្បាប់ទទូរក្បាល ដែលត្រូវគ្របឬបិទបាំងខ្លួនដោយស្លៀកពាក់សំលៀកបំពាក់ក្រៅ ពីលើខោអាវ ដែលបាំងនិងរាំងមិនឲ្យមើលឃើញគម្រង់ខ្លួននិងសក់ ។

សំលៀកបំពាក់ពិតសម្រាប់ស្ត្រីមុស្លីមគឺស្លៀកពាក់រលុង គ្របខ្លួនទាំងអស់ ពីមុខទៅដល់កដៃ ហើយធ្លាក់ដល់កជើង ។ មិនត្រូវស្លៀកពាក់អ្វីដែលរឹបខ្លួន ដែលបណ្ដាលឲ្យចេញរាង ដែលមានពណ៌លេចឬដែលថ្លាមើលធ្លុះទេ ។

**លោកស្រី ហ្វាត់ម៉ាស់** -ហេតុអ្វីសៃយីដ្ធគិតថាការបិទបាំងខ្លួនជាការដាក់ខណ្ឌសីមាគ្រប់គ្រាន់ ?

**សៃយីដ្ធ** - គួរអានអធិប្បាយបំភ្លឺដោយឲ្យហេតុផលថ្លៃថ្លាថា៖

أَن يُعۡرَفۡنَ فَلَا يُؤۡذَيۡنَۗ

*ដើម្បីនឹងឲ្យគេស្គាល់ពួកនាង និងដើម្បីនឹងមិនឲ្យគេប្រមាថពួកនាង (៣៣:៥៩) ។*

ពេលស្ត្រីបិទបាំងខ្លួន សំលៀកបំពាក់ស្ត្រីនិយាយជំនួសស្ត្រី ។ មានន័យមិនចំថាស្ត្រីមិនចង់ឲ្យគេចូលមកជិតខ្លួនដោយមិនសមរម្យទេ ។ ការបិទបាំងខ្លួននេះជាការបង្ហាញអត្តសញ្ញាណអ៊ីស្លាមរបស់ស្ត្រីដែរ ។

**លោកស្រី ហ្វាត់ម៉ាស់** - មុនអាយ៉ាស់ដែលទាមទារឲ្យស្ត្រីបិទបាំងខ្លួន

គម្ពីរអាលគួរអានលើកឡើងនូវចំណុចពាក់ព័ន្ធមួយ ។

قُل لِّلْمُؤْمِنِينَ يَغُضُّوا۟ مِنْ أَبْصَٰرِهِمْ وَيَحْفَظُوا۟ فُرُوجَهُمْ ۚ ذَٰلِكَ أَزْكَىٰ لَهُمْ ۗ

*[ហៃសាស្តា !] ចូរអ្នកថ្លែងប្រាប់បុរសអ្នកមានសទ្ធាទាំងឡាយឲ្យពួកគេដាក់ភ្នែក (កុំសម្លឹងមើលអ្វីដែលត្រូវហាម ដែលឲ្យទោស ដោយសេចក្តីត្រេកត្រអាលឡើយ) ហើយឲ្យពួកគេការពារខ្មាសពួកគេ (វៀរចាកមេថុន) ។ វាជាអំពើមួយដ៏បរិសុទ្ធបំផុតសម្រាប់ពួកគេ (២៤:៣០) ។*

**សៃយីដ្** - មិនត្រឹមតែជាចំណុចពាក់ព័ន្ធទេ ថែមទាំងជាការថ្លែងដែលសមហេតុសមផលទៀតផង ។ មុនគម្ពីរអានប្រាប់អំពីសំលៀកបំពាក់ដែលស្ត្រីត្រូវប្រើនោះ អល់ឡោះហ៊ូ ﷻ ប្រាប់បុរសមុន ឲ្យបុរសដាក់ភ្នែកជាមុននិងឲ្យការពារខ្មាស ។

**លោកស្រី ហ្វាត់ម៉ាស់** - "ដាក់ភ្នែក" តើមានន័យថានេះជាបង្គាប់ប្រៀបធៀប ឬជាបង្គាប់ចំៗសម្រាប់បុរស ?

**សៃយីដ្** - មានអត្ថន័យទាំងពីរ ។ ទ្រឹស្តីនៅពីក្រោយអាយ៉ាស់គឺថាត្រូវគោរពស្ត្រី ។ មិនត្រូវចាត់ទុកស្ត្រីឬមើលស្ត្រីដោយចេតនាអាក្រក់ទេ ។ បុរសត្រូវតែចេះគោរព ។ អាយ៉ាស់នេះបញ្ជាក់ប្រាប់ថាបុរសមិនត្រូវគិតអំពីស្ត្រីឬមើលស្ត្រីដោយមានបំណងផ្លូវភេទទេ ។

អ៊ីស្លាមចាត់ទុកស្ត្រីជាគូអង្គជីវិតទាំងមូល ។ គម្ពីរអានចែងហើយចែងទៀតថាស្ត្រីត្រូវបង្កើតមកពីសារធាតុតែមួយនឹងបុរស ហើយនេះជាការរំលឹកដែរថាស្ត្រីមិនអន់ជាងទេ[2] ។ អ៊ីស្លាមថាស្ត្រីនិងបុរសត្រូវបង្កើតមកស្មើ

---

[2] សូមមើលគម្ពីរអាន ៤:១; ៥៣:៤៥-៤៦ ។

គ្នា ។ ហេតុដូច្នេះ ត្រូវគោរពនិងទទួលស្គាល់អ្នកទាំងពីរស្មើគ្នា ។[3]

តែសហគមន៍ខ្លះចាត់ទុកការបិទបាំងខ្លួនជាការនៅក្រោមបង្គាប់ ឬជាការបន្ថោកឋានៈមួយប្រភេទសម្រាប់ស្ត្រី ។ ជាពិត បើគេសាកសួរខ្លួនឯងអំពីការមើលមកស្ត្រីនៅក្នុងសហគមន៍ខ្លះ ជាពិសេសនៅក្នុងសហគមន៍ប៉ែកខាងលិច និងអំពីមធ្យោបាយឃោសនា អំពីគ្រឹះស្ថាន អំពីឧស្សាហកម្មផ្សាយពាណិជ្ជកម្ម តើមធ្យោបាយឃោសនានោះ គ្រឹះស្ថាននោះនិងឧស្សាហកម្មផ្សាយពាណិជ្ជកម្មនោះមើលមកស្ត្រីដូចម្ដេចខ្លះ ។ តើគេអាចអារកាត់បានទេថាស្ត្រីមានសេរីភាពត្រឹមត្រូវតាមមនុស្សធម៌ ?

តើនេះគឺអ្វីដែលយើងចង់ផ្ទេរជាកេរដំណែលឲ្យទៅកូនស្រីយើង បងប្អូនស្រីយើង ភរិយាយើងមែនទេ ថាផ្លូវតែមួយគត់សម្រាប់ស្ត្រីដែលអាចធ្វើឲ្យគេទទួលស្គាល់ខ្លួន ដែលអាចធ្វើឲ្យគេឃើញថាខ្លួនមានសេចក្ដីថ្លៃថ្នូរនោះគឺមានតែផ្លូវបណ្ដោយឲ្យគេជញ្ជក់យកផលប្រយោជន៍ពីខ្លួន ? អកុសលគេផ្ដោតទៅលើរូបកាយស្ត្រីតែម្យ៉ាង ជាជាងផ្ដោតទៅលើបុគ្គលលក្ខណៈនិងប្រាជ្ញា ។ ខ្ញុំបាទយល់ឃើញថានេះគឺការនៅក្រោមបង្គាប់គេនិងជាការបន្ថោកឋានៈមួយប្រភេទ ជាពិសេស វាជាការប្រមាថមើលងាយស្ត្រី ។

អ៊ីស្លាមមិនចាត់ទុកស្ត្រីជាល្បែងកំសាន្តទេ ។ អ៊ីស្លាមឲ្យតម្លៃស្ត្រី ។ ដែលអ៊ីស្លាមបិទបាំងសម្រស់កាយស្ត្រីនោះ ព្រោះតែចង់ឲ្យបុរសទទួលស្គាល់ប្រាជ្ញា បុគ្គលលក្ខណៈនិងអារម្មណ៍របស់ស្ត្រី ។

**លោកស្រី ហ្វាត់ម៉ាស់** - តើបង្គាប់គម្ពីរអានភាគច្រើនកើតឡើងមកពីព្រឹត្តិការណ៍ពិតមែនទេ ដូចជាបទបញ្ញត្តិឲ្យស្ត្រីបិទបាំងខ្លួននោះជាដើម ?

---

[3] សូមមើលគម្ពីរអាន ៣:១៩៥ ។

**សៃយីដ្** - បង្គាប់ភាគច្រើនដែលមានចែងនៅក្នុងគម្ពីរអាននោះមិនមែនជាលទ្ធផលនៃឧបត្តិហេតុឬស្ថានការណ៍លំបាកទាំងអស់ទេ ។ អស់រយៈពេលជាងម្ភៃបីឆ្នាំ អ៊ីស្លាមត្រូវនាំចូលជាសន្សឹមៗទៅក្នុងសហគមន៍ជាមគ្គុទេសក៍ដឹកនាំសម្រាប់មនុស្សជាតិ ។ ខ្សែបន្ទាត់ ការណែនាំ បទបញ្ជា និងច្បាប់បានផុសឡើងនៅក្នុងអំឡុងពេលម្ភៃបីឆ្នាំនេះឯង ។

ដោយដឹងថាសង្គមពិសេសដែលព្រះសាសាដាﷺបានរស់នៅនោះ ជាសង្គមគ្មានច្បាប់ ហើយដែលត្រូវការចង្អុលណែនាំនិងកែប្រែ ការប្រែប្រួលបែបនេះមិនអាចប្រព្រឹត្តទៅបានក្នុងអំឡុងពេលដ៏ខ្លីទេ ។ អ៊ីស្លាមបានប្រឈមនឹងសង្គមដែលស្អិតជាប់នឹងទំនៀមទម្លាប់ តាំងពីច្រើនសតវត្សមកហើយ ហើយបានគិតរឿងកែប្រែយ៉ាងប្រយ័តប្រយែង ។

ក្នុងរឿងខ្លះ គម្ពីរអានដោះស្រាយបញ្ហាជាអន្លើៗ ហើយចែងអំពីបញ្ហានោះតាមវិធីមួយដែលទាក់ទាញអារម្មណ៍មករកបញ្ហានោះ ។ ក្នុងរឿងខ្លះទៀត គម្ពីរអានលើកយកឧបត្តិហេតុជាមូលហេតុបង្កើតច្បាប់ខ្លះ ឬដាក់អាយ៉ាស្ខ្លះចុះមក ដូចជាឧបត្តិហេតុនៅក្នុងផ្សារជាដើមដែលបណ្តាលឲ្យកើតមាននូវច្បាប់ជួញដូរ ។

ជួនកាល គម្ពីរអានធ្វើដំណោះស្រាយដែលនឹងទៅជាបទបញ្ញត្តិ នៅទីបំផុត ។ ឧទាហរណ៍ ការផឹកស្រា ។ អ៊ីស្លាមចង់លុបបំបាត់ការផឹកស្រាឲ្យអស់ តែត្រូវដាក់ការហាមផឹកស្រានោះបន្តិចម្តងៗ នៅក្នុងសហគមន៍ដែលធ្លាប់តែផឹកស្រា ។

ដំបូង គម្ពីរអានចែងថាពេលមុស្លីមឈរស្វ័ឡាត្ញ ចិត្តមិនត្រូវពុល (ឬស្រវឹង) ទេ ។ បន្ទាប់មក នៅចុងក្រោយ គម្ពីរអានហាមផ្តាច់សេពសុរា ។ ក្រោយមក

គេបានបង្កើតច្បាប់ តែក្រោយពីនោះត្រូវលើកចោល ។ ការដាក់ឲ្យអនុវត្តិច្បាប់មានមូលហេតុផ្សេងៗ តែបទបញ្ញត្តិទាំងអស់នោះមិនសុទ្ធតែមកពីឧបត្តិហេតុពិសេសទេ ។

អាយ៉ាស់ដែលទាមទារឲ្យស្ត្រីទទូរក្បាលនោះ បណ្ដាលមកពីឧបត្តិហេតុ (តែមិនសុទ្ធតែកើតមកពីឧបត្តិហេតុផ្ទាល់ទាំងអស់ទេ) ។ អាយ៉ាស់ត្រូវកំណត់ជាមុនស្រេចហើយ តែកាលៈទេសៈជាឱកាសដាក់អាយ៉ាស់នេះចុះមក ។

ឧបត្តិហេតុដែលបណ្ដាលឲ្យបើកឲ្យដឹងព្រះបន្ទូលដំបូង ដែលចែងអំពីការបិទបាំងខ្លួនស្ត្រីនោះគឺ យុវជនម្នាក់បានភាំងស្មារតីដោយសារសម្រស់ស្ត្រីម្នាក់ដែលដើរក្បែរខ្លួន ។ ពេលសម្លឹងមើលស្ត្រីនោះ បុរសនោះដើរជល់ជញ្ជាំង មុតក្បាលនឹងវត្ថុស្រួច ។[4]

ឧបត្តិហេតុទីពីរបានកើតឡើងនៅក្នុងផ្សារ រវាងបុរសយ៉ាហ៊ូឌីអ្នកជួញដូរនិងស្ត្រីអតិថិជនមុស្លីម ។ តាមប្រមើលទៅ ស្ត្រីនោះគ្របដើមទ្រូងមិនជិតធ្វើឲ្យបុរសអ្នកជួញដូរបៀតបៀនគាត់ បង្ករឿង ។

**លោកស្រី ហ្វាត់ម៉ាស់** - គួរអានប្រើពាក្យ "ឃុលបាប់" និង "ឃុម្វូរ" ដើម្បីអធិប្បាយសំលៀកបំពាក់សម្រាប់បិទបាំងខ្លួន តែពាក្យ "ហ៊ីយ៉ាប់" ត្រូវប្រើសម្រាប់អធិប្បាយសំលៀកបំពាក់សម្រាប់បិទបាំងខ្លួនមហេសីព្រះសាស្ដា ﷺ ។

إِذَا سَأَلْتُمُوهُنَّ مَتَاعًا فَسْئَلُوهُنَّ مِن وَرَآءِ حِجَابٍ ۚ

[4] សូមមើលសៀវភៅ أصول الكافي ជុំទី ៥ ទំព័រ ៥២១ ។ ទាក់ទងនឹងគួរអាន ២៤:៣១ ។

*ពេលពួកអ្នកសូមអ្វីមួយពីពួកនាង(បណ្តាភរិយារបស់ព្រះសាស្តា) ចូរពួកអ្នកសូមពីក្រោយរបាំង (៣៣:៥៣) ។*

លោកអ្នកប្រាជ្ញប្រើអាយ៉ាស់នេះជាវិធីបិទបាំងខ្លួនមួយប្រភេទ ដែលរាប់បញ្ចូលមុខនិងដៃរបស់ស្ត្រីមុស្លីមទាំងអស់ ។ តើអាយ៉ាស់នេះពាក់ព័ន្ធនឹងមហេសីព្រះសាស្តាﷺ ឬស្ត្រីមុស្លីមទាំងអស់ ?

**សៃយីដ្** - ទោះបីលោកអ្នកប្រាជ្ញខ្លះជឿថាអាយ៉ាស់ ៣៣:៥៣ អាចប្រើសម្រាប់ស្ត្រីមុស្លីមទាំងអស់ក៏ដោយ តែលោកអ្នកប្រាជ្ញទូទៅមូលមតិគ្នាថាអាយ៉ាស់នេះផ្តោតទៅលើតែមហេសីព្រះសាស្តាﷺទេ និងចែងចំពោះតែមហេសីព្រះសាស្តាﷺទេ ។

លោកអ្នកប្រាជ្ញ (អ៊ូឡាម៉ាអ៊ុ علماء) មានប្រសាសន៍ថាព្រឹត្តិការណ៍នានាដែលបានកើតឡើងជុំវិញព្រះសាស្តាﷺជាមូលហេតុនៃការដាក់អាយ៉ាស់នេះចុះមក ។ ពួកសត្រូវព្រះសាស្តាﷺ ក្នុងសម័យព្រះអង្គﷺ តែងតែចំអកនិងប្រមាថព្រះសាស្តាﷺថា ពួកវានឹងរៀបការជាមួយមហេសីព្រះអង្គﷺពេលព្រះអង្គﷺសោយទិវង្គត ។ រឿងនេះធ្វើឲ្យព្រះសាស្តាﷺរំខានចិត្ត ។ ហេតុដូច្នេះឯងបានជាចម្រូងចម្រាសគ្នាអំពីអាយ៉ាស់នេះ ។

ក៏ប៉ុន្តែខ្លឹមសារនៅពីក្រោយអាយ៉ាស់នេះ គឺការពារស្ត្រីពីបទល្មើសរបស់បុរសដែលចាត់ទុកស្ត្រីគ្រាន់តែជាវត្ថុបំពេញបំណងផ្លូវភេទ ។

فَسْـَٔلُوهُنَّ مِن وَرَآءِ حِجَابٍۚ ذَٰلِكُمۡ أَطۡهَرُ لِقُلُوبِكُمۡ وَقُلُوبِهِنَّۚ

*ចូរពួកអ្នកសូមពីក្រោយរបាំង វាជា អំពើត្រឹមត្រូវបំផុតសម្រាប់ចិត្តពួកអ្នក និងចិត្តពួកនាង (៣៣:៥៣) ។*

ល្អបំផុតនិងត្រឹមត្រូវតាមការពិត អាចយកខ្លឹមសារលំអិតរបស់អាយ៉ាស់

នេះមកប្រើបានក្នុងសហគមន៍ដែលធ្វើបាបស្ត្រី ឬប៉ាន់ប្រមាណស្ត្រីតាមរូបរាង ។

**លោកស្រី ហ្វាត់ម៉ាស់** - ទោះជាយ៉ាងណាក៏ដោយ អ៊ីស្លាម៉ាអ៊ុំខ្លះណែនាំថា នៅក្នុងសង្គមខ្លះស្ត្រីត្រូវបិទបាំងខ្លួនទាំងអស់ ។ តើរឿងនេះមិនផ្ទុយនឹងទ្រឹស្តីដែលថាបុរសត្រូវ "ដាក់ភ្នែក" នោះទេ ហើយកុំគិតអាក្រក់អំពីស្ត្រី ? តើបុរសអាចរៀនអនុវត្តិទ្រឹស្តីនេះបានដូចម្តេចទៅ បើគេសូមឥតឈប់ឲ្យស្ត្រីមុស្លីមបិទបាំងខ្លួនជិតស្លឹបនោះ ?

**សៃយីដ្** - អ៊ីស្លាម៉ាអ៊ុំភាគច្រើនមិនអារកាត់ឲ្យធ្វើដល់ថ្នាក់នេះទេ (គឺបិទបាំងខ្លួនជិតស្លឹប) ។ មែន ប្រសើរបំផុតបើបុរសទាំងអស់អនុវត្តិសិក្ខាបទ និងគោលការណ៍អ៊ីស្លាម តែវាអាចជាការលំបាកណាស់ ។ ជាទូទៅ បុរសចាប់ចិត្តពេលឃើញរូបរាងស្ត្រី ។ បុរសខ្លះមានតែវិធីមួយគត់សម្រាប់បង្ក្រាបការចាប់ចិត្តនេះ គឺលាក់វា ។

**លោកស្រី ហ្វាត់ម៉ាស់** - សៃយីដ្មានប្រសាសន៍អំពីលក្ខខណ្ឌគោលក្នុងការស្លៀកពាក់នោះគឺចាប់ពីលើមុខដល់កដៃ ដល់ក្រោមកជើង ។ ដូចនេះមែនទេដែលលោកអ៊ីស្លាម៉ាអ៊ុំឲ្យអត្ថន័យអាយ៉ាស់ដែលចែងថា៖

مَا ظَهَرَ مِنۡهَاۖ

*គ្រឿងលំអផ្នែកក្រៅ (២៤:៣១)* ?

**សៃយីដ្** - ទោះបីគួរអានមិននិយាយលំអិតអំពី "គ្រឿងលំអផ្នែកក្រៅ" ក៏ដោយ តែអ៊ីស្លាម៉ាអ៊ុំអាស្ហ៍លុល-បៃត៍បានសិក្សាយ៉ាងជ្រាលជ្រៅហាឌីស្ហ៍ព្រះសាស្តាﷺនិងហាឌីស្ហ៍អ៊ីម៉ាំអាស្ហ៍លុល-បៃត៍ ដែលច្រើនតែបញ្ជាក់អំពីកន្លែងដែលគេអនុញ្ញាតឲ្យលែងបាន ពោលគឺ ប្រអប់ជើង ប្រអប់ដៃនិង

ផ្ទៃមុខ ។[5]

**លោកស្រី ហ្វាត់ម៉ាស់** - ហេតុអ្វីមិនរាប់បញ្ចូលផ្ទៃមុខក្នុងលក្ខខណ្ឌនោះ ព្រោះវាជាប៉ែកមួយរបស់ស្ត្រីដែលទាក់ទាញបំផុត ?

**សៃយីដ** - ការលែងផ្ទៃមុខជាអត្តសញ្ញាណកម្មមួយប្រភេទ ។ ត្រូវតែឲ្យគេស្គាល់មុខ ។ ម្យ៉ាងទៀតស្ត្រីត្រូវការមើលនិងសន្ទនា ។ មូលហេតុនៃការមិនបិទបាំងដៃនិងជើងនោះគឺចល័តភាពជាពិសេស ។

**លោកស្រី ហ្វាត់ម៉ាស់** - អ៊ូឡាម៉ាអ៊ុំខ្លះបានធ្វើឲ្យការបិទបាំងខ្លួនពីក្បាលដល់ជើងនោះជាភារកិច្ចរបស់ស្ត្រី ។ ហេតុអ្វីដូច្នេះ ?

**សៃយីដ** - អ៊ូឡាម៉ាអ៊ុំដែលចេញច្បាប់បែបនេះផ្អែកលើហាឌីស្សដែលថាស្ត្រីត្រូវបិទបាំងបាតជើង ព្រោះហាឌីស្សភាគច្រើនដែលស្តីអំពីការបិទបាំងខ្លួនមិនរាប់បញ្ចូលតែផ្ទៃមុខនិងប្រអប់ដៃទេដែលអាចមិនបិទបាំងបាននោះ ។ ម្យ៉ាងទៀត មានហាឌីស្សពិតមួយថែងថាបើមានការសង្ស័យអំពីរឿងណាមួយ គប្បីដាក់វិធានការប្រុងប្រយ័ត្ន (اِحْتِيَاط) ។

**លោកស្រី ហ្វាត់ម៉ាស់** - គួរអានថែងថា

وَلَا يُبْدِينَ زِينَتَهُنَّ إِلَّا مَا ظَهَرَ مِنْهَا

*មិនឲ្យពួកនាងបង្ហាញគ្រឿងលំអរបស់ពួកនាងទេ លើកលែងតែគ្រឿងលំអផ្នែកក្រៅប៉ុណ្ណោះ [ដែលមិនអាចចៀសវាងបាន] (២៤:៣១) ។*

---

[5] សូមមើលសៀវភៅ أصول الكافي ជុំទី ៥ ទំព័រ ៥២១ ។ សូមមើលសៀវភៅ وسائل الشيعة រឿងនីកាស់ វគ្គ ៣៦ និង ១០៩ ។

បន្ទាប់មក គួរអានចែងថាអ្នកណាខ្លះត្រូវអនុញ្ញាតឲ្យឃើញស្ត្រីមិនបិទបាំងខ្លួន ។ ក៏ប៉ុន្តែ អល់ឡោះហ្ ﷻ ហាក់ដូចជាបើកឲ្យដឹងថាសំលៀកបំពាក់មានកម្រិតផ្សេងៗ សម្រាប់មនុស្សដែលមានទំនាក់ទំនងជាមួយស្ត្រី ។ តើសៃឃីដ្ឋអាចអធិប្បាយបានទេអំពីកម្រិតសំលៀកបំពាក់ផ្សេងៗរបស់ស្ត្រីនៅចំពោះមុខអ្នកដទៃ ?

وَقُل لِّلْمُؤْمِنَٰتِ يَغْضُضْنَ مِنْ أَبْصَٰرِهِنَّ وَيَحْفَظْنَ فُرُوجَهُنَّ وَلَا يُبْدِينَ
زِينَتَهُنَّ إِلَّا مَا ظَهَرَ مِنْهَا ۖ وَلْيَضْرِبْنَ بِخُمُرِهِنَّ عَلَىٰ جُيُوبِهِنَّ ۖ وَلَا يُبْدِينَ زِينَتَهُنَّ
إِلَّا لِبُعُولَتِهِنَّ أَوْ ءَابَآئِهِنَّ أَوْ ءَابَآءِ بُعُولَتِهِنَّ أَوْ أَبْنَآئِهِنَّ أَوْ أَبْنَآءِ بُعُولَتِهِنَّ أَوْ
إِخْوَٰنِهِنَّ أَوْ بَنِىٓ إِخْوَٰنِهِنَّ أَوْ بَنِىٓ أَخَوَٰتِهِنَّ أَوْ نِسَآئِهِنَّ أَوْ مَا مَلَكَتْ أَيْمَٰنُهُنَّ أَوِ
ٱلتَّٰبِعِينَ غَيْرِ أُو۟لِى ٱلْإِرْبَةِ مِنَ ٱلرِّجَالِ أَوِ ٱلطِّفْلِ ٱلَّذِينَ لَمْ يَظْهَرُوا۟ عَلَىٰ عَوْرَٰتِ
ٱلنِّسَآءِ ۖ وَلَا يَضْرِبْنَ بِأَرْجُلِهِنَّ لِيُعْلَمَ مَا يُخْفِينَ مِن زِينَتِهِنَّ ۚ وَتُوبُوٓا۟ إِلَى ٱللَّهِ
جَمِيعًا أَيُّهَ ٱلْمُؤْمِنُونَ لَعَلَّكُمْ تُفْلِحُونَ ﴿٣١﴾

*ចូរអ្នកថ្លែងប្រាប់ស្ត្រីដែលមានសទ្ធាទាំងឡាយឲ្យពួកនាងដាក់ភ្នែក (កុំសម្លឹងមើលអ្វីដែលត្រូវហាមដែលឲ្យទោស ដោយសេចក្ដីត្រេកត្រអាលឡើយ) ឲ្យពួកនាងការពារខ្មាស (វៀរចាកមេថុន) ពួកនាង មិនឲ្យពួកនាងបង្ហាញគ្រឿងលំអរបស់ពួកនាងទេ លើកលែងតែគ្រឿងលំអផ្នែកក្រៅប៉ុណ្ណោះ [ដែលមិនអាចចៀសវាងបាន] ឲ្យពួកនាងគ្របដើមទ្រូងដោយសំពត់ទទូរ កុំឲ្យពួកនាងបង្ហាញគ្រឿងលំអពួកនាងចំពោះអ្នកណា ក្រៅពីស្វាមីពួកនាង ក្រៅពីបិតាពួកនាង ក្រៅពីបិតាក្មេករបស់ពួកនាង ក្រៅពីកូនប្រុសៗរបស់ពួកនាង ក្រៅពីកូនប្រុសៗរបស់ស្វាមីពួកនាង ក្រៅពីបងប្អូនប្រុសរបស់ពួកនាង ក្រៅពីកូនប្រុសៗរបស់បងប្អូនប្រុសរបស់ពួកនាង ក្រៅពីកូនប្រុសៗរបស់បងប្អូនស្រីរបស់ពួកនាង ក្រៅពីបណ្ដាស្ត្រីភេទដូចពួកនាង ក្រៅពីទាសីទាំងឡាយរបស់ពួកនាង ក្រៅពីទាសៈដែលពុំមាន*

*កាមរាគ ក្រៅពីក្មេងប្រុសៗមិនទាន់គ្រប់អាយុដែលមិន ទាន់ដឹងរឿងផ្ទែកលាក់បាំងរបស់ស្ត្រី និងចូរកុំឲ្យពួកនាងតន្ត្រំជើងក្នុងបំណងបើកឲ្យគេដឹងដល់គ្រឿងលំអដែលពួកនាងបិទបាំង ។ ហៃអ្នកមានសទ្ធាទាំងឡាយ ចូរពួកអ្នកសូមខមាទោសចំពោះអល់ឡោះហ៍ ដើម្បីពួកអ្នកនឹងមានសុខុមាលភាព[ក្នុងជីវិតពួកអ្នកនិងក្នុងលោកមុខ] (២៤:៣១) ។*

**សៃយីដ្** - ការកត់សម្គាល់របស់លោកស្រីត្រឹមត្រូវ ។ អាយ៉ាស៊្ហបង្ហាញនូវកម្រិតផ្សេងៗនៃសំលៀកបំពាក់ស្ត្រីទាក់ទងទៅនឹងអ្នកដទៃ ។

អ៊ីម៉ាំ មូហាំម៉ាដ្ អាល់-បាក្វៀរ صلوات الله عليه والسلام[6]មានវចនៈថាការបង្ហាញគ្រឿងលំអស្ត្រី (زينة) នោះមានបីថ្នាក់ឬប្រការ ពោលគឺ ខ្លួនប្រាណស្ត្រី ។ គ្រឿងសម្អាងទីមួយសម្រាប់អ្នកដទៃឬមនុស្សផ្ទៃកមុខ ។ គ្រឿងសម្អាងថ្នាក់ទីពីរសម្រាប់សមាជិកគ្រួសារដែលជាសាច់សាលោហិត ដូចជាឪពុក បងប្អូនប្រុសឬកូនប្រុសជាដើម ។ គ្រឿងសម្អាងថ្នាក់ទីបីសម្រាប់ស្វាមី ។

បើស្ត្រីចូលសង្គមជួបជុំឬចូលរួមជាមួយបុរស ស្ត្រីត្រូវបិទបាំងខ្លួនដូចនៅក្នុងឧទាហរណ៍ដែលបានលើកឡើង ស្តីអំពីសំលៀកបំពាក់ឃ្នុលបាប់និងឃ្មូរ ។ ប៉ែកដែលស្ត្រីមិនចាំបាច់បិទបាំងនៅកន្លែងសាធារណៈគឺប្រអប់ដៃនិងផ្ទៃមុខ ។

ពេលស្ត្រីនៅផ្ទះជុំជាមួយសមាជិកគ្រួសារសាច់ជិត ឬជុំជាមួយតែស្ត្រី ស្ត្រីគប្បីស្លៀកពាក់ឲ្យសមរម្យ ។ ឧទាហរណ៍ សំលៀកបំពាក់ត្រូវគ្របប៉ែកលើដើមទ្រូងដល់ក្រោមជង្គង់ ។ ទោះបីស្ត្រីនៅជុំជាមួយឪពុក កូនប្រុស

[6] អ៊ីម៉ាំ អាល់-បាក្វៀរ صلوات الله عليه والسلام ជាអ៊ីម៉ាំអាស៊្ហលុល-បៃត៍ទី ៥ និងជាអ្នកស្នងព្រះសាស្តា صلى الله عليه وآله وسلم ។

បងប្អូនប្រុសឬស្ត្រីក៏ដោយ ក៏ស្ត្រីត្រូវនៅតែស្លៀកពាក់សមរម្យជាដរាប ។

ពេលស្ត្រីនៅជាមួយស្វាមីមួយទល់មួយ ស្ត្រីមិនត្រូវរួញរានិងត្រូវមានសេរីភាពលែងប៉ែកណាមួយនៃខ្លួនប្រាណក៏បាននៅចំពោះមុខស្វាមីខ្លួន ។

អ៊ីស្លាមយល់ឃើញថាស្ត្រីមានពីរចំហៀង ចំហៀងមួយជាចំហៀងមនុស្សធម៌ ចំហៀងមួយទៀតជាចំហៀងស្ត្រីភេទ ។ អ៊ីស្លាមចង់ឲ្យស្ត្រីបើកឲ្យឃើញគុណសម្បត្តិមនុស្សធម៌របស់ខ្លួនជាសាធារណៈ ។ គួរអានថែងប្រៀបធៀបអំពីចំណុចនេះ ។

وَلَا يَضْرِبْنَ بِأَرْجُلِهِنَّ لِيُعْلَمَ مَا يُخْفِينَ مِن زِينَتِهِنَّ

*ចូរកុំឲ្យពួកនាងគន្ត្រំជើងក្នុងបំណងបើកឲ្យគេដឹងដល់ គ្រឿងលំអដែលពួកនាងបិទបាំង (២៤:៣១) ។*

ស្ត្រីមុស្លីមមិនត្រឹមតែត្រូវបិទបាំងខ្លួនប្រាណមួយមុខទេ តែត្រូវប្រព្រឹត្តិខ្លួនឲ្យសមរម្យដូចនោះដែរ ។ បិទបាំងខ្លួនគ្រាន់តែជាលក្ខណៈមួយរបស់ហ៊ីយ៉ាប់ប៉ុណ្ណោះ កត្តាមួយទៀតគឺអាកប្បកិរិយារបស់ស្ត្រី ។

**លោកស្រី ហ្វាត់ម៉ាស់** - តើគួរអានថែងអំពីប្រភេទទណ្ឌកម្មសម្រាប់ស្ត្រីទេ បើស្ត្រីនោះមិនគោរពច្បាប់ហ៊ីយ៉ាប់ ?

**សៃយីដ** - បន្ទាប់ពីបានថែងអំពីការបិទបាំងខ្លួនស្ត្រី គួរអានបានបញ្ចប់ដោយថែងថា៖

وَتُوبُوٓاْ إِلَى ٱللَّهِ جَمِيعًا أَيُّهَ ٱلْمُؤْمِنُونَ لَعَلَّكُمْ تُفْلِحُونَ

*ហៃអ្នកមានសទ្ធាទាំងឡាយ ចូរពួកអ្នកសូមខមាទោសចំពោះអល់ឡោះហ្ទ៍ ដើម្បីពួកអ្នកនឹងមានសុខុមាលភាព [ក្នុងជីវិតពួកអ្នកនិងក្នុងលោកមុខ] (២៤:៣១) ។*

ទូប៊ូ (تُوبُوا) មកពីពាក្យ អ៊ីណាប់បា (نَابَ) មានន័យថាត្រឡប់វិញឬបែរក្រោយវិញ ។ ពាក្យនេះមានន័យសំខាន់បំផុតសម្រាប់អាយ៉ាស់ពិសេសនេះ ត្រង់កន្លែងអល់ឡោះហ្ទ៍ﷻអំពាវនាវឲ្យស្ត្រីមានសទ្ធាបែរមករកព្រះអង្គﷻដោយដាក់ខ្លួន ឲ្យគោរពព្រះបញ្ជាព្រះអង្គﷻដោយស្មោះ ដើម្បីនឹងបានទៅដល់សេចក្ដីត្រឹមត្រូវនិងបានសេចក្ដីចម្រើន ។

**លោកស្រី ហ្វាត់ម៉ាស់** - តើសៃយីដ្ទយល់ឃើញថាហ៊្ចីយ៉ាប់ក្លាយទៅជាសញ្ញាបញ្ជាក់ជំនឿរបស់ស្ត្រីទេ ?

**សៃយីដ្** - សម្រាប់ស្ត្រីខ្លះវាក្លាយទៅជាកត្តាបញ្ជាក់ជំនឿរបស់ខ្លួន ជាពិសេស ស្ត្រីដែលរស់នៅក្នុងសហាគមន៍ប៉ែកខាងលិចឬក្នុងប្រទេសដែលអះអាងថាខ្លួនមុស្លីមតែលះបង់ចោលហ៊្ចីយ៉ាប់ ។ សម្រាប់ស្ត្រីខ្លះដែលរស់នៅក្នុងសហាគមន៍បែបនេះ ការអនុវត្តិហ៊្ចីយ៉ាប់ក្លាយទៅជានិមិត្តរូបនៃជំនឿសាសនារបស់ខ្លួន ជាសញ្ញាមោទនភាពសាសនាដែលចាក់គ្រឹះលើជំនឿស៊ប់ចិត្តចំពោះលទ្ធិរបស់ខ្លួន ។ លើសពីនេះទៀត ហ៊្ចីយ៉ាប់ជាមធ្យោបាយសម្រាប់អភិរក្សអត្តសញ្ញាណសាសនាអ៊ីស្លាមរបស់ខ្លួន ។

**លោកស្រី ហ្វាត់ម៉ាស់** - តើសៃយីដ្ទអាចអធិប្បាយពំពីកត្តាកំណត់ក្នុងការតែងខ្លួនរបស់ស្ត្រីបានទេ ?

**សៃយីដ្** - មិនមានកំណត់សម្រាប់ស្ត្រីក្នុងការតែងខ្លួនសម្រាប់ស្វាមីខ្លួននោះទេ ការពិត គេគាំទ្រយ៉ាងខ្លាំងឲ្យធ្វើដូច្នេះ ។ ក៏ប៉ុន្តែ ពេលស្ត្រីនៅក្រៅ

ផ្ទះ ក្នុងសង្គម ត្រូវតែងខ្លួនជាធម្មតា លើកលែងតែវត្ថុពីរដែលអាចបន្ថែមបានដើម្បីសុខភាព គឺគូល (كُحْل គ្រឿងគូសភ្នែក) និង ហ៊្ហីនណាអ៊ុ (حِنَّاء គ្រឿងលាប) ។

គូលជាសារជាតិខ្មៅធម្មជាតិមួយប្រភេទ ដែលដូចខ្មៅដៃសម្រាប់គូសភ្នែក ប្រើនៅលើភ្នែកជាថ្នាំសម្រាប់ពង្រឹងកម្លាំងភ្នែក ។ ហ៊្ហីនណាអ៊ុជាសារជាតិធម្មជាតិសម្រាប់លាប ប្រើសម្រាប់ធ្វើឲ្យសម្បុរស្បែកប្រសើរឡើងនិងធ្វើឲ្យសក់ក្រាស់ ។ ប៉ុន្តែ មិនអាចបង្ហាញហ៊្ហីនណាអ៊ុឲ្យសារធារណៈជនឃើញជាស្នាមសាក់ឬជាសិល្បលំអខ្លួនប្រាណបានទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - អ៊ូឡាម៉ាអ៊ុខ្លះចេញច្បាប់ថាហាមស្ត្រីពាក់គ្រឿងអលង្ការ ។ តើនេះមែនទេដែលជាមូលហេតុដែលថា

وَلَا يَضْرِبْنَ بِأَرْجُلِهِنَّ لِيُعْلَمَ مَا يُخْفِينَ مِن زِينَتِهِنَّ

*ចូរកុំឲ្យពួកនាងតន្ត្រំជើងក្នុងបំណងបើកឲ្យគេដឹងដល់ គ្រឿងលំអដែលពួកនាងបិទបាំង* ? (២៤:៣១)

**សៃយីដ៍** - អាយ៉ាស់នេះថែងប្រៀបធៀបក្នុងន័យថាមធ្យោបាយទាក់ទាញចិត្ត ធ្វើឲ្យស្រើប ឬល្បួងចិត្តបុរសដោយចេតនា ហើយការធ្វើបែបនេះត្រូវហាមចំពោះស្ត្រី ទោះជាដោយសំលៀកបំពាក់ ដោយគ្រឿងអលង្ការ ដោយមធ្យោបាយផាត់មុខ ឬដោយបូកពារក៏ដោយ ។

ក៏ប៉ុន្តែ បើស្ត្រីពាក់គ្រឿងអលង្ការហួសហេតុឬហួសពីធម្មតាចំពោះមុខគេឯង វាជាអំពើដែលត្រូវហាម ។ មតិទូទៅរបស់អ៊ូឡាម៉ាអ៊ុគឺស្ត្រីអាចពាក់គ្រឿងអលង្ការសាមញ្ញបាន ដូចជាចិញ្ចៀនរៀបការនិងនាឡិកាសាមញ្ញជាដើមបាន ។ ក្រវិលច្រមុះ ខ្សែដៃ ស្នេហ៍មុខនិងខ្សែកមិនត្រូវបង្ហាញ

ចំពោះមុខគេឯងទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - អ្វីខ្លះច្បាប់ស្លៀកពាក់របស់បុរស ?

**សៃយីដ់** - អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ មុនដាក់ច្បាប់បិទបាំងខ្លួនស្ត្រី អល់ឡោះហ៊ូ ﷻ បានថែងចំពោះបុរសថា៖

قُل لِّلۡمُؤۡمِنِينَ يَغُضُّواْ مِنۡ أَبۡصَٰرِهِمۡ وَيَحۡفَظُواْ فُرُوجَهُمۡۚ ذَٰلِكَ أَزۡكَىٰ لَهُمۡۚ

*[ហែសាស្តា !] ចូរអ្នកថ្លែងប្រាប់បុរសអ្នកមានសទ្ធាទាំងឡាយឲ្យពួកគេដាក់ភ្នែក (កុំសម្លឹងមើលអ្វីដែលត្រូវហាម ដែលឲ្យទោស ដោយសេចក្តីត្រេកត្រអាលឡើយ) ហើយឲ្យពួកគេការពារខ្មាសពួកគេ (វៀរចាកមេថុន) ។ វាជាអំពើមួយដ៏បរិសុទ្ធបំផុតសម្រាប់ពួកគេ (២៤:៣០) ។*

ច្បាប់សុជីវធម៌ត្រូវដាក់មកលើបុរសដែរ ។ ពេលបុរសដឹងថារូបរាងរបស់ខ្លួននោះជាការទាក់ទាញមួយប្រភេទដែរសម្រាប់ស្ត្រី បុរសត្រូវតែគោរពខ្លឹមសារអាយ៉ាស់នេះ ។

**លោកស្រី ហ្វាត់ម៉ាស់** - គេមិនបានកំណត់លក្ខខណ្ឌសំលៀកបំពាក់បុរសដូចសំលៀកបំពាក់ស្ត្រីទេ ។ ហេតុអ្វីទៅ ?

**សៃយីដ់** - ការពិត បុរសក៏មានច្បាប់ស្លៀកពាក់ដែរ ។ បុរសមានកំណត់ក្នុងការបិទបាំងខ្លួនពេលនៅជុំជាមួយស្ត្រី ។ បុរសត្រូវបិទបាំងដើមទ្រូងដល់ក្រោមជង្គង់ ។ សំលៀកបំពាក់មិនត្រូវដូចសំលៀកបំពាក់ស្ត្រីទេ ។

សំលៀកបំពាក់បុរសមិនត្រូវចង្អៀត ចេញរាងឬទាក់ទាញចិត្តទេ ។ អ៊ូឡាម៉ាអ៍បន្ថែមថា បើបុរសដឹងថាខ្លួនប្រាណរបស់ខ្លួននោះទាក់ទាញចិត្ត

ស្ត្រី បុរសត្រូវបិទបាំងខ្លួន ។ បុរសមានករណីយកិច្ចស្លៀកពាក់ឲ្យសមរម្យ ។ ហាមបុរសស្លៀកពាក់សូត្រនិងពាក់មាសដែរ ។

**លោកស្រី ហ្វាត់ម៉ាស់** - ហេតុអ្វីគួរអានមិនថែងអំពីច្បាប់ស្លៀកពាក់របស់បុរស ?

**សៃយីដ់** - តាមទម្លាប់ ក្នុងសម័យមុនអ៊ីស្លាម បុរសក្នុងសហគមន៍នោះបិទបាំងខ្លួន រីឯស្ត្រី ជាទូទៅ មិនបិទបាំងខ្លួនទេ ។ ពេលអ៊ីស្លាមជឿនលឿនឈានទៅមុខ អ៊ីស្លាមបានកែប្រែកន្លែងណាដែលត្រូវការផ្លាស់ប្តូរ ។ សម័យនោះ បុរសបានស្លៀកពាក់ត្រឹមត្រូវស្រេចហើយ ហេតុដូច្នេះគួរអានមិនបង្គាប់ឲ្យធ្វើប្រការណា ដែលគេកំពុងតែអនុវត្តិហើយនោះទេ ។ ក៏ប៉ុន្តែ ហាឌីស្ររបស់ព្រះសាស្តាﷺនៅតែថែងអំពីលក្ខខណ្ឌសំលៀកបំពាក់បុរសជានិច្ច ។

**លោកស្រី ហ្វាត់ម៉ាស់** - តែបុរសភាគច្រើនមិនទទួលស្គាល់ថាខ្លួនចាំបាច់ត្រូវបិទបាំងខ្លួនឡើយ ។

**សៃយីដ់** - ព្រោះតែពួកគេមិនស្គាល់ច្បាប់និងការអនុវត្តិអ៊ីស្លាម ។

## វគ្គ ៥ - ការថែរក្សាកូន

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ីស្លាមយល់ឃើញយ៉ាងណាអំពីការថែរក្សាកូន ?

**សៃយីដ្** - គួរអានណែនាំគូស្វាមីភរិយាស្របតាមរឿងនេះថា

وَأۡتَمِرُواْ بَيۡنَكُم بِمَعۡرُوفٖۖ

*ចូរពួកអ្នកពិភាក្សាគ្នាដោយ ស្របតាមគន្លងធម៌ (៦៥:៦) ។*

បើគូស្វាមីភរិយារួមដៃគ្នា ហើយបានព្រមព្រៀងគ្នាថាត្រូវធ្វើអ្វីដែលល្អប្រសើរសម្រាប់កូននោះ អ៊ីស្លាមនឹងគាំទ្រ ។

រឿងថែរក្សាកូនមិននៅលើប្រុសឬស្រីទេ វានៅលើសមត្ថភាពនិងការសមរម្យរបស់ឪពុកឬម្តាយ ពោលគឺ មួយណា (គឺឪពុក ឬ ម្តាយ) ដែលត្រៀមខ្លួនជាស្រេចល្អជាងគេដើម្បីចិញ្ចឹមកូន ។ បើឪពុកម្តាយមិនមូលមតិគ្នារឿងចិញ្ចឹមកូនទេ ក្នុងករណីភាគច្រើន ឪពុកជាអ្នកមានសិទ្ធិចិញ្ចឹមកូន ។

សូមរំលឹកម្តងទៀត លក្ខខណ្ឌផ្អែកលើការសន្មត់ថាឪពុកមានលក្ខខណៈគ្រប់គ្រាន់[ក្នុងការថៃកូន]ផ្អែកសាសនានិងផ្អែកសីលធម៌ ។ ពុំនោះទេ កូនអាចនៅជាមួយម្តាយបាន ឯឪពុកត្រូវបន្តការចាយវាយដើម្បីផ្គត់ផ្គង់កូនតទៅទៀត ។

បើគេប្រគល់ការថែរក្សាកូនឲ្យទៅឪពុក មិនបានសេចក្តីថាម្តាយមិនអាចជួបកូនបាននោះទេ ។ ម្តាយនឹងនៅតែអាចទៅរកកូនបានដដែល ។ ឪពុកមិនអាចហាមម្តាយទៅជួបកូនបានឡើយ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ុឡាម៉ាអ៍មានមតិរួមយ៉ាងណាអំពីលក្ខខណ្ឌអាយុកូនពេលឪពុកម្ដាយមិនមូលមតិគ្នាអំពីសិទ្ធិថែរក្សាកូន ?

**សៃយីដ្** - មិនមានមតិរួមនៅក្នុងចំណោមអ៊ុឡាម៉ាអ៍ទេ តែច្បាប់ទូទៅគឺពេលឪពុកម្ដាយបែកផ្លូវគ្នា ហើយមិនយល់ស្របគ្នារឿងមើលថែរក្សាកូន ម្ដាយជាអ្នកមើលថែរក្សាកូនប្រុសលុះវាបានអាយុពីរខួប កូនស្រីលុះវាបានអាយុប្រាំពីរឆ្នាំ ។ តែច្បាប់នេះមានលក្ខខណ្ឌ ហើយត្រូវអនុវត្តិតាមលក្ខខណ្ឌនោះ ម្ដងមួយករណីៗ ។

បើឪពុកម្ដាយទាំងពីរជាអ្នកមានសទ្ធានិងជាបុគ្គលត្រឹមត្រូវ តុលាការអ៊ីស្លាមនឹងកាត់ឲ្យកូនរស់នៅជាមួយម្ដាយ ច្រើនឆ្នាំដំបូងនៃជីវិតកូននោះ ។ អំឡុងពេលនេះសំខាន់ណាស់សម្រាប់ការធាត់ធំរបស់ក្មេង ហើយបុគ្គលប្រសើរបំផុតសម្រាប់ឆ្លើយតបសេចក្ដីត្រូវការរបស់ក្មេង ក្នុងអំឡុងពេលនេះគឺមាតា ។ ចំណែកឯក្មេងស្រី ភាគច្រើន មកពីមូលហេតុធម្មជាតិស្ត្រីភេទ មានសិទ្ធិនៅក្រោមការបីបាច់រក្សារបស់មាតាយូរជាងក្មេងប្រុស ។

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ីស្លាមយកចិត្តទុកដាក់អំពីការចង់បានរបស់កូនទេ ដែលវាចង់នៅជាមួយឪពុកឬចង់នៅជាមួយម្ដាយនោះ ?

**សៃយីដ្** - បើក្មេងពេញវ័យ ដឹងខុសត្រូវហើយ ដឹងថាអ្វីល្អសម្រាប់ខ្លួនឯងនោះហើយ តុលាការអ៊ីស្លាមនឹងយកចិត្តទុកដាក់អំពីចំណង់ចំណូលចិត្តរបស់ក្មេងនោះ ។

**លោកស្រី ហ្វាត់ម៉ាស់** - ឧបមាថាឪពុកម្ដាយទាំងគូមានលក្ខខណៈគ្រប់គ្រាន់[ក្នុងការថែរក្សាកូន]ផ្នែកសាសនា ផ្នែកសីលធម៌និងផ្នែកថវិកា

ម្នាក់ៗ (គឺឪពុកនិងម្តាយ) ចង់ចិញ្ចឹមកូន តើអ៊ីស្លាមដោះស្រាយករណីនេះបែបណា ?

**សៃយីដ៍** - សន្មត់ថាឪពុកម្តាយទាំងគូចង់ចិញ្ចឹមកូន ហើយមានលក្ខខណៈគ្រប់គ្រាន់ក្នុងវិស័យដែលលោកស្រីបានថានោះ គេនឹងប្រគល់ឲ្យឪពុកសិទ្ធិចំណាយនិងសិទ្ធិចិញ្ចឹមកូន ។

ដែលអ៊ីស្លាមចាត់ទុកឪពុកជាអ្នកថែរក្សាកូនពេញច្បាប់នោះ ស្ថិតនៅលើមូលហេតុច្រើន ។ មូលហេតុមួយក្នុងចំណោមមូលហេតុសំខាន់បំផុតនោះ គឺការរៀបការថ្មី ។ ភាគច្រើន ក្រោយពីបានលែងលះគ្នា គេរៀបការថ្មី ។ បុរសមានកូនទទួលជោគជ័យប្រសើរជាងស្ត្រីមានកូន ក្នុងការរៀបការថ្មី ។

ទោះជាមិនសមហេតុសមផលទេក៏ដោយ តែកូនអាចជាឧបសគ្គសម្រាប់ស្ត្រីដែលចង់រៀបការថ្មី ។ អ៊ូឡាម៉ាអ៊ំក៏គិតដែរអំពីចំណុចដែលកូនត្រូវនាំទៅនៅផ្ទះបុរសផ្សេង វាអាចនឹងមិនព្រមទទួលស្គាល់បុរសនោះទេ ។ មូលហេតុខាងលើនេះជាការប៉ុនប៉ងការពារនិងឃុំគ្រងកូន ព្រមទាំងឪពុកម្តាយដែរ ។

**លោកស្រី ហ្វាត៉ុម៉ាស៊ុ -**

وَٱلْوَٰلِدَٰتُ يُرْضِعْنَ أَوْلَٰدَهُنَّ حَوْلَيْنِ كَامِلَيْنِ ۖ لِمَنْ أَرَادَ أَن يُتِمَّ ٱلرَّضَاعَةَ ۚ

*បណ្តាស្រីជាម្តាយត្រូវឲ្យកូនៗខ្លួនបៅដោះគ្រប់ពីរខួបបរិបូរ បើឪពុកមានបំណងឲ្យបៅដោះរហូតដល់គ្រប់កំណត់ (២:២៣៣) ។*

តើគូរអានចង់និយាយថាឪពុកមានសិទ្ធិសម្រេចផ្តាច់ព្រ័ត្រថា ម្តាយជាមេ

ដោះឬមិនមែនជាមេដោះមែនទេ ?

**សៃយីដ្** - នៅក្នុងអត្ថបទគួរអានច្បាប់ដើម គឺអត្ថបទគួរអានសរសេរជាភាសាអារ៉ាប់នោះ គួរអានចែងថាឪពុកម្ដាយទាំងពីរនាក់ត្រូវមូលមតិគ្នាក្នុងការបំបៅដោះកូនឲ្យគ្រប់ពេលកំណត់ មិនមែនតែឪពុកម្នាក់ទេជាអ្នកសម្រេចនោះ ។

**លោកស្រី ហ្វាត្ម៉ាស្** - តើគេនឹងផ្អែកលើហេតុផលអ្វី ដើម្បីនឹងប្រគល់សិទ្ធចិញ្ចឹមកូនពេញលក្ខណៈឲ្យម្ដាយ ?

**សៃយីដ្** - មានហេតុផលច្រើន ។ ឧទាហរណ៍ ការធ្វើទុក្ខទោស អំពើហិង្សាការទុកចោល ឬការធ្វើបាបកូនពីសំណាក់ឪពុកនឹងត្រូវសម្រេចបែបនេះ ។ម្យ៉ាងទៀត បើឪពុកខូចសីលធម៌ ប្រមាថសាសនា ឬមិនមានការសមរម្យក្នុងខ្លួន - ប្រការទាំងនេះក៏ជាកត្តាផ្ដាច់ព្រ័ត្រក្នុងការអារកាត់ដែរ ។

**លោកស្រី ហ្វាត្ម៉ាស្** - ជួនកាលពេលឪពុកស្លាប់ ជីតាខាងឪពុកប៉ុនប៉ងទាមទារសិទ្ធិចិញ្ចឹមកូនៗ ។ តើអ៊ីស្លាមអនុញ្ញាតឲ្យជីតាយកកូនទេថ្វីបើនៅមានម្ដាយដែលមានសមត្ថភាពចិញ្ចឹមកូននោះ ?

**សៃយីដ្** - អត់ពីឪពុក អ៊ីស្លាមអនុញ្ញាតឲ្យតែជីតាខាងឪពុកទេជាអ្នកមានសិទ្ធិចិញ្ចឹមកូន បើជីតានោះចង់ ។ ក៏ប៉ុន្តែ បើមាតាមានសមត្ថភាពចិញ្ចឹមកូនដោយមានថវិកានិងសីលធម៌គ្រប់គ្រាន់ ដោយមិនធ្វេសប្រហែសសោះ មាតានោះអាចសូមឲ្យតុលាការអ៊ីស្លាម ឬសូមឲ្យអ៊ូឡាម៉ាអ៍ជួយដោះស្រាយដើម្បីប្រគល់សិទ្ធិចិញ្ចឹមកូនមកឲ្យខ្លួន ។

## វគ្គ ៦ - ផ្តល់កសិណ និង ធ្វើអាជ្ញាកណ្តាល

**លោកស្រី ហ្វាត់ម៉ាស្ញុំ** - នៅក្នុងអាយ៉ាស្ញុំគួរអានទាំងអស់ដែលស្តីអំពីការផ្តល់កសិណឬការធ្វើជាសាក្សីនោះ គោលនយោបាយ "បុរសមួយ ស្ត្រីពីរ" ពាក់ព័ន្ធតែនឹងការជួញដូរទេ ។ អាយ៉ាស្ញុំទាក់ទិនទាំងអស់ឯទៀតស្តីអំពីរឿងទូទៅហើយចែងថាសាក្សីពីរនាក់ ដោយមិននិយាយដល់ភេទប្រុសឬភេទស្រីទេ ។[1] អាយ៉ាស្ញុំបន្តស្តីអំពីការផ្តល់កសិណពាក់ព័ន្ធនឹងការជួញដូរក្នុងធុរកិច្ច ។ ហេតុអ្វីបានជាមានអាត្រាធៀប (គឺស្ត្រីនិងបុរសមិនស្មើភាពគ្នា) ហើយនឹងដូច្នេះក្នុងការផ្តល់កសិណឬការធ្វើជាសាក្សីទាំងអស់ទេ ?

شَهِيدَيْنِ مِن رِّجَالِكُمْۖ فَإِن لَّمْ يَكُونَا رَجُلَيْنِ فَرَجُلٌ وَٱمْرَأَتَانِ مِمَّن تَرْضَوْنَ مِنَ ٱلشُّهَدَآءِ أَن تَضِلَّ إِحْدَىٰهُمَا فَتُذَكِّرَ إِحْدَىٰهُمَا ٱلْأُخْرَىٰۚ

*ចូរពួកអ្នកចាត់តាំងឲ្យមានសាក្សីពីរនាក់ ក្នុងចំណោមមនុស្សប្រុសរបស់ពួកអ្នក ។ បើពុំមានមនុស្សប្រុសពីរនាក់ទេ ចូរយកប្រុសមួយនាក់និងស្រីពីរនាក់ ក្នុងចំណោមមនុស្សដែលពួកអ្នកពេញចិត្តឲ្យធ្វើជាសាក្សី ដើម្បីក្រែងលោស្រីណាមួយ ក្នុងចំណោមសាក្សីស្រីទាំងពីរនាក់នោះភ្លាត់ភ្លាំង ស្រីម្នាក់ទៀតនឹងបានជួយរំលឹក (២:២៨២) ។*

ម្យ៉ាងទៀត ហាក់ដូចជាមានការលើកលែងអាត្រានេះចោលពេលការផ្តល់កសិណរបស់ស្ត្រីស្មើនឹងការផ្តល់កសិណរបស់បុរស ។ ការពិតវាឆ្លើយបដិសេធហើយឈ្នះលើការផ្តល់កសិណរបស់ស្វាមីណា ដែលចោទភរិយាខ្លួនថាប្រព្រឹត្តអំពើសហាយស្មន់ ដូច្នេះវាបង្ហាញឲ្យឃើញថាភរិយានោះគ្មានកំហុស ។

---

[1] សូមមើលគួរអាន ៦៥:២; ១:១០៦; ៤:១៥ ។

وَٱلَّذِينَ يَرۡمُونَ أَزۡوَٰجَهُمۡ وَلَمۡ يَكُن لَّهُمۡ شُهَدَآءُ إِلَّآ أَنفُسُهُمۡ فَشَهَٰدَةُ أَحَدِهِمۡ أَرۡبَعُ شَهَٰدَٰتِۭ بِٱللَّهِ إِنَّهُۥ لَمِنَ ٱلصَّٰدِقِينَ ۝٦

*ជនទាំងឡាយណាដែលចោទភរិយារបស់ខ្លួន [ថាពួកនាងមានសហាយស្មន់] ដោយពុំមានសាក្សីទេក្រៅពីខ្លួនឯងផ្ទាល់ ការធ្វើសាក្សីរបស់ជនទាំងនោះគ្រប់ៗគ្នា បិតនៅលើការស្បថបួនដង ចំពោះអល់ឡោះហ្វ៍ថាខ្លួននិយាយពិត (គឺឲ្យគេស្បថក្នុងព្រះនាមអល់ឡោះហ្វ៍បួនដងថាខ្លួននិយាយពិតក្នុងការចោទភរិយារបស់ខ្លួន) (២៤:៦)*

وَٱلۡخَٰمِسَةُ أَنَّ لَعۡنَتَ ٱللَّهِ عَلَيۡهِ إِن كَانَ مِنَ ٱلۡكَٰذِبِينَ ۝٧

*និង[ឲ្យស្បថ]លើកទីប្រាំថា សូមឲ្យបណ្ដាសារបស់អល់ឡោះហ្វ៍ធ្លាក់មកលើខ្លួនគេ ប្រសិនបើគេនិយាយកុហក (២៤:៧) ។*

وَيَدۡرَؤُاْ عَنۡهَا ٱلۡعَذَابَ أَن تَشۡهَدَ أَرۡبَعَ شَهَٰدَٰتِۭ بِٱللَّهِ إِنَّهُۥ لَمِنَ ٱلۡكَٰذِبِينَ ۝٨

*តែមិនធ្វើទណ្ឌកម្មលើស្ត្រី(ភរិយា)ទេ បើនាងស្បថចំពោះអល់ឡោះហ្វ៍បួនដងថាគេ (ស្វាមីរបស់នាង) ជាអ្នកនិយាយកុហកម្នាក់ក្នុងចំណោមអ្នកនិយាយភូតភរពិតមែន (គឺគេបាននិយាយកុហក) (២៤:៨) ។*

**សៃយីដ្** - ទោះបីអាយ៉ាស់គួរអានយោងដែលលោកស្រីថានោះមិននិយាយអំពីអត្រាសាក្សីក៏ដោយ តែសាក្សីភាគច្រើនច្រើនតែផ្អែកលើអាយ៉ាស់ ២:២២៨ មួយប៉ុណ្ណោះដែលនិយាយអំពីអត្រានោះ ។

ក៏ប៉ុន្តែ មានករណីឬរឿងខ្លះដែលទាមទារការពិនិត្យនិងការយល់ដឹង ហើយមានតែស្ត្រីទេដែលអាចស្គាល់បទពិសោធន៍នេះបាន ។ ការផ្ដល់កសិណឬការធ្វើជាសាក្សីរបស់ស្ត្រីមិននៅក្នុងអត្រា "បុរសមួយ ស្រីពីរ"

ទាំងអស់ឬជាចាំបាច់គ្រប់ករណីនោះទេ ។

ចំណែកឯរឿងផ្ទាល់ខ្លួនរបស់ស្ត្រី ដូចជារដូវខែ ការមានផ្ទៃពោះ ការរួមដំណេក ឬការសម្រាលកូន ជាដើម ក្នុងករណីភាគច្រើន អ៊ិឡាម៉ាអ៊ុំ ឬតុលាការយល់ព្រមថាកសិណរបស់ស្ត្រីសំខាន់ជាងកសិណរបស់បុរស ។

ទាក់ទងនឹងអាយ៉ាស់ជួញដូរ ជាទូទៅកាលពីដើម ស្ត្រីមិនជំនាញខាងចរចាដូចបុរសទេ ។ ធុរកិច្ចជាមុខរបររបស់បុរស ។ បុរសដឹងនិងមានបទពិសោធន៍ជាងខាងជួញដូរ ខាងជំនួញ ខាងឲ្យខ្ចី ។ល។ ជាទូទៅ បុរសពូកែខាងធុរកិច្ចជាងស្ត្រី ។ ហេតុដូច្នេះ អត្រាស្ត្រីពីរនាក់ក្នុងការធ្វើសាក្សីនោះច្រើនតែផ្អែកលើបទពិសោធន៍របស់ស្ត្រីខាងជួញដូរ មិនមែនផ្អែកលើសមត្ថភាព ប្រាជ្ញាឬការខ្វះទំនុកចិត្តរបស់ស្ត្រីទេ ។

ٱثۡنَانِ ذَوَا عَدۡلٍ مِّنكُمۡ

*បុរសសុចរិតពីរនាក់ជ្រើសរើសក្នុងចំណោមពួកអ្នក (៥:១០៦) ។*

គួរអានម៉ឹងម៉ាត់រឿងធានាការជួញដូរ បុរសម្នាក់មិនគ្រប់គ្រាន់ទេដើម្បីភ្ជាប់កាតព្វកិច្ចជួញដូរ ត្រូវឲ្យមានបុរសពីរនាក់ ។ សូមរំលឹកម្តងទៀតថាវាមិនផ្អែកនៅលើភេទទេ (គឺមិនប្រកាន់ថាប្រុសឬស្រីទេ) ។ អ៊ីម៉ាំស្វ៉ឌិក្វ صلوات الله عليه والسلام មានវចនៈថា៖ "បុគ្គលណាចង់ធ្វើធុរកិច្ច បុគ្គលនោះគប្បីដឹងច្បាប់និងវិន័យរបស់ធុរកិច្ច ។ បើបុគ្គលនោះធ្វើការជួញដូរដោយមិនស្គាល់ច្បាប់នោះទេ បុគ្គលនោះអាចរងការឈឺចាប់បានដោយសារតែការជួញដូរឥតផលឬដែលធ្វើឲ្យមានមន្ទិល ។"[2]

[2] សូមមើលសៀវភៅ أصول الكافي; معاملات ។

រីឯចំណុចទីពីររបស់លោកស្រី គឺអាយ៉ាស់ដែលអាចឆ្លើយបដិសេធស្វាមីដែលចោទភរិយាខ្លួនថាមានសហាយស្មន់នោះ វាមិនជាប់ទាក់ទិននឹងការធ្វើសាក្សីឬការផ្ដល់កសិណទេ តែអាយ៉ាស់នេះសម្រាប់ប្រើជាមធ្យោបាយការពារខ្លួន ។

**លោកស្រី ហ្វាត់ម៉ាស់** - យោលតាមការអធិប្បាយរបស់សៃយីដ្ ស្ត្រីសម័យមុនខ្វះការពិសោធន៍រឿងធ្វើធុរកិច្ច ។ ក៏ប៉ុន្តែ សម័យយើង ស្ត្រីមានសញ្ញាប័ត្រធុរកិច្ចថែមទាំងជំនាញខាងវិស័យនេះទៀតផង ។ តើច្បាប់នេះនឹងនៅតែដាក់ឲ្យអនុវត្តិលើស្ត្រីទាំងនោះទេ ដែលប្រកបមុខរបរធុរកិច្ចនោះ ?

**សៃយីដ្** - បទបញ្ញត្តិអ៊ីស្លាមអនុលោមទៅតាមបែបបទសង្គម មិនមែនអនុលោមទៅតាមការលើកលែងទេ ។ ខ្ញុំបាទយល់ស្របជាមួយយោបល់លោកស្រីដែលថាស្ត្រីក្លាយទៅអ្នកជំនួញ តែទោះជាយ៉ាងណាក៏ដោយមិនអាចប្រែក្រឡាប់ច្បាប់អ៊ីស្លាមបានទេដោយងាយៗ ព្រោះតែស្ត្រីខ្លះក្លាយទៅអ្នកជំនាញវិស័យណាមួយនោះ ។

តុលាការមុស្លីមប្រយ័តប្រយែងណាស់ពេលស៊ើមអង្កេត ពេលពិនិត្យនិងពេលសាកសួរសាក្សី ។ សូមលើកយករឿងសន្មត់មួយជាឧទាហរណ៍ ក្នុងរឿងសន្មត់នេះស្ត្រីអ្នកជំនាញជាសាក្សីក្នុងការឈ្លោះប្រកែករឿងធុរកិច្ច ។ តុលាការមុស្លីមនឹងយកចិត្តទុកដាក់ អំពីការផ្ដល់កសិណរបស់ស្ត្រីនោះដោយពិនិត្យកេរ្តិ៍ឈ្មោះ បទពិសោធន៍ ចំណេះវិជ្ជានិងអំពីការគួរឲ្យជឿបានក្នុងរឿងនោះ ហាក់ដូចជាស្ត្រីនោះជាបុរសម្នាក់ដែរ ។ម្យ៉ាងទៀតព្រោះតែស្ត្រីនោះជាអ្នកជំនាញមួយរូបក្នុងវិស័យនេះ គេអាចចាត់ទុកកសិណរបស់ស្ត្រីនោះដូចកសិណរបស់បុរសដែរ ។ តែអ្ល់ឡាម៉ាអ៊្វ័នឹងមិនបំភ្លៃច្បាប់អត្រាក្នុងការធ្វើសាក្សីទេ ទោះបីមានករណីប្លែកពីធម្មតាក៏

ដោយ ។

**លោកស្រី ហ្វាត់ម៉ាស៊ុ** - តែលក្ខខណ្ឌ "បុរសមួយ ស្ត្រីពីរ" នឹងនៅតែជាឧបសគ្គសម្រាប់ស្ត្រីដែលគេយកយោបល់ខ្លួនទៅពិភាក្សា ដើម្បីឲ្យដឹងថាតើវាសមហេតុផលឬទេនោះ ផ្ទុយនឹងបុរសដែលមិនបាច់ដាក់យោបល់ ឬការចេះដឹងរបស់ខ្លួនឲ្យគេពិភាក្សាទេ តាំងដើមមកម្ល៉េះ ។

**សៃយីដ្** - ក្នុងសាសនាអ៊ីស្លាមមានសាច់រឿងច្រើនដែលគ្រប់គ្រងរឿងទំនាស់ ដូចជាច្បាប់ជួញដូរ ច្បាប់ព្រហ្មទណ្ឌ ច្បាប់គ្រួសារ ជាដើម ។ រៀបរាប់អំពីច្បាប់ទាំងនេះធ្វើឲ្យយើងបែរចេញពីសាច់រឿងយើង ហើយខាតពេលច្រើនទៀតផង ។ ដើម្បីឆ្លើយសំណួរលោកស្រីយ៉ាងចំៗ សម្រាប់ករណីខ្លះវាដូច្នេះមែន តែសម្រាប់ករណីឯទៀតមិនអាចអនុវត្តិបានទេ វាតាមតែករណីនិងរឿងរ៉ាវនៅជុំវិញករណីនោះ ។

សំខាន់លើសពីនោះទៀត ពេលផ្តល់កសិណាឬធ្វើសាក្សី មិនថាប្រុសឬស្រី ឬខោអាវទេ ភាគីដែលជាប់ពាក់ព័ន្ធក្នុងសវនាការនឹងត្រូវត្រួតពិនិត្យយ៉ាងល្អិតល្អន់ ដូច្នេះសាក្សីនឹងត្រូវពិភាក្សាដើម្បីនឹងដឹងថាសមហេតុផលឬទេ ។

បើតុលាការដឹងច្បាស់ថាសាក្សីណាមួយខ្វះសមត្ថកិច្ច ឬមិនគួរឲ្យទុកចិត្តបាន ទោះជាសាក្សីជាបុរសច្រើននាក់ក្តី ឬតុលាការសង្ស័យថាមានភាពមិនពិតប្រាកដក្តី តុលាការនឹងមិនយកជាការការផ្តល់កសិណារបស់អ្នកទាំងនោះទេ ។ ត្រង់នេះទៀត មិនផ្អែកតែលើភេទតែមួយមុខទេ ការគួរឲ្យទុកចិត្តបានក៏ជាកត្តាសំខាន់មួយដែរ ។

**លោកស្រី ហ្វាត់ម៉ាស៊ុ** - គេឃើញថាបទបញ្ញត្តិ ខលើកចោលនិងគោល

ការណ៍ណែនាំភាគច្រើនសម្រាប់ស្ត្រី ក្នុងអ៊ីស្លាម ទាក់ទងនឹងអារម្មណ៍របស់ស្ត្រី ពោលគឺ អាការសរិរៈសាស្ត្រនិងអាការចិត្តសាស្ត្ររបស់ស្ត្រី ។ អ៊្វឡាម៉ាអ៊ុំអ៊ីស្លាមប៉ុនប៉ងផ្តល់ភ័ស្តុតាងថាច្បាប់ ឬគោលការណ៍ដឹកនាំនោះជាការសមហេតុផលដោយផ្អែកលើធម្មជាតិស្ត្រី ជាពិសេសរឿងបទបញ្ញត្តិធ្វើសាក្សីឬវិនិច្ឆ័យ ។

អ៊្វឡាម៉ាអ៊ុំថាការវិនិច្ឆ័យរបស់ស្ត្រីនៅក្រោមអារម្មណ៍ ដូចជាអាការផ្លាស់ប្តូរផ្លូវសតិអារម្មណ៍និងផ្លូវចិត្តមុនឬក្នុងពេលមានរដូវខែ និងពេលមានផ្ទៃពោះមុននិងក្រោយសម្រាលកូនជាដើម ហើយថាប្រការទាំងនេះជាពាក្យសំអាងរបស់លក្ខន្តិកៈក្នុងការផ្តល់កសិណា ឬក្នុងការមិនឲ្យវិនិច្ឆ័យ ។ សៃយីដ្ឋបានបញ្ជាក់ថាការផ្តល់កសិណានៅលើករណី និងនៅលើការគួរឲ្យទុកចិត្តរបស់បុគ្គលជាចម្បង មិនចាំបាច់ថាប្រុសឬស្រីក្នុងករណីទាំងអស់ទេ ។ តើសៃយីដ្ឋអាចអធិប្បាយលំអិតរឿងចៅក្រមស្ត្រីនិងរឿងអាវេតនិយម (គឺការងាយរំជួលចិត្ត) បានទេ ?

**សៃយីដ្ឋ** - ខ្ញុំបាទសូមនិយាយរឿងមួយប្រាប់លោកស្រី ។ ច្រើនឆ្នាំកន្លងមកហើយ កាលខ្ញុំបាទរស់នៅជាមួយឪពុកម្តាយនិងបងប្អូន ។ យប់មួយយើងបានឮមនុស្សលួចចូលក្នុងបន្ទប់ខាងក្រោយផ្ទះយើង ។ ពេលយើងទៅមើល យើងបានឃើញយុវជនម្នាក់កំពុងលួចទូរទស្សន៍យើង ។ យើងបានចាប់ខ្លួនយុវជននោះ បម្រុងនឹងហៅនគរបាល តែគាត់យំថាបើយើងប្រគល់គាត់ឲ្យទៅនគរបាល គាត់នឹងជាប់ពន្ធនាគារ ។

ដោយបានឃើញគាត់យំ អង្វរករនិងសូមខមាទោស ម្តាយខ្ញុំដែលបានឃើញបានឮឧបត្តិហេតុទាំងអស់នោះក៏អាណិតអាសូរគាត់ ។ ម្តាយយើងក៏បានសូមកុំឲ្យយើងហៅអាជ្ញាធរនិងសូមឲ្យយើងលែងគាត់វិញ ។ ទោះបីបងប្អូនខ្ញុំក៏អាណិតគាត់ដែរក៏ដោយ តែទាំងអស់គ្នាដឹងថាយុវជននោះត្រូវ

តែទទួលខុសត្រូវទង្វើរបស់ខ្លួន ។

រឿងនេះមិនទាក់ទិននឹងការសន្ទនាយើងទេ ក៏ប៉ុន្តែឧបត្តិហេតុនេះបង្ហាញឲ្យឃើញច្បាស់នូវលក្ខណៈងាយរំភើបចិត្តរបស់ស្ត្រីជាទូទៅ ។ លក្ខណៈអារេតនិយមរបស់ស្ត្រីមិនមែនជាសញ្ញានៃការខ្វះសមត្ថភាពយល់ដឹង ឬខ្វះប្រាជ្ញានោះទេ ។ ការពិត អារេតនិយមរបស់ស្ត្រីជាប្រការដែលគួរឲ្យសរសើរនិងជាប៉ែកសំខាន់មួយដែលជាប់នឹងអត្តភាពរបស់ស្ត្រី ។ ហើយវាជាអ្វីដែលសំខាន់បំផុតមួយដែរសម្រាប់គ្រួសារនិងសុខុមាលភាពសង្គម ។

ដូចខ្ញុំបាទបាននិយាយរួចមកហើយ លក្ខខណៈអារេតនិយមរបស់ស្ត្រីមិនមែនជាកង្វះនៅក្នុងការបង្កើតស្ត្រីមកនោះទេ តែក្នុងករណីខ្លះ សម្រាប់ស្ត្រីខ្លះ អារេតនិយមអាចពិបាកទប់បាន ឬអាចពិបាកគ្រប់គ្រង ។ ឧទាហរណ៍ អំពើហាសាវយង់ឃ្នង ឃាតកម្មសាហាវ ឬការប្រយុទ្ធក្នុងសង្គ្រាមជាដើម ។

ទាំងនេះជាបញ្ហាប្រកបដោយសារៈសំខាន់ សូម្បីតែបុរសខ្លះក៏មិនអាចដោះស្រាយឬវិនិច្ឆ័យបានទេដែរ ។ សូមរំលឹកម្តងទៀត ក្នុងករណីខ្លះ វាពិបាកបំផុតសម្រាប់ស្ត្រីក្នុងការដោះស្រាយរឿងទាំងនេះ ។ អស់លោកអ៊ីឡាម៉ាអ៍មានប្រសាសន៍ថា បុរសច្រើនតែមានសមត្ថភាពជាងស្ត្រីក្នុងការដោះស្រាយរឿងនេះ ។ ហេតុដូច្នេះ នៅក្នុងវិស័យខ្លះនៃប្រព័ន្ធតុលាការ ចៅក្រមប្រុសស័ក្តិសមជាងក្នុងការដោះស្រាយរឿងបែបនេះ ។

ចំណែកឯចៅក្រមស្រី មានស្ត្រីចៅក្រមមុស្លីមដែលដឹកនាំករណីក្តី ។ ស្ត្រីមុស្លីមមិនត្រូវលើកលែងពីមុខងារចៅក្រមនៅក្នុងតុលាការណាមួយទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - អ៊ុលិមជាមុខងារខ្ពស់បំផុតមួយក្នុងចំណោមថ្នាក់

ដឹកនាំអ៊ីស្លាម មុច្ជតាហ៊ីដ្ធជាអ្នកស្រាវជ្រាវអ៊ីស្លាម ។ តើស្ត្រីមុស្លីមអាចទៅជាអ៊ុាលិមឬមុច្ជតាហ៊ីដ្ធបានទេ តើសៃយីដ្ធអាចផ្តល់អាយ៉ាស់គួរអានឬហាឌីស្សព្រះសាស្តាصلى الله عليه وآله وسلمជាអំណះអំណាងចម្លើយរបស់សៃយីដ្ធបានទេ ?

**សៃយីដ្ធ** - ព្រះសាស្តាصلى الله عليه وآله وسلمមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាភារកិច្ចរបស់មុស្លីមគ្រប់រូប ប្រុសក្តីស្រីក្តី ។" ចូរកត់សម្គាល់ថាព្រះសាស្តាصلى الله عليه وآله وسلمបានសង្កត់ហាឌីស្សដោយចែងអំពីភេទដាច់ឡែក ។ អ៊ុាលិមគឺបុគ្គលដែលបានសិក្សាអ៊ីស្លាមដល់កម្រិតខ្ពស់ ទៅជាអ៊ុាលិមគឺបាននូវចំណេះវិជ្ជា ។ ចំណេះវិជ្ជាមិនមានទីបញ្ចប់ទេហើយមិននៅលើភេទជាដាច់ខាត ។

អ៊ីជ្ជទីហាដ្ធជាកម្រិតសាសនាខ្ពស់បំផុតក្នុងការសិក្សាអ៊ីស្លាម ។ ពេលអ្នកណាមួយបានដល់កម្រិតអ៊ីជ្ជទីហាដ្ធ គេហៅអ្នកនោះថាមុច្ជតាហ៊ីដ្ធ ។ មុច្ជតាហ៊ីដ្ធជាបុគ្គលដែលមានសមត្ថភាពទាញបញ្ហា និងបទបញ្ញត្តិខាងសាសនាចេញពីប្រភពព័ត៌មានដើមដូចជាគួរអាន និងហាឌីស្សព្រះសាស្តាصلى الله عليه وآله وسلمជាដើមបាន ។ ស្ត្រីមុស្លីមច្រើននាក់បានដល់ថ្នាក់អ៊ីជ្ជទីហាដ្ធ ។

មានស្ត្រីមុស្លីមមុច្ជតាហ៊ីដ្ធល្បីៗជាច្រើនដែលជាសាស្ត្រាចារ្យនៅក្នុងសិក្ខាសាលា បង្ហាត់បង្រៀនអ៊ីស្លាមដល់និស្សិត សរសេរសៀវភៅស្តីអំពីនីតិសាស្ត្រនិងទស្សនៈវិជ្ជាខាងច្បាប់អ៊ីស្លាមដែរ ។

ស្ត្រីមុច្ជតាហ៊ីដ្ធមិនមែនអ្វីដែលថ្មីទេ ។ ព្រះនាងហ្វាទីម៉ាស់سلام الله عليها ព្រះរាជបុត្រីរបស់ព្រះសាស្តាصلى الله عليه وآله وسلم ជាអ្នកចេះដឹងបំផុតម្នាក់អំពីអ៊ីស្លាម ។ ព្រះនាងបានបង្ហាត់គេឯងឲ្យចេះដឹងអ៊ីស្លាម ។ បណ្តាសាវកធំៗរបស់ព្រះសាស្តាصلى الله عليه وآله وسلمតែងតែសូមយោបល់ពីព្រះនាងរឿងសាសនា ។ ព្រះនាងស្សៃណាប់سلام الله عليها ព្រះរាជបុត្រីរបស់ព្រះនាងហ្វាទីម៉ាស់سلام الله عليها ក៏បានបង្ហាត់បង្រៀននៅឯទីក្រុងគូហ្វាស់ដែរ ។ ព្រះនាងស្សៃណាប់سلام الله عليها ដូចព្រះនាងហ្វាទីម៉ាស់سلام الله عليها

ដែរ ល្បីល្បាញជាអ្នកប្រាជ្ញ (អ៊ូឡាម៉ាអ៍) ឯកខាងសាសនា ។

## វគ្គ ៧ - ការដាក់ពិន័យ

وَٱلَّٰتِي تَخَافُونَ نُشُوزَهُنَّ فَعِظُوهُنَّ وَٱهْجُرُوهُنَّ فِي ٱلْمَضَاجِعِ وَٱضْرِبُوهُنَّ ۖ فَإِنْ أَطَعْنَكُمْ فَلَا تَبْغُوا۟ عَلَيْهِنَّ سَبِيلًا ۗ

*រីឯបណ្តាស្ត្រី (គឺភរិយា) ដែលពួកអ្នកក្រែងថាពួកនាងប្រព្រឹត្តមិនត្រឹមត្រូវ ចូរពួកអ្នកអប់រំពួកនាង [បើមិនមានប្រសិទ្ធិភាពទេ] ចូរពួកអ្នកទុកពួកនាងចោលនៅកន្លែងដេក [បើមិនមានប្រសិទ្ធិភាពទេ] ចូរពួកអ្នកវាយ[1] ប្រដៅពួកនាង[ឲ្យស្របតាមច្បាប់អល់ឡោះហ៍] ។ បើពួកនាងព្រមស្តាប់បង្គាប់ពួកអ្នក [ត្រឹមត្រូវតាមព្រះបញ្ញត្តិ] ពួកអ្នកចូរកុំសាងជម្លោះជាមួយពួកនាង (៤:៣៤) ។*

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ីស្លាមអនុញ្ញាតឲ្យដាក់ទណ្ឌកម្មរាងកាយទេ ?

**សៃយីដ្** - អ៊ីស្លាមមិនគាំទ្រឬអំពាវនាវការដាក់ទណ្ឌកម្មខ្លួនប្រាណទេ ។ អ៊ីស្លាមជ្រោមជ្រែងសហប្រតិបត្តិការរួមដៃគ្នា ការគោរពគ្នា ការយោគយល់គ្នារវាងគូស្វាមីភរិយា ។

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ខ្ញុំﷺភ្ញាក់ផ្អើលណាស់ដែលបុរសវាយភរិយាខ្លួន ថ្វីដ្បិតតែអ្នកដែលត្រូវវាយគឺបុរសនោះទេ ។"[2]

ព្រះសាស្តាﷺមានព្រះវចនថា៖ "គេមិនត្រូវធ្វើទារុណកម្មកាយឬធ្វើអ្វី

---

[1] វាយ (وَٱضْرِبُوهُنَّ) ព្រះសាស្តាﷺបានថែងកំណត់ថាការវាយនោះគឺការគោះ (គឺវាយថើរៗ) ។

[2] សូមមើលសៀវភៅ ប៊ីហ្ហារ អាល់-អាន់វ៉ារ (بِحَار ٱلْأَنْوَار) ។

ផ្សេងចំពោះភរិយាខ្លួនជាដាច់ខាត ពីព្រោះអ្នកណាធ្វើបែបនេះ អ្នកនោះប្រព្រឹត្តិល្មើសវិធានការដែលព្រះជាម្ចាស់ﷻនិង ព្រះសាស្ដាﷺព្រះអង្គﷻដាក់មក ។"[3]

ព្រះសាស្ដាﷺមានព្រះវចនថា៖ "តើបុគ្គលណាមួយក្នុងចំណោមអស់លោកអាចវាយភរិយាខ្លួនដូចគេវាយបាសេះ រួចហើយអាចថើបនាងបានដូចម្ដេច ?"[4]

ព្រះសាស្ដាﷺ ដែលជាព្រះអគ្គមហាប្រមុខគំរូឯក មិនដែលវាយស្ត្រីណាមួយ សត្វណាមួយ មនុស្សណាមួយឡើយដែលឈ្លានពានព្រះអង្គﷺ ។ អ៊ែស្ហាស់ មហេសីព្រះសាស្ដាﷺ បានឲ្យដឹងថា៖ "ព្រះសាស្ដាﷺមិនដែលវាយបម្រើណាមួយ ស្ត្រីណាមួយ ឬអ្នកណាមួយឡើយ លើកលែងតែនៅក្នុងយ៉ីហ្វាដ់ (ការពារអ៊ីស្លាម) ។"[5]

**លោកស្រី ហ្វាត់ម៉ាស់** - និយាយពីអាយ៉ាស់ "រសើប" ដែលសៃយីដ្ឋមានប្រសាសន៍ខ្លីៗ "وَٱضۡرِبُوهُنَّ" (វាយថើរៗ) នៅក្នុង "សិទ្ធិគូស្វាមីភរិយា" ដែលសៃយីដ្ឋបានអធិប្បាយរួចមកហើយអំពីមូលហេតុ និងនៅក្នុងឱកាសណាគេឲ្យប្រើច្បាប់នេះ ។ សៃយីដ្ឋមានប្រសាសន៍ខ្លីៗថាស្ត្រីអាចប្រព្រឹត្តដូចគ្នាបានចំពោះស្វាមីខ្លួន ដោយប្រើតុលាការអ៊ីស្លាមអនុវត្តិទណ្ឌកម្មនេះ ។ តើសៃយីដ្ឋអាចរៀបរាប់លំអិតរឿងនេះបានទេ ?

**សៃយីដ្ឋ** - គួរអានមិនអំពាវនាវឲ្យជ្រើសយកទណ្ឌកម្មជាមធ្យោបាយដំបូង

---

[3] សូមមើលសៀវភៅ إرشادُ القُلُوب ។

[4] សូមមើលសៀវភៅ صحيح البخاري ។

[5] សូមមើលសៀវភៅ الطبقات الكبرى ។

ឬជាមធ្យោបាយកែប្រែ ឬជាច្បាប់ជាចាំបាច់នោះទេ ។ គួរអានថែងនូវវិធានការសំខាន់ពីរដែលត្រូវជ្រើសយកជាដំបូង ។ នៅក្នុងមធ្យោបាយចុងក្រោយបំផុតប៉ុណ្ណោះដែលត្រូវប្រើវិធានការធ្វើទណ្ឌកម្ម ប្រសិនបើវាជាមធ្យោបាយតែមួយគត់ដើម្បីដោះស្រាយបញ្ហាបានសម្រេច ។

អ្វីដែលសំខាន់ដែរនោះ គឺត្រូវដឹងថាច្បាប់នេះត្រូវអនុវត្តតែក្នុងពេលដែលស្ថានការណ៍ដុនដាបខ្លាំង ដែលអាចបណ្តាលឲ្យគ្រួសារមានគ្រោះថ្នាក់ ។ មិនត្រូវដាក់ឲ្យប្រើសិក្ខាបទនេះក្នុងករណីខ្វែងគំនិតគ្នាសាមញ្ញ ឬដឹងមុនដែលកើតឡើងជាធម្មតាក្នុងជីវិតអាពាហ៍ពិពាហ៍ទេ ។

គួរអានមិនបង្ខំឲ្យអនុវត្តច្បាប់នេះទេ នេះជាបញ្ញត្តិមិនចាំបាច់ ។ គួរអានឲ្យដំបូន្មានស្វាមីឬភរិយាធ្វើវិធានការដំបូងដើម្បីបន្ធូរស្ថានការណ៍ ដោយដាស់តឿន ដោយស្វែងរកអន្តរាគមន៍ពីគ្រួសារ ដោយស្វែងរកយោបល់ពីអ្នកឯកទេសឬយោបល់ខាងសាសនាសម្រាប់ភាគី (គឺស្វាមីឬភរិយា) ដែលប្រព្រឹត្តល្មើស ។ ទីពីរ បើនៅតែមានបញ្ហា គប្បីព្យួរទំនាក់ទំនងផ្លូវកាយ ឧទាហរណ៍ មិនរួមគ្រែតែមួយ ។

ក្រោយពីបានស្វែងរកវិធានការ និងការដាស់តឿនសព្វគ្រប់ហើយស្ថានភាពនៅតែមិនផ្លាស់ប្តូរ ហើយពុំមានការដោះស្រាយផ្សេងពីការធ្វើទោសទេដើម្បីដោះស្រាយស្ថានការណ៍លំបាក ហេតុដូច្នេះគេអាចឲ្យប្រើការធ្វើទោសបាន ។ ក៏ប៉ុន្តែ មិនដូចគ្នាទេរវាងភាគី (គឺស្វាមីឬភរិយា) ដែលជាអ្នកអនុវត្តច្បាប់ធ្វើទោសនោះ ។

គួរអានអនុញ្ញាតឲ្យស្វាមីអនុវត្តច្បាប់នេះ តែមិនថែងអំពីភរិយាអនុវត្តច្បាប់នេះទៅលើស្វាមីទេ ។ តែនេះមិនមានន័យថាគេមិនអាចអនុវត្តច្បាប់នេះបានទៅលើស្វាមីនោះទេ ។

អ៊ីស្លាមណែនាំឲ្យភរិយាអនុវត្តិការធ្វើទោសនេះ តាមរយៈតុលាការអ៊ីស្លាម ។ តុលាការអ៊ីស្លាមមានអំណាចធ្វើទោសស្វាមីផ្នែករាងកាយ ។ អ៊ីស្លាមមិនចង់ឲ្យភរិយា យកខ្លួនទៅប្រឈមនឹងស្វាមីល្មើសច្បាប់ទេ ព្រោះបុរសអាចទៅជាកាចសាហាវមកលើភរិយា ។

**លោកស្រី ហ្វាត់ម៉ាស់** - តើគេអនុញ្ញាតឲ្យធ្វើទណ្ឌកម្មដល់កម្រិតណា ?

**សៃយីដ្** - របៀបនិងវិធានការអនុវត្តិទណ្ឌកម្មនេះនៅក្រោមការគ្រប់គ្រងតាមច្បាប់យ៉ាងតឹងរ៉ឹង ។ មិនត្រូវចុះដៃអនុវត្តិទណ្ឌកម្មនេះលើសពីការវាយថើៗទេ (គឺគោះថ្នមៗ) ។ ការគោះថើៗនេះមិនត្រូវធ្វើឲ្យមានស្នាមលើរាងកាយទេ មិនត្រូវធ្វើឲ្យមានស្នាមជាំឬធ្វើឲ្យបាក់បែកឆ្អឹងទេ ។ បើការអនុវត្តិទណ្ឌកម្មបណ្តាលឲ្យមានស្លាកស្នាមបែបនេះ អ្នកអនុវត្តិទណ្ឌកម្មនេះត្រូវពិន័យដោយបង់ថ្លៃសងគេ ។ ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ប្រជារាស្ត្រអើយ ចូរកុំវាយស្ត្រីរបស់អស់លោកដោយដំបង ព្រោះអំពើបែបនេះនឹងមានការវាយសងបកមកវិញ [គ៉ីស្វស្វ៉ قصاص] ។"[6]

សម្រាប់អ្នកខ្លះ ធ្វើទោសបន្តិចបន្តួចអាចធ្វើឲ្យអ្នកនោះកែប្រែអាកប្បកិរិយាមិនគប្បីបាន ចំណែកឯអ្នកឯទៀតវាពុំមានប្រយោជន៍ទេ ។ ប្រសិនបើស្វាមីឬភរិយាដឹងជាមុនថាការធ្វើទោសនេះ ពុំអាចដោះស្រាយបញ្ហាបានទេ យកល្អឲ្យលែងលះគ្នាជាជាងបណ្តោយឲ្យស្ថានការណ៍កាន់តែដុនដាបឡើង ។

**លោកស្រី ហ្វាត់ម៉ាស់** - សៃយីដ្ធបានលើកឡើងថា "ពេលស្ថានការណ៍

[6] សូមមើលសៀវភៅ ប៊ីហ្ការ អាល់-អាន់វ៉ារ (بِحار الأنوار) ។

ដុនជាបន្លាំង ហើយជាមធ្យោបាយដើម្បីកែប្រែស្ថានការណ៍បើស្វាមីឬភរិយាសុខចិត្តផ្លាស់ប្តូរ អាចសូមឲ្យធ្វើទោសបាន"។ ក៏ប៉ុន្តែវិធីធ្វើទោស "វាយថើរៗ" នេះមិនដាច់ខាតទេ បើគេគិតដល់ស្វាមីឬភរិយាជាបុគ្គលមានអាកប្បកិរិយាមិនល្អតែម្តងនោះ ។ ធម្មតាវាយថើៗមិនអាចជួយឲ្យបានសម្រេចទេ ។ ហេតុអ្វីសៃយីដ្ធយល់ឃើញថាគួរអានត្រូវតែដាក់បទបញ្ញត្តិនេះមក ?

**សៃយីដ្** - អ្នកឡាម៉ាអ៊្យល់ឃើញថាទំនាក់ទំនងស្វាមីភរិយាមិនត្រូវមានទណ្ឌកម្មផ្នែករាងកាយទេ ។ ក៏ប៉ុន្តែ ធ្វើទោសស្រាលៗអាចធ្វើឲ្យមានការខ្មាស ការអៀនឬការបង្អាប់មួយប្រភេទ ។ ជួនកាលមនុស្សដែលប្រព្រឹត្តិខុសនោះហាក់ដូចជាមិនដឹង ឬមិនសូវយកចិត្តទុកដាក់នឹងទង្វើខ្លួនទេ ។ ជួនកាល សម្រាប់មនុស្សខ្លះ ត្រូវតែរំលឹកមនុស្សនោះ - ពោលគឺដាស់មនុស្សនោះឲ្យភ្ញាក់សតិអារម្មណ៍ ឲ្យមនុស្សនោះដឹងថាទង្វើរបស់ខ្លួនមានកម្រិតធ្ងន់ស្រាល (គឺខុសឬត្រូវ) ។

**លោកស្រី ហ្វាត់ម៉ាស់** - នាងខ្ញុំបានអានសៀវភៅអ៊ីស្លាមខ្លះដែលថាបើភរិយាមិនព្រមគោរពសិទ្ធិរួមដំណេកជាមួយស្វាមីទេ ស្វាមីនោះមានសិទ្ធិធ្វើទោសភរិយានោះ ? តើមែនទេ ?

**សៃយីដ្** - នេះមិនមែនជាការធ្វើទោសសមហេតុសមផលទេ ។ ឱកាសមួយគត់ដែលអាចធ្វើទោសលើរាងកាយបាននោះ គឺពេលស្ថានការណ៍នាំមកនូវគ្រោះថ្នាក់ដល់បុគ្គល ពោលគឺ ដល់ស្វាមីឬភរិយា ឬដល់គ្រួសារ ហើយការធ្វើទោសនេះ អាចដោះស្រាយបញ្ហាបានសម្រេចដូចបំណងមែន ។ អ្នកឡាម៉ាអ៊្ភាគច្រើនសូមណែនាំឲ្យស្វាមីសូមជំនួយពីតុលាការអ៊ីស្លាមជាជាងជ្រើសយកបទល្មើសផ្នែករាងកាយ ក្នុងគោលបំណងដោះស្រាយបញ្ហានីមួយ ។

**លោកស្រី ហ្វាត់ម៉ាស្ទ៍** - សៃយីដ្ធមានប្រសាសន៍នៅក្នុងវគ្គ "សិទ្ធិរបស់គូស្វាមីភរិយា" ថាបុរសនិងស្ត្រីស្មើគ្នាក្នុងការធ្វើទោស ។ ក៏ប៉ុន្តែ គូរអានចែងថាបើដឹងជាក់ច្បាស់ថាស្ត្រីប្រព្រឹត្តិអនាចារ ទោសរបស់ស្ត្រីនោះគឺត្រូវឃុំឃាំងខ្លួននៅក្នុងផ្ទះលុះស្លាប់ ។

តែបើបុរសប្រព្រឹត្តិអនាចារ រួចហើយស្មារលាក់បហុសហើយកែខ្លួនឲ្យល្អវិញ គេឲ្យបុរសនោះរួចខ្លួន ។ តើសៃយីដ្ធអាចអធិប្បាយរឿងនេះបានទេ ?[7]

**សៃយីដ្ធ** - អាយ៉ាស្ទ៍នេះត្រូវលើកចោលនៅក្នុងគូរអាន ។ ការធ្វើទោសរឿងប្រព្រឹត្តិខុសផ្លូវភេទនិងរឿងផឹតក្បត់ស្វាមីភរិយានោះស្មើគ្នា សម្រាប់បុរសនិងស្ត្រី ។

---

[7] សូមមើលគូរអាន ៤:១៥-១៦ ។

## វគ្គ ៨ - ពហុពន្ធភាព (មានប្រពន្ធច្រើនក្នុងពេលតែមួយ)

وَإِنۡ خِفۡتُمۡ أَلَّا تُقۡسِطُواْ فِي ٱلۡيَتَٰمَىٰ فَٱنكِحُواْ مَا طَابَ لَكُم مِّنَ ٱلنِّسَآءِ مَثۡنَىٰ وَثُلَٰثَ وَرُبَٰعَۖ فَإِنۡ خِفۡتُمۡ أَلَّا تَعۡدِلُواْ فَوَٰحِدَةً أَوۡ مَا مَلَكَتۡ أَيۡمَٰنُكُمۡۚ ذَٰلِكَ أَدۡنَىٰٓ أَلَّا تَعُولُواْ ۝٣

*បើសិនជាពួកអ្នកខ្លាចធ្វើមិនត្រឹមត្រូវចំពោះបណ្ដាកូនកំព្រាស្រី ចូរពួកអ្នករៀបការជាមួយ បណ្ដាស្ត្រីដែលពួកអ្នកពេញចិត្ត ពីរនាក់ បីនាក់ ឬបួននាក់ តែបើពួកអ្នកខ្លាចធ្វើមិនត្រឹមត្រូវ [ចំពោះបណ្ដាភរិយារបស់ពួកអ្នក] ចូរពួកអ្នករៀបការជាមួយស្រីតែមួយនាក់ ឬ[បែរទៅរក]អ្វីដែលពួកអ្នកមាន [ដែលស្របតាមច្បាប់] ។ នេះគឺអ្វីដែលប្រសើរសម្រាប់ពួកអ្នក ដើម្បីពួកអ្នកនឹងមិនឃ្លាតចេញពីផ្លូវត្រង់ត្រូវ [ឬដើម្បីពួកអ្នកនឹងមិនប្រព្រឹត្តអំពើទុច្ចរិត] (៤:៣) ។*

**លោកស្រី ហ្វាត់ម៉ាស់** - តើអ៊ីស្លាមមានអ្វីជាអំណះអំណាងរឿងពហុពន្ធភាព (គឺរឿងមានប្រពន្ធច្រើនក្នុងពេលតែមួយ) ?

**សៃយីដ** - អ៊ីឡាម៉ាអ៊ុំមានមូលហេតុច្រើនរឿងពហុពន្ធភាព ដូចជាស្ត្រីមិនអាចរួមដំណេកជាមួយស្វាមីរហូតបានទេពេលមានរដូវខែ ពេលមានផ្ទៃពោះ ឬពេលស្ងួតអង្គធាតុញី (គឺពេលអស់រាគ) ជាដើម ។ អ៊ីឡាម៉ាអ៊ុំបានសំអាងដែរទៅលើវិសមាមាត្រស្ត្រីដែលគ្រប់វ័យរៀបការ ធៀបនឹងចំនួនបុរសដែលអាចរៀបការបាន ។

ទោះបីមូលហេតុខាងលើនេះច្បាស់បន្តិចក៏ដោយ តែមិនងាយស្គាល់ខ្លឹមសារពិតរបស់ពហុពន្ធភាពទេ ។ ពហុពន្ធភាពអាចជាជម្រើស[ដំណោះស្រាយ]មួយសម្រាប់អ្នកខ្លះ ពោលគឺ សម្រាប់ប្រុសនិងស្រីស្មើគ្នា ឬនៅ

ក្នុងករណីពិសេសខ្លះ ឬសម្រាប់ស្ថានការណ៍អនាគត ។

ជាញឹកញយ ពេលគេនិយាយដល់ពហុពន្ធភាព គេទិទានរឿងនេះ ។ ពហុពន្ធភាពមិនមែនច្បាប់កំហិតទេ តែជាទង្វើដែលគេអនុញ្ញាត ។ អាពាហ៍ពិពាហ៍ដែលមិនអាចប្រៀបបាន និងដែលឲ្យផលប្រយោជន៍ដាច់គេគឺអាពាហ៍ពិពាហ៍ឯកពន្ធភាព (គឺរៀបការជាមួយភរិយាតែមួយ) មុស្លីមភាគច្រើនអនុវត្តិឯកពន្ធភាព ។ អ៊ីស្លាមអ៊ុំសម័យបច្ចុប្បន្នមិនណែនាំឬគាំទ្រពហុពន្ធភាពទេ តែគេនៅតែប្រើវាជាមធ្យោបាយដំណោះស្រាយ បើគេជួបប្រទះករណីឬកាលៈទេសៈប្លែកពីធម្មតា ។

សម្រាប់អ្នកខ្លះ ឬនៅក្នុងកាលៈទេសៈនីមួយ គេអាចប្រើពហុពន្ធភាពជាដំណោះស្រាយ ។ ឧទាហរណ៍ នៅឯប្រទេសខ្លះ ស្ត្រីមេម៉ាយឬស្ត្រីដែលត្រូវលែងលះអាចជាកត្តារាំងការរៀបការជាថ្មី ។ តាមទម្លាប់ បុរសដែលរៀបការដំបូងនឹងមិនរៀបការជាមួយស្ត្រីប្រភេទនេះទេ ។ បើគិតពីកាលៈទេសៈនេះ តើគប្បីធ្វើយ៉ាងណា ?

តើស្ត្រីទាំងនេះនៅតែឥតរៀបការអស់មួយជីវិតឬ ? ប្រសិនបើមានបុរសអភិសមាចារនិងមានលទ្ធភាព ដែលចង់ការពារស្ត្រីទាំងនេះដោយស្មោះ ? តើនេះមិនមែនទង្វើត្រឹមត្រូវទេ ?

**លោកស្រី ហ្វាត់ម៉ាស់** - អ្នករិះគន់លើកឡើងជាញឹកញយថាអ៊ីស្លាមគាំទ្រពហុពន្ធភាពដើម្បីបន្តអំណាចលុបលើ បន្តការសង្កត់សង្កិននិងការត្រអាលនឹងកាមរបស់បុរស ។

**សៃយីដ៍** - សម្តីបែបនេះមិនសមហេតុផលទេ ហើយវាផ្ទុយពីគោលការណ៍អ៊ីស្លាមនិងខ្លឹមសាររបស់ពហុពន្ធភាព ។ អ៊ីស្លាមឆ្លើយប្រកែកបុរសណា

ដែលយកពហុពន្ធភាព ជាមធ្យោបាយទាញយកផលប្រយោជន៍ពីស្ត្រី ដើម្បីសេចក្តីសុខសាន្តផ្ទាល់ខ្លួន ។

អ៊ីស្លាមមិនមែនអ្នកផ្តើមគំនិតឬអ្នកផ្សាយពហុពន្ធភាពទេ ។ ពហុពន្ធភាពមានតាំងពីយូរមុនអ៊ីស្លាមម្ល៉េះ ។ សាសនាយ៉ាហ្វូឌី សាសនាគ្រិស្ត ព្រមទាំងវប្បធម៌ច្រើនទៀតបានអនុវត្តិពហុពន្ធភាព ហើយវប្បធម៌ខ្លះនៅតែធ្វើបែបនេះតរៀងមក ។ ព្រះសាស្តាធំៗអនុវត្តិពហុពន្ធភាព ដូចជាព្រះសាស្តាដាវុដﷺ ព្រះសាស្តាស៊ូឡៃម៉ានﷺនិងព្រះសាស្តាអ៊ីបរ៉ហ៊ីមﷺជាដើម ។ ការពិត អ៊ីស្លាមជាសាសនាមួយគត់ដែលដាក់កម្រិតនិងសម្រួលអាពាហ៍ពិពាហ៍ពហុពន្ធភាពឲ្យត្រឹមត្រូវ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើច្បាប់សម្រួលពហុពន្ធភាពដាក់កម្រិតអ្វីខ្លះ ?

**សែឃីដ្** - មុនអ៊ីស្លាមផុសឡើង ពហុពន្ធភាពពុំមានកម្រិតចំនួនភរិយាទេ ភរិយាដែលនៅក្នុងអាពាហ៍ពិពាហ៍ពហុពន្ធភាព ច្រើនតែរងការប្រព្រឹត្តិមិនស្មើភាពគ្នា ។ ពេលអ៊ីស្លាមដាក់ច្បាប់លើពហុពន្ធភាព អ៊ីស្លាមដាក់កម្រិតពហុពន្ធភាពឲ្យមានលក្ខខណ្ឌបីគឺ៖

១. អាពាហ៍ពិពាហ៍ពហុពន្ធភាពមិនបានលើបុរសទាំងអស់ទេ ។
២. មានកម្រិតមានភរិយាត្រឹមបួននាក់ ។
៣. ត្រូវប្រព្រឹត្តិចំពោះភរិយាស្មើភាពគ្នា ។

فَإِنْ خِفْتُمْ أَلَّا تَعْدِلُوا۟ فَوَٰحِدَةً

*បើពួកអ្នកខ្លាចធ្វើមិនត្រឹមត្រូវ [ចំពោះបណ្តាភរិយារបស់ពួកអ្នក] ចូរពួកអ្នករៀបការជាមួយស្រីតែមួយនាក់ (៤:៣) ។*

អ៊ីស្លាមដាក់ភារកិច្ចលើស្វាមីជាអ្នកទ្រទ្រង់ និងចាយវាយទៅលើភរិយា ។ ខ្ញុំបាទបាននិយាយរួចហើយនៅក្នុងវគ្គ "សិទ្ធិរបស់គូស្វាមីភរិយា" ថាស្វាមីមួយគត់ជាអ្នកឧបត្ថម្ភគ្រួសារ ។ បុរសទាំងអស់មិនសុទ្ធតែមានសមត្ថភាពឧបត្ថម្ភនិងចាយវាយដើម្បីទ្រទ្រង់ភរិយាម្នាក់ទេ ហើយកាន់តែមិនអាចទ្រទ្រង់ភរិយាច្រើននាក់បានទេដែរ ថែមទាំងកូនទាំងអស់ទៀតផង ។

អាពាហ៍ពិពាហ៍ទាមទារការមិនខ្វះខាតហិរញ្ញវត្ថុ បើបុរសចង់មានភរិយាច្រើននាក់ បុរសនោះត្រូវមានសមត្ថភាពឧបត្ថម្ភគ្រួសារខ្លួនស្មើភាពគ្នា ដូចជាផ្ទះសម្បែងដូចគ្នា ការបើកប្រាក់ចំណាយស្មើគ្នាជាដើម ។ ពុំនោះទេ គេមិនអនុញ្ញាតឲ្យបុរសនោះមានភរិយាលើសពីម្នាក់ទេ ។

ក្រៅពីចំណុចហិរញ្ញវត្ថុ អ៊ីស្លាមបង្កើតច្បាប់ប្រតិបត្តិសម្រាប់អាពាហ៍ពិពាហ៍ពហុពន្ធភាព ។ មានច្រើនវិធានការដែលចែងរបៀបប្រតិបត្តិពិសេស ។ ឧទាហរណ៍ ស្វាមីត្រូវបែងចែកពេលវេលាស្មើគ្នារវាងភរិយាទាំងឡាយ ត្រូវចំណាយពេលយប់និងពេលថ្ងៃស្មើគ្នារវាងភរិយាទាំងឡាយ ។

បើស្វាមីនាំភរិយាម្នាក់ទៅដើរកំសាន្តឬធ្វើដំណើរ ស្វាមីនោះត្រូវធ្វើដូចនេះចំពោះភរិយាឯទៀតដែរនៅពេលដូចគ្នា ។ បើស្វាមីឲ្យអំណោយភរិយាណាមួយ ត្រូវឲ្យភរិយាឯទៀតនូវអំណោយដែលមានតម្លៃស្មើគ្នាដែរ ។

ពហុពន្ធភាពអាពាហ៍ពិពាហ៍ ក្នុងសាសនាអ៊ីស្លាម មានសមភាពជាមូលដ្ឋានចម្បង ។ ហេតុដូច្នេះ មិនអនុញ្ញាតឲ្យស្វាមីប្រព្រឹត្តដោយលំអៀងឲ្យភរិយាណាមួយមានសិទ្ធិជាងភរិយាឯទៀត ឬរើសអើងភរិយាណាមួយ

ទេ ។ ហ្វាឌីស្ទព្រះសាស្តាﷺដាស់តឿនស្វាមីណាដែលមានភរិយាច្រើន ដែលមិនប្រព្រឹត្តិដោយយុត្តិធម៌ និងសមធម៌ស្មើភាពគ្នារវាងភរិយាទាំងឡាយ ។

**លោកស្រី ហ្វាត់ម៉ាស់** - ចំណែកឯចិត្តរបស់គូស្វាមីភរិយាវិញ តើយ៉ាងណាដែរ ? តើអ៊ីស្លាមសម្រួលឲ្យមានការស្មើភាពគ្នាផ្នែកចិត្តនៅក្នុងពហុពន្ធភាពអាពាហ៍ពិពាហ៍ដូចម្តេចដែរ ?

**សៃយីដ្** - ពេលគួរអានដាក់ឲ្យមានយុត្តិធម៌នៅក្នុងពហុពន្ធភាពអាពាហ៍ពិពាហ៍ គួរអានចង់និយាយដល់សម្ភារៈនិងការប្រព្រឹត្តិ ។ ស្វាមីត្រូវតែផ្តល់ឲ្យភរិយាម្នាក់ៗនូវការរស់នៅស្មើគ្នា និងត្រូវតែប្រព្រឹត្តិចំពោះភរិយាម្នាក់ៗដោយមេត្រីភាព ។

ចំណែកឯមនោសញ្ចេតនា វាកើតឡើងតាមអត្តនោម័តិ ជាជាងតាមការព្យាយាមដោយស្មារតី ។ ក៏ប៉ុន្តែគួរអានចែងដល់ចំណុចនេះ ។

وَلَن تَسۡتَطِيعُوٓاْ أَن تَعۡدِلُواْ بَيۡنَ ٱلنِّسَآءِ وَلَوۡ حَرَصۡتُمۡۖ

*ពួកអ្នកមិនអាចមានសមធម៌[យ៉ាងសុក្រឹត]រវាងបណ្តាភរិយារបស់ពួកអ្នកទេ ទោះបីពួកអ្នកប៉ងប្រាថ្នាយ៉ាងខ្លាំងក៏ដោយ (៤:១២៩) ។*

មនោសញ្ចេតនាជាអាការមួយដែលមនុស្សមិនមានអំណាចគ្រប់គ្រងបានទេ គួរអានក៏ចែងដូច្នេះដែរ ។ ទោះបីមនុស្សមិនអាចគ្រប់គ្រងមនោសញ្ចេតនាខ្លួនឯងបានទាំងស្រុងក៏ដោយ តែមានអំណាចទាំងស្រុងលើការប្រព្រឹត្តិរបស់ខ្លួន ។ ស្វាមីដែលមានភរិយាច្រើនមិនត្រូវសម្តែងឲ្យឃើញមនោសញ្ចេតនាចំពោះភរិយាសំណព្វចិត្ត ឬមានអាកប្បកិរិយា

ដែលបើកឲ្យឃើញថាខ្លួនស្រឡាញ់ភរិយាណាមួយជាងគេទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើមានទំទាក់ទំនងអ្វីរវាងកូនកំព្រាស្រីនិងពហុពន្ធភាព ?

وَإِنْ خِفْتُمْ أَلَّا تُقْسِطُوا۟ فِى ٱلْيَتَٰمَىٰ فَٱنكِحُوا۟ مَا طَابَ لَكُم مِّنَ ٱلنِّسَآءِ مَثْنَىٰ وَثُلَٰثَ وَرُبَٰعَ ۖ فَإِنْ خِفْتُمْ أَلَّا تَعْدِلُوا۟ فَوَٰحِدَةً

*បើសិនជាពួកអ្នកខ្លាចធ្វើមិនត្រឹមត្រូវចំពោះបណ្តាកូនកំព្រាស្រី ចូរពួកអ្នករៀបការជាមួយ បណ្តាស្ត្រីដែលពួកអ្នកពេញចិត្ត ពីរនាក់ បីនាក់ ឬបួននាក់ តែបើពួកអ្នកខ្លាចធ្វើមិនត្រឹមត្រូវ [ចំពោះបណ្តាភរិយារបស់ពួកអ្នក] ចូរពួកអ្នករៀបការជាមួយស្រីតែមួយនាក់ (៤:៣) ។*

**សៃយីដ្** - ក្នុងសម័យមុនអ៊ីស្លាមផុសឡើង បុរសធ្លាប់តែយកកូនកំព្រាស្រីមកចិញ្ចឹម ។ តាមទម្លាប់ បើកូនកំព្រាស្រីមានទ្រព្យ បុរសដែលចិញ្ចឹមកូនកំព្រាស្រីនោះនឹងរៀបការជាមួយកូនស្រីកំព្រានោះ ហើយយកទ្រព្យកូនស្រីកំព្រានោះ ។ ជាញឹកញយណាស់ ស្វាមីទាំងនេះធ្វើបាបកូនស្រីកំព្រានោះហើយមិនបង់ខាន់ស្លាឲ្យភរិយាកូនព្រានោះទេ ។ ក្រោយពីអ៊ីស្លាមមកដល់ អល់ឡោះហ្វ៎ហាមធ្វើបែបនេះ ហើយព្រះអង្គ៎ដាក់កម្រិតទង្វើដែលជាប់ទាក់ទងរវាងកូនកំព្រាស្រីនិងភរិយាច្រើន ។

ចំណុចសំខាន់ពាក់ព័ន្ធនឹងអាយ៉ាស់នេះគឺ នៅក្នុងគួរអានប្រែជាភាសាអង់គ្លេស ឃ្លា *"ធ្វើត្រឹមត្រូវ"* ត្រូវប្រើពីរដងក្នុងរបៀបតែមួយ ។ ក៏ប៉ុន្តែនៅក្នុងភាសាអារ៉ាប់ គេប្រើពាក្យពីរផ្សេងគ្នា ដើម្បីបញ្ជាក់យ៉ាងច្បាស់នូវកម្រិតទង្វើរវាងរៀបការកូនកំព្រាស្រីនិងរៀបការស្ត្រីធម្មតា នៅក្នុងពហុពន្ធភាពអាពាហ៍ពិពាហ៍ ។

ឃ្លាទីមួយស្តីអំពីរបៀបប្រព្រឹត្តិចំពោះកូនកំព្រាស្រី ក្នុងពាអាពាហ៍ពិពាហ៍ ។ *"បើសិនជាពួកអ្នកខ្លាចធ្វើមិនត្រឹមត្រូវចំពោះបណ្តាកូនកំព្រាស្រី* (وَإِنْ خِفْتُمْ أَلَّا تُقْسِطُوا)*"* ធៀបនឹងការប្រព្រឹត្តិក្នុងពហុពន្ធភាពអាពាហ៍ពិពាហ៍ដែលប្រើពាក្យថា *"តែបើពួកអ្នកខ្លាចធ្វើមិនត្រឹមត្រូវ* (فَإِنْ خِفْتُمْ أَلَّا تَعْدِلُوا)" ។ ពាក្យ "ទុក្ចសុីទូ (تُقْسِطُوا)" និង "តាក់ឌីលូ" (تَعْدِلُوا) ជាកម្រិតទង្វើពីរផ្សេងគ្នា ។ "ទុក្ចសុីទូ (تُقْسِطُوا)" គឺកម្រិតខ្ពស់នៃយុត្តិធម៌ នៃសមធម៌និងនៃភាពត្រឹមត្រូវ ហើយគេប្រើក្នុងការប្រព្រឹត្តិចំពោះកូនកំព្រាស្រីក្នុងការរៀបការ ។

"តាក់ឌីលូ" (تَعْدِلُوا) ជាសេចក្តីត្រឹមត្រូវសាមញ្ញ ហើយគេប្រើវាក្នុងការប្រព្រឹត្តិចំពោះភរិយាមិនមែនកូនកំព្រា នៅក្នុងពហុពន្ធភាពអាពាហ៍ពិពាហ៍ ។ ការប្រព្រឹត្តិចំពោះកូនកំព្រាស្រីក្នុងអាពាហ៍ពិពាហ៍លើសយ៉ាងច្រើនពីការប្រព្រឹត្តិចំពោះភរិយាក្នុងពហុពន្ធភាពអាពាហ៍ពិពាហ៍ ។ មូលហេតុគឺ កូនកំព្រាស្រីទន់ខ្សោយងាយត្រូវបុរសកេញប្រវ័ញ្ច ព្រោះពួកនាងពុំមានឪពុកឬគ្រួសារដឹកនាំនិងការពាតកិត្តិយសទេ ។

ស្ថានភាពនេះខុសពីស្ថានភាពភរិយាមិនមែនកូនកំព្រា ក្នុងពហុពន្ធភាពអាពាហ៍ពិពាហ៍ដែលមានឪពុកឬសាច់ញាតិប្រុសដឹកនាំជីវិត ។ ហេតុដូច្នេះគួរអានព្រមាននិងដាស់តឿនថា បើបុរសមិនអាចប្រព្រឹត្តិល្អបំផុតចំពោះកូនកំព្រាស្រីបានទេ ចូរចៀសវាងរៀបការជាមួយកូនកំព្រាស្រី ហើយជ្រើសយកការរៀបការជាមួយស្ត្រីផ្សេង ។

**លោកស្រី ហ្វាត់ម៉ាស់** - ហេតុអ្វីសៃយីដ្ឋគិតថាអ៊ីស្លាមមិនលុបពហុពន្ធភាពអាពាហ៍ពិពាហ៍ចោល ?

**សៃយីដ្** - បច្ចុប្បន្ននេះ មានសហគមន៍ខ្លះនៅតែទាមទារនិងចង់បានពហុពន្ធភាពអាពាហ៍ពិពាហ៍ ។ ម្យ៉ាងទៀត មានសហគមន៍ដែលគេទទួលស្គាល់យ៉ាងខ្លាំង ហើយគេមិនរិះគន់គោលបំណងបរិសុទ្ធនៃពហុពន្ធភាព (ផ្តល់ជម្រកដល់ស្ត្រីខ្លះ) ទេ ។

ស្ត្រីខ្លះនៅក្នុងសហគមន៍បែបនេះមិនត្រូវគេមើលងាយ មិនត្រូវគេគំរាម ហើយមិនស្ទាក់ស្ទើរអំពីរឿងនេះទេ ។ ក្នុងករណីខ្លះ ពហុពន្ធភាពអាពាហ៍ពិពាហ៍ជាដំណោះស្រាយសម្រាប់សហគមន៍ខ្លះដែលស្ត្រីត្រូវការគ្នីគ្នា និងទីពឹងពាក់ ហេតុដូច្នេះ ចោលពហុពន្ធភាពអាពាហ៍ពិពាហ៍អាចជាអំពើអយុត្តិសម្រាប់ស្ត្រីទាំងនោះ ។

**លោកស្រី ហ្វាត់ម៉ាស់** - ទោះបីវាជាសំណួរដែលគេសួរជាញឹកញយក៏ដោយ តែនាងខ្ញុំគិតថាអ្វីដែលសំខាន់នោះគឺត្រូវពន្យល់មូលហេតុដែលព្រះសាស្តាﷺមានមហេសីច្រើននាក់ ។

**សៃយីដ្** - មុនព្រះសាស្តាﷺមានមហេសីច្រើននាក់ ព្រះអង្គﷺអភិសេកមហេសីតែមួយក្នុងព្រះអភិសេកដំបូងបង្អស់ ។ ព្រះសាស្តាﷺបានអភិសេកជាមួយខ៌ទីយ៉ាស្ﷺ ព្រះមហេសីដំបូង អស់រយៈពេល ២៥ ឆ្នាំ លុះព្រះនាងﷺសោយទិវង្គត ។

យោបល់ខ្ញុំអំពីមូលហេតុព្រះសាស្តាﷺមានមហេសីច្រើននាក់នោះ មានបីខគឺ៖ មូលហេតុមនុស្សធម៌ មូលហេតុនយោបាយ និងមូលហេតុដែលគេចាត់ទុកថាជាករណីពិសេស ។

ដំបូង ប្រវត្តិអាពាហ៍ពិពាហ៍របស់ព្រះសាស្តាﷺបានបង្ហាញថាស្ត្រីទាំង

អស់ដែលព្រះអង្គﷺបានអភិសេកនោះជាស្ត្រីត្រូវលែងលះ ឬជាស្ត្រីមេម៉ាយ លើកលែងស្ត្រីព្រហ្មចារីម្នាក់ ។ ក្នុងសម័យនោះ ពុំមានមណ្ឌលសង្គមដែលផ្តល់ជម្រកសង្គ្រោះដល់ស្ត្រីចំពូកនេះ ។

ក្នុងករណីភាគច្រើន ស្ត្រីទាំងនេះត្រូវការស្វាមីដើម្បីជាជម្រកនិងជាពំនាក់ផ្នែកកាយ ផ្នែកចិត្តនិងផ្នែកសាសនា ។ ព្រះសាស្តាﷺ ក្នុងព្រះនាមជារដ្ឋបុរសនិងជាបុរសស្រឡាញ់មនុស្សធម៌ មានកាតព្វកិច្ចចាំបាច់ត្រូវជួយជ្រោមជ្រែងស្ត្រីទាំងនេះ ។ ក្នុងករណីមួយ ព្រះអង្គﷺបានអភិសេកស្ត្រីមេម៉ាយម្នាក់ មានកូនប្រាំមួយនាក់ ដែលស្វាមីស្លាប់ដោយបានការពារអ៊ីស្លាម ។

ទីពីរ អាពាហ៍ពិពាហ៍ខ្លះរបស់ព្រះសាស្តាﷺបង្ហាញឲ្យដឹងថាជាអាពាហ៍ពិពាហ៍នយោបាយ ។ ទំនៀមអាពាហ៍ពិពាហ៍ខ្លះនៅក្នុងទ្វីបអារ៉ាប់មានន័យលាក់បាំងជាសញ្ញាពាណិជកម្ម ជាការចងស្ពានមេត្រីនយោបាយ ។ ពេលពួកគេរៀបការក្រៅស្រុកកំណើតខ្លួន ពួកគេទៅជាជិតស្និទ្ធនឹងសហគមន៍របស់ស្វាមីឬភរិយា ។ មហេសីភាគច្រើនរបស់ព្រះសាស្តាﷺ មានវណ្ណៈផ្សេងៗ មកពីក្រុមពួកផ្សេងៗ មកពីស្រុកទេសផ្សេងៗ ហេតុដូច្នេះ ព្រះអង្គﷺអាចការពារនិងផ្សាយសាសនាអ៊ីស្លាមបានតាមរយៈស្ពានមេត្រីអាពាហ៍ពិពាហ៍ ។

ទីបី ស្ត្រីខ្លះសូមរៀបការជាមួយព្រះសាស្តាﷺ ។ ឧទាហរណ៍ សម័យមួយស្ត្រីម្នាក់បានមកជួបព្រះសាស្តាﷺ សូមឲ្យព្រះអង្គﷺរៀបការជាមួយគាត់ ។ ព្រះអង្គﷺបានធ្វើដូច្នេះក្រោយពីអល់ឡោះហ្វ៍ﷻបានដាក់វ៉ាហ៊្យីអនុញ្ញាតថា៖

وَٱمۡرَأَةٗ مُّؤۡمِنَةً إِن وَهَبَتۡ نَفۡسَهَا لِلنَّبِيِّ إِنۡ أَرَادَ ٱلنَّبِيُّ أَن يَسۡتَنكِحَهَا خَالِصَةٗ لَّكَ مِن دُونِ ٱلۡمُؤۡمِنِينَۗ

*និងស្រីមានសទ្ធាប្រសិនបើនាងប្រគល់ខ្លួននាងផ្ទាល់ឲ្យសាស្តា បើសាស្តាប្រាថ្នារៀបការជាមួយនាង នេះគឺឯកសិទ្ធិសម្រាប់អ្នកតែមួយគត់ មិនបានលើបណ្តាអ្នកមានសទ្ធាដទៃទេ (៣៣:៥០) ។*

## វគ្គ ៩ - ការចែកមរតក

يُوصِيكُمُ ٱللَّهُ فِىٓ أَوْلَٰدِكُمْ ۖ لِلذَّكَرِ مِثْلُ حَظِّ ٱلْأُنثَيَيْنِ ۚ

*អល់ឡោះហ៍ដាក់បង្គាប់លើពួកអ្នកអំពីរឿង [ចែកមរតករវាង] បណ្ដាកូនរបស់ពួកអ្នកថា៖ កូនប្រុសត្រូវបានប៉ុនចំណែករបស់កូនស្រីពីរនាក់ (៤:១១) ។*

**លោកស្រី ហ្វាត់ម៉ាស់** - ក្នុងសាសនាអ៊ីស្លាម តើអត្រាចែកមរតកអាចធ្វើបានចំពោះតែកូនៗទេ ?

**សៃយីដ** - រឿងមរតក ដូចរឿងច្រើនដែលបានអធិប្បាយកន្លងមកហើយដែរ ត្រូវគ្រប់គ្រងសម្រួលដោយយោលតាមករណីដែរ ហេតុដូច្នេះ ការចែកមរតកមិនអាចធ្វើទៅបានគ្រប់ករណីមរតកទេ ។

មានកត្តាច្រើនដែលត្រូវយកចិត្តទុកដាក់ មុននឹងចែកមរតក ។ ក្នុងគ្រប់ករណីទាំងអស់ វានៅលើអ្នកស្លាប់ នៅលើអ្នកជាប់សាច់ឈាមអ្នកស្លាប់ ដូចជា បើអ្នកស្លាប់ស្លាប់ចោលភរិយា ស្លាប់ចោលកូន ចោលឪពុកម្ដាយចោល បងប្អូនស្រី ចោលបងប្អូនប្រុស ឬអ្នកស្លាប់ពុំមានកូនចៅទេជាដើម ។ ក្រោយពីបានដឹងច្បាស់សាច់សាលោហិតហើយ ទើបអាចបែងចំណែកមរតកបាន ។

ឧទាហរណ៍ បើឪពុកម្ដាយស្លាប់ នៅសល់តែកូនស្រីទាំងអស់ កូនស្រីទាំងអស់គ្នានោះបានចំណែកមរតកស្មើគ្នា ។ បើឪពុកស្លាប់ នៅសល់តែកូនមួយគត់នៅរស់ មិនមានប្រពន្ធឬមិនមានឪពុកម្ដាយរបស់អ្នកស្លាប់នៅរស់ទេ កូននោះបានទ្រព្យទាំងអស់របស់ឪពុកស្លាប់ ទោះជាកូនប្រុសក្ដីទោះជាកូនស្រីក្ដី សាច់ញាតិឯទៀតមិនមានសិទ្ធិទាមទារមរតកទេ ។

ហេតុដូច្នេះ មិនមែនច្បាប់ទទួលមរតកទាំងអស់ចែងឲ្យប្រុសទទួលបានមរតកពីរចំណែកលើសស្រីទេ ។

មានប្រការច្រើនទៀតដែលស្ត្រីបានចំណែកមរតកស្មើនឹងបុរស ។ ក្នុងករណីច្រើន ម្តាយមានសិទ្ធិបានចំណែកមរតក ដែលបានមកពីកូនប្រុសស្មើនឹងឪពុក (ពោលគឺ ពេលកូនប្រុសស្លាប់ ម្តាយនិងឪពុកបានមរតកស្មើគ្នា គឺបានមួយភាគប្រាំមួយដូចគ្នា) ។

និយាយដោយជាក់លាក់ អំពីអាយ៉ាត់ដែលលោកស្រីលើកមកនិយាយនោះ[1] បើមានកូនប្រុសនិងកូនស្រី ហើយភោគទ្រព្យនោះជារបស់ឪពុកម្តាយកូនៗទាំងនោះ គេនឹងដាក់ឲ្យប្រើច្បាប់អត្រាទទួលមរតកនោះ ។ កូនប្រុសត្រូវបានពីរភាគបី ឯកូនស្រីត្រូវបានមួយភាគបីក្នុងចំណែកមរតក ។

**លោកស្រី ហ្វាត់ម៉ាស់** - ហេតុអ្វីបានជា នៅក្នុងគ្រួសារតែមួយ កូនប្រុសបានកេរមរតកឪពុកម្តាយច្រើនជាងកូនស្រី ?

**សៃយីដ** - ការបែងចែកមិននៅលើការរើសអើងភេទទេ តែនៅលើមូលដ្ឋានបទបញ្ញត្តិអ៊ីស្លាមដែលមានទ្រឹស្តីថា បុរសជាអ្នកមានភារកិច្ចចាយវាយដើម្បីទ្រទ្រង់គ្រួសារ ។ ហេតុដូច្នេះ តម្លៃជួសជុលជាមូលហេតុចម្បងនៃការកំណត់អត្រាចំណែកមរតក ។

កូនប្រុសមានភារកិច្ចចាយវាយក្នុងការចិញ្ចឹមម្តាយដែលនៅរស់ និងបងប្អូនបង្កើតដែលនៅក្នុងបន្ទុកខ្លួន ។ អាស្រ័យហេតុនេះ កូនប្រុសអាចប្រើ

---

[1] សូមមើលគួរអាន ៤:១១ ។

ភោគទ្រព្យរបស់ឪពុកស្លាប់ជាមធ្យោបាយចិញ្ចឹមគ្រួសារ ។ នេះគឺគណនីសន្សំមួយប្រភេទដែលផ្តល់ឲ្យកូនប្រុសនូវភារកិច្ចជាអ្នកចែកចាយ និងជាអ្នកផ្គត់ផ្គង់គ្រួសារ ។

កូនប្រុស ផ្ទុយពីកូនស្រី មានភារកិច្ចផ្គត់ផ្គង់និងគាំទ្រគ្រួសារបង្កើតក្នុងការចាយវាយ ។ ស្ត្រីមុស្លីម ទោះជាកូនស្រីក្តី បងប្អូនស្រីក្តី ឬម្តាយក្តី រួចផុតពីភារកិច្ចផ្គត់ផ្គង់ខ្លួនឯងនិងអ្នកដទៃក្នុងការចាយវាយ ។

អ្វីៗដែលស្ត្រីរកបាននិងទទួលបាននោះជារបស់ខ្លួនផ្ទាល់ ។ ស្ត្រីមិនចាំបាច់ត្រូវទ្រទ្រង់ឬផ្គត់ផ្គត់អ្នកណាទេ ។ ស្ត្រីមុស្លីមមានសិទ្ធិទទួលមរតកក្នុងនាមជាកូនស្រី ក្នុងនាមជាម្តាយ ក្នុងនាមជាភរិយា និងក្នុងនាមជាបងប្អូនស្រី ។ ដូច្នេះ ក្នុងករណីខ្លះ ស្ត្រីអាចមានទ្រព្យច្រើនជាងបុរស ។

**លោកស្រី ហ្វាត់ម៉ាស៊ុំ** - តើអាចផ្ទេរទ្រព្យឲ្យទៅអ្នកណាមួយបានទេក្នុងពេលដែលម្ចាស់បណ្តាំនៅរស់ ?

**សៃយីដ្** - ម្ចាស់បណ្តាំប្រុសឬម្ចាស់បណ្តាំស្រីអាចផ្ទេរភោគទ្រព្យរបស់ខ្លួនឲ្យទៅអ្នកណាមួយក៏បានក្នុងពេលដែលខ្លួននៅរស់ ។ មានន័យថា ម្ចាស់បណ្តាំអាចផ្លាស់ប្តូរឈ្មោះអ្នកមានសិទ្ធិទទួលភោគទ្រព្យរបស់ខ្លួន ពីឈ្មោះខ្លួនឲ្យទៅឈ្មោះភាគីផ្សេង ដោយពេញច្បាប់ ។ តាមផ្នែកទ្រឹស្តី ម្ចាស់បណ្តាំអាចបរិច្ចាគភោគទ្រព្យទាំងអស់របស់ខ្លួន ក្នុងពេលដែលខ្លួននៅរស់ មិនទុកអ្វីៗឲ្យមានសល់ជាកេរមរតកឡើយ ។

**លោកស្រី ហ្វាត់ម៉ាស៊ុំ** - តើម្ចាស់បណ្តាំប្រុសឬម្ចាស់បណ្តាំស្រីអាចចែកកេររបស់ខ្លួនមួយភាគបីឲ្យទៅអ្នកណាមួយបានទេ ?

**សៃឃីដ្** - នៅក្នុងសំបុត្របណ្តាំ ម្ចាស់បណ្តាំអាចបរិច្ចាគកេររបស់ខ្លួនមួយភាគបីឲ្យទៅអ្នកណាមួយក៏បាន ឲ្យទៅវិទ្យាស្ថាន ឬឲ្យទៅអង្គការណាមួយក៏បានដែលម្ចាស់បណ្តាំប្រុស ឬម្ចាស់បណ្តាំស្រីនោះបានជ្រើសរើសស្រេចហើយ ។

**លោកស្រី ហ្វាត់ម៉ាស់** - សព្វថ្ងៃនេះ ឪពុកម្តាយច្រើនតែសុខចិត្តបែងចែកកេរមរតករបស់ខ្លួនឲ្យទៅកូនប្រុសស្រីស្មើៗគ្នា ។ តើធ្វើបែបនេះអាចចាត់ទុកជាបទល្មើសសម្តីគួរអានបានទេ ?

**សៃឃីដ្** - បើឪពុកម្តាយបានសរសេរសំបុត្របណ្តាំ (ឲ្យធ្វើក្រោយពីខ្លួនស្លាប់) ថាឲ្យចែកកេរមរតកស្មើៗគ្នារវាងកូនប្រុសនិងកូនស្រី វាអាចជាបទល្មើសបញ្ញាគួរអានបាន ។ នៅក្នុងអាយ៉ាស់ច្រើនដែលចែងអំពីការចែកមរតកនោះ គួរអានព្រមានជាមុនបណ្តាអ្នកដែលមិនគោរពព្រះបញ្ញា ។

فَرِيضَةً مِّنَ ٱللَّهِۗ

*នេះជា[ចំណែកដែលជា]កាតព្វកិច្ច ដែលកំណត់មកពីអល់ឡោះហ្ទ៍ (៤:១១) ។*

وَصِيَّةً مِّنَ ٱللَّهِۗ

*នេះជាព្រះបញ្ញារបស់អល់ឡោះហ្ទ៍ (៤:១២) ។*

وَمَن يَعۡصِ ٱللَّهَ وَرَسُولَهُۥ وَيَتَعَدَّ حُدُودَهُۥ يُدۡخِلۡهُ نَارًا خَٰلِدًا فِيهَا وَلَهُۥ عَذَابٞ مُّهِينٞ ١٤

*អ្នកណាល្មើសបង្គាប់អល់ឡោះហ៍និងព្រះសាស្តាព្រះអង្គ បំពារបំពានក្របខ័ណ្ឌអល់ឡោះហ៍ ព្រះអង្គនឹងឲ្យអ្នកនោះចូលភ្លើងនរក នឹងនៅក្នុងនោះជានិច្ចអនន្ត អ្នកនោះនឹងរងទណ្ឌកម្មអាម៉ាស់ (៤:១៤) ។*

ក៏ប៉ុន្តែ គេអនុញ្ញាតឲ្យឪពុកម្តាយផ្ទេរកម្មសិទ្ធិ ភោគទ្រព្យឬប្រាក់របស់ខ្លួនឲ្យទៅកូនណាមួយបាន ។ ទង្វើនេះអាចជួយឪពុកម្តាយខ្លះបានដែលមានកូនមិនស្តាប់បង្គាប់យ៉ាងជាក់ស្តែងនោះ ។ ឧទាហរណ៍ ឪពុកម្តាយមានកូនប្រុសម្នាក់មិនត្រឹមត្រូវ មានកូនស្រីម្នាក់ត្រឹមត្រូវ ។

គេអាចសន្មត់បានថា ឪពុកម្តាយអាចក្រែងខ្លាចកូនមិនស្តាប់បង្គាប់នោះចាយវាយឬប្រើប្រាស់កេរមរតកនោះមិនត្រឹមត្រូវ ផ្ទុយពីកូនស្រីដែលថែទាំឪពុកម្តាយ ជ្រោមជ្រែងឪពុកម្តាយនិងរក្សាកិត្តិយសឪពុកម្តាយ ហើយនឹងការពារនិងថែរក្សាភោគទ្រព្យរបស់ខ្លួនបានយ៉ាងត្រឹមត្រូវ ។ ឪពុកម្តាយអាចជ្រើសរើសផ្ទេរកម្មសិទ្ធិរបស់ខ្លួនមួយប៉ែក ឬទាំងអស់ឲ្យទៅកូនណាម្នាក់បានដោយស្របច្បាប់ ក្នុងពេលដែលខ្លួននៅរស់ ទោះបីកូននោះជាកូនស្រីក៏ដោយ ។

**លោកស្រី ហ្វាត់ម៉ាស់** - សៀវភៅអ៊ីស្លាមខ្លះបានសរសេរថាព្រោះតែស្ត្រីរួចផុតពីការចូលប្រលូកក្នុងសមរភូមិទើបមានសិទ្ធិបានមរតកតិច តើត្រឹមត្រូវទេ ?

**សៃយីដ់** - មិនគប្បីចាត់ទុកជាមូលហេតុសមហេតុផលទេ ។

**លោកស្រី ហ្វាត់ម៉ាស់** - តើមានរឿងផ្សេងៗពាក់ព័ន្ធនឹងស្ត្រីមុស្លីមដែលសំខាន់ត្រូវបំភ្លឺត្រង់នេះទេ ?

**សៃយីដ្** - រឿងពាក់ព័ន្ធនឹងស្ត្រីមុស្លីមមិនមានទីបញ្ចប់ទេ ។ ក៏ប៉ុន្តែ អ្វីដែលសំខាន់នោះគឺ ស្ត្រីមុស្លីមត្រូវសិក្សាឲ្យចេះដឹងនិងស្គាល់សិទ្ធិរបស់ខ្លួនក្នុងសាសនា ។ ស្ត្រីមុស្លីមមានសិទ្ធិស្គាល់ជម្រើសនិងឱកាសរបស់ខ្លួនដែលអ៊ីស្លាមផ្តល់ឲ្យ ។ ពេលបានដឹងស្គាល់សិទ្ធិរបស់ខ្លួន ស្ត្រីអាចធានាអនាគតរបស់ខ្លួនបាន ។

# សេចក្ដីបញ្ចប់

បន្ទាប់ពីបានសាកសួរ បានពិចារណានិងបានសរសេរ នាងខ្ញុំបានចាប់ផ្ដើមបន្ទូរដៃហើយរិះគិត។ នាងខ្ញុំនៅតែភ្ញាក់ផ្អើល អំពីព័ត៌មានដែលនាងខ្ញុំប្រមែប្រមូលបាន ដែលនាងខ្ញុំបានពិភាក្សា បានអធិប្បាយនិងបានយល់ដឹងនោះ ថាសិទ្ធិនិងកោសល្លរបស់ស្ត្រីក្នុងសាសនាអ៊ីស្លាមគួរឲ្យស្ញើចនិងហាក់ដូចជាពុំមានព្រំដែនទេ។ សិទ្ធិដែលគួរឲ្យរំភើបបំផុត សម្រាប់នាងខ្ញុំក្នុងនាមជាស្ត្រី ដែលត្រូវបង្កើតមកនិងក្នុងទំនាក់ទំនងជាមួយអល់ឡោះហ៊្ 🕯 សិទ្ធិនោះគឺនាងខ្ញុំស្មើនឹងបុរស ហើយក្នុងករណីខ្លះគេស្ញប់ស្ញែងនាងខ្ញុំជាងបុរសទៅទៀត។

សួនផ្សំមនុស្សធាតុនៃខ្លួនស្ត្រី មិនអន់ជាងសួនផ្សំមនុស្សធាតុនៃខ្លួនបុរសទេ។ យើងស្មើគ្នា។ នាងខ្ញុំមិនមើលស្រាលចំណុចនេះទេ តែវាអះអាងបន្ថែមថាអល់ឡោះហ៊្ទ្រង់យុត្តិធម៌មែន។ សមស្របនឹងយុត្តិធម៌របស់អល់ឡោះហ៊្ អល់ឡោះហ៊្មិនចង់ឲ្យមានការរើសអើងក្នុងការទទួលស្គាល់ប្រព័ន្ធច្បាប់ ឬឲ្យមានការលំអៀងឲ្យបុរសចំណេញក្នុងការចែកមរតកនោះទេ។

ទោះបីមនុស្សខ្លះអាចបកស្រាយ ឬយល់ឃើញថារឿងនេះជារឿងដុនដាប ឬជាមធ្យោបាយដើម្បីធ្វើឲ្យមានអន្តរាយនិងបង្ខូចលក្ខន្តិកពិតរបស់ស្ត្រីមុស្លីមឲ្យកាន់តែយូរអង្វែងតរៀងទៅទៀតក៏ដោយ តែពេលច្បាប់ត្រូវអធិប្បាយរ៉ាយរ៉ាប់យ៉ាងពិស្ដារ ត្រូវកំណត់និងត្រូវចាត់ចែងយ៉ាងត្រឹមត្រូវគេឃើញថាគោលទ្រឹស្ដីរបស់ច្បាប់សមហេតុសមផលមែន។

អ៊ីស្លាមមិនផ្ដល់សិទ្ធិដែលមិនធម្មតាឲ្យស្ត្រីទេ។ អ៊ីស្លាមញ៉ាំងសង្គមឲ្យទទួលស្គាល់ព័ត៌មានសកលថាស្ត្រីកើតមកជាមួយសិទ្ធិ និងសមត្ថភាព

មនុស្សនិយមដែលមិនអាចផ្តាច់ចោលបាន ។ នៅក្នុងចំណោមសាសនាធំៗទាំងបីដែលប្រកាន់យកព្រះតែមួយ មានតែសាសនាអ៊ីស្លាមទេដែលទទួលស្គាល់ស្ត្រីជានមុស្សពេញលក្ខណៈនៅក្នុងលោក តាមព្រះរាជតម្រាស់ ។

ស្ត្រីមុស្លីមអាចរៀបចំគម្រោងសីលធម៌ អាចធ្វើតាមគោលបំណង តាមគោលដៅនិងតាមរបៀបរស់នៅបានពេញទី ។ កាលពី ១៤០០ ឆ្នាំមុន អ៊ីស្លាមបានធ្វើឲ្យស្ត្រីភេទជឿនលឿនយ៉ាងយូរ មុនចលនាគាំទ្រសិទ្ធិស្ត្រីក្នុង ឆ្នាំ ១៨០០ (ក្នុងសតវត្សរ៍ទី ១៩) នៅទិសខាងលិចបានកើតឡើងម៉្លេះ ។

តែសត្រូវធំបំផុតរបស់ស្ត្រីក្នុងអ៊ីស្លាមនោះគឺអវិជ្ជាអំពីអ៊ីស្លាមតែម្តង ។ ស្ត្រីមុស្លីមត្រូវតែខិតខំសិក្សាឲ្យចេះដឹងនិងស្គាល់សាសនារបស់ខ្លួន ។ ស្ត្រីត្រូវខំភាវនាពិចារណាឲ្យជ្រៅជ្រះ ត្រូវសាកសួរខ្លួនឯង ហើយបើចាំបាច់ ត្រូវព្យាយាមសាកសួរខ្លួនឯងអំពីសិទ្ធិដែលអស់ឡោះហ្វ៎ឲ្យមកខ្លួននោះ ។

ត្រូវតែប្រាប់ឲ្យស្ត្រីមុស្លីមដឹងស្គាល់សិទ្ធិនិងជម្រើសរបស់ខ្លួន ។ លើសពីនោះទៀត បុរស (ស្វាមី ឪពុកនិងកូនប្រុស) ត្រូវដឹងសិទ្ធិស្ត្រីនិងកាតព្វកិច្ចដែលខ្លួនត្រូវបំពេញចំពោះស្ត្រី (ម្តាយ ភរិយានិងកូនស្រី) ។ បើយើងដឹងថាតើសិទ្ធិយើងក្នុងសាសនាមានទំនាក់ទំនងរវាងគ្នានិងគ្នា និងមានទំនាក់ទងនឹងខ្លួនយើងផ្ទាល់តែម្តងដូចម្តេចខ្លះនោះ យើងនឹងអាចបំពេញកាតព្វកិច្ចនិងអាចប្រព្រឹត្តខ្លួនបានយ៉ាងល្អប្រសើរ ។

ស្ត្រីមុស្លីមខ្លះ ពេលរៀបការ មិនដឹង (គេមិនប្រាប់ឲ្យដឹង) សិទ្ធិរបស់ខ្លួនទេ ។ អាពាហ៍ពិពាហ៍មុស្លីមខ្លះបានព្រមព្រៀងធ្វើឡើងដោយមិនឲ្យស្ត្រីស្គាល់សិទ្ធិខ្លួនឯងទេ ។ ទោះបីស្វាមីជាម្ចាស់សិទ្ធិលែងលះជាស្វ័យប្រវត្តិ

ក៏ដោយ ស្ត្រីមុស្លីមក៏ត្រូវតែដឹងដែរថា ក្នុងនាមជាភរិយា ខ្លួនមានសិទ្ធិតវ៉ា ។

ស្ត្រីមុស្លីម ពេលរៀបការ អាចដាក់ខសន្យាក្នុងកិច្ចព្រមព្រៀងអាពាហ៍ពិពាហ៍បានច្រើនខដែលសំខាន់សម្រាប់ខ្លួន ដូចជាបន្តការសិក្សាឬប្រកបមុខរបរដែលត្រូវនឹងវិស័យសិក្សារបស់ខ្លួន និងច្រើនរឿងទៀតជាដើម ។ អ៊ីស្លាមបើកឱកាសឲ្យស្ត្រីមុស្លីមអាចយល់ព្រមបាន អាចផ្លាស់ប្តូរបាន ឬអាចច្រានចោលបានលក្ខខណ្ឌណាមួយក៏បាន ឲ្យតែគូស្វាមីភរិយាយល់ស្របមូលមតិគ្នា ហើយលក្ខខណ្ឌទាំងនោះមិនបំពារបំពានគួរអាននទេ ។

ខ្លឹមសាររបស់មនុស្សធម៌គឺតស៊ូដើម្បីសេរីភាពផ្ទាល់ខ្លួន ដោយមិនជាន់ឈ្លីសន្តិសុខសង្គម ដោយមិនរួញរា ដោយមិនអើពើនឹងព្រំដែនរបស់មនុស្សឯទៀតដែលព្យាយាមគ្រប់គ្រងគេទាំងបង្ខំ ដែលគេមិនត្រូវការនោះ ទោះជាមនុស្សនោះជាប្រុសក្តី ជាស្រីក្តី ។ ពុំមានអ្នកណាមួយចង់ឲ្យអ្នកឯទៀតគ្រប់គ្រងខ្លួនទេ ។

អ៊ីស្លាមបានបោះជំហានទៅកាន់ដែនដីថ្មី គឺប៉ែកខាងលិច ។ គេអាចមើលឃើញស្ត្រីមុស្លីមនៅឯអាមេរិកកាន់តែច្បាស់ឡើង ។ នៅសល់សំណួរមួយគឺ តើទ្រឹស្តីនិងច្បាប់អ៊ីស្លាមនឹងត្រូវគ្នានឹងស្ត្រីអាមេរិកមិនមែនមុស្លីមឬទេ ។ អ៊ូឡាម៉ាអ៍ត្រូវគិតអំពីរឿងនេះពេលបង្កើតច្បាប់ពាក់ព័ន្ធនឹងស្ត្រី ។

ច្បាប់ភាគច្រើនដែលទាក់ទងនឹងស្ត្រីមិនត្រូវបង្ខាំងទុកទេ សម្រាប់សហគមន៍ឬប្រទេសខ្លះ ។ ទីបំផុតច្បាប់ទាំងឡាយនឹងបានទៅដល់មនុស្សគ្រប់រូប ហើយច្បាប់ទាំងនោះនឹងឆ្លុះបញ្ចាំងទៅលើស្ត្រីដែលអនុវត្តអ៊ីស្លាមនៅជុំវិញពិភពលោក ។

នាងខ្ញុំអំពាវនាវស្ត្រីមុស្លីមពីកំណើតដែលមិនអនុវត្តិអ៊ីស្លាម សូមឲ្យស្រាវជ្រាវឡើងវិញនូវសារធាតុដើមរបស់អ៊ីស្លាម ដែលជាកេរមរតករបស់ខ្លួននោះ ។ នាងខ្ញុំសូមជួយជម្រុញស្ត្រី មុស្លីមនិងមិនមែនមុស្លីម ដែលស្វែងរកការពិត ឲ្យសាកសួរនិងស៊ើមអង្កេតសម្រាប់ខ្លួនឯងអំពីសិទ្ធិស្ត្រីក្នុងសាសនាអ៊ីស្លាម ។

ជាញឹកញយពេក វប្បធម៌និងទំនៀមទម្លាប់បានក្លែងអ៊ីស្លាមដោយស្នាមប្រឡាក់និងស្រមោលនៃបំណាងពិតរបស់អ៊ីស្លាម ។ ពេលគេសិក្សាអ៊ីស្លាមដោយអារម្មណ៍សមហេតុផលនិងមិនលំអៀង គេនឹងឃើញថាអ៊ីស្លាមជាសាសនាដែលមានខ្លឹមសារម៉ឹងម៉ាត់និងច្បាស់លាស់ សម្រាប់បុរសនិងសម្រាប់ស្ត្រី ។

ហ្វាទីម៉ាស់ ស្ទ៍លេស៊
ខែមូហារ៉ម ១៤២២
ខែមេសា ឆ្នាំ ២០០១

## បញ្ជីមាតិកា


អារម្ភកថា ........................................ ៣
អំពីអ្នកនិពន្ធ ........................................ ៤
អារម្ភកថារបស់សៃយីដ្ អាល់-ក្ទស្ស៊ីនី ........................................ ៦
អារម្ភកថារបស់លោកស្រី ហ្វាត់ម៉ាស្ស៊ ស្ងលេស្ទ ........................................ ១២
វគ្គ ១ - ស្វែងរកការបំភ្លឺ ........................................ ១៨
វគ្គ ២ - សិទ្ធិរបស់គូស្វាមីភរិយា, តរុណាវ័យ, ម៉ាស្ស៊រ៍ ........................................ ៤៤
-សិទ្ធិរបស់គូស្វាមីភរិយា ........................................ ៤៤
-តរុណាវ័យ (ភាពពេញក្រមុំ) ........................................ ៩៩
-ម៉ាស្ស៊រ៍ (ខាន់ស្លា) ........................................ ១០៥
វគ្គ ៣ - ការលែងលះ, ការលែងលះនិងម៉ាស្ស៊រ៍, ម្ចាស់ទ្រព្យ ........................................ ១១០
-ការលែងលះ ........................................ ១១០
-ការលែងលះនិងម៉ាស្ស៊រ៍ ........................................ ១៣៨
-ម្ចាស់ទ្រព្យ ........................................ ១៣៩
វគ្គ ៤ - ហ៊ីយ៉ាប់ (សំពត់ទទូរក្បាល) ........................................ ១៤២
វគ្គ ៥ - ការថែរក្សាកូន ........................................ ១៦២
វគ្គ ៦ - ផ្តល់កសិណា និង ធ្វើអាជ្ញាកណ្តាល ........................................ ១៦៦
វគ្គ ៧ - ការដាក់ពិន័យ ........................................ ១៧៥
វគ្គ ៨ - ពហុពន្ធភាព (មានប្រពន្ធច្រើនក្នុងពេលតែមួយ) ........................................ ១៨១
វគ្គ ៩ - ការចែកមរតក ........................................ ១៩១
សេចក្តីបញ្ចប់ ........................................ ១៩៧